


1– India, before the time of the Buddha, was called Jambudvipa. It was divided into many kingdoms, large and small, some of which were ruled by kings and some of which were ruled jointly by several royal tribes.

១- ប្រទេសឥណ្ឌា កាលមុនពុទ្ធសម័យហៅថា **ជម្ពូទ្វីប** ។ ប្រទេសឥណ្ឌាចែកចេញជាច្រើនព្រះរាជាណាចក្រទាំងធំទាំងតូច ក្នុងនោះ ព្រះរាជាណាចក្រខ្លះគ្រប់គ្រងដោយព្រះមហាក្សត្រ ខ្លះទៀតគ្រប់គ្រងដោយពួកព្រះរាជកុលសម្ព័ន្ធផ្សេងៗ ។



2- One of these many small kingdoms was called Kapilavastu, which was located on the north bank of the Rapti River, on the rim of the Himalayas. The ruler of this kingdom was King Suddhodana of the Sakya Clan. His family name was Gautama, and his queen was called Maya.

២- មាននរាជាណាចក្រតូចមួយក្នុងចំណោមរាជាណាចក្រទាំងឡាយឈ្មោះ **កបិលពស្តុ** ដែលមានទីតាំងនៅត្រើយខាងជើងទន្លេ **រាប្តិ** នៅជាប់ជើងភ្នំហេមពាន្ត ។ ព្រះរាជានៃព្រះរាជាណាចក្រនេះព្រះនាមព្រះបាទ **សុទ្ធោទនៈ** ក្នុងសក្យវង្ស គោតមគោត្រ . ព្រះរាជអគ្គមហេសីរបស់ព្រះអង្គព្រះនាម **មហាមាយា** ។



3– After they were married, King Suddhodana and Queen Maya lived happily together. After many years the queen became pregnant. She asked the King to permit her to return to her home city of Devadarsita to give birth to their child. King Suddhodana readily consented and ordered the troop of royal attendants to prepare for the trip and to clean up and beautify the roads the queen would travel on.

៣- ក្រោយពីព្រះរាជានិងព្រះរាជទេពីទ្រង់រាជាភិសេករួចហើយ . ព្រះបាទសុទ្ធោទនៈនិងព្រះនាងមាយាទ្រង់គង់នៅជាមួយគ្នាប្រកបដោយសេចក្ដីសុខជារៀងរហូតមក ។ ជាច្រើនឆ្នាំក្រោយមក ព្រះនាងក៏ទ្រង់មានគភ៌។ ព្រះនាងទ្រង់ក៏ទូលសុំរាជានុញ្ញាតពីព្រះមហាក្សត្រ បំណងយាងទៅកាន់នគរ **ទេវទហៈ** ដែលជានគរនៃព្រះមាតា ព្រះបិតាព្រះនាង ដើម្បីប្រសូតបុត្រនៅទីនោះ ។ ព្រះបាទសុទ្ធោទនៈទ្រង់សព្វព្រះទ័យយល់ព្រមរាជានុញ្ញាតតាមការទូលសុំ ហើយក៏ទ្រង់បញ្ជាឱ្យក្រុមព្រះរាជបរិវាររៀបចំក្បួនដំណើរ.បោសសំអាត និងតាក់តែងលំអផ្លូវថ្វាយព្រះនាងទ្រង់យាង ។



4– At the junction of Kapilavastu and the city of Devadarsita was a place called Lumbini Park. Every summer, the people of the two cities flocked to this park to rest or to play under the Sala trees. They enjoyed the beautiful flowers blooming all over the tree-branches and the melodious twittering of birds and the humming of the ever-busy honey bees.

៤- នៅត្រង់ព្រំប្រទល់នគរកបិលវត្ថុនិងនគរទេវទហៈ មានឧទ្យានមួយឈ្មោះ **លុម្ពិនី** ។ រៀងរាល់រដូវក្តៅ មនុស្សម្នានៃនគរទាំងពីរតែងនាំគ្នាមកសំរាកនិងលេងកំសាន្តក្រោមម្លប់ដើមសាលព្រឹក្ស ក្នុងនគរ នោះ ។ ជនទាំងឡាយសប្បាយរីករាយនឹងបុប្ផាគ្រប់យ៉ាងដែលមានក្លិននិងពណ៌សំរស់ស្រស់ស្អាត ដែលកំពុង-បញ្ចេញផ្កាគ្រប់មែកនៃដើមឈើទាំងពួង ព្រមទាំងសំលេងបក្សាបក្សីដំពិរោះរណ្តំនិងសូរសំលេងហ៊ុមៗនៃហ្វូងឃ្មុំភុមរទាំងឡាយកំពុងហាច់ហើរឆ្វៀងឆ្វាត់ទៅវិញទៅមកមិនដាច់ ។



5- The time Queen Maya arrived at Lumbini Park was on the fifteenth of June, the full-moonday, on Friday (according to the reckoning of the Khmer tradition). This date is now according to the solar calender the full moonday of May of every year. As the time was going towards noon the weather became very hot, so she ordered the troops to stop so that she could rest for a while in the shade of the trees. But before long, while walking around under the Sala trees and enjoying the beautiful scenery, she felt her birth pangs and thereafter gave birth to a prince amidst the songs of birds and humming of bees.

៥- ពេលព្រះនាងទ្រង់យាងដល់សួនឧទ្យានលុម្ពិនីនៅថ្ងៃទី១៥ ខែមិថុនា. ថ្ងៃសុក្រ ១៥កើតពេញបូរមី (ខែពិសាខ) (ស្របតាមការគិតនៃប្រពៃណីខ្មែរ) ។ កាលបរិច្ឆេទនេះ . បច្ចុប្បន្នយកតាមសុរិយគតិ គឺថ្ងៃ១៥កើតពេញបូរមីខែ ឧសភា ជារៀងរាល់ឆ្នាំ ។ ដោយពេលវេលាចេះតែធ្វើដំណើរទៅមុខ ដល់ថ្ងៃជិតត្រង់អាកាសធាតុក៏ក្តៅខ្លាំង. ព្រះនាងទ្រង់បញ្ជាឱ្យពួកសេនាមាត្យឈប់នៅទីនោះបន្តិចសិន ដើម្បីព្រះនាងបានសំរាកបន្ទូភាពនឿយហត់ក្រោមម្លប់ព្រឹក្សាទាំងឡាយនោះ ។ តែមិនជាយូរប៉ុន្មាន . ពេលព្រះនាងកំពុងយាងប្រទក្សិណដើមសាលព្រឹក្ស ដោយកំពុងសព្វព្រះទ័យនឹងទេសភាពដ៏ត្រកាល. ព្រះនាងក៏ទ្រង់ប្រឈួនព្រះឧទរប្រសូតបុត្រ រួចបន្តិចក្រោយមកក៏ប្រសូតបានព្រះរាជកុមារមួយអង្គ ស្ថិតក្នុងចំណោមសូរសំលេងដ៏ពិរោះជក់ចិត្តឥតឧបមានៃហ្វូងបក្សាបក្សីនិងមធុករទាំងពួង ។



6- Queen Maya gave birth to the Prince in Lumbini Park and the palace maids in her attendance were very busy in looking carefully after the queen and the prince. The palace maids also requested the queen and the prince to return to Kapilavastu. King Suddhodana was very happy at the sight of the newborn prince. He ordered additional care for the queen and the prince.

៦- ព្រះនាងមាយារាជទេវីទ្រង់ប្រសូតព្រះរាជបុត្រក្នុងព្រៃលុម្ពិនីនោះ ។ ពួកស្នំភីលៀងទាំងឡាយដែល-តាមទៅជាមួយព្រះនាង មានកិច្ចការមមាញឹកក្នុងការបីបាច់ថែរក្សាយ៉ាងយកចិត្តទុកដាក់បំផុតចំពោះព្រះនាងនិងព្រះរាជកុមារ ។ ពួកស្នំទាំងនោះ បានទូលយាងព្រះក្សត្រីយ៍និងរាជកុមារឱ្យទ្រង់ត្រឡប់ទៅកបិលវត្ថុវិញ ។ ចំណែកព្រះបរមរាជាសុទ្ធោទនៈទ្រង់សប្បាយព្រះទ័យយ៉ាងខ្លាំងកាលដែលបានទតឃើញព្រះរាជបុត្រ ។ ព្រះអង្គត្រាស់បញ្ជាឱ្យមានការបំរើរក្សាថែមទៀតដល់ព្រះអគ្គមហេសីនិងព្រះរាជបុត្ររបស់ព្រះអង្គ ។



7– On the mountains, ouside Kapilavastu, lived many hermit sages. Among them was Asita, an old sage who commanded great respect from the people and King Suddhodana. When Asita learned that the King was the proud father of a new prince, he rushed to the palace at Kapilavastu in order to read the physiognomy of the prince.

៧- នៅតាមភ្នំនានាខាងក្រៅទីក្រុងកបិលវត្ថុ មានតាបសឥសីជាច្រើនគង់នៅដើម្បីប្រតិបត្តិធម៌ ។ ក្នុងនោះមានតាបសមួយរូបឈ្មោះ **អសិត** ជាតាបសវ័យចាស់ដែលបានទទួលការគោរពស្រលាញ់ពីប្រជាជននិងព្រះបាទសុទ្ធោទនៈ ។ នៅពេលអសិតតាបសជ្រាបថា ព្រះរាជាទ្រង់បានក្លាយជាព្រះបិតាដ៏ល្អរបស់ព្រះ រាជកុមារដែលទើបប្រសូតនោះ លោកក៏ធ្វើដំណើរឆ្ពោះចូលទៅកាន់ព្រះរាជវាំងនៃក្រុងកបិលវត្ថុ ដើម្បីទាយព្រះលក្ខណៈថ្វាយព្រះរាជកុមារ ។



8– When the old sage arrived at the palace, King Suddhodana, to show reverence to Asita and expecting blessing from him, ordered that the prince be brought out. Asita looked attentively and discovered that the prince, indeed, had a look of great virtue in his countenace. He was very excited, and a smile of joy appeared on his face; but almost as quickly, a tear dropped from his eye.

៨- នៅពេលដែលតាបសទៅដល់ព្រះរាជវាំង. ដើម្បីសំដែងនូវការគោរពដ៏ខ្ពង់ខ្ពស់ចំពោះអសិតតាបស និងទទួលពរសព្ទសាធុការ. ព្រះបាទសុទ្ធោទនៈទ្រង់ត្រាស់បញ្ជាឱ្យនាំព្រះរាជកុមារចេញមកក្រៅ ។ អសិតតាបសទ្រង់សំលឹងមើលដោយយកព្រះម័យទុកដាក់ ហើយក៏ឃើញច្បាស់ថា ពិតណាស់ ព្រះរាជកុមារមានមីកព្រះភ័ក្ត្រពេញដោយបុណ្យបារមីដ៏អស្ចារ្យ ។ តាបសមានការរំជួលចិត្តយ៉ាងខ្លាំង . ហើយក៏ញញឹមដោយក្តីត្រេកអរសប្បាយរីករាយ ដែលបង្ហាញឱ្យឃើញតាមរយៈទឹកមុខរបស់គាត់ ប៉ុន្តែរំពេចនោះ ក៏ត្រឡប់ជាយំទៅវិញ ។



9– King Suddhodana was puzzled. He asked Asita why he wept. Asita replied: " The prince has the look of a Great Man. Someday he will attain Enlightenment, perfe- cted in both wisdom and virtue, and become the teacher and master of men and devas. I wept because of my age. By the time the prince attains Enlightenment and becomes the Savior of the world, I shall not be around." After saying this, he knelt down to pay worship to the prince. Uncon- scioiusly, King Suddhodana followed him, also kneeling down to the prince.

៩-ព្រះបាទសុទ្ធោទនៈទ្រង់ឆ្ងល់ ក៏សួរទៅអសិតតាបសថា ហេតុអ្វីបានជាគាត់យំ ។ អសិតតាបសក្រាបបង្គំទូលថា : " បពិត្រព្រះសម្មតិទេព, ព្រះរាជកុមារទ្រង់មានព្រះលក្ខណៈជាមហាបុរស ។ នៅថ្ងៃណាមួយ នាពេលអនាគតព្រះរាជកុមារនេះនឹងបានសំរេចនូវការត្រាស់ដឹង ដោយមានភាពល្អឥតហ្មងទាំងព្រះបញ្ញានិងបុណ្យបារមីផង ហើយព្រះរាជកុមារនឹងបានជាសាស្ដាចារ្យលើមនុស្សនិងទេវតាទាំងឡាយ ។ បានជាខ្ញុំយំ ក៏ព្រោះខ្ញុំមានវ័យចាស់ណាស់ទៅហើយ ។ ខ្ញុំនឹងខកខានមិនបានឃើញព្រះរាជកុមារនៅពេលដែលព្រះអង្គបានត្រាស់ដឹងជាអ្នកចម្លងសត្តនិករទាំងឡាយក្នុងលោក " ។ ក្រោយពីពោលដូច្នេះហើយ, គាត់លុតជង្គង់ថ្វាយបង្គំព្រះរាជកុមារ ។ ដោយស្មុងក្នុងព្រះទ័យ , ព្រះបាទសុទ្ធោទនៈក៏លុតជង្គង់ថ្វាយបង្គំព្រះរាជបុត្រតាម តាបសដែរ ។



10– Five days after the prince's birth, King Suddhodana gathered many scholars in the palace hall in order to decide on the name of the prince. After conferring with each other, the scholars selected "Siddhartha" which means "Realization of all aims" as the new prince's name.

១០- ព្រះរាជកុមារប្រសូតបាន៥ថ្ងៃ ព្រះបាទសុទ្ធោទនៈទ្រង់បានអញ្ជើញអស់ព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតហោរាមកប្រជុំគ្នាក្នុងសាលទេវាវិនិច្ឆ័យដើម្បីប្រារព្ធពិធីថ្វាយព្រះនាមព្រះរាជបុត្រ ។ ក្រោយពីបានពិភាក្សាគ្នាមកព្រាហ្មណ៍ទាំងនោះបានសំរេចជ្រើសយកឈ្មោះ " **សិទ្ធត្ថ** " មានន័យថា " អ្នកសំរេចរាល់បំណងទាំងឡាយ " ថ្វាយដល់ព្រះរាជកុមារ ។



11– During the day of the naming ceremony, the scholars had a chance to view closely the virtuous look on the prince's face. They unanimously predicted: "If the prince succeds his father and becomes King, he will become a Cakravarti; but if,instead, he leaves home to pursue spiritual wisdom, he will become a Buddha." But one young scholar, named Kaundinya, firmly testified: "When Prince Siddhartha grows up he will abandon the throne in pursuit of supreme wisdom, and he will attain perfect enlightenment and become the first supreme teacher of the world."

១១-ក្នុងថ្ងៃប្រារព្ធពិធីថ្វាយព្រះនាម. ពួកព្រាហ្មណ៍ទាំងអស់បានមើលឃើញយ៉ាងជាក់ច្បាស់នូវព្រះលក្ខណៈបុណ្យបារមីលើព្រះភ័ក្ត្រព្រះរាជកុមារ ។ ព្រាហ្មណ៍ទាំងនោះបានធ្វើការទាយដូចៗគ្នាថា " ព្រះអង្គម្ចាស់រាជកុមារ កាលបើទ្រង់សួងរាជពីព្រះបិតា .ព្រះអង្គនឹងបានជាស្តេចចក្រពត្តិត្រួតលើស្តេចនគរដទៃៗទៀត នេះម្យ៉ាង. ម្យ៉ាងទៀត បើព្រះអយ្យបុត្រចេញចាកផ្ទះដើម្បីស្វែងរកព្រះពោធិញ្ញាណវិញ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធដោយពិត " ។ ចំណែកព្រាហ្មណ៍ម្នាក់ទៀតដែលមានវ័យក្មេងជាងគេឈ្មោះ **កោណ្ឌញ្ញ** បានទាយបញ្ជាក់យ៉ាងសុក្រិត្យតែម្យ៉ាងថា " នៅពេលដែលព្រះសិទ្ធត្ថរាជកុមារទ្រង់មានវ័យចំរើនចំរើនឡើង ព្រះអង្គនឹងលះបង់រាជបល្ល័ង្កស្វែងរកព្រះពោធិញ្ញាណ ហើយព្រះអង្គនឹងសំរេចនូវសព្វញ្ញុតញ្ញាណ បានជាសាស្តាចារ្យឯកក្នុងលោក "។



12– The people and scholars of the country all wished for the prince to become a Cakravarti when he grew up. King Suddhodana wished for this too. He certainly did not want his son to leave home and become a teacher, for he expected the prince, when the time came, to have a family like other human beings, raise children, and succeed him in ruling the country.

១២-ប្រជារាស្ត្រនិងមន្ត្រីទាំងឡាយក្នុងព្រះនគរចង់ឱ្យព្រះរាជកុមារសោយរាជសម្បត្តិជាស្តេចចក្រពត្តិនៅពេលដែលព្រះអង្គមានព្រះជន្មពេញវ័យ ។ ព្រះបាទសុទ្ធោទនៈវិញ ក៏មានព្រះបំណងដូច្នោះដែរ។ ព្រះអង្គមិនមានព្រះទ័យចង់ឱ្យព្រះរាជបុត្រចាកចោលព្រះរាជវាំងទៅបួសនិងធ្វើជាសាស្តាចារ្យនោះទេ។ អ្វីដែលព្រះអង្គសង្ឃឹមទុកនោះគឺទ្រង់ចង់ឱ្យព្រះអង្គម្ចាស់មានគ្រួសារប្រពន្ធកូនដូចជាអស់មនុស្សផងទាំងពួងនិងជាអ្នកស្នងព្រះអង្គក្នុងការគ្រប់គ្រងព្រះនគរនៅពេលទ្រង់មានវ័យចំរើនធំឡើង ។



13– Two days after the prince was named, Queen Maya died of some illness. Everybody was grief-stricken at this turn of events, but the saddest person was, of course, her husband King Suddhodana, for Queen Maya was a woman of the highest caste and also the most virtuous of the ladies of the court.

១៣- រយៈពេលពីរថ្ងៃក្រោយពិធីថ្វាយព្រះនាមព្រះរាជកុមារ . ព្រះនាងមហាមាយារាជទេវីក៏ទ្រង់សោយទីវង្គតដោយព្រះរោគាពាធ ។ មនុស្សម្នាទាំងឡាយយំសោកខ្សឹកខ្សួលគ្រប់ៗគ្នាចំពោះមរណៈទុក្ខនេះ. តែអ្នកដែលកើតទុក្ខក្រៀមក្រំជាងគេគឺអង្គព្រះសុទ្ធោទនៈជាព្រះស្វាមីព្រះនាង. ដោយសារតែព្រះនាងមាយាជាស្ត្រីមានវណ្ណៈខ្ពស់ ថែមទាំងជាស្ត្រីមានលក្ខណៈសម្បត្តិល្អបំផុតក្នុងចំណោមស្ត្រីក្នុងព្រះរាជវាំង ។



14– After Queen Maya passed away, King Suddhodana entrusted another concubine with the task of taking care of the baby prince, Maha PraJa Pati, Prince Siddharta's aunt. She took care of th prince and brought him up with as much devotion as she would have shown to her own son. Thus Prince Siddharta never really knew his own mother.

១៤-បន្ទាប់ពីព្រះនាងមហាមាយាទេវីសោយទីវង្គតទៅ ព្រះបាទសុទ្ធោទនៈទ្រង់បានតែងតាំងស្រីស្នំម្នាក់ទៀតគឺព្រះនាង**មហាបជាបតី** ដែលជាព្រះមាតុច្ឆា (ម្តាយមីង)របស់ព្រះរាជកុមារ មានភារកិច្ចក្នុងការចិញ្ចឹមបីបាច់ព្រះអង្គម្ចាស់ ។ ព្រះនាងចិញ្ចឹមថែរក្សាបីបមថ្នាក់ថ្នមព្រះរាជកុមារដោយសេចក្តីស្រលាញ់ក្រៃលែងដូចបុត្ររបស់ព្រះនាងបង្កើត ។ ព្រោះហេតុដូច្នោះហើយ បានជាព្រះសិទ្ធត្ថទ្រង់មិនស្គាល់ព្រះមាតាបង្កើតរបស់ព្រះអង្គយ៉ាងណានោះទេ ។



15– Under the careful eye of his aunt ,Maha Prajapati, the prince gradually grew up. He was very handsome and healthy, a perfect darling to everyone. When he was eight- year old, the King began to invite all kinds of masters to the palace to educate him in the skills of reading, composition, mathematics, archery and other arts.

១៥-ក្រោមការបីបមថ្នមថែដ៏អស់ពិចិត្តនៃព្រះមាតុច្ឆាមហាបជាបតិ. ព្រះអង្គម្ចាស់រាជកុមារទ្រង់មានវ័យវឌ្ឍនាការចំរើនឡើងបន្តិចម្តង១ជាលំដាប់ ។ ព្រះអង្គទ្រង់មានព្រះរូបព្រះឆោមល្អស្រស់សង្ហារក្រៃលែងនិងទ្រង់មានព្រះសុខភាពល្អ ព្រមទាំងជាទីស្រលាញ់ពេញចិត្តនៃជនទាំងពួង ។ នៅពេលដែលព្រះអង្គមានព្រះជន្ម ៨វស្សា. ព្រះមហាក្សត្រទ្រង់បានអញ្ជើញគ្រូដ៏ជំនាញ១ឱ្យមកកាន់ព្រះបរមរាជវាំង ដើម្បីបង្រៀនព្រះរាជបុត្រនូវការអានអក្សរ ការនិពន្ធ. គណិតវិទ្យា. វិជ្ជាបាញ់ធ្នូ និងសិល្បវិធីផ្សេង១ទៀត ។



16– Since everyone of his teachers was an expert in his field, Prince Siddhartha completed all his studies with ease and thoroughness. When speed of progress and level of accomplishment were considered, his superiority over all the other princes was apparent. People, including his teachers, father and aunt, were really surprised to see that Prince Siddhartha really had no difficulty at all in learning anything. Once any skill or knowledge was demonstrated or expounded, he immediately understood, remembered and never forgot it.

១៦-ដោយសារគ្រូម្នាក់១របស់ព្រះអង្គសុទ្ធតែជាគ្រូដ៏ស្ទាត់ជំនាញក្នុងការបង្រៀន. សិទ្ធត្ថរាជកុមារទ្រង់បញ្ចប់ការសិក្សារៀនសូត្របានដោយងាយនិងមានភាពប្រាកដប្រជាទៀតផង ។ នៅពេលដែលមានការរីកចំរើនឡើងនូវកិរិតថ្មីព្រះហស្ថយ៉ាងលឿនគួរឱ្យកត់សំគាល់មក . កេរ្តិ៍ឈ្មោះរបស់ព្រះអង្គដែលមានលើសព្រះអង្គម្ចាស់កុមារដទៃ១ទៀតនោះ បង្ហាញឱ្យឃើញកាន់តែច្បាស់ឡើង១ថែមទៀត ។ មនុស្សទាំងឡាយរួមទាំងគ្រូទាំងអស់ . ព្រះបិតា និងព្រះមាតុច្ឆា មានភាពអស្ចារ្យក្នុងចិត្តយ៉ាងខ្លាំងដោយបានឃើញព្រះសិទ្ធត្ថរៀនវិជ្ជានីមួយ១បានចេះចាំយ៉ាងងាយស្រួល ។ នៅពេលដែលគ្រូបង្ហាញឬពន្យល់នូវមុខជំនាញឬចំណេះដឹងអ្វីមួយ ព្រះរាជកុមារទ្រង់យល់និងចងចាំបានភ្លាមមួយរំពេច ដោយមិនភ្លេចវិញសោះឡើយ ។



17-- Even though Prince Siddhartha was such a clever pupil, at the same time the crown prince, the heir to the throne, he never neglected to treat his teachers with manners and all due respect. For the prince believed that only through the instruction from teachers could men acquire knowledge of very great value. Besides, the nature of the prince was such that he treated everyone with equal geniality and politeness.

១៧-ទោះបីព្រះសិទ្ធត្ថជាសិស្សដ៏ឆ្លាតវាងវៃបែបហ្នឹងក៏ដោយ .សូម្បីនៅពេលដែលនឹងឡើងសោយរាជ ជាអ្នកស្នងរាជសម្បត្តិ ក៏ព្រះអង្គទ្រង់តែងយកព្រះទ័យទុកដាក់គោរពប្រតិបត្តិចំពោះព្រះគ្រូទាំងនោះដ៏សមគួរ ។ ព្រោះព្រះអង្គទ្រង់យល់ឃើញថា មានតែការបង្រៀនប្រៀនប្រដៅពីសំណាក់គ្រូអាចារ្យទាំងឡាយទេ ដែលធ្វើឱ្យមនុស្សយើងបានទទួលនូវចំណេះវិជ្ជាដ៏មានតំលៃក្រៃលែងនោះបាន។ ម្យ៉ាងទៀត ចរិតធម្មជាតិរបស់ព្រះអង្គគឺថា ព្រះអង្គតែងទ្រង់ប្រព្រឹត្តនូវភាពរួសរាយរាក់ទាក់និងសុភាពរាបសារស្មើគ្នា១ចំពោះមនុស្សទូទៅទាំងអស់ ។



18– Prince Siddhartha's accomplishment in physical skill was no less than his virtue in conduct and deportment. Besides being genial and polite, the prince was also very courageous. He never feared or hesitated when competing with other boys in various skills. During that time, all males of the royal tribe were educated to become gallant knights. The prince, since his early youth, had been trained to be a kind and brave knight, and he was also able to drive a chariot very skillfully.

១៨-ថ្វីព្រះហស្តក្នុងមុខជំនាញខាងកំលាំងកាយរបស់ព្រះសិទ្ធត្ថក៏មិនចាញ់គ្នានឹងគុណធម៌របស់ព្រះអង្គដែរ ។ ក្រៅពីភាពរួសរាយនិងសុភាពរាបសារ . ព្រះរាជកុមារទ្រង់ក៏មានភាពអង់អាចក្លាហានណាស់ដែរ ។ ព្រះអង្គមិនដែលខ្លាចញញើតឬអល់អែកក្នុងព្រះទ័យដល់ម្តងណាឡើយ នៅពេលប្រកួតប្រជែងជាមួយកុមារផងទាំងឡាយទៀតក្នុងជំនាញផ្សេង១ ។ ក្នុងកំឡុងពេលនោះដែរ . រាជកុមារទាំងឡាយនៃក្រុមព្រះរាជវង្សត្រូវបានហ្វឹកហាត់ដើម្បីធ្វើជាមន្ត្រីក្លាហាន ។ ព្រះរាជកុមារ តាំងពីនៅក្មេង ទ្រង់បានហ្វឹកហ្វឺនដើម្បីក្លាយជាមន្ត្រីដ៏អង់អាចក្លាហាននិងស្លូតបូតម្នាក់ ហើយព្រះអង្គជិះសេះបរ[illegible]ស្ទាត់ជំនាញបំផុតទៀតផង ។



19-There was a chariot race, which the prince had won against the toughest rival in the country. Although a competition of this sort required that the participants struggle very hard for victory, the prince treated his horse gently. The horse, in return, also exerted its full strength and with all its might helped the prince to become the victor. For the horse, too, felt that the prince should be only a winner, not a loser.

១៩- ក្នុងព្រះនគរមានប្រណាំងសេះមួយដែលព្រះអង្គទ្រង់ជាអ្នកបានទទួលជ័យជំនះលើគូប្រកួតដ៏ស្វិតស្វាញ ។ ទោះបីជាការប្រកួតប្រជែងតម្រូវឱ្យបេក្ខជនទាំងអស់ប្រឹងប្រែងតស៊ូអស់ពីសមត្ថភាពដើម្បីដណ្តើមជោគជ័យក៏ដោយ ក៏ព្រះរាជកុមារនៅតែបំបោលសេះយ៉ាងថ្នមៗ ។ ចំណែកឯសេះវិញ ខំប្រឹងបញ្ចេញកំលាំងដ៏ពេញទំហឹងរបស់ខ្លួនផងដែរ ហើយជាមួយកំលាំងដ៏ខ្លាំងក្លានេះ បានជួយឱ្យព្រះអង្គទ្រង់បានជាអ្នកទទួលជ័យជំនះ ។ ដោយឡែកសេះវិញ ក៏បានដឹងរួចជាមុនហើយថា រាជកុមារជាម្ចាស់នឹងប្រាកដជាអ្នកឈ្នះ មិនមែនជាអ្នកចាញ់ឡើយ ។



20– The prince was gentle not only to his own horse, but he was kind also to all other animals. Being a crown prince, Siddhartha had never encountered suffering and misery in his life. But his sympathetic nature made him aware that all creatures, whether people or animals, equally desire happiness and detest suffering and pain.

២០-ព្រះរាជកុមារទ្រង់មិនត្រឹមតែមានព្រះទ័យស្លូតបូតស្រលាញ់តែសេះរបស់ព្រះអង្គមួយប៉ុណ្ណោះទេ ថែមទាំងមានព្រះទ័យប្រកបដោយមេត្តាដល់សត្វដទៃៗទៀតដោយមិនរើសមុខ ។ ក្នុងនាមជាព្រះរជ្ជទាយាទ ព្រះសិទ្ធត្ថទ្រង់មិនធ្លាប់ជួបប្រទះនូវសេចក្តីទុក្ខសោកសោះក្នុងជីវិត ។ ប៉ុន្តែសមានចិត្តអំពីកំណើតធ្វើឱ្យព្រះអង្គទ្រង់ដឹងថា មនុស្សសត្វទាំងឡាយមិនថាមនុស្សឬសត្វទេ សុទ្ធតែចង់បានសេចក្តីសុខហើយស្អប់ខ្ពើមសេចក្តីទុក្ខដូចគ្នាៗ ។



21– At the age of eight, the prince began to show, in his conduct, a particularly merciful nature. In any place and on whatever occasion, he avoided doing anything harmful to any creature; on the contrary, he tried to succor any suffering creature. For example, one day the prince saw one of his attendants beating a snake with a rod. He immediately stopped the attendant, exhorting him not to beat it.

២១- ក្នុងព្រះជន្ម៨ព្រះវស្សា. ព្រះអង្គទ្រង់ចាប់ផ្តើមបង្ហាញឱ្យឃើញនូវលក្ខណៈនៃមេត្តាចិត្តដ៏អស្ចារ្យរបស់ព្រះអង្គ ។ នៅទីណា. កន្លែងណា. ពេលណាៗក៏ដោយ ព្រះអង្គទ្រង់មិនដែលបង្កទុក្ខទោសគ្រោះថ្នាក់ដល់សត្វណាមួយដល់ម្តងឡើយ .ផ្ទុយទៅវិញ ព្រះអង្គមានតែខិតខំសង្គ្រោះស្រោចស្រង់សត្វដែលរងទុក្ខឱ្យត្រឡប់ជាបានសុខវិញ ។ ជាក់ស្តែង មានមួយថ្ងៃនោះ ព្រះរាជកុមារទ្រង់ទតឃើញមិត្តម្នាក់របស់ព្រះអង្គដែលលេងជាមួយគ្នា វាយសត្វពស់មួយ ។ ព្រះអង្គទតឃើញដូច្នោះ ទ្រង់ក៏ឃាត់ក្មេងនោះភ្លាម ដោយមិនឱ្យវាយវាតទៅទៀត ។



22– One day, Prince Siddhartha was playing with his companions in the palace garden. Many of his young companions were also playing there. Among them was Prince Devadatta, a cousin of Prince Siddhartha, whose personal character was entirely different from the Prince's.

២២-ថ្ងៃមួយ ព្រះសិទ្ធត្ថកុមារទ្រង់កំពុងរត់លេងជាមួយមិត្តភ័ក្រ្តជាច្រើនក្នុងសួនឧទ្យាននៃព្រះរាជវាំង. ក្នុងនោះ ក៏មានព្រះរាជកុមារ **ទេវទត្ត** ដែរ ដែលត្រូវជាបងប្អូនជីដូនមួយរបស់ព្រះអង្គ ។ ព្រះរាជកុមារទេវទត្ត មានចរិតខុសគ្នាស្រឡះពីព្រះសិទ្ធត្ថរាជកុមារ ។



23– Prince Siddhartha was genial and polite, and his heart was full of mercy and benevolence. He never oppressed others, but often helped the oppressed. Prince Devadatta was cruel and jealous and fond of killing. This day Devadatta was carrying his bow and arrows, shooting the flying swans for fun. One swan was shot in the wing and fell to the ground. It was badly wounded and appeared to be in much pain.

២៣-ព្រះសិទ្ធត្ថកុមារទ្រង់ជាកុមារស្លូតបូតសុភាពរាបសារណាស់ .ព្រះទ័យព្រះអង្គពោរពេញទៅដោយមេត្តា និងការសន្ដោសប្រោសប្រណីចំពោះមនុស្សសត្វទាំងឡាយ ។ ព្រះអង្គទ្រង់មិនដែលធ្វើអាក្រក់ចំពោះសត្វលោកដល់ម្ដងឡើយ . ព្រះអង្គទ្រង់តែងតែជួយដល់សត្វដែលត្រូវគេធ្វើបាប ។ ចំណែកឯ ទេវទត្ត ជាមនុស្សកាចឃោរឃៅ. ជាអ្នកគិតតែបៀនបៀន និទ្ទាឈ្នានីសគេ និងចូលចិត្តតែខាងកាប់សំលាប់ ។ ដូចក្នុងថ្ងៃនេះ ទេវទត្តកំពុងកាន់ធ្នូនិងស្ពាយគ្រាប់ព្រួញយ៉ាងច្រើន ហើយក៏បាញ់សំដៅទៅហ្វូងក្ងានដែលកំពុងហើរ ដើម្បីជារឿងសើចលេង ។ សត្វក្ងានមួយត្រូវព្រួញត្រង់ស្លាបក៏ធ្លាក់មកដី ។ ក្ងាននោះរងរបួសជាទម្ងន់ហើយក៏ដល់ទូរការឈឺចាប់យ៉ាងខ្លាំង ។



24– Siddhartha quickly ran up to the swan, which he picked up; removed the arrow from its wing and wrapped the wound with cool leaves to stop the blood and softly patted its body. Devadatta angrily stepped over to him, intending to snatch the swan, at the same time yelling at Siddhartha, demanding that he return the bird to him.

២៤-ឃើញយ៉ាងនេះ ព្រះសិទ្ធត្ថរត់យ៉ាងលឿនសំដៅទៅក្ងាន រួចលើកបឺដកព្រួញចេញពីស្លាប ហើយក៏រុំរបួសដោយស្លឹកឈើស្រស់ៗត្រជាក់ដើម្បីកុំឱ្យហូរឈាម រួចបោសធ្វូលីចេញពីខ្លួនវាយ៉ាងថ្នមៗ ។ ទេវទត្តដើរសំដៅទៅរកព្រះអង្គទាំងកំហឹង ក្នុងបំណងនឹងកន្ត្រាក់យកក្ងាននោះពីព្រះអង្គ. ដោយស្រែកគំហកដាក់ព្រះសិទ្ធត្ថ ដោយទទូចទាមទារឱ្យព្រះអង្គប្រគល់សត្វក្ងានមកខ្លួន ។



25– Under no conditions would the Prince Siddhartha return the wounded bird to him. He said: " If the bird had died, it woud probably belong to the shooter; but as long as it is still alive, it naturally belongs to the savior." But Prince Devadatta insisted: "I shot the bird down, so it belongs to me" Finally Prince Siddhartha suggested: "Let the scholars of the country settle this argument at a conference." Prince Devadatta agreed to this.

២៥-ក្រោមការនិយាយឥតលក្ខណ៍ ព្រះសិទ្ធត្ថទ្រង់មិនប្រគល់សត្វរងរបួសនេះឱ្យទេ ។ ព្រះអង្គទ្រង់ប្រាប់ថា " បើសត្វនេះវាស្លាប់ វានឹងបានទៅអ្នកបាញ់ . តែបើដរាបណាវានៅរស់ទេ ជាធម្មតា វាជារបស់អ្នកដែលបានសង្គ្រោះវា "។ តែទេវទត្តនៅតែចចេសតវ៉ាថា " យើងជាអ្នកបាញ់វា .ដូច្នេះវាជារបស់យើង ! " ។ បន្តិចមក ព្រះសិទ្ធត្ថកុមារទ្រង់ប្រាប់ថា " ចូរចាំឱ្យពួកមន្ត្រីទាំងឡាយក្នុងព្រះនគរដោះស្រាយបញ្ហាជម្លោះនេះក្នុងអង្គប្រជុំចុះ" ។ ទេវទត្តក៏យល់ព្រម ។



26– On the day when the scholars were to gather and confer on various matters, there was plenty of dispute about the problem of the swan. They all had different opinions. Some said the bird should belong to Prince Siddhartha because he had saved it's life. Some, on the contrary, believed that Prince Devadatta should have the bird because he had brought it down. Everyone seemed to have his own reason for choosing one point of view or another.

២៦-នៅថ្ងៃដែលពួកមន្ត្រីបានមកប្រជុំគ្នា ដើម្បីនឹងពិភាក្សាបញ្ហាផ្សេងៗ. ក៏មានបញ្ហាជម្លោះដ៏ធំមួយអំពីរឿងសត្វក្ងានផងដែរ។ មន្ត្រីទាំងឡាយមានយោបល់ផ្សេងៗគ្នាចំពោះរឿងនេះ ។ ពួកមន្ត្រីខ្លះនិយាយថា សត្វនេះគួរតែបានទៅព្រះសិទ្ធត្ថ ព្រោះព្រះអង្គទ្រង់បានសង្គ្រោះជីវិតវា ។ តែមន្ត្រីមួយចំនួនទៀត អះអាង ថា កុមារទេវទត្តទេ ដែលគួតែបានសត្វនេះ ពីព្រោះព្រះអង្គបានបាញ់វា ។ មន្ត្រីម្នាក់ៗចេះតែលើកហេតុផលឡើងតាមតែទស្សនៈរៀងៗខ្លួន ។



27– Finally, a young scholar stood up, loudly proclaiming, "all living creatures belong to those who save or guard their lives, not to those who damage their lives. In fact, this wounded bird shall belong to its savior, that is, to Prince Siddhartha !"

២៧-ចុងបញ្ចប់នៃការប្រជុំនោះ , មន្ត្រីវ័យក្មេងម្នាក់ក្រោកឈរឡើង ពោលអះអាងខ្លាំងៗថា " សត្វដែលមានជីវិតទាំងឡាយត្រូវតែបានទៅអ្នកដែលសង្គ្រោះស្រោចស្រង់ឬការពារជីវិតវា, មិនត្រូវបានទៅអ្នកដែលបំផ្លិចបំផ្លាញជីវិតវាទេ ។ មែនពិត , សត្វដែលដល់នូវរបួសដ៏ធ្ងន់នេះ ត្រូវតែបានទៅអ្នកសង្គ្រោះវា គឺអង្គព្រះសិទ្ធត្ថកុមារ ! " ។



28– The confering scholars all accepted the statement made by their young colleague, unanimously deciding that the bird belonged to Prince Siddhartha, for he was the one who had saved its life. So prince Siddhartha carefully nursed the swan untill its wound had completely healed. Then he set the bird free to fly back to the forest to live a free and pleasant life among its own kind. From that day, Prince Devadatta began to hate Prince Siddhartha and intended secretly to plot against him.

២៨-មន្ត្រីទាំងអស់ក្នុងអង្គប្រជុំព្រមទទួលយកសេចក្តីសំរេចដែលធ្វើឡើងដោយសមាជិកវ័យក្មេងម្នាក់របស់ខ្លួន. ដោយសំរេចជាឯកឆន្ទថា សត្វនេះត្រូវតែបានទៅព្រះសិទ្ធត្ថ ដោយសារតែព្រះអង្គទ្រង់ជាអ្នកសង្គ្រោះជីវិតវា ។ កាលបើបានក្លាន់ហើយ ព្រះសិទ្ធត្ថទ្រង់ចិញ្ចឹមថែរក្សាវារហូតទាល់តែមុខរបួសបានជាសះស្បើយរួចហើយព្រះអង្គទ្រង់ក៏លែងឱ្យវាមានសេរីភាព ហើរទៅរស់នៅក្នុងព្រៃជាមួយហ្វូងរបស់វា ប្រកបដោយសេចក្តីសុខសប្បាយ ។ តាំងពីថ្ងៃនោះរៀងមក ទេវទត្តកុមារទ្រង់ក៏ចាប់ផ្តើមចងគំនុំគុំគួនស្អប់ព្រះសិទ្ធត្ថ ហើយក៏ប៉ុនប៉ងយ៉ាងសំងាត់ដើម្បីប្រឆាំងព្យាបាទលើព្រះអង្គ ។



29- Evryone of these Indian people knew that everything they needed came from the soil. Therefore, they considered the tilling of the soil and the producing of food as their most important work and labor which would benefit the country as well as themselves. Hence, a yearly practice was observed in which the king and his ministers all went to the fields in person to take part in a tilling and plowing ceremony at seed sowing time in order to set an example for the people, showing them that plowing the soil and growing crops was not demeaning work but was, on the contrary, a very glorious work that one could do.

២៩-ប្រជាជនឥណ្ឌាទាំងឡាយដឹងថា អ្វីៗសព្វយ៉ាងទាំងអស់ដែលជាទីត្រូវការរបស់មនុស្សកើតពីព្រះធរណី ព្រោះហេតុដូច្នោះ គេត្រូវតែគិតគូដល់ការកាប់គាស់ភ្ជួររាស់ដីនិងបង្កបង្កើនផលដំណាំ ដែលជាអាជីកម្មដ៏សំខាន់បំផុតសំរាប់ចិញ្ចឹមជីវិត . ការធ្វើអាជីវកម្មនឹងនាំមកនូវផលប្រយោជន៍សំរាប់ប្រទេសជាតិផង សំរាប់ចិញ្ចឹមជីវិតខ្លួនឯងផង ។ ដោយហេតុយ៉ាងនេះហើយ. ជារៀងរាល់ឆ្នាំ គេឃើញព្រះមហាក្សត្រនិងពួកមន្ត្រីបរមរាជវាំងយាង និងអញ្ជើញទៅស្រែដើម្បីចូលរួមដោយផ្ទាល់ក្នុងពិធីកាប់គាស់ភ្ជួររាស់ដីជាប្រចាំឆ្នាំនៅក្នុងរដូវសាបព្រោះបណ្ដុះពូជដំណាំ ដើម្បីធ្វើជាគំរូឱ្យប្រជាជនបានដឹង .ដោយមានព្រះបំណងបង្ហាញឱ្យប្រជាជនទាំងឡាយឃើញថា ការធ្វើស្រែចំការ មិនមែនជាការងារថោកទាបទេ . តាមពិត. វាជាការងារដ៏ល្អប្រសើរបំផុតដែលមនុស្សត្រូវតែធ្វើ ។



30– In Kapilavastu, the end of summer marked the season for the farmers to start tilling. King Suddhodana and his officials customarily led the Royal Tiller Festival outside the city. Every year this was a big ceremony. The people of the city all came out to see the King plowing the land and to enjoy the very colorful feast. On this day also, Prince Siddhartha accompanied King Suddhodana to the ceremony.

៣០- នៅនគរកបិលភស្តុ នាចុងបំណាច់នៃគិម្ហន្តរដូវ ដែលគេចាំបានថា ជារដូវដែលប្រជាកសិករដល់ពេលធ្វើស្រែ ។ ព្រះមហាក្សត្រសុទ្ធោទនៈនិងពួកមន្ត្រីព្រះបរមរាជវាំងបានប្រារព្ធពិធី **បុណ្យច្រត់ព្រះនង្គ័ល** នៅខាងក្រៅព្រះរាជធានីទៅតាមទំនៀមទម្លាប់ ។ ជារៀងរាល់ឆ្នាំបុណ្យច្រត់ព្រះនង្គ័លនេះ ជាពិធីបុណ្យមួយដ៏ធំ ។ ប្រជាជនក្នុងរាជធានីទាំងមូលនាំគ្នាចេញមកមើលព្រះមហាក្សត្រទ្រង់ច្រត់ព្រះនង្គ័លនិងដើម្បីកំសាន្តសប្បាយក្នុងពិធីបុណ្យដ៏មហោឡារិកនេះ ។ នៅថ្ងៃនោះ ព្រះសិទ្ធត្ថកុមារទ្រង់បានយាងទៅកាន់ពិធីនោះជាមួយនឹងព្រះបាទសុទ្ធោទនៈជាព្រះវររាជបិតាផងដែរ ។



31-The King began the ceremony in the field. He raised a beautifully decorated gold plow and began to plow the land. A group of officials followed him, plowing the land with silver-decorated plows. Finally, there came the farmers, two in a row, using their own plows. The stiff brown mud was loosened and was then ready for seeding.

៣១-ព្រះមហាក្សត្រទ្រង់ប្រារព្ធកម្មវិធី ។ ព្រះអង្គទ្រង់ចាប់កាន់ព្រះនង្គ័លមាសដែលតាក់តែងយ៉ាងល្អឆើត រួចទ្រង់ក៏ចាប់ភ្ជួរ ។ ពួកមន្ត្រីទាំងឡាយនាំគ្នាភ្ជួរតាមក្រោយព្រះអង្គដោយនង្គ័លតុបតែលំអដោយប្រាក់ ។ ក្រោយគេបំផុតគឺពួកប្រជាកសិករ ដោយភ្ជួរនង្គ័លរបស់ខ្លួនផ្ទាល់។ ផ្ទាំងដីពណ៌ក្រមៅដ៏រឹង ត្រូវគេរាស់បំបែក បន្ទាប់មក គេប្រុងប្រៀបធ្វើការសាបព្រោះពូជដំណាំ ។



32–At lunchtime, the attendants of Prince Siddhartha all went to enjoy the feast, leaving the prince alone. So prince Siddhartha walked by himself to the shade of a thriving Jambu tree, sat down, quietly calmed his mind by expelling all its wrong thougts and began to contemplate: " The King, the officials, and the farmers are here to hold the Royal Tiller ceremony, and now they are happily feasting."

៣២- នៅពេលបាយថ្ងៃត្រង់. អ្នកមកជាមួយព្រះសិទ្ធត្ថទាំងអស់ទៅជុំគ្នាសប្បាយរីករាយក្នុងពិធីបុណ្យ . ទុកឱ្យព្រះអង្គគង់នៅតែមួយព្រះអង្គឯង ។ បានឱកាសល្អដូច្នេះ ព្រះសិទ្ធត្ថទ្រង់យាងដោយព្រះអង្គឯងទៅកាន់ដើមជម្ពូព្រឹក្សដែលមានម្លប់ត្រឈឹងត្រឈៃ. ទ្រង់គង់ចំរើនសមាធិ .ទ្រង់តាំងព្រះទ័យយ៉ាងស្ងប់ ដោយកំចាត់បង់នូវចិត្តសៅហ្មង រួចទ្រង់ប្រមូលអារម្មណ៍ឱ្យមូល ដោយទ្រង់គិតថា " ព្រះមហាក្សត្រ. ពួកមន្ត្រីនិងប្រជាកសិករទាំងឡាយមកជួបជុំគ្នាទីនេះ ដើម្បីប្រារព្ធពិធីបុណ្យច្រត់ព្រះនង្គ័ល . ឥឡូវនេះពួកគេកំពុងតែសប្បាយនឹងពិធីបុណ្យនេះ "។



33– But the oxen did not seem to be happy at all. They had to exert a force greater than their physical strength to pull the plows and to break the hard earth. They toiled so much that they could not stop panting. Obviously they were not happy. While the people here were enjoying themselves today, they all had to do hard work. And if, occasionally, they were to do something not quite up to their masters' expectation, harsh threats and merciless whips would fall on them.

៣៣- ប៉ុន្តែមើលទៅគោទាំងនោះវិញមិនសប្បាយទាល់តែសោះ ។ វាត្រូវខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត ដើម្បីអូសទាញនង្គ័លពុះជ្រែកបំបែកផ្ទាំងព្រះធរណីដ៏រឹង ។ វាធ្វើការយ៉ាងលំបាកហត់ឡើយក្រៃលែង ស្ទើរតែដកដង្ហើមមិនដល់គ្នា ។ ប្រាកដណាស់ គោទាំងនោះមិនសប្បាយសោះឡើយ ។ ខណៈដែលមនុស្សគេសប្បាយរីករាយក្អាកក្អាយ ឯគោវិញត្រូវខំធ្វើការយ៉ាងលំបាកបំផុត ។ មានម្តងម្កាល , បើវាអូសរនាស់នង្គ័លមិនពេញចិត្តម្ចាស់វាទេនោះ វានឹងត្រូវម្ចាស់ស្រែកគំរាមកំហែង ដេរប្រទេចនិងវាយសំពងគ្មានអាណិតអាសូរបន្តិចសោះឡើយ ។



34– The prince also noticed the activities of various other creatures around him. He saw a lizard, which was crawling out from a crevice in the earth, catching and eating working ants with its tongue. Short afterwards, a snake approached, killed the lizard by biting through its head, and swallowed it. Just at that moment, the prince was astonished to see a hawk suddenly descend from the sky, seize the snake, tear it apart and eat it.

៣៤- ព្រះរាជកុមារទ្រង់មើលឃើញផងដែរនូវអំពើរបស់សព្វសត្វដទៃទៀតនៅជុំវិញព្រះអង្គ ។ ព្រះអង្គទ្រង់ទតឃើញសត្វបង្កួយមួយដែលវាចេញពីរន្ធកំពុងចាប់ស្រមោចស៊ីជាអាហារ ។ មួយរំពេចក្រោយមក ស្រាប់តែមានសត្វពស់មួយលូនមកដល់ រួចក៏ខាំចឹកសត្វបង្កួយនោះស៊ីជាអាហារតគ្នា ។ នៅចំពេលនោះ ព្រះរាជកុមារត្រង់ភ្ញាក់យ៉ាងខ្លាំងដោយទ្រង់ទតឃើញសត្វស្ទាំងមួយហើយចុះពីលើអាកាសយ៉ាងលឿន ខ្ទាំចាប់សត្វពស់នោះហើយចឹកចោះចឹកហែកហួរស៊ីបន្តទៀត ។



35- Siddhartha again went into deeper thought and began to question himself thus: "If things are like that, then is it not the case that, then which is said to be beautiful in life, will also certainly hide ugliness behind its back? At last the prince came to realize that although he was very happy now, there was how- ever a kind of great suffering, that was always covering mankind and all beings. Although Prince Siddhartha was still young he was able to have such profound thoughts and to attain to the state of non–differentiation regarding all things and enter into the Firs: Dhyana.

៣៥-ព្រះសិទ្ធត្ថទ្រង់ញុំាងព្រះទ័យឱ្យតាំងសិប់ជ្រៅនៅក្នុងសមាធិបន្តទៅទៀត។ រួចទ្រង់សួរព្រះអង្គឯងថា " បើអ្វី១ទាំងអស់ដូច្នោះមែន . វាមិនជាបញ្ហាទេឬ ? . គេនិយាយថា ជីវិតនេះល្អ .ចុះតើមានភាពអាក្រក់លាក់ខ្លួនពួននៅពីក្រោយភាពល្អនេះដែរឬទេ ? ទីបំផុត ព្រះអង្គទ្រង់ដឹងថា ទោះជាពេលនេះ គេសប្បាយរីករាយក្អាកក្អាយក៏ពិតមែន តែមុខជានឹងជួបសេចក្តីទុក្ខ ឈឺចាប់ខ្លោចផ្សាណាមួយជាមិនខាននៅពេលខាងមុខ. សេចក្តីទុក្ខតែងតែកើតមានគ្របដណ្តប់រួបរិតគ្រប់មនុស្សសត្វទាំងអស់ ។ ព្រះសិទ្ធាត្ថទ្រង់ព្រះជន្មនៅក្មេងសោះ តែព្រះអង្គទ្រង់អាចព្រះតិរិះពិចារណាជ្រាលជ្រៅវែងឆ្ងាយដូចនេះបាន និងទ្រង់អាចសំរេចចាត់ទុកនូវសភាវទាំងឡាយថា មានសភាពដូចគ្នា១ទាំងអស់ (គឺមានសុខ មានទុក្ខ) ហើយព្រះអង្គទ្រង់ខំតាំងព្រះទ័យភាវនារហូតបានសំរេចចូលដល់ **បឋមជ្ឈាន** ។



36-When the Royal Tiller ceremony and the feast were over, the attendants began to think of the prince. They rushed back to him and found the prince sitting motionless ike a stone statue under the Jambu tree. They awakened him and told him that the king was looking for him for it was time to go home. On the way, Prince Siddhartha was filled with compassion for all creatures, because every single creature, in the course of keeping itself alive, has to struggle constantly against pain and suffering.

៣៦-នៅពេលពិធីបុណ្យច្រត់ព្រះនង្គ័លចប់សព្វគ្រប់អស់ហើយ ជនទាំងឡាយដែលជាអ្នកបំរើព្រះអង្គគេនាំគ្នារកមើលព្រះអង្គ ។ ឃើញព្រះអង្គទ្រង់កំពុងគង់នៅស្ងៀមដូចជារូបចម្លាក់នៅក្រោមដើមព្រីងដូច្នោះ គេក៏នាំគ្នាស្ទុះសំដៅទៅរកព្រះអង្គ ។ ជនទាំងនោះ តើនព្រះអង្គឡើងហើយទូលថា ព្រះបិតាទ្រង់កំពុងតែរកព្រះអង្គដើម្បីនឹងយាងត្រឡប់ទៅព្រះបរមរាជវាំងវិញ ។ នៅតាមផងផ្លូវព្រះសិទ្ធត្ថទ្រង់មានព្រះទ័យប្រកបដោយករុណាអាណិតអាសូរដល់សព្វសត្វទាំងអស់. ព្រោះសត្វទាំងឡាយ នៅពេលដែលចង់ឱ្យជីវិតរស់ត្រូវតែតស៊ូពុះពារសេចក្តីលំបាកនិងទុក្ខវេទនាទាំងឡាយ ។



37- Knowing that the Prince had thought of seeking the ultimate truth, troubled King Suddhodana. He feared that if such thoughts were not eliminated, the prince probably would soon leave him and abandon the country, and then there would be no one to inherit the throne. He felt that the only way to change the prince's mind was to double the joy and pleasure available to him in the the royal palace. To achieve this end, his first plan was to construct three splendid new palaces.

៣៧-ដោយដឹងថា ព្រះរាជកុមារទ្រង់ព្រះតិរិះដល់ការស្វែងរកនូវសច្ចធម៌. ព្រះមហាក្សត្រសុទ្ធោទនៈទ្រង់ខ្វល់ខ្វាយព្រះទ័យយ៉ាងខ្លាំង ។ ព្រះអង្គទ្រង់បារម្ភខ្លាចក្រែងព្រះបំណងរបស់រាជបុត្របានសំរេច ហើយរាជបុត្រមុខជានឹងចាកចោលព្រះអង្គ លះបង់ព្រះនគរ តទៅអនាគត ពិតជាមិនមានអ្នកស្នងរាជសម្បត្តិបន្តពីព្រះអង្គឡើយ ។ ព្រះអង្គទ្រង់យល់ថា មធ្យោបាយតែមួយគត់ដែលអាចញ៉ាំងព្រះទ័យព្រះរាជបុត្រឱ្យឈប់គិតពីរឿងនោះគឺត្រូវបន្ថែមភាពសប្បាយរីករាយដោយគ្រឿងទាក់ទាញអារម្មណ៍ផ្សេងៗដល់ព្រះអង្គ ដើម្បីឱ្យព្រះអង្គទ្រង់សព្វព្រះទ័យតែក្នុងរាជវាំងប៉ុណ្ណោះ ។ ដើម្បីឱ្យបានសំរេចព្រះបំណងនេះ គំរោងការណ៍ដំបូងទ្រង់ត្រាស់បញ្ជាឱ្យជាងកសាងប្រាសាទថ្មីបីដ៏ល្អប្រណីតសំរាប់ព្រះរាជបុត្រ ។



38-The first palace was built of fragrant wood. Inside, the air was warm, and everything was designed for maximum comfort. This was the prince's winter palace. The second was the prince's summer palace, which was built of polished marble. The third palace was built of brick with a green-tiled roof. This was the prince's lodge in the monsoon season. King Suddhodana also ordered that a beautiful garden be built around the three palaces, which was to have many ponds containing lotus plants of various colors. Thus the prince could take a walk or a horseback ride or do whatever he enjoyed most.

៣៨-ប្រាសាទទីមួយធ្វើអំពីឈើក្រអូប ។ ផ្ទៃខាងក្នុងមានធាតុអាកាសក្តៅស្រួល ហើយអ្វីៗទាំងអស់គេរៀបចំលំអតុបតែងឱ្យមានផាសុកភាពដ៏ជាទីកក់ក្តៅ ។ ប្រាសាទនេះសំរាប់ព្រះរាជកុមារគង់នៅក្នុងរដូវត្រជាក់ ។ ប្រាសាទទីពីរជាប្រាសាទត្រជាក់សំរាប់ទ្រង់គង់នៅក្នុងរដូវក្តៅ ដែលធ្វើអំពីថ្មពាលដ៏ភ្លឺរលោង ។ ប្រាសាទទីបីធ្វើអំពីឥដ្ឋដុត ដំបូលប្រក់ក្បឿងពណ៌បៃតង ។ ប្រាសាទនេះសំរាប់ព្រះអង្គគង់នៅក្នុងរដូវវស្សា ។ ព្រះបាទសុទ្ធោទនៈទ្រង់មានព្រះរាជបញ្ជាឱ្យធ្វើសួនច្បារដាំលំអដោយបុប្ផាទាំងឡាយ មានក្លិនក្រអូបព័ទ្ធជុំវិញប្រាសាទទាំងបី. ក្នុងស្រះទឹកទាំងឡាយមានផ្កាបទុមជាតិធំៗពណ៌ផ្សេងៗរីកស្គុះស្គាយសាយភាយក្លិនគន្ធពិដោរ ។ ធ្វើយ៉ាងនេះដើម្បីឱ្យព្រះរាជកុមារទ្រង់សប់ព្រះទ័យសប្បាយក្នុងការយាងឬគង់លើអាជានេយ្យកំសាន្តសប្បាយ ឬទ្រង់ចង់ធ្វើដូចម្តេចក៏បាន តាមតែទ្រង់សព្វព្រះទ័យ ។



39-The years went by very quickly, and the Prince Siddhartha had now become a young man. All the material pleasures the King had bestowed on him turned out to be valueless to the contemplative prince. The King had thought that his actions would make the prince happy, but everything proved to be in vain.

៣៩-ពេលវេលាចេះតែកន្លងផុតទៅយ៉ាងលឿន. ព្រះសិទ្ធត្ថកុមារទ្រង់ក៏មានវ័យចំរើនឡើងពេញរូបពេញរាង ។ គ្រប់គ្រឿងកំសាន្តអារម្មណ៍ទាំងឡាយ ដែលព្រះវរបិតាទ្រង់បានប្រទានដល់ព្រះអង្គទាំងប៉ុន្មាន វាប្រែទៅជាគ្មានឥទ្ធិពលដល់ព្រះអង្គសោះឡើយ ។ ព្រះមហាក្សត្រទ្រង់ព្រះតំរិះថា រាល់ទង្វើរបស់ព្រះអង្គទាំងអស់ គួរតែធ្វើឱ្យបុត្របានសប្បាយ .ឥឡូវអ្វីៗសព្វយ៉ាងប្រែទៅជាឥតសារឥតការទៅវិញ ។



40-He then summoned his ministers to a meeting, asking them if there were any other means to prevent the Prince from abandoning his position as potential leader of the country to become a religious teacher as the old sage Asita had predicted. The officials offered their opinion: "The best way to hold the prince is to seek out the most beautiful girl in the land and have the prince get married to her. Once the prince has experienced the sweetness of married life, he will choose nothing else. Then he will follow your intention and take over the throne in the future."

៤០- ក្រោយមកព្រះមហាក្សត្រទ្រង់បានកោះប្រជុំរដ្ឋមន្ត្រីទាំងឡាយ ដើម្បីស្នើសុំយោបល់ក្រែងមានមធ្យោបាយអ្វីផ្សេងទៀតដើម្បីទប់ស្កាត់កុំឱ្យព្រះរាជបុត្រលះបង់តួនាទីជាអ្នកដឹកនាំដ៏មានសក្តានុពលក្នុងព្រះនគរ ទៅធ្វើជាសាស្តាចារ្យខាងសាសនា ដូចដែលអសិតតាបសបានព្យាករណ៍ទុកមកនោះ ។ រដ្ឋមន្ត្រីទាំងឡាយបានទូលថ្វាយយោបល់ថា " បពិត្រមហារាជ មធ្យោបាយល្អបំផុតដើម្បីចងរឹតព្រះរាជកុមារ គឺមានតែរកនារីដែលមានរូបឆោមល្អដាច់គេក្នុងព្រះនគរមករៀបអភិសេកថ្វាយព្រះរាជកុមារតែម្យ៉ាងប៉ុណ្ណោះទេ. ក្រាបទូល ។ កាលណាព្រះកុមារជាម្ចាស់ទ្រង់បានទទួលនូវរសជាតិផ្អែមល្ហែមនៃជីវិតប្តីប្រពន្ធហើយនោះ ព្រះអង្គទ្រង់នឹងមិនរើសរកអ្វីផ្សេងទៀតឡើយ ។ ពេលនោះ ព្រះបំណងព្រះមហារាជនឹងបានសំរេច. ហើយព្រះរាជកុមារពិតជាទ្រង់ទទួលស្នងរាជសម្បត្តិគ្រប់គ្រងព្រះនគរតទៅអនាគតជាក់ជាមិនខាន " ។



41-The King considered the suggestion offered by the ministers as alright. Then he ordered the selection of the most beautiful girl in the country to take place. On the particular day decreed for the selection, all candidates had to come to the city of Kapilavastu. Each of them was required to walk in front of the prince and would receive a present from him. The King also ordered a group of highly intelligent officials to be stationed in a place where the beautiful girls were to pass before the prince. Their duty was to observe carefully which girl the prince likea best.

៤១-ព្រះបរមរាជាទ្រង់ព្រះតំរិះថា យោបល់របស់រដ្ឋមន្ត្រីទាំងឡាយត្រឹមត្រូវប្រាកដមែន ។ ថ្ងៃជាលំដាប់តមក ព្រះអង្គទ្រង់ត្រាស់បញ្ជាឱ្យគេរៀបចំពិធីជ្រើសរើសរកបវរកញ្ញាកុមារីស្រីក្រមុំដែលមានរូបឆោមល្អដាច់គេក្នុងព្រះនគរ ។ ក្នុងទិវាដ៏មហាឱឡារិកនោះ ក៏មានចេញរាជប្រកាសស្ដីពីការជ្រើសរើសនូវបេក្ខនារីទាំងអស់ឱ្យអញ្ជើញមកកាន់រាជធានីនៃនគរកបិលវត្ថុ ។ បេក្ខនារីទាំងអស់ត្រូវដើរជាជួរៗបន្តបន្ទាប់គ្នានៅពីមុខព្រះរាជកុមារនិងត្រូវទទួលយកអំណោយរង្វាន់ពីព្រះអង្គផង ។ ព្រះមហាក្សត្រត្រាស់បញ្ជាឱ្យមន្ត្រីមួយក្រុមដែលមានចំណេះដឹងខ្ពស់ខាងពិនិត្យមើលលក្ខណៈ អង្គុយត្រង់កន្លែងដែលបេក្ខនារីដើរកាត់ពីមុខព្រះរាជកុមារ ។ មន្ត្រីទាំងអស់មានតួនាទីពិនិត្យមើលយ៉ាងម៉ត់ចត់និងប្រុងប្រយ័ត្នបំផុតចំពោះនាងកញ្ញាក្រមុំណាមួយដែលព្រះរាជកុមារទ្រង់ស្រលាញ់ពេញព្រះទ័យខ្លាំងជាងគេ ។



42- On the day of the beauty contest, candidates from all over the country passed, one after another, in front of the prince. They were all very beautiful. Each of them received a present directly from the hand of the prince. The girls were all very happy and felt honored to accept a present from the prince. However, when they returned to their groups, they all began to fear that they might not be pretty enough.

៤២-ក្នុងឱកាសប្រឡងប្រជែងជ្រើសរើសបវរកញ្ញានោះ . កុមារីស្រីក្រមុំទាំងឡាយមកពីគ្រប់ខេត្តជនបទរាជធានីតូចធំទាំងអស់ក្នុងព្រះនគរ បានដើរបង្ហាញរូបឆោមលក្ខណៈចរិយាចំពីមុខព្រះរាជកុមារម្នាក់ម្ដងៗ ។ នាងកញ្ញាទាំងអស់សុទ្ធសឹងតែមានលក្ខណៈរូមឆោមល្អស្រស់គួរឱ្យគន់គ្រប់ៗគ្នា ហើយនាងម្នាក់ៗក៏បានទទួលនូវអំណោយអំពីព្រះហស្ដព្រះរាជកុមារផ្ទាល់ ។ កុមារីស្រីក្រមុំទាំងនោះមានចិត្តសប្បាយរីករាយឥតឧបមាដោយមានកិត្តិយសបានទទួលនូវអំណោយពីព្រះអង្គ ។ ទោះជាយ៉ាងនេះក្ដី នៅពេលដែលពួកនាងត្រឡប់ចូលទៅកន្លែងរបស់គេវិញ . គេមានអារម្មណ៍ថា ពួកគេមិនសូវជាល្អណាស់ណាទេ មើលទៅ ។



43-For they felt that, Prince Siddhartha was unlike other young men, he had not paid attention to their beauty at all. Indeed, the prince had handed a present to each of the girls, but his mind, all the time, appeared to be centered on some other thing, which was much more important than the smiling appearances and beautiful and voluptous bodily movements of the girls. And that was why some of girls said that when the prince had handed them presents, they felt that he was not an ordinary human being at all, but, on the contrary, that he was a celestial being.

៤៣-គេបានដឹងថា ព្រះសិទ្ធត្ថខុសប្លែកពីកម្លោះផ្សេងៗទៀត ព្រះអង្គទ្រង់មិនចាប់អារម្មណ៍នឹងសម្រស់លំអរបស់ស្រីក្រមុំទាំងនោះទាល់តែសោះ ។ ព្រះអង្គទ្រង់បានប្រទានទូវរង្វាន់ដល់ពួកគេក៏ពិតមែន តែគ្រប់ពេលទាំងអស់ ព្រះទ័យព្រះអង្គហាក់ដូចជាទ្រង់ផ្តោតសំដៅទៅលើអ្វីផ្សេងៗដែលសំខាន់ជាងអាការៈញញឹមប្រិមប្រិយសម្រស់ស្រស់សង្ហារនិងកាយវិការទន់ល្វន់ល្វៃដ៏គួរឱ្យប្រតិព័ទ្ធស្នេហាពេកក្រៃរបស់កញ្ញាស្រីក្រមុំទាំងនោះទៅទៀត ។ ហេតុនោះហើយ បានជាពួកនាងកញ្ញាខ្លះនិយាយថា ពេលដែលព្រះអង្គម្ចាស់ទ្រង់ព្រះប្រទានរង្វាន់ដល់ពួកនាង . នាងមានអារម្មណ៍ថា ព្រះអង្គទ្រង់មិនមែនជាមនុស្សធម្មតាទេ ប៉ុន្តែព្រះអង្គជាមនុស្សទេពដោយពិត ។



44-The line of girls had almost come to an end, and the presents were all given away. The prince still sat calmly, thinking about other things. Everyone thought that the last contestant had come before the prince and received her present, but suddenly a beautiful girl hastily entered , for she had arrived late.

៤៤-ក្បួនដំណើរជាជួរៗបន្តបន្ទាប់គ្នានៃបវរកញ្ញាទាំងឡាយជិតនឹងផុតអស់ទៅហើយ រង្វាន់ទៀតសោតទ្រង់បានព្រះប្រទានអស់គ្មានសល់ ។ ព្រះរាជកុមារទ្រង់នៅតែគង់យ៉ាងស្ងប់ស្ងៀម ដោយទ្រង់នៅតែគិតអ្វីផ្សេងៗដដែល ។ ជនទាំងឡាយគិតថា បេក្ខនារីចុងក្រោយបានមកដល់ពីមុខព្រះរាជកុមារហើយ. ទាំងបានទទួលព្រះអំណោយសំរាប់នាងផងដែរ រួចហើយក៏ដើរចេញទៅ តែរំពេចភ្លាមនោះ ស្រាប់តែមានកុមារីស្រីក្រមុំដ៏ល្អសោភាម្នាក់ទៀតចូលមកយ៉ាងប្រញាប់ប្រញាល់. ព្រោះតែនាងមកដល់ក្រោយគេ ។



45-When this girl entered, the observers noticed that the prince was somewhat astonished. Like the other girls had done, she also walked before the prince, bashfully with bowed head. But after she had passed by, she looked backed smilingly and asked: "Any present for me?" The prince replied: "I am really sorry, but all the present are gone. However, you may have this!"And he took from his neck an exquisite golden chain and wound it about the girl's arm.

៤៥-នៅពេលដែលកុមារីព្រហ្មចារិនីរូបនេះចូលមកដល់. ទស្សនិកជនទាំងឡាយក៏ដូចជាក្រុមមន្ត្រីដែលអង្គុយចាំពិនិត្យមើល សឹងបានសំគាល់ឃើញថា ព្រះរាជកុមារទ្រង់ភ្ញាក់ព្រះស្មារតីភ្លែតឡើងនៅពេលដែលបានឃើញនាង ។ ដូចជាកញ្ញាៗទាំងឡាយទៀតដែរ . នាងដើរពីមុខព្រះរាជកុមារ ដាក់ភ្នែកក្រឡេកចុះក្រោមគោរពដោយអឹមអៀន ។ ប៉ុន្តែក្រោយពីដើរផុតពីព្រះអង្គបន្តិចក៏ងាកមកសំលឹងមើលព្រះអង្គវិញប្រកបដោយទឹកមុខញញឹមប្រិមប្រិយ ហើយក៏ទូលសួរព្រះអង្គថា " បពិត្រព្រះរាជកុមារ ! ព្រះអង្គមានរង្វាន់អ្វីសំរាប់ខ្ញុំម្ចាស់ឬទេ ? " ព្រះអង្គទ្រង់ត្រាស់តបថា " ឱ្យបងសុំទោស . រង្វាន់អស់ហើយ តែសូមប្អូនស្រីសំលាញ់មទទួលយករបស់នេះជារង្វាន់ចុះ !" ( លុះមានព្រះបន្ទូលដូច្នេះហើយ ) ទ្រង់ក៏ដោះខ្សែព្រះសុវណ្ណមាសដ៏ល្អឆើតបំពាក់ព្រះហស្តឱ្យនាង ។



46-The officials who were ordered by the King to observe were very happy to see this. They dicovered that the girl who had entered last was Yasodhara, the daughter of King Suppabuddha. They reported this to King Suddhodana, who sent his minister to visit King Suppabuddha, proposing that Princess Yasodhara marry Prince Siddhartha.

៤៦-មន្ត្រីទាំងឡាយដែលព្រះរាជាទ្រង់ត្រាស់បញ្ជាឱ្យពិនិត្យមើល. មានចិត្តសោមនស្សយ៉ាងខ្លាំងដោយបានឃើញអាការៈយ៉ាងនេះ ។ គេបានដឹងនិងស្គាល់យ៉ាងច្បាស់ថា បវរកញ្ញាដែលចូលមកដល់ក្រោយគេបង្អស់នេះគឺព្រះនាង **យសោធរា** ជាព្រះរាជបុត្រីរបស់ព្រះមហាក្សត្រព្រះបាទ **សុប្បពុទ្ធ** ។ ពួកអាមាត្យមន្ត្រីក៏បង្គំក្រាបទូលរឿងនេះដល់ព្រះបាទសុទ្ធោទនៈៗក៏ទ្រង់បញ្ជូនមន្ត្រីឱ្យទៅថ្វាយបង្គំទូលពត៌មាននេះ ដល់ព្រះបាទសុប្បពុទ្ធ ដើម្បីស្នើសុំចងស្ពានមានមេត្រីស្តីដណ្តឹងរាជកុមារីព្រហ្មចារិនីយសោធរា ទ្រង់រៀបរាជាភិសេកថ្វាយព្រះសិទ្ធត្ថរាជកុមារ ។



47– The people at the foot of the Himalaya were sturdy and brave. Thus, according to the custom of the Sakya Clan, when a young prince was about to marry, he had to demonstate to the public that he was a clever man, and as well versed in horseback-riding, archery, and fencing as the other brave, young men were. Respecting this custom, Prince Siddhartha openly invited all the clever and brave youths of the country to a contest of skills at Kapilavastu.

៤៧-មនុស្សទាំងឡាយរស់នៅតាមជើងភ្នំហិមពាន្ត សុទ្ធតែជាអ្នកមានថ្វីដៃខ្លាំងពូកែនិងអង់អាចក្លាហាន ។ ហេតុដូច្នោះហើយ បានជាទម្លាប់របស់សក្យត្រកូល កាលណាព្រះរាជបុត្រអង្គណាទ្រង់ចង់រៀបរាជភិសេក ព្រះរាជបុត្រអង្គនោះ ត្រូវតែសំដែងបង្ហាញនូវចំណេះវិជ្ជាផ្សេងៗដល់មហាជនឱ្យបានដឹងថា ជាអ្នកឆ្លាតវាងវៃ ខ្លាំងពូកែជាងអ្នកឯទៀតមែន ព្រមទាំងជាអ្នកថ្វីកស្ទាត់ជំនាញក្នុងការជិះសេះ បាញ់ធ្នូ និងវិជ្ជាគុនដាវខ្លាំងជាងបុរសផងឯទៀតៗ ។ ទ្រង់គោរពតាមប្រពៃណីទំនៀមទំលាប់នៃព្រះរាជវង្សានុវង្ស ព្រះសិទ្ធត្ថជាអម្ចាស់នៃយើងទ្រង់ប្រកាសយ៉ាងនិងអញ្ជើញជាសាធារណៈដល់បណ្ដាយុវជនដែលមានចិត្តក្លាហាននិងខ្លាំងពូកែក្នុងព្រះនគរទាំងមូលឱ្យមកប្រកួតប្រជែងថ្វីដៃជាមួយព្រះអង្គនៅក្នុងក្រុងកបិលវត្ថុ ។



48-Every one of these youths was an expert horseman, archer and fencer. Each young man, in turn, demonstrated his skills in front of the King, his officials and the people. Prince Siddhartha also participated in the contest, riding his white horse Kanthaka, and he turned out to be the most skillful of all the youths. In archery, Prince Siddhartha shot farther than his cousin Prince Devadatta, who was regarded by all as the best archer in the country.

៤៨- យុវជនប្រលងទាំងអស់សុទ្ធតែជាអ្នកមានថ្វីពូកែខាងជិះសេះ. បាញ់ធ្នូនិងជាអ្នកគុនដាវជំស្ទាត់ជំនាញ ។ យុវជនម្នាក់ៗបានបញ្ចេញថ្វីដៃរបស់ខ្លួននៅចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រនិងនាហ្មឺនសព្វមុខមន្ត្រី ព្រមទាំងប្រជាជនទាំងឡាយ ។ ព្រះអង្គម្ចាស់សិទ្ធត្ថដែលទ្រង់យាងចូលក្នុងការប្រកួតនោះ ព្រះអង្គទ្រង់គង់លើសេះឈ្មោះ **កណ្ឋកៈ** សម្បុរស ហើយទ្រង់បានសំដែងឱ្យឃើញថា ព្រះអង្គជាអ្នកស្ទាត់ជំនាញបំផុតលើគូប្រកួតទាំងអស់ ។ ក្នុងការប្រកួតបាញ់ធ្នូវិញ ព្រះអង្គទ្រង់បាញ់បានឆ្ងាយជាងទេវទត្តដែលជាជីដូនមួយនឹងព្រះអង្គ ហើយដែលជនទាំងឡាយចាត់ទុកថា ជាអ្នកបាញ់ធ្នូយ៉ាងពូកែបំផុតក្នុងព្រះនគរ ។



49-As a swordsman, Prince Siddhartha was able to cut down a tree with one stroke. After he had struck the tree, the tree remained standing, so that witnesses thought the prince had missed. But when the wind began to blow, the tree toppled slowly down, for the prince had sliced through the tree with no trace; the blade of the sword had passed through the tree as if it had cut through cream. In the fencing contest, the prince was also the victor with honor. Before that, his stepbrother, Prince Nanda, was generally recognized as the top swordsman.

៤៩-ចំណែកអ្នកគុនដាវវិញ. ព្រះសិទ្ធត្ថទ្រង់អាចកាប់ដើមឈើតែមួយដាវឱ្យរលំដួលបាន ។ ដើមឈើដែលព្រះអង្គទ្រង់បានកាប់ដាច់ហើយនោះ វានៅតែឈរនឹងដដែល ដូច្នេះ សក្ខីជនទាំងឡាយយល់ឃើញថា ព្រះសិទ្ធត្ថទ្រង់បរាជ័យហើយ ។ ប៉ុន្តែនៅពេលដែលខ្យល់បក់មកចំ ដើមឈើនោះក៏ដួលរលំសន្សឹមៗ ដោយហេតុថា ព្រះអង្គម្ចាស់សិទ្ធត្ថទ្រង់កាប់ផ្តាច់វាដោយគ្មានឃើញស្នាមមុខដាវបន្តិចសោះ ផ្លែដាវដ៏មុតនេះកាត់ផ្តាច់ដើមឈើដូចជាគេកាត់ការ៉េម ។ ក្នុងការប្រកួតគុនដាវព្រះរាជកុមារទ្រង់ជាអ្នកទទួលបានជោគជ័យប្រកបដោយកិត្តិយសដ៏ល្បីល្បាញទៀត ។ ចំណោះវិជ្ជាគុនដាវនេះកាលពីពេលមុន. ប្អូនរបស់ព្រះអង្គគឺរាជកុមារនន្ទៈ( ជាប្អូនចុង )ដែលគេទទួលស្គាល់ថា ជាអ្នកគុនដាវដ៏កំពូលម្នាក់ ។



50-Next came the horseracing contest. Prince Siddhartha's white horse Kanthaka ran so fast that the other racers were left far behind. So the other contestants complained: "The Prince wins so easily just because he has the fastest horse. Anyone riding Kanthaka would win first place. On the contrary, if someone were to race that rarely mounted queer black horse, then whoever the rider might be would surely be the loser."·

៥០-ថ្ងៃបន្ទាប់មក ការប្រណាំងសេះបានមកដល់ . សេះកណ្ឋកៈសម្បុរសរបស់ព្រះសិទ្ធត្ថរត់លឿនជាងសេះប្រណាំងដទៃទៀត ដែលធ្វើឱ្យសេះឯទៀតៗនៅឆ្ងាយដាច់ពីក្រោយ ។ ដូច្នេះហើយបានជាអ្នកប្រកួត ជាច្រើនគ្នាញត្អូញត្អែររអ៊ូរទាំថា " ព្រះអង្គម្ចាស់ទ្រង់បានឈ្នះដោយងាយយ៉ាងនេះ ដោយសារតែព្រះអង្គមានសេះពូកែបំផុតទេ ។ បើឱ្យគេរាល់គ្នាជិះសេះកណ្ឋកៈវិញ គេនឹងបានដល់ទីផ្តាច់ព្រ័ត្រមុន ហើយឈ្នះដូចតែគ្នា ។ ម្យ៉ាងទៀត បើអ្នកណាត្រូវបានប្រឡងហើយ ទៅជិះសេះសម្បុរខ្មៅដែលមិនធ្លាប់ជិះសោះ ពេលនោះ អ្នកជិះណាក៏ដោយ ពិតជាទទួលបរាជ័យដូចតែគ្នាមិនខានឡើយ ។



51-So they exchanged their horses, everyone trying, in turn, to mount that fierce haughty black horse, but it threw everyone to the ground. It was now Prince Anirud-dha's turn to try, and being the best rider in the country, he mounted the black horse with only a slight effort, and then he whipped it hard to force it to run around the yard.

៥១-ដោយផ្អែកលើហេតុយ៉ាងនេះ តេក៏ប្តូរសេះគ្នា. ម្នាក់ៗខំព្យាយាមជិះសេះសម្បុរខ្មៅដែលកាចសាហាវ តាមវេនរៀងៗខ្លួន ។ ប៉ុន្តែឡើងមិនទាន់ដល់ខ្នងសេះស្រួលបួលផង ក៏ត្រូវសេះវាប្រាយធ្លាក់មកដីវិញ ។ ដល់វេនព្រះរាជកុមារ **អនុរុទ្ធ** ត្រូវជិះ. ក្នុងនាមជាអ្នកជិះសេះយ៉ាងល្បីល្បាយបំផុតក្នុងនគរ អនុរុទ្ធទ្រង់ឡើងជិះសេះខ្មៅនេះ ដោយទ្រង់មិនសូវជាប្រឹងប៉ុន្មានទេ ហើយបន្ទាប់មកទ្រង់ក៏បំបោលឱ្យវារត់ជុំវិញទីលានប្រកួត ។



52-However, Prince Anirudha stayed in place for only a moment, for unexpectedly the fierce, untamed horse reared, turned its head, and caught the Prince's leg in its mouth and threw him from its back to the ground. If the yardguards had hesitated in going to help him or remained behind the horse without beating it, the wild animal would unquestionably have killed Prince Aniruddha.

៥២-ព្រះអនុរុទ្ធទ្រង់គង់លើខ្នងសេះបានប្រហែលពីបីនាទីប៉ុណ្ណោះ. សេះកំណាចសាហាវហួសពីការស្មាននេះស្ទុះឡើងទាំងជំហរ ត្រវីក្បាលងាកក្រោយខាំព្រះបាទព្រះអង្គ ហើយត្រវែងគ្រវាត់ទម្លាក់អនុរុទ្ធពីលើខ្នងវាធ្លាក់ដល់ដី ។ បើកុំតែបានពួកអ្នកចាំទីលានប្រកួតស្ទុះចូលមកជួយទាន់ កុំអីសត្វសេះសាហាវនេះធ្វើឱ្យអនុរុទ្ធអស់ព្រះជន្មដោយឥតសង្ស័យឡើយ ។



53-Now it was Prince Siddhartha's turn to mount. Everybody felt that if even Prince Aniruddha, the best rider in the country, had been thown and almost killed, Prince Siddhartha could probably do no better. But Prince Siddhartha approached the horse lightly, and put one hand on its neck while rubbing its nose with his other hand, at the same time softly murmurring a few words and then tapping the horse on the sides of its body.

៥៣-ឥឡូវនេះដល់វេនព្រះសិទ្ធត្ថជាម្ចាស់ ។ ទស្សនិកជនទាំងឡាយមានអារម្មណ៍ថា សូម្បីតែ ព្រះអនុរុទ្ធទ្រង់ជាអ្នកពូកែជិះសេះបំផុតក្នុងនគរទៅហើយនៅតែធ្លាក់ស្ទើរតែទីវង្គត ចុះទម្រាំព្រះសិទ្ធត្ថវិញ ប្រហែលជាទ្រង់មិនអាចជិះបានឡើយ ។ ប៉ុន្តែព្រះសិទ្ធត្ថទ្រង់យាងចូលទៅជិតសេះនោះតិចៗ សន្សឹមៗ ព្រះហស្តម្ខាងទ្រង់កាន់កវា ព្រះហស្តម្ខាងទៀតទ្រង់ស្ទាបអង្អែលច្រមុះវាថ្នមៗ រួចហើយទ្រង់មានព្រះវាចារហ៊ឹមៗដំពិរោះផ្អែម លៃមពីរបីព្រះឱស្ឋនិងទ្រង់ទះខ្លួនវាទាំងសងខាងថ្នមៗ ។



54-Everybody was quite surprised that the fierce black horse had really calmed down, gently letting the prince ride him, it obediently moved foreward or backward as the prince directed. The people who were gathered there clearly saw that the horse was acting completely according to the prince's will. It was the first time that any person had ever dared to come close to this proud horse and tame it without a whip.

៥៤-ជនទាំងឡាយភ្ញាក់ផ្អើលស្ងប់ស្ងែងក្នុងចិត្តយ៉ាងខ្លាំងដោយឃើញសេះខ្មៅកំណាចនោះត្រឡប់ជាស្លូតវិញ ហើយឱ្យព្រះអង្គគង់លើវាបានយ៉ាងស្រួល ព្រះសិទ្ធត្ថទ្រង់ចង់បញ្ជាឱ្យវាទៅមុខទៅក្រោយឬបត់ឆ្វេង បត់ស្តាំ វាតាមទាំងអស់ ។ ជនទាំងឡាយដែលបានចូលរួមក្នុងទីនោះទាំងប៉ុន្មានបានឃើញផ្ទាល់នឹងភ្នែកយ៉ាងច្បាស់លាស់ថា សេះដែលកំពុងរត់យ៉ាងពេញទំហឹងនោះ ដោយសារតែព្រះទ័យដ៏ល្អរបស់ព្រះអង្គ ។ នេះជាលើកទីមួយ ដែលមានអ្នកហ៊ានមកជិតសេះកំណាចនេះ ហើយផ្សាំងវាបានដោយងាយ ។



55-Finally everyone agreed that Prince Siddhartha was the best rider in the country and most qualified to be Princes Yasodhara's husband. And King Suppabuddha was also very pleased to give the hand of his beloved daughter to the young, courageous prince Siddhartha in marriage.

៥៥-ទីបញ្ចប់ជនទាំងឡាយទទួលយល់ព្រមថា រាជកុមារសិទ្ធត្ថទ្រង់ជាអ្នកជិះសេះដ៏ពូកែលើសគេក្នុងព្រះនគរនិងជាមនុស្សមានលក្ខណៈសម្បត្តិល្អបរិបូណ៌បំផុតដែលត្រូវបានធ្វើជាព្រះស្វាមីរបស់ព្រះរាជកុមារីព្រហ្មចារិនីយសោធរា ។ ព្រះបាទសុប្បពុទ្ធមានព្រះទ័យសប្បាយក្រៃលែង ទ្រង់ព្រមថ្វាយព្រះរាជបុត្រីជាទីស្នេហារបស់ព្រះអង្គដល់ព្រះសិទ្ធត្ថដ៏អង់អាចក្លាហាននេះ ដើម្បីរៀបអភិសេក ។



56-The wedding of Princess Yasodhara to Prince Siddhartha was an event in which the whole country rejoiced. The young couple lived in a palace that King Suddhodana had specially built for them, one which contained all kinds of splendid accomodations designed for the sole purpose of giving them comfort, satisfaction and pleasure. Now King Suddhodana began to feel relaxed, feeling assured that the Prince would no longer think about leaving home .

៥៦- ពិធីរាជាភិសេកព្រះនាងយសោធរានិងព្រះសិទ្ធត្ថជាពិធីមួយដែលមនុស្សក្នុងព្រះនគរទាំងមូល ត្រេកអររីករាយសប្បាយគ្រប់ៗគ្នា ។ គូស្វាមីភរិយាវ័យក្មេងទាំងពីរអង្គទ្រង់គង់នៅក្នុងប្រាសាទដែលព្រះបាទសុទ្ធោទនៈបានសាងថ្វាយយ៉ាងវិសេសវិសាល ជាប្រាសាទដែលមានកន្លែងគង់នៅដ៏អស្ចារ្យឥតគណនាប្រដូចបានដែលគេរៀបចំតុបតែងលំអដើម្បីបំណងតែមួយគត់គឺធ្វើឱ្យស្វាមីភរិយាទាំងពីរ មានផាសុកភាពមានការសព្វព្រះហឬទ័យនិងទ្រង់សប្បាយរីករាយតែប៉ុណ្ណោះ ។ ឥឡូវនេះ ព្រះបាទសុទ្ធោទនៈមានអារម្មណ៍ធូរស្បើយផុតពីទុក្ខកង្វល់ ដោយសំអាងថា ជាប់ចំណងប៉ុណ្ណោះហើយ ព្រះអង្គម្ចាស់ទ្រង់នឹងមិនប្រែព្រះចិន្តាគិតអំពីដំណើរចេញចោលព្រះរាជដំណាក់ទៀតឡើយ ។



57-In order to prevent the prince from thinking of leaving home or of other things. King Suddhodana ordered that no one should ever mention in front of the prince anything having to do with misery or unhappiness, such as old age, sickness, death. etc. The attendants of the prince were ordered to constantly provide songs, dances, and music and never to appear tired before him.

៥៧-ដើម្បីការពារកុំឱ្យព្រះអង្គម្ចាស់ទ្រង់គិតអំពីការចាកចោលរាជបល្ល័ង្ក ឬគិតពីអារម្មណ៍ផ្សេងៗ. ព្រះបាទសុទ្ធោទនៈទ្រង់មានព្រះរាជឱង្ការហាមប្រាមថាមិនឱ្យមាននរណាម្នាក់និយាយអំពីរឿងអ្វីមួយដែលមានទុក្ខសោកឬអព្វមង្គលដូចជាការចាស់.ឈឺ.ស្លាប់ជាដើមឱ្យព្រះរាជបុត្រឮឡើយ ។ ស្រីអ្នកកំដរព្រះរាជបុត្រទាំងអស់ត្រូវបញ្ជាឱ្យច្រៀងរាំនិងប្រគុំតន្ត្រីជាប់ជានិច្ច ហើយមិនឱ្យសំដែងអាការនឿយហត់នៅចំពោះព្រះភ័ក្ត្រព្រះរាជបុត្រឡើយ ។



58– In addition to this, the King ordered the construction of high walls all around the palace and gardens where the prince lived. Only young and beatiful girls were allowed to enter into the gardens and the palace from beyond the walls. Should someone within the walls accidentally fall and injure himself, the person had to be taken out immediately and could not return before complete recovery. The gate of the garden was closely guarded to prevent the prince from going outside for any reason, except with the King's permission.

៥៨-ជាងនេះទៀត ព្រះរាជាទ្រង់ត្រាស់បញ្ជាឱ្យគេធ្វើកំពែងខ្ពស់ៗព័ទ្ធជុំវិញប្រាសាទនិងសួនឧទ្យានទាំងឡាយដែលព្រះអង្គគង់នៅ ។ មានតែពួកកុមារីស្រីក្រមុំក្មេងៗដែលមានរូបឆោមល្អតែប៉ុណ្ណោះ ដែលគេអនុញ្ញាតឱ្យចូលក្នុងសួនឧទ្យាននិងប្រាសាទបាន ។ បើមានអ្នកណាម្នាក់នៅខាងក្នុងកំពែងភ្លាំងដើរដួលដោយចៃដន្យឬដោយប្រការណាមួយហើយមានរបួស. អ្នកនោះត្រូវតែយកចេញជាបន្ទាន់ហើយមិនអាចត្រឡប់វិញបានឡើយ លុះត្រាតែជាសះស្បើយទើបអនុញ្ញាតឱ្យចូលមកទៀតបាន ។ ទ្វារសួនឧទ្យានមានអ្នកយាមយ៉ាងហ្មត់ចត់គ្រប់ទាំមី ដើម្បីការពារកុំឱ្យព្រះមហាបុរសទ្រង់យាងចេញទៅក្រៅលើកលែងតែកាលណាមានការអនុញ្ញាតពីព្រះមហាក្សត្រ ។



59-Although Suddhodana had a selected group of attendants for the prince and tried in every way to keep his son from experiencing anything unpleasant in his life, the prince was not as happy as his father had hoped. The prince eagerly desired to see other joyful things of the world, things that were beyond the palace walls. The prince also wanted to know what the life of the people, other than that of the sons of the kings and their high officials, was like. Time and time again the prince pleaded with his father, informing him that he would never be happy unless he could see the outside world.

៥៩-ទោះបីព្រះបាទសុទ្ធោទនៈទ្រង់បានជ្រើសរើសឱ្យមានក្រុមអ្នកកំដរល្អៗក្មេងៗសំរាប់ព្រះរាជបុត្រនិងទ្រង់បានខិតខំព្យាយាមគ្រប់មធ្យោបាយ ដើម្បីរារាំងព្រះអង្គមិនឱ្យជួបអ្វីមួយដែលមិនជាទីសប្បាយក៏ដោយ ក៏ព្រះអង្គម្ចាស់ទ្រង់មិនសប្បាយព្រះទ័យដូចដែលព្រះបិតាសង្ឃឹមទុកនោះឡើយ ។ ព្រះសិទ្ធត្ថជាម្ចាស់ទ្រង់មានព្រះបំណងប្រាថ្នាយ៉ាងខ្លាំងដើម្បីទតមើលវត្ថុល្អៗជាទីសប្បាយផ្សេងៗដទៃទៀតក្នុងលោក ដែលមាននៅខាងក្រៅកំផែងនៃព្រះបរមរាជវាំង ។ ព្រះអង្គម្ចាស់មានព្រះបំណងចង់ដឹងថា តើជីវិតរស់នៅរបស់មនុស្សទាំងឡាយ. ក្រៅពីពួកកូនស្តេចនិងកូននាហ្មឺនមន្ត្រីធំៗ.មានរបៀបរស់នៅយ៉ាងណា ។ ព្រះអង្គទ្រង់អង្វរទូលសុំព្រះបិតាម្តងជាពីរដងដោយទូលថា ព្រះអង្គទ្រង់មិនសប្បាយព្រះទ័យសោះឡើយ បើទ្រង់មិនបានយាងទៅទតលោកខាងក្រៅទេ ។



60- Unable to refuse the persistent demand of the prince to travel outside the palace, King Suddhodana finally consented. He ordered that, on the day of the prince's outing, every house must be cleaned, painted and decorated with flags and flowers. Along the way no one was allowed to be seen working, and blind, sick old men and leprous persons had to stay home until the carriage of the prince had passed.

៦០-ដោយទ្រង់មិនអាចបដិសេធនូវការទូលសុំដ៏ទទូចដដែលៗរបស់ព្រះរាជបុត្រដើម្បីយាងទៅទស្សនាខាងក្រៅព្រះបរមរាជវាំងទៀតបាន ព្រះបាទសុទ្ធោទនៈទង់ក៏យល់ព្រមរាជានុញ្ញាត ។ ព្រះរាជាទ្រង់ប្រកាសថា នៅថ្ងៃដែលព្រះរាជបុត្រទ្រង់យាងចេញទៅខាងក្រៅព្រះរាជវាំង គ្រប់ផ្ទះទាំងអស់ ត្រូវបោសសំអាតលាបថ្នាំនិងតុបតែងលំអរដោយដោតទង់និងផ្កាភ្ញីឱ្យបានល្អ ។ នៅតាមដងផ្លូវ មិនត្រូវឱ្យឃើញមានជនណាម្នាក់កំពុងធ្វើការងារឡើយ ហើយមនុស្សចាស់ មនុស្សឈឺ . មនុស្សខ្វិនខ្វាក់អន្ធការ. និងមនុស្សកើតឃ្លង់ឬរោគផ្សេងៗត្រូវស្ថិតនៅតែក្នុងផ្ទះ មិនត្រូវចេញក្រៅឡើយរហូតដល់ព្រះរាជបុត្រយាងទៅហួស ។



61- Everything was ready. Prince Siddhartha, in a splendid carriage, came out of the palace and toured around the city. Everywhere he saw crowds of people with smiling faces enthusiastically welcoming him. On seeing the prince, some people shouted: "Long live the prince!", while others approached his carriage and spread flowers on the road. The carriage thus continued moving on along the flower-covered path.

៦១-អ្វីៗសព្វយ៉ាងបានរៀបចំរួចជាស្រេច. ព្រះសិទ្ធត្ថ គង់ក្នុងរាជរថដ៏ល្អវិចិត្រអស្ចារ្យរចនាដោយក្បូរក្បាច់ផ្សេងៗ យាងចេញពីព្រះបរមរាជវាំងទ្រង់បានទស្សនាជុំវិញរាជធានី ។ គ្រប់ទីកន្លែងទាំងអស់ដែលព្រះអង្គយាងដល់ ទ្រង់បានទតឃើញហ្វូងមហាជនទាំងឡាយ មានទឹកមុខញញឹមស្រស់ស្រាយរាក់ទាក់អបអរសាទរទទួលស្វាគមន៍ព្រះអង្គគ្រប់ៗគ្នា ។ នៅពេលបានឃើញព្រះអង្គភ្លាម អ្នកខ្លះស្រែកសាទរថ្វាយពរជ័យថា "សូមឱ្យព្រះរាជបុត្រជាម្ចាស់មានព្រះជន្មយឺនយូរ" អ្នកខ្លះទៀត ចូលទៅជិតរាជរថហើយ ក៏បាចផ្កាគន្ធពិដោរនៅលើផ្លូវ ។ ចំណែករាជរថចេះតែបន្តដំណើរសន្សឹមៗតាមបណ្ដោយផងផ្លូវដែលក្រាលគ្របទៅដោយផ្កាភ្ញី ។



62-All at once, a white-haired old man, clad in dirty rags and tatters, limped out of his house and reached the road before anyone could stop him. His haggard face was full of wrinkles and freckles, his eyes dull and dim, and only one tooth remained in his dry and withered mouth. His back was severely hunched and he had to rely on a cane to move his body. Wailing and begging along the road, he would certainly have starved to death if he had failed to get food for even one day.

៦២-ពេលនោះស្រាប់តែមានមនុស្សចាស់ម្នាក់ សក់ស្កូវព្រោង . សំលៀកបំពាក់តត្រិចជាចំរយីរយៃ ដើរខ្ញើចៗញ៉ីរញ៉ាក់ទទ្រាក់ទទ្រើកចេញពីផ្ទះគាត់មកដល់ថ្នល់ ហើយគ្មាននរណាម្នាក់ឃើញគាត់ជាមុននិងបានឃាត់គាត់ឡើយ ។ មុខគាត់ស្គាំងស្គមខ្ទងផតឡើងខ្មៅជាំជុំៗគួរឱ្យអាណោចអាធ័ម .ស្បែកស្វិតជ្រីវជ្រួញរយីករយាក. ភ្នែកទាំងទ្វេងចិតងងល់អន្ធការ ឯធ្មេញសោតសល់តែមួយក្នុងមាត់ក្រពិតៗស្វិតក្រៀមក្រោះ ។ ខ្នងគាត់កោងគម ដំណើរទ្រេតទ្រោតយ៉ាងខ្លាំង ដៃកាន់ឈើច្រត់ទប់កាយ ស្រែកទ្រហោយំសុំទានតាមផ្លូវ ។ គាត់ប្រាកដជាដាច់ពោះស្លាប់មិនខាន បើសុំទានមិនបានអីទេនោះ ។



63– People were very much upset by the daring appearance of this old man since this was the prince's first excursion, and the king had issued an order prohibiting the presence of all old and sick persons. They rushed to stop this old man from advancing further, intending to drive him home, but it was already too late. The prince had already seen him!

៦៣-មហាជនទាំងឡាយជ្រួលច្របល់តប់ប្រមល់យ៉ាងខ្លាំងដោយបានឃើញអាការៈហ៊ានហួសប្រមាណឥតមានកោតខ្លាចរបស់តាចាស់រូបនេះ ព្រោះនេះជាដំណើរយាងកំសាន្តលើកទីមួយរបស់រាជកុមារ ហើយព្រះរាជាទ្រង់បានចេញព្រះរាជប្រកាសហាមប្រាមមិនឱ្យឃើញមានមនុស្សចាស់. មនុស្សឈឺណាម្នាក់ឡើយ នៅពេលដែលព្រះអង្គម្ចាស់យាងដល់ ។ ជនទាំងឡាយស្ទុះស្ទារប្រុងចូលទៅបញ្ឈប់ដំណើរតាចាស់ជរានោះមិនឱ្យដើរទៅមុខទៀត ក៏ប៉ុន្តែវាហួសពេលណាស់ទៅហើយ ព្រោះព្រះអង្គទ្រង់ទតឃើញគាត់មុនរួចជាទៅហើយ ។



64- Prince Siddhartha was quite surprised at the sight of the old man. He did not know what the creature was. So he asked his driver Chandaka: "Chandaka! What is that? A person? If he is a person, why is his back so curved and not as straight as other people's? Why does he shake? And the hair, why is it white? What happened to his eyes? Where are his teeth? Are some people born this way? Chandaka! Tell me what all this means!"

៦៤-ព្រះសិទ្ធត្ថទ្រង់ភ្ញាក់រន្ធត់យ៉ាងខ្លាំងនៅពេលបានឃើញមនុស្សចាស់នោះ ។ ព្រះអង្គទ្រង់ពុំស្គាល់ថា តើគេជាសត្វអ្វីឡើយ ។ ទ្រង់ឆ្ងល់ខ្លាំងដូច្នេះ ក៏ទ្រង់សួរ **ឆន្នៈ** ជានាយសារថីថា " នែ៎ **ឆន្នៈ** ! តើនោះជាអ្វី? ជាមនុស្សមែនទេ? បើគាត់ជាមនុស្ស ហេតុអ្វីក៏ខ្នងគាត់កោងខ្លាំងម្ល៉េះ យ៉ាងម៉េចមិនត្រង់ដូចខ្នងគេរាល់គ្នា? ហេតុអ្វីបានជាគាត់ញាក់ញ័រយ៉ាងនេះ? រួចចុះសក់គាត់ហេតុអ្វីបានជាពណ៌សអ៊ីចឹង? តើភ្នែករបស់គាត់កើតអ្វី? ចុះធ្មេញគាត់បាត់ទៅណាអស់? ហើយមានមនុស្សប៉ុន្មាននាក់ទៀតមានអាការៈបែបនេះ? នែ៎ **ឆន្ន** ! ចូរឯងប្រាប់យើងមក តើវាយ៉ាងម៉េចហ្នឹង ? "



65-Chandaka replied: " This is an old man. He was not born this way. When he came into the world, he was like everybody else. At first, he was also a strong and dignified youth, having dense black hair and bright eyes. After having lived for a long time, he has changed into this shape. Don't let it bother you Prince, for it is only the business of this old person."

"What does it mean, Chandaka?" Do you say that everyone will look like this after having lived for a long time, or is it not necessarily so? I have not seen this condition before!" Chandaka replied: "When one has lived a long time, he will be like this. It cannot be avoided."

៦៥-នាយឆន្នៈក៏ក្រាបបង្គំទូលថា “ បពិត្រ នេះជាមនុស្សចាស់ ព្រះអង្គ! ហើយគាត់មិនមែនកើតមកមានលក្ខណៈបែបហ្នឹងតែម្ដងទេ ។ កាលដែលគាត់កើតមកក្នុងលោកនេះ គាត់ក៏មានលក្ខណៈដូចមនុស្សរាល់គ្នាដែរ ។ ដំបូងឡើយ គាត់ជាមនុស្សម្នាក់មានកំលាំងពលំមាំមួន . មានកេរ្ដិ៍ឈ្មោះកិត្តិយសល្បាញល្បី. មានសក់ខ្មៅរលោងរលើប មានភ្នែកភ្លឺថ្លា ។ ក្រោយពីរស់នៅអស់រយៈកាលយូរឆ្នាំមក គាត់ក៏ប្រែទៅជារបៀបយ៉ាងនេះ ។ បពិត្រព្រះអង្គ! សូមទ្រង់តាំងព្រះទ័យនៅជាសុខចុះ . ព្រោះនោះជាដំណើរជីវិតរបស់មនុស្សចាស់តែប៉ុណ្ណោះ ។

ព្រះសិទ្ធត្ថជាម្ចាស់ទ្រង់សួរទៀតថា “នែ៎ ឆន្នៈតើនេះមានន័យដូចម្ដេច?” “ឯងចង់និយាយថា នេះជារឿងធម្មតាមែនទេ?” តើឯងថា មនុស្សគ្រប់រូបនឹងមានទំនងតាមលំអាននេះឬយ៉ាងណា ក្រោយពីរស់នៅអស់កាលជាច្រើនឆ្នាំមក? តាំងពីយើងកើតមក យើងមិនដែលជួបស្ថានភាពយ៉ាងនេះទេ” ។ ឆន្នៈ ទូលតបថា “កាលណាជនណាម្នាក់រស់នៅអស់កាលយូរ គេនឹងប្រែទៅជាមនុស្សដូចនេះ . គ្មានជនណាម្នាក់ អាចគេចផុតបានឡើយ សូមព្រះអង្គទ្រង់ជ្រាប ” ។



66- "Chandaka! Do you really mean that everybody will be like this some day, even you and I? My father ? My wife? Is it possible that all of us will some day have no teeth, have white hair and be hunchback, moving around with canes and shaking like this old man?"

"Indeed so!"answered Chandaka. "When one lives long enough, he will be like this man, for no one can avoid getting old!"

៦៦- “នែ៎ឆន្នៈ! អ្នកប្រាកដថា មនុស្សគ្រប់រូបទាំងអស់នឹងប្រែក្លាយទៅជារបៀបនេះ នៅថ្ងៃណាមួយខាងមុខ. ទាំងអ្នកឯង ទាំងខ្ញុំ? ទាំងព្រះបិតាខ្ញុំ? ទាំងមហេសីខ្ញុំផងមែនទេ? តទៅមុខ នៅថ្ងៃណាមួយ យើងទាំងអស់គ្នានឹងបាក់ធ្មេញ សក់ស្កូវ ខ្នងកោងគមញ្ញាក់ញញ័រ ដើរទៅណាមកណាត្រូវកាន់ឈើច្រត់ដូចតាចាស់ម្នាក់នេះមែនទេ ? ” ។

នាយឆន្នៈទូលថា “សូមទ្រង់ព្រះមេត្តាប្រោស ពិតជាដូច្នេះមែនព្រះអង្គ!” “ កាលណាជនណាម្នាក់មានជីវិតរស់នៅយូរៗទៅ គេនឹងមានសភាពដូចមនុស្សនេះ ដោយគ្មានបុគ្គលណាមួយអាចចៀសផុតពីជរាភាពនេះបានឡើយ! ” ។



67-Prince Siddhartha immediately told Chandaka to drive him back to the palace, for he was no longer in the mood to continue his journey around the city. He only wanted to be alone so that he could contemplate deeply the dreadful problem that he had just encountered. Soon he became aware that although he was the prince, the successor to the throne, he and the people dear to himself would, nevertheless, lose everything some day in the future. All his joys and pleasures would turn into nothing, for there would be no way to avoid getting old and, in this matter, no one is an exception, whatever his condition – rich, poor or powerful or mean.

៦៧- ភ្លាមនោះ ព្រះសិទ្ធត្ថទ្រង់ត្រាស់បញ្ជាឆន្នអាមាត្យឱ្យបររាជរថត្រឡប់ទៅកាន់ព្រះរាជវាំងវិញ ។ ដោយហេតុថា ព្រះអង្គទ្រង់មិនចង់បន្តព្រះរាជដំណើរឱ្យបានជុំវិញព្រះរាជធានីទៀតឡើយ ។ ព្រះអង្គទ្រង់ចង់គង់នៅតែមួយព្រះអង្គឯងប៉ុណ្ណោះ ដើម្បីទ្រង់បានពិចារណាឱ្យវែងឆ្ងាយដល់ទីជំរៅនៃបញ្ហាដ៏រន្ធត់ដែលទ្រង់ទើបបានជួបប្រទះ ។ ភ្លាមនោះ ព្រះអង្គទ្រង់បានរលឹកដឹងយ៉ាងច្បាស់ណាស់ថា ទោះបីព្រះអង្គជាព្រះរាជបុត្រ ជាវជ្ជទាយាទស្នងរាជបល្ល័ង្កក៏ដោយ ក៏ព្រះអង្គនិងមនុស្សទាំងឡាយដែលមានខ្លួនជាទីស្រលាញ់ក្រៃលែង នឹងបាត់បង់នូវអ្វីៗសព្វយ៉ាងនៅពេលណាមួយក្នុងអនាគតមិនខាន ។ ការត្រេកអរ ការសប្បាយរីករាយទាំងអស់នឹងទៅជាគ្មានន័យអ្វីទាល់តែសោះ ,ព្រោះហេតុដូច្នោះ គ្មានផ្លូវណាមួយដែលអាចចៀសឱ្យផុតពីភាពជរាគ្រាំគ្រាទ្រុឌទ្រោមនេះបានឡើយ ហើយជរាភាពនេះ គ្មានការលើកលែងចំពោះជនណាម្នាក់ទេ ទោះអ្នកនោះឯងជាមនុស្សបែបណាក៏ដោយ ជាអ្នកមាន អ្នកក្រ ជាអ្នកមានអំណាចស័ក្តិយស ឬឥតអំណាចក្រីក្រក៏ដោយ ។



68-That night, Prince Siddhartha could not sleep. He was very disturbed when he thought that some day he and his wife would become old like that old man he had seen during the day. He then began to have grave doubts, thinking: "Has there ever been anyone in the world who has tried to find a way to avoid or transcend the cruel process of aging? If I, put aside everything else and concentrate solely on this prolem, can I not find a way to benefit myself and all other people?"

៦៨-ក្នុងវេលារាត្រីនោះ, ព្រះសិទ្ធត្ថទ្រង់ផ្ទុំពុំលក់សោះ ។ ព្រះអង្គទ្រង់ព្រះកង្វល់ជាអនេកប្រការនៅពេលដែលទ្រង់ព្រះចិន្តាឃើញថា ថ្ងៃណាមួយព្រះអង្គនិងព្រះអគ្គមហេសីនឹងប្រែទៅជាចាស់ជរាដូចតាចាស់ម្នាក់ដែល ទ្រង់បានជួបកាលពីពេលថ្ងៃ ។ ពេលនោះ ព្រះអង្គទ្រង់ព្រះវិតក្កៈយ៉ាងខ្លាំង, ទ្រង់ចេះតែគិតថា " តើក្នុងលោកសន្និវាសនេះ មិនធ្លាប់មាននរណាម្នាក់ព្យាយាមស្វែងរកមាគ៌ាដើម្បីគេចវេសចៀសវាង ឬពុះពារឆ្លងឱ្យផុតនូវដំណើរចាស់ជរាដ៏កំណាចនេះទេឬ ? ចុះបើអាត្មាអញ លះបង់អ្វីៗទាំងពួងទុកមួយអន្លើសិន, ហើយខំពិចារណាចំរើនភាវនាចុះក្នុងអារម្មណ៍តែមួយលើបញ្ហានេះ តើអាត្មាអញអាចស្វែងរកមាគ៌ាដើម្បីជួយដល់ខ្លួនឯងផង និងដល់សត្វលោកដទៃផងបានដែរ ឬទេ ? " ។



69-Someone related the incident that had happened during the excursion to the King. The King was very sad, and again he ordered that a search be undertaken for interesting things to distract and amuse the prince. But , as had happened before, all was in vain. The young prince was not only indifferent to these things, but even once again asked his father's permission to go out, this time alone and unannounced, in order to see all the things of every day life.

៦៩-អ្នកខ្លះក៏បានទៅក្រាបបង្គំទូលអំពីឧបទ្ទវហេតុដែលកើតឡើងចំពេលដំណើរកំសាន្តដល់ព្រះរាជា ។ ព្រះរាជាទ្រង់ក្រៀមក្រំពុំសប្បាយព្រះទ័យសោះឡើយ ទ្រង់ក៏មានព្រះរាជឱង្ការឱ្យគេចាត់វិធានការណ៍ ស្វែងរកវត្ថុជាទីចាប់ចិត្តសំរាប់បុត្រជូន ដើម្បីបន្ធូបំភ័ន្តទាក់ទាញអារម្មណ៍និងធ្វើឱ្យព្រះរាជបុត្របានសប្បាយភ្លេចគិតដល់អ្វី១ទាំងអស់ ។ ប៉ុន្តែមិនខុសពីកាលមុនដែរ អ្វី១ទាំងអស់គ្មានអានុភាពបន្តិចបន្តួចឡើយ ។ ព្រះសិទ្ធត្ថជាអម្ចាស់មិនត្រឹមតែព្រងើយកន្តើយចំពោះវត្ថុទាំងនោះទេ តែថែមទាំងទូលសុំការអនុញ្ញាតពីព្រះរាជបិតាដើម្បីយាងចេញទៅក្រៅរាជវាំងម្តងទៀតទៅវិញ តែលើកនេះទ្រង់យាងទៅមួយព្រះអង្គឯង ហើយទ្រង់មិនប្រកាសឱ្យគេដឹងដូចមុនឡើយ . ក្នុងព្រះបំណងទតមើលកិច្ចការសព្វបែបយ៉ាងក្នុងជីវិតប្រចាំថ្ងៃរបស់ប្រជាជនទូទៅ ។



70-Naturally the King did not want to give his permission, for he was still more afraid that this time the prince would see many ordinary people, who have to sweat and toil all their days, not sons of kings and rich men; and he also feared that what the old sage had predicted might, indeed, come true. But love and compassion for his son finally forced him to permit the prince to go as he had requested. But he still hoped that those unpleasant things might not be seen by the prince.

៧០-តាមធម្មតា. ព្រះមហារាជទ្រង់មិនចង់ប្រទានរាជានុញ្ញាតទេ ពីព្រោះព្រះអង្គនៅតែមានព្រះទ័យព្រួយបារម្ភថា លើកនេះព្រះរាជបុត្រនឹងបានឃើញប្រជាជនសាមញ្ញជាច្រើនដែលមិនមែនជាបុត្រស្តេចឬអ្នកមាន. ដូច្នេះគេត្រូវបញ្ចេញកំលាំងធ្វើការដំលំបាកហូរញើសស្រោកជារៀងរាល់ថ្ងៃ. ហើយព្រះអង្គទ្រង់បារម្ភផងដែរនូវអ្វីដែលព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតតាបសទស្សន៍ទាយទុកមក ប្រហែលនឹងកើតឡើងដោយពិតឬយ៉ាងណា ។ តែដោយសារសេចក្តីស្នេហានិងមេត្តាករុណាចំពោះបុត្រ ទីបំផុតក៏បង្ខំឱ្យព្រះអង្គទ្រង់កាត់ព្រះទ័យព្រមរាជានុញ្ញាតដល់ព្រះរាជបុត្ររបស់ព្រះអង្គយាងចេញទៅ ។ ប៉ុន្តែព្រះរាជាទ្រង់នៅតែមានសង្ឃឹមថាវត្ថុអព្វមង្គលមិនជាទីសប្បាយក្សេមក្សាន្តទាំងឡាយនឹងមិនកើតឡើងដល់ព្រះមំសចក្ខុព្រះរាជបុត្រទៀតឡើយ ។



71-This time Prince Siddhartha went out on foot. He was disguised as a youth of a noble family and was followed only by Chandaka, who also dressed differently in order not to be recognized. So the prince, for the first time, saw the activities of an ordinary day in the capital. Many people were doing all different kinds of work. Blacksmiths pounded iron pieces with steel hammers to make plows, sickles, and oxen cart wheels, etc.

៧១-ម្ដងនេះព្រះសិទ្ធត្ថទ្រង់យាងដោយព្រះបាទទាផ្ទាល់ ។ ព្រះអង្គទ្រង់ស្លៀកពាក់បន្លំធ្វើជាមនុស្សក្នុងត្រកូលខ្ពង់ខ្ពស់ម្នាក់ ដោយមានតែឆន្នអាមាត្យម្នាក់ប៉ុណ្ណោះទៅជាមួយ ដោយស្លៀកពាក់ខុសគ្នា ដើម្បីកុំឱ្យគេមើលស្គាល់ ។ ដូច្នេះពេលដំបូង ព្រះរាជឱរសទ្រង់ទតឃើញសកម្មភាពធម្មតា១ក្នុងទីក្រុង ។ មនុស្សម្នាទាំងឡាយកំពុងធ្វើការទៅតាមមុខសញ្ញានៃការងារផ្សេង១របស់ខ្លួន ។ ជាងដែកទាំងឡាយដំដែកដោយញញួរដើម្បី ធ្វើនង្គ័ល. កណ្ដៀវនិងដែកកង់រទេះជាដើម ។ល។



72-Along the streets there were shops of rich merchants, craftsmen were making all kinds of adornments for women; dye shops were full of cloth of various colors; bakeries sold cakes to people waiting to buy them. At that time Prince Siddhartha felt happy and was very glad to see the conditions of these industriously working people.

៧២-នៅតាមផ្លូវវិថិនានា មានផ្ទះលក់ទំនិញជាច្រើនរបស់ពួកពាណិជ្ជករ . ឯពួកសិប្បករទាំងឡាយកំពុងធ្វើគ្រឿងប្រដាប់តាក់តែងកាយគ្រប់ប្រភេទសំរាប់ស្ត្រី ។ ហាងសំលៀកបំពាក់មានលក់សំលៀកបំពាក់គ្រប់ពណ៌. អ្នកធ្វើនំក៏លក់នំឱ្យអតិថិជនទាំងឡាយដែលកំពុងរង់ចាំទិញត្រៀបត្រា ។ នៅពេលនោះ ព្រះសិទ្ធត្ថរាជឱរសទ្រង់សប្បាយក្សេមក្សាន្តក្នុងព្រះរាជហឫទ័យនិងទ្រង់ត្រេកអរក្រៃលែងដោយបានទតឃើញទិដ្ឋភាពរបស់អ្នកនគរទាំងឡាយកំពុងប្រកបរបរអាជីវកម្មដូច្នេះ ។



73- But soon bad and ugly things began happening again. While the prince was strolling along, he suddenly heard a moan from the roadside, that sounded as if someone was calling for help. The prince approached the area, looked at the place where the moan was coming from, and found a man lying on the ground. His body was twisting incessantly, both his face and body were discolored with a nauseating purple hue, his eyes rolled back and forth in his head, and everytime he struggled to rise he fell heavily to the ground again, never making it to his feet.

៧៣-ប៉ុន្តែភ្លាមនោះស្រាប់តែមានឧបទ្ទវហេតុដ៏អាក្រក់ គួរឱ្យខ្លាចបានកើតឡើងម្តងទៀត ។ នៅពេលដែលព្រះអង្គកំពុងយាងលំហែទតមើលទិដ្ឋភាពទាំងពួងតាមបណ្តោយផ្លូវ . វេលានោះទ្រង់ក៏ឮសូរសំលេងស្រែកយំកន្ទក់កន្ទេញថ្ងូចថ្ងូរគ្រលូចគួរឱ្យតក់ស្លុតនៅចិញ្ចើមថ្នល់ម្ខាង ដែលសំលេងនោះហាក់ដូចជាស្រែករកអ្នកណាម្នាក់ឱ្យជួយ ។ ឮដូច្នោះ ព្រះអង្គទ្រង់យាងដល់ទីនោះភ្លាម. ទ្រង់ខំសំលឹងរកមើលត្រង់ទិនែ្លងដែលលេចឮសំលេង ហើយក៏បានប្រទះឃើញបុរសម្នាក់កំពុងដេកបម្រះនទៀលគ្រវីគ្រវាត់ដៃជើង សំលេងថ្ងូរហ៊ុះៗនៅលើដី ។ ដងខ្លួនគាត់ឡើងរមួលពត់ពែនដោយការឈឺចុកចាប់ឥតឈប់ឈរ . ទាំងមុខមាត់ ទាំងខ្លួនប្រាណប្រឡាក់ឡើងស្រមកៗកកដោយញើសក្អែល.ខ្ទុះឈាម ទៅជាសម្បុរឡើងស្វាយ ឃើញគួរឱ្យខ្ពើមរអើមពន់ពេក ។ ភ្នែកទាំងពីរវិលក្រឡឹតក្រឡាប់ហាក់ដូចប្រាប់ពីភាពក្រវល់ក្រវាយមហិមា . គាត់ខំត្រដរត្រដួសប្រវេប្រវារស្រវារក្រោកឡើង តែក្រោកមិនបាន ប្រាណក៏ដួលប្រួសទៅវិញយ៉ាងខ្លាំង . ងើបក្បាលឡើងទៀត ដួលទៅវិញទៀត. ទោះខំងើបឡើងយ៉ាងណាក៏ងើបក្រោកមិនរួចសោះឡើយ ។



74- Since Prince Siddhartha was so very merciful, he quickly approached the man and held him up, placing his head upon his own knee causing him to feel gradually comfortable and then asked what caused the pain and why he could not stand up. The man tried to say something, but he did not even have the strength to speak. Chandaka hastily approached, and the prince asked: "Chandaka, tell me why this man is in this condition! Look how he is breathing! Why does he not answer me?"

៧៤- ព្រះសិទ្ធត្ថដោយទ្រង់មានព្រះទ័យប្រកបដោយមេត្តាករុណាអាណិតអាសូរក្រៃពេកចំពោះសព្វសត្វ ឃើញដូច្នោះ ព្រះអង្គស្ទុះចូលទៅដល់បុរសនោះយ៉ាងប្រញាប់ ទ្រង់ចាប់លើកក្បាលគាត់ដាក់លើព្រះជានុព្រះអង្គផ្ទាល់ ទ្រង់បបោសអង្អែលដោយព្រះហស្ថដ៏ទន់ល្មន់ធ្វើឱ្យគាត់បានបាត់ការឈឺចាប់បន្តិចម្តងៗ ហើយទ្រង់មានព្រះបន្ទូលសួរថា តើអ្នកកើតជំងឺអ្វី ហើយយ៉ាងម៉េចបានជាក្រោកឈរមិនរួច ។ បុរសអ្នកជំងឺខំប្រឹងហារមាត់និយាយ. តែហេវហត់ដង្ហក់ញាក់ញ័រចំប្រប់ គ្មានកំលាំងនិយាយចេញបាន ។ (ឃើញដូច្នោះ) នាយឆន្នអាមាត្យទៅដល់ភ្លាម. ព្រះអង្គត្រាស់សួរឆន្នៈថា " នែ៎ឆន្នៈ ចូរឯងប្រាប់យើងមកមើល ហេតុអ្វីបានជាមនុស្សនេះស្ថិតក្នុងស្ថានភាពខុសគេទៅវិញ ! ចូរឯងមើលដង្ហើមគាត់យ៉ាងម៉េចហ្នឹង ! ហេតុអ្វី ក៏គាត់មិននិយាយតបមកយើង ? " ។



75- Chhandaka shouted in horror: "Don't touch this man! He is a sick person! Poison flows in his veins, and toxic poison is burning inside him, makng it difficult for him to breath so that finally he will stop breathing." The prince asked: "Will other people be like this? Could I, too, become like this?"

Chandaka answered: "If one comes into close contact with him, one may very possibly become like him. My prince, please lay him down and don't touch him, for the poison of the disease in his body may be passed on to you, and then you may well become sick like him!"

៧៥- នាយឆន្នៈស្រែកឡើងទាំងភ័យស្លន់ស្លោថា "សូមទ្រង់កុំប៉ះពាល់មនុស្សនេះឱ្យសោះ! គាត់ជាមនុស្សឈឺទេ! ជាតិពុលកំពុងហូរចូលគ្រប់សរសៃឈាម ហើយជាតិពុលនៃជំងឺដ៏សាហាវនេះកំពុងតែដុតឆេះរោលរាលក្តៅឈឺផ្សាក្នុងខ្លួនគាត់ ធ្វើឱ្យគាត់ដកដង្ហើមប្រជិតប្រជកដង្ហក់ដូចឈ្នក់ផ្សែង. ដូច្នេះ ទីបំផុតឆាប់ៗនេះគាត់នឹងដល់នូវមរណៈ" ។ ព្រះអង្គទ្រង់សួរទៀតថា " តើមនុស្សទាំងពួងទៀតនឹងមានសភាពដូចនេះដែរឬ? តើយើងនឹងក្លាយដូចគាត់នេះដែរឬ ?

នាយឆន្នក៏ទូលថា "បពិត្រព្រះអង្គ ប្រសិនបើអ្នកណាម្នាក់ចូលប៉ះពាល់ហែបទិតជិតដិតនឹងគាត់ អ្នកនោះអាចនឹងក្លាយជាមនុស្សដូចគាត់ពិតៗ ។ ម្ចាស់ថ្លៃខ្ញុំអើយ ! សូមទ្រង់ដាក់គាត់ចុះទៅ ទ្រង់កុំកាន់គាត់ឱ្យសោះ ព្រោះជំងឺដែលមានជាតិពុលដ៏សាហាវនៅក្នុងខ្លួនគាត់ អាចឆ្លងដល់ព្រះអង្គ. ហើយព្រះអង្គនឹងទៅជាឈឺដូចគាត់មិនខាន!" ។



76- "Chandaka ! Apart from this illness are there still more serious illnesses?" "Yes, there are many, and they are all in the same, very fainful." "Are there no people who can help? Can't mankind conquer the sickness when it attacks? That's too frightful!" "It is very common, and no one knows on what day he will fall sick, for one can fall sick anytime and any place." "Is it true, Chandana? Anybody may fall ill, including my whole clan and even me? "Yes, even I may fall sick also."

៧៦-" នែ ឆន្នៈ! ក្រៅពីជំងឺនេះ តើនៅមានជំងឺដង្កាត់រោគាព្យាធិធ្ងន់ធ្ងរអ្វីផ្សេងៗច្រើនទៀតទេ?" "ទ្រង់ព្រះមេត្តាប្រោស នៅមានច្រើនទៀតព្រះអង្គ. ហើយរោគាព្យាធិទាំងអស់នោះមានលក្ខណៈឈឺចុកចាប់ខ្លោចផ្សាយ៉ាងក្រៃលែងដូចៗគ្នា " ។ "តើមិនមានអ្នកណាអាចជួយគ្នាបានទេឬ ? តើមនុស្សយើងមិន អាចច្បាំងតទល់យកឈ្នះលើព្យាធិកំណាចនេះបានទេឬ? វាគួរឱ្យខ្លាចសម្បើមណាស់!" "វាមានជាទូទៅ ដោយគ្មានបុគ្គលណាមួយអាចដឹងជាមុនថា តើនៅថ្ងៃណាមួយគេនឹងមានជំងឺទេ . គេនឹងធ្លាក់ខ្លួនឈឺនៅពេលណាមួយនិងនៅកន្លែងណាមួយមិនខានឡើយ" ។ "វាពិតមែនឬឆន្នៈ ? មនុស្សម្នាក់ៗនឹងដល់នូវជំងឺដង្កាត់. រួមទាំងរាជវង្សានុវង្សយើងទាំងមូលផង ទាំងខ្លួនយើងផងឬ?" "បពិត្រព្រះអង្គ .រឿងនេះពិតណាស់ សូម្បីខ្លួនខ្ញុំព្រះអង្គក៏គេចមិនផុតពីរោគាពាធនេះដែរ " ។



77- "If it is like this, then the existence of man in the world is only to be feared since nobody knows whether he might not, when he goes this evening to sleep be transfor- med on the following morning into a sick man like that one. Chandaka, is that so?"

"Yes, it is so. No one in the world knows when he may become sick, suffer, and end by dying!"

" Death? What does it mean? It's very strange, Chanadaka. What is death?" Please, Prince, just look over there!"

៧៧-" ប្រសិនបើដូច្នោះមែន, ជីវិតមនុស្សក្នុងលោកនេះ គួរឱ្យភ័យខ្លាចណាស់ ដោយហេតុថា គ្មានបុគ្គលណាម្នាក់ដឹងថា តើគេអាចជាមនុស្សមានជំងឺឬយ៉ាងណានោះទេ នៅពេលដែលគេចូលដេកនាពេលយប់ ហើយភ្ញាក់ឡើងវិញនាព្រឹកស្អែក ។ អីចឹងមែនទេ ឆន្នៈ?

" បពិត្រព្រះអង្គ, ពិតជាដូច្នោះមែនហើយ . ក្នុងលោកយើងនេះ គ្មានជនណាដឹងជាមុនបានទេថា តើពេលណាគេនឹងមានជំងឺ, រងទុក្ខវេទនា និងទីបំផុតនៃសេចក្តីស្លាប់ទេ!" ។

" សេចក្តីស្លាប់ឬ? តើសេចក្តីស្លាប់នោះដូចម្តេច ?វាចម្លែកខ្លាំងណាស់ .ឆន្នៈ. សេចក្តីស្លាប់នោះយ៉ាងម៉េចទៅហ្ន៎? "

" សូមទ្រង់ព្រះមេត្តាប្រោស. សូមព្រះអង្គក្រឡេកមើលខាងនុ៎ះ ព្រះអង្គនឹងបានឃើញ ហើយ!" ។



78-The Prince looked where Chandaka directed him, and he saw a group of people marching along lamenting. Four men in front carried a stiff, immobile person on a board, a person with shrunken cheeks and gaping mouth, speechless and ugly. Although the four men rocked the board they were carrying quite sharply and clumsily, the person lying on top did not say a word. The prince watched the group moving along and began to wonder why everyone wept and why the person on the board did not caution the carriers to proceed more carefully.

៧៨-ព្រះពោធិសត្វទ្រង់ទតទៅកន្លែងដែលនាយឆន្នៈចង្អុលប្រាប ហើយទ្រង់បានឃើញមនុស្សមួយក្រុមកំពុងនាំគ្នាដើរបណ្តើរយំសោកទម្រ៉ឺះខ្សឹកខ្សួលបណ្តើរ ។ បុរសបួននាក់ខាងមុខគេ កំពុងសែងសាកសពមនុស្សម្នាក់នៅលើក្តាមួយបន្ទះ . សាកសពនោះ ថ្ពាល់សងខាងឡើងរួញខើចខ្ចី, មាត់ហារច្រហរ, គ្មាននិយាយស្តីអ្វីសោះ ។ ទោះបីអ្នកសែ្ងងទាំងបួនសែងបន្ទះក្តារឃ្លេងឃ្លោងយោលយោគខ្លាំងៗដូចម្តេចក្តី, ក៏អ្នកដែលដេកស្តូកស្តឹងនឹងថ្កល់លើក្តារនោះ ឥតចេញវាចាអ្វីឡើយ ។ ព្រះអង្គទ្រង់ទតឃើញពួកអ្នកទាំងនោះចេះតែដើរទៅ ហើយទ្រង់ឆ្ងល់ក្នុងព្រះទ័យថា ហេតុអ្វីបានជាពួកគេទាំងអស់យំសោកខ្សឹកខ្សួលយ៉ាងនេះ ហើយហេតុអ្វីក៏អ្នកដែលដេកនៅលើបន្ទះក្តា មិនព្រមប្រាប់ពួកអ្នកសែងនោះឱ្យគេប្រយ័ត្នប្រយែងខ្លះផង ។



79-After moving on a little further, the group halted. They placed the person they were bearing on top of a pile of wood and started a fire. The prince was shocked, and his hair stood on end. Yet the person continued sleeping quietly even as the fire began to lick his head and feet. The prince asked in a trembling voice saying: "Chandaka, why does that man stay asleep and let them burn him ?"

"That man is dead. He has feet, but can no longer walk; he has ears, but can no longer hear; he is not conscious of anything. He has absolutely no feeling for heat, cold, fire or snow. He is already dead!"

៧៩-ក្រោយពីដើរបានឆ្ងាយបន្តិចទៅ ពួកអ្នកទាំងនោះក៏ឈប់ដើរទៅទៀត ។ គេដាក់សាកសពដែលគេបានសែងមកនោះលើគំនរអុសដែលគេតរទុកជាស្រេច រួចហើយគេក៏ដុតភ្លើង ។ ព្រះអង្គទ្រង់តក់ស្លុតរន្ធត់ព្រះទ័យព្រះកេសាឡើងបះច្រូង ។ ឯសាកសពនោះនៅតែដេកស្ងួកស្ងៀមឥតកំរើកសោះ សូម្បីតែភ្លើងឆេះក្បាលនិងជើងហើយក៏ដោយ ។ ព្រះអង្គទ្រង់សួរនាយឆន្នសេនាទាំងសំលេងញាប់ញ័រថា " នែ៎ ឆន្ន: ហេតុដូចម្តេចបានជាមនុស្សនុ៎ះ នៅដេកសម្ងំស្ងៀមឱ្យគេដុតតាមចិត្តអីចឹង ? "

នាយឆន្ន:ទូលថា "បុរសនោះ ស្លាប់ហើយព្រះអង្គ . គាត់មានជើងមែនតែគាត់មិនអាចដើរបានទៀតទេ. គាត់មានត្រចៀកមែន តែស្តាប់លែងឮទៀតហើយ. គាត់លែងដឹងលែងឮអ្វីទាំងអស់ ។ គាត់មិនមានវិញ្ញាណដឹងក្តៅ ត្រជាក់ ដឹងភ្លើង ដឹងទឹកទៀតទេ ។ គាត់ស្លាប់បាត់ទៅហើយ ព្រះអង្គ! " ។



80- "Dead? Chandaka! This is death? Shall I, the son of the King, also die like that man? My father, Yasodhara and all the people I know, will they also someday be like that man on the pile of wood?"

"Anybody who is alive will some day die. There is no way to avoid it. No one can live forever. Men cannot stop the coming of death."

The prince remained silently and said no more, he felt the fearfulness of death imprisoning everybody, without being a way to escape death.

៨០- "ស្លាប់? ឆន្ន:! នេះជាសេចក្តីស្លាប់? ចុះតើខ្ញុំជាបុត្ររបស់ព្រះមហាក្សត្រ នឹងស្លាប់ដូចអ្នកនោះដែរទេ? ព្រះបិតាយើងក្តី យសោធរាជាទីស្រលាញ់របស់យើងក្តី និងមនុស្សទាំងឡាយដែលយើងស្គាល់ក្តី ថ្ងៃណាមួយពួកគេនឹងដល់នូវសេចក្តីស្លាប់ដូចបុរសដែលនៅដេកលើគំនរអុសនោះមែនដែរទេ?"

"ជនណាក៏ដោយដែលមានជីវិតរស់នៅ គេនឹងត្រូវស្លាប់នៅថ្ងៃណាមួយមិនខាន ។ គ្មានផ្លូវណាមួយដើម្បីគេចឱ្យផុតពីមរណទុក្ខនេះបានឡើយ. គ្មានបុគ្គលណាម្នាក់អាចរស់នៅជាជីវិតអមតៈបានទេ ហើយក៏គ្មានជនណា អាចឃាត់ឃាំងរារាំងសេចក្តីស្លាប់នេះមិនឱ្យកើតមានបានឡើយ" ។

ព្រះពោធិសត្វទ្រង់នៅស្ងៀមគ្មានព្រះបន្ទូលអ្វីទៀតឡើយ ព្រះអង្គទ្រង់មានព្រះទ័យរន្ធត់ញាប់ញ័រភ័យខ្លាចពន់ពេកចំពោះមរណទុក្ខនេះដែលតែងតែគ្របសង្កត់រូបរិតជីវិតមនុស្សសត្វគ្រប់រូប ដោយគ្មានផ្លូវណាមួយដើម្បីគេចចេញឱ្យផុតពីមរណភាពនេះបាន ។



81- Prince Siddhartha quietly returned to the palace, went to his room, sat down alone, and thought deeply about what he had seen. Finally he said to himself: "It is too frightful that everybody in the world must die someday and that no one can prevent this. Ah! There must be some way to avoid it. I shall do all I can to discover the way by which father, Yasodhara, myself and all other people will no longer be controlled by the power of old age, sickness and death. I must do my best to find the way!"

៨១-ព្រះសិទ្ធត្ថ ព្រះអង្គទ្រង់យាងត្រឡប់មកកាន់ព្រះរាជវាំងវិញយ៉ាងស្ងៀមស្ងាត់. ព្រះអង្គយាងទៅកាន់ក្រឡាព្រះបន្ទំ ទ្រង់គង់តែមួយព្រះអង្គឯង ហើយទ្រង់ព្រះតំរិះពិចារណាវែងឆ្ងាយអំពីរឿងដែលទ្រង់បានជួប ។ ទីបំផុត ព្រះអង្គទ្រង់មានព្រះបន្ទូលតែមួយព្រះអង្គឯងថា "គួរឱ្យភ័យខ្លាចស្ញប់ស្ញែងណាស់ព្រោះមនុស្សគ្រប់រូបក្នុងលោកសន្និវាសនេះ ត្រូវស្លាប់នៅពេលណាមួយមិនខាន ហើយគ្មានជនណាម្នាក់អាចតទល់ហាមឃាត់សេចក្តីស្លាប់នេះបានឡើយ ។ ហ្ន៎! ត្រូវតែមានមាគ៌ាណាមួយដើម្បីគេចផុតពីសេចក្តីស្លាប់នេះ ។ អាត្មាអញត្រូវតែខំព្យាយាមប្រឹងប្រែងស្វែងរកមាគ៌ាធ្វើយ៉ាងណាដើម្បីកុំឱ្យព្រះបិតា ព្រះនាងយសោធរា ខ្លួនអាត្មាអញ និងសព្វសត្តនិករទាំងអស់ស្ថិតនៅក្រោមអំណាចត្រួតត្រានៃការចាស់ ឈឺ ស្លាប់តទៅទៀត ។ អាត្មាអញត្រូវ តែខិតខំព្យាយាមឱ្យអស់សមត្ថភាពដើម្បីស្វែងរកមាគ៌ានេះលុះត្រាតែបាន!" ។



82-Sometime later, while the prince was riding in the garden, he saw a monk in a yellow robe. The prince watched the monk attentively, perceiving that his mind was full of peace and happiness. So the prince asked Chandaka: " What is the life of this sort of person like?" Chandaka replied: "This is a person who cultivates the way, a person who has left his family and given up his desire in order to seek the way of deliverance from worldly suffering. The prince was very pleased to hear the name 'Sramana' spoken.

៨២- ក្នុងកាលជាខាងក្រោយមកទៀត ខណៈដែលព្រះអង្គទ្រង់កំពុងយាងកំសាន្តលើអាជាទេយ្យក្នុងឧទ្យានព្រះអង្គ ទ្រង់បានទតឃើញបព្វជិតមួយអង្គគ្រងសំពត់កាសាវពស្ត្រពណ៌លឿង ។ ព្រះអង្គទតមើលដោយព្រះទ័យទុកដាក់បំផុត ហើយទ្រង់ដឹងថាព្រះទ័យព្រះអង្គពោរពេញទៅដោយសន្តិភាព និងសេចក្តីសុខណាស់ ។ ទ្រង់ឃើញអាការៈដូច្នេះ ព្រះអង្គទ្រង់ក៏សួរនាយឆន្នៈថា "នាយឆន្នៈ មនុស្សនេះមានជីវិតដូចម្តេច?" ឆន្នៈទូលថា "បពិត្រព្រះអង្គ នេះជាមនុស្សម្នាក់ដែលកំពុងត្រួសត្រាយផ្លូវ, ជាបុគ្គលដែលបានចាកចេញពីវង្សត្រកូល, លះបង់រាគៈតណ្ហា ដើម្បីស្វែងរកមាគ៌ារលាស់ចេញចាកទុក្ខទាំងពួងក្នុងលោកនេះ ។ ព្រះអង្គទ្រង់រីករាយសប្បាយក្រៃលែងដោយទ្រង់បានឮឈ្មោះដែលគេហៅថា' **សមណៈ** ' ដូច្នេះ ។



83-During that whole day, the prince sat quietly but happily in the garden, his mind captured by the idea of becoming a Sramana. Just then someone told the prince that his wife had given birth to a lovely boy, but instead of expressing his joy, the prince was a bit flustered, and he said absent-mindedly: "This ring has hemmend me in !This ring has hemmed me in!" It was because the prince spoke in this manner just at this time that the newborn baby was named Rahula, which means a ring or a circle.

៨៣-អស់ពេលពេញមួយថ្ងៃ. ព្រះអង្គទ្រង់គង់យ៉ាងស្ងៀមស្ងាត់និងសប្បាយរីករាយក្នុងព្រៃឧទ្យាន. ព្រះទ័យទ្រង់ជក់ជាប់តែនឹងការគិតសាងបព្វជ្ជាតែប៉ុណ្ណោះ ។ ពេលនោះ ស្រាប់តែមានគេទៅក្រាបបង្គំទូលថា ព្រះរាជទេពីរបស់ព្រះអង្គទ្រង់ប្រសូត្របានបុត្រមួយព្រះអង្គគួរជាទីស្រលាញ់ណាស់ ។ ទ្រង់មិនសំដែងសេចក្តីត្រេកអរចំពោះដំណឹងនេះឡើយ. ព្រះអង្គទ្រង់ត្រឡប់ជាមានព្រះកង្វល់ខ្វល់ខ្វាយព្រះទ័យទៅវិញ ហើយទ្រង់មានព្រះបន្ទូលយ៉ាងសោះកក្រោះថា "ចំណងនេះបានចងអញហើយតើ! ចំណងនេះបានចងអញហើយតើ!" បានជាទ្រង់មានព្រះបន្ទូលដូចនេះ ដោយសារពេលនេះ បុត្រដែលទើបប្រសូត្រថ្មីមានព្រះនាមថា **រាហុល** នោះដែលមានន័យថា **ចំណង** ឬ **អន្ទាក់** ។



84-Since the day of Rahula's birth, those who lived with Prince Siddhartha all clearly observed that the prince had changed entirely. He was more solemn than before and more contemplative. King Suddhodana was very worried, indeed, about his son's condition; and so he tried with his last effort to re-awaken his interest by searching the whole country for the intelligent and beautiful dancing girls. He lodged them permanectly in the prince's palace, ordering them to sing beautiful songs and to perform pleasing dances, which, he hoped, would arouse the prince's pleasure and interest in the things of this world.

៨៤-ចាប់តាំងពីថ្ងៃដែលរាហុលកុមារប្រសូតមក ជនទាំងឡាយដែលនៅជាប់ជាមួយព្រះសិទ្ធត្ថបានសង្កេតឃើញយ៉ាងច្បាស់ថា ព្រះរាជឱរសទ្រង់មានការប្រែប្រួលយ៉ាងច្រើន ។ ព្រះអង្គទ្រង់មានព្រះអាការៈស្រពាប់ស្រពោននិងសញ្ជប់សញ្ជឹងខ្លាំងជាងពេលមុនៗទាំងអស់ ។ ចំណែកព្រះមហាក្សត្រសុទ្ធោទនៈវិញ ទ្រង់ព្រះវិតក្កៈក្រវល់ក្រវាយក្រៀមក្រំបារម្ភព្រួយក្រៃលែង ចំពោះអាការៈខុសពីធម្មតារបស់ព្រះរាជបុត្រព្រះអង្គ. ដូច្នេះ ព្រះរាជាទ្រង់ខំព្យាយាមទាក់ទាញដ៏ខ្លាំងក្លាជាចុងក្រោយដើម្បីដាស់អារម្មណ៍ព្រះរាជបុត្រឱ្យភ្ញាក់ទាក់ជាប់ចិត្ត ស្រើបស្រាលឡើងវិញ ដោយទ្រង់ជ្រើសរើសយកតែកុមារីស្រីរបាំដែលមានទេពកោសល្យប៉ិនប្រសប់និងមាន រូបឆោមស្រស់ល្អបំផុតក្នុងព្រះនគរឱ្យចូលមករាំច្រៀងកំដរព្រះរាជបុត្រ ។ ព្រះរាជាទ្រង់ត្រាស់ឱ្យពួកស្រីរបាំទាំងនោះស្ថិតនៅជាប់ជានិច្ចទាំងយប់ទាំងថ្ងៃក្នុងដំណាក់ព្រះរាជឱរស និងទ្រង់ត្រាស់បង្គាប់ឱ្យច្រៀងតែចំរៀងពិរោះៗនិងរាំតាមចង្វាក់ទាក់ទាញអារម្មណ៍ឱ្យបានសប្បាយ ធ្វើដូច្នោះ ព្រះអង្គទ្រង់សង្ឃឹមថា វានឹងដាស់ពញ្ញាក់អារម្មណ៍ព្រះរាជបុត្រឱ្យត្រេកត្រអាលសប្បាយភ្លើតភ្លើននិងពេញព្រះទ័យចំពោះវត្ថុផ្សេងៗនាលោកិយនេះ ។



85-At first the prince watched and listened to the dances and songs provided for him in order not to disappoint his father. But, in reality, these enchanting songs and dances attracted only a few inattentive glances from the prince, for his mind was concentrated on the other things. The prince was thinking of one problem only; that is, how to liberate himself and all other people completely from the fearfulness of aging, sickness and death. Finally the prince became tired and fell asleep, and so the dancing girls had a chance to rest until the prince had awakened and then they performed again.

៨៥-ពេលដំបូង ព្រះរាជឱរសទ្រង់ទតព្រះនេត្រនិងទ្រង់ព្រះសណ្ដាប់ការប្រគុំតូរ្យតន្ត្រី ចំរៀងច្រៀងរាំដែលគេប្រគំឡើងសំរាប់ព្រះអង្គ ដើម្បីកុំឱ្យព្រះវររាជបិតាទ្រង់ខ្វល់ខ្វាយខកខូចព្រះទ័យ ។ តែតាមពិត តូរ្យតន្ត្រីរបាំរាំច្រៀងពិរោះរណ្ដំទាំងនេះ មិនអាចទាក់ទាញព្រះក្រសែចក្ខុព្រះអង្គឱ្យទ្រង់ជាប់ចិត្តជិតអារម្មណ៍ដល់តិចតួចឡើយ ។ ព្រះទ័យព្រះអង្គទ្រង់សញ្ជប់សញ្ជឹងរាកអារម្មណ៍ចេញទៅវិញ ។ ព្រះអង្គទ្រង់រិះគិតតែពីបញ្ហាម្យ៉ាងតែប៉ុណ្ណោះថាតើត្រូវរំដោះខ្លួនព្រះអង្គ និងមនុស្សលោកទាំងអស់ឱ្យរួចផុតពីសេចក្ដីភ័យខ្លាចនៃការចាស់ឈឺ ស្លាប់ ទាំងស្រុងដូចម្ដេចបាន ។ ដល់ទីបញ្ចប់ព្រះរាជឱរសទ្រង់អស់ព្រះកាយពល ហើយក៏ទ្រង់ផ្ទំលង់លក់ទៅ ។ ឯពួកស្រីៗរបាំឃើញព្រះអង្គផ្ទំលក់ដូច្នោះក៏នាំគ្នាឈប់សំរាកប្រាសខ្លួនដេកលក់រហូតដល់ព្រះអង្គទ្រង់តើនឡើងវិញ ទើបគេនាំគ្នាចាប់ផ្ដើមប្រគុំភ្លេងសំដែងតទៅទៀត ។



86- The prince awakened after a little while, finding that the dancing girls had all fallen asleep because of fatigue. While sleeping, they exhibited all kinds of ugly attributes, being entirely unaware of the impression that they were making. Some slept like pigs; some opened their mouths, dripping saliva which damaged the make-up on their faces; some ground their teeth loudly like angry ghosts. They all appeared to be quite ugly and disgusting. The prince was very surprised to see how the girls he liked so much could be transformed in this manner.

៨៦- នៅពេលទ្រង់ផ្ទំលក់បានបន្តិច ទ្រង់ក៏តើនឡើងវិញទៀត ដោយបានទតឃើញពួកស្រីរបាំទាំងអស់ដេកលង់លក់ដោយសារតែការនឿយហត់អស់កំលាំងនឹងការរាំច្រៀង ។ ខណៈដែលកំពុងតែដេកលក់ នាងៗទាំងនោះសំដែងអាការៈផ្សេងៗគួរឱ្យជិនណាយ. ដោយឥតដឹងខ្លួនទាល់តែសោះថា ពួកគេកំពុងតែមានអាការៈយ៉ាងណានោះទេ ។ នាងខ្លះដេកដូចជ្រូក. ខ្លះដេកហាមាត់ច្រហរស្រមុកងូកង៉កៗ ហៀរទឹកមាត់ចេញមក ធ្វើឱ្យរលប់រលាយក្រែមម្សៅលើថ្ពាល់ទាំងសងខាង. នាងខ្លះទៀតដេកសង្កៀតធ្មេញលាន់ឮដូចខ្មោចលង ។ ពួកគេទាំងអស់មានអាការៈគួរឱ្យចុញទ្រាន់ និងខ្ពើមរអើមពន់ពេកណាស់ ។ ព្រះអង្គទ្រង់មានព្រះទ័យស្ដុតញាប់ញ័រយ៉ាងខ្លាំងដោយបានទតព្រះនេត្រឃើញស្រីទាំងនោះ ដែលព្រះអង្គទ្រង់ធ្លាប់តែសព្វព្រះទ័យ ឥឡូវបែជាមានអាការៈគួរឱ្យនឿយណាយយ៉ាងនេះទៅវិញ ។



87-This picture of the sleeping girls, once regarded as pretty and lovely by the prince, now appeared to be terribly ugly. It was, indeed, the most nauseating thing that had ever happened to the prince. Therefore, the prince became determined to shake off all that disturbed his mind and to go out to search for real happiness and to become free from all pain and suffering. Prince Siddhartha rose silently, careful to avoid waking the girls, quietly left the room, and ordered Chandaka to get his horse Kanthaka ready.

៨៧- រូបរាងស្រីដែលកំពុងដេកទាំងនេះ ព្រះអង្គទ្រង់ធ្លាប់តែចាត់ទុកថាជានារីមានរូបស្រស់ស្អាតនិងជាទីស្នេហា តែឥឡូវប្រែជាអាក្រក់គួរឱ្យតក់ស្លត់រន្ធត់ខ្លាចទៅវិញ ។ ពិតប្រាកដណាស់ វាជារឿងមួយគួរខ្ពើមរអើនិងខ្ពើមឆ្អើមបំផុតដែលមិនធ្លាប់កើតមានដល់ព្រះអង្គម្ចាស់ឡើយ ។ ព្រោះហេតុដូច្នេះ បានជាព្រះអង្គទ្រង់សំរេចព្រះទ័យគេចចេញឱ្យផុតពីសភាវៈទាំងឡាយដែលតែងរំខានរារាំងដល់ព្រះទ័យព្រះអង្គ ហើយព្រះអង្គទ្រង់នឹងចេញទៅដើម្បីស្វែងរកសេចក្តីសុខដ៏ពិតប្រាកដនិងបានរំដោះខ្លួនឱ្យរួចផុតពីសេចក្តីទុក្ខទាំងឡាយ ។ ព្រះសិទ្ធត្ថទ្រង់ក្រោកឡើងយ៉ាងស្ងៀមស្ងាត់ដើម្បីកុំឱ្យពួកស្រីៗរបាំដឹងខ្លួនទាន់ . ទ្រង់យាងចាកចេញពីបន្ទប់ដោយមិនឱ្យឮស្នូរសើរបអ្វីបន្តិចសោះឡើយ ហើយទ្រង់ព្រះបញ្ជាឱ្យនាយឆន្នៈរៀបចំសេះកណ្ឋកៈទុកថ្វាយទ្រង់រួចជាស្រេច ។



88- While Chandaka was getting the horse, Prince Siddhartha felt that he should see his newborn son before he left. So he went to the room of Princess Yasodhara, where he found the princess, holding the baby in her arms, sound asleep. The prince thought; "If I move her hand, she will certainly wake up; if she wakes up, she will stop me from going. But I must go immediately, and I shall come back to see my son and his mother after I find the ultimate truth."

៨៨-ក្នុងខណៈដែលឆន្នៈសារថីកំពុងរៀបចំសេះអាជានេយ្យ. ព្រះរាជឱរសសិទ្ធត្ថទ្រង់រំពឹងនឹកថា គួរណាស់តែព្រះអង្គយាងទៅទតបុត្រាដែលទើបប្រសូត្របន្តិចសិនមុននឹងយាងចេញទៅ ។ ព្រះអង្គទ្រង់ក៏យាងចូលកាន់ក្រឡាព្រះបន្ទំរបស់ព្រះនាងយសោធរារាជទេវី ហើយទ្រង់បានទតឃើញព្រះនាងកំពុងអោបបុត្រផ្ទុំលង់លក់ទៅហើយ ។ ព្រះអង្គទ្រង់ព្រះចិន្តាថា:" បើអាត្មាអញលើកព្រះហស្ថព្រះនាងចេញ. ព្រះនាងប្រាកដជាភ្ញាក់ដឹងខ្លួនមិនខាន កាលបើព្រះនាងទ្រង់ភ្ញាក់ហើយនោះ ព្រះនាងនឹងឃាត់ឃាំងរាំងដំណើរមិនឱ្យអាត្មាអញចេញទៅជាដាច់ខាត ។ តែល្ហើយចុះ អាត្មាអញត្រូវតែចេញទៅឥឡូវនេះឱ្យបាន កាលណាអាត្មាអញបានសំរេចបរមត្ថសច្ចៈហើយ សឹមអាត្មាអញនឹងត្រឡប់មកជួបបុត្រនិងព្រះមាតារបស់បុត្រវិញ " ។



89- In the silence of the night, Prince Siddhartha left the palace without waking anyone. He left the city riding his very understanding horse Kanthaka. Only Chandaka followed him, and no one hindered them. After riding for a little while, the prince stopped his horse and turned around, taking a final look at the city of Kapilavastu in the pure, bright moonlight; but his will to go on was unshaken!

៨៩-ក្នុងវេលារាត្រីដ៏សែនស្ងាត់ជ្រងំ ព្រះសិទ្ធត្ថទ្រង់យាងចាកចេញពីព្រះរាជវាំងដោយគ្មាននរណាម្នាក់ដឹងឡើយ ។ ព្រះអង្គទ្រង់យាងចេញពីរាជធានីដោយសេះកណ្ឋកៈដែលជាសត្វមានចិត្តយល់អធ្យាស្រ័យដល់ម្ចាស់ណាស់ ។ មានតែឆន្នសេនាម្នាក់ប៉ុណ្ណោះដែលទៅជាមួយព្រះអង្គ .ហើយឥតមានជនណាម្នាក់ធ្វើឱ្យរាំងស្ទះដល់ព្រះរាជដំណើរនេះឡើយ ។ ក្រោយពីទ្រង់ព្រះដំណើរបានបន្តិចមក ព្រះអង្គទ្រង់បញ្ឈប់សេះ ហើយក៏បែរព្រះភ័ក្ត្រមកក្រោយ ដើម្បីទ្រង់ទតមើលរាជធានីនៃនគរកបិលវត្ថុក្រោមពន្លឺដួងច័ន្ទដ៏បរិសុទ្ធភ្លឺចាំងចិញ្ចែងចិញ្ចាចជាលើកចុងក្រោយ. តែព្រះទ័យក្នុងព្រះដំណើរព្រះអង្គចេះតែទៅមុខ ដោយមិនញាប់ញ័រស្រណោះស្តាយក្រោយឡើយ ! ។



90-Prince Siddhartha, riding his horse Kanthaka, arrived at the bank of the Anoma River by dawn. The prince dismounted, stood at the riverside, took off the precious dress he was wearing and handed it to Chandaka, resolutely ordering him to take it and Kandaka back to Kapilavastu and tell the King what had happened. At this time, Prince Siddhartha Gautama of the Sakya Clan was twenty-nine years old. He left his country and family to become a Sramana in order to conquer all the pain and suffering of mankind.

៩០-ព្រះសិទ្ធត្ថរាជឱរស .យាងដោយសេះកណ្ឋកៈ . ទ្រង់ក៏បានយាងទៅដល់មាត់ស្ទឹង **អនោមា** នាវេលាព្រះអរុណរះ ។ ព្រះអង្គយាងចុះពីលើខ្នងសេះ ទ្រង់ឈរលើមាត់ស្ទឹង ហើយក៏ដោះគ្រឿងអលង្ការសំលៀកបំពាក់ដ៏មានតំលៃដែលព្រះអង្គស្លៀកពាក់តាក់តែងព្រះកាយប្រគល់ឱ្យឆន្នៈ. រួចហើយត្រាស់បង្គាប់ឱ្យឆន្នៈនាំយកគ្រឿងអលង្ការនិងសេះកណ្ឋកៈវិលត្រឡប់ទៅព្រះនគរកបិលវត្ថុវិញ ហើយថ្វាយដំណឹងនេះ ដល់ព្រះរាជបិតាផង ។ ក្នុងពេលនោះ ព្រះសិទ្ធត្ថគោតមនៃសក្យវង្សទ្រង់មានព្រះជន្មគំរប់២៩ព្រះវស្សា ។ ព្រះអង្គទ្រង់ចាកចោលព្រះនគរ និងព្រះរាជវង្សទៅសាងព្រះផ្នួសបួសជាសមណៈដើម្បីកំចាត់បង់នូវជំងឺដម្កាត់និងទុក្ខសោកទាំងឡាយរបស់មនុស្សជាតិ ។



91 -After Chandaka left him to go back to Kapilavastu with the dress and Kanthaka, Siddhartha stayed for seven days in the mango grove of Anupiya, near the bank of the Anoma River, then he journeyed southward and came to Rajagrha, the capital of the country of Magadha, ruled by king Bimbisara. In the morning, he bathed in a stream near the city; then, like all sramanas, he entered the city to accept for food. The people of Rajagrha, noticing the distinguished appearance of Siddhartha, offered him their best food.

៩១-ក្រោយពីនាយឆន្នៈថ្វាយបង្គំលាព្រះអង្គត្រឡប់ទៅនគរកបិលវត្ថុវិញ ដោយនាំទាំងគ្រឿងអលង្ការ និងសេះកណ្ឋកៈផងនោះ. ព្រះសិទ្ធត្ថទ្រង់បានគង់នៅក្នុងព្រៃស្វាយមួយកន្លែងឈ្មោះ **អនុបិយ** ក្បែរឆ្នេរស្ទឹងអនោមាអស់៧ថ្ងៃ ពេលនោះព្រះអង្គស្តេចយាងទៅទិសខាងត្បូង ទៅកាន់ទីក្រុង **រាជគ្រឹះ** ជារាជធានីនៃនគរមគធៈ. ព្រះមហាក្សត្រសោយរាជនគរនោះ ព្រះនាមព្រះបាទ **ពិម្ពិសារ** ។ ក្នុងវេលាព្រឹក ព្រះអង្គទ្រង់ជំរះព្រះកាយក្នុងស្ទឹងនៅក្បែររាជធានី រួចហើយព្រះអង្គទ្រង់ក៏និមន្តយាងចូលក្នុងរាជធានីដើម្បីបិណ្ឌបាតដូចសមណៈដទៃទៀតដែរ ។ អ្នកក្រុងរាជគ្រឹះ នាំគ្នាពិចពិលរមិលមើលនូវព្រះរាជដំណើរដ៏ស្រគត់ស្រគំថ្លៃថ្នូរសម ឥតបីផ្ទឹមនៃព្រះអង្គ និងថ្វាយប្រគេនដល់ព្រះអង្គនូវអាហារបិណ្ឌបាតដ៏ប្រណីតៗ ។



92-Having obtained his meal for the day, Siddhartha left Rajagrha, heading toward Pandava Hill, where he ate his food. Since the day that Siddhartha had first accepted offering of food in the city, the news had spread that a Sramana of distinguished appearance and of incomparably grave and noble demeanour had arrived. This news also reached the palace. King Bimbisara, knowing of the presence of such a Sramana, sent his son to check out the situation. He discovered that this sramana was the prince of Kapilavastu, the successor to the throne, who had given up everything and become a bhikkhu in search of the means to liberate all mankind from the imprisonment of old age, sickness and death.

៩២- ដោយទ្រង់បានចង្ហាន់បិណ្ឌបាត្រល្មមសំរាប់មួយថ្ងៃហើយ. ព្រះសិទ្ធត្ថទ្រង់ស្តេចយាងចេញពីក្រុងរាជគ្រឹះវិញ ឆ្ពោះទៅកាន់ញកភ្នំ **បណ្ឌវៈ** រួចព្រះអង្គទ្រង់ឆាន់ចង្ហាន់បិណ្ឌបាត្រនៅទីនោះ ។ ចាប់តាំងពីថ្ងៃដែលព្រះសិទ្ធត្ថជាអម្ចាស់ទ្រង់យាងនិមន្តចូលទៅបិណ្ឌបាត្រជាលើកដំបូងក្នុងរាជធានីមក. ដំណឹងក៏លេចឮសុះសាយថា មានសមណៈមួយអង្គទ្រង់មានព្រះរូបឆោមល្អល្អះ មានព្រះអាការៈស្រគត់ស្រគំថ្លៃថ្នូរល្អឥតអ្វីផ្ទឹមបាន ទ្រង់មានការប្រព្រឹត្តប្រតិបត្តិដ៏ល្អប្រសើរ. បានមកដល់រាជធានីនេះ។ ដំណឹងនេះមិនស្ងាត់បាត់ក៏លេចឮរហូតដល់ព្រះរាជវាំង ។ ព្រះបាទពិម្ពិសារ ដោយទ្រង់បានជ្រាបដំណឹងនេះទ្រង់ក៏ប្រើរាជបុត្រាឱ្យទៅស៊ើបអង្កេតស្ថានការណ៍នោះ ។ រួចព្រះរាជាទ្រង់បានដឹងថា សមណៈអង្គនេះជាព្រះរាជបុត្រនៃស្តេចនគរកបិលវត្ថុ. ទ្រង់ជារជ្ជទាយាទគ្រប់គ្រងព្រះនគរ. ព្រះអង្គស្តេចទ្រង់បានលះបង់អ្វីៗសព្វយ៉ាងទាំងអស់មកបួសជាភិក្ខុដើម្បីស្វែងរកមធ្យោបាយរំដោះមនុស្សសត្វទាំងឡាយឱ្យរួចផុតពី ចាស់. ឈឺ. ស្លាប់ ។



93– Having this knowledge, King Bimbisara went to Pandava Hill and invited Siddhartha to stay in his capital city, where it would be very convenient for the King to offer him food and all the necessities of life. But Siddhartha graciously declined the invitation, saying: "I cannot remain in one place before realizing my goal and aspiration." So King Bimbisara made an agreement with Siddhartha to the effect that when his aspiration of perfect enlightenment was realized, he would come first to the city of Rajagrha to instruct and enlighten King Bimbisara and his people.

៩៣-   ដោយទ្រង់បានជ្រាបយ៉ាងនេះហើយ. ព្រះបាទពិម្ពិសារស្តេចទ្រង់យាងទៅកាន់ភ្នំបណ្ឌវហើយទ្រង់ថ្វាយបង្គំនិមន្តព្រះសិទ្ធត្ថឱ្យគង់ប្រថាប់ក្នុងរាជធានីរបស់ព្រះអង្គ   ដើម្បីឱ្យងាយស្រួលសំរាប់ព្រះមហាក្សត្រស្តេចថ្វាយប្រគេនចង្ហាន់និងបរិក្ខារផងទាំងពួង ដែលចាំបាច់សំរាប់ជីវិតដល់ព្រះអង្គ ។ ប៉ុន្តែព្រះសិទ្ធត្ថជាអង្គម្ចាស់ទ្រង់មិនទទួលការនិមន្តនោះឡើយ ដោយទ្រង់មានព្រះបន្ទូលថា " ចំរើនពរ អាត្មាមិនអាចគង់នៅតែមួយកន្លែងបានទេ ដរាបណាមិនទាន់បានសំរេចគោលបំណង" ។ ទ្រង់បានឮដូច្នេះ. ព្រះបាទពិម្ពិសារក៏បានធ្វើបដិញ្ញា ( ប្តេជ្ញា ) ជាមួយព្រះសិទ្ធត្ថយ៉ាងដូច្នេះថា នៅពេលណាបំណងប្រាថ្នារបស់ព្រះអង្គ គឺការត្រាស់ដឹងបានសំរេចបរិបូរណ៌ហើយ សូមឱ្យព្រះអង្គទ្រង់យាងមករាជធានីនៃនគររាជគ្រឹះមុនគេ ដើម្បីសំដែងធម៌ប្រោសព្រះបាទពិម្ពិសារ ព្រមទាំងប្រជារាស្ត្ររបស់ព្រះអង្គផង ។



94– One day Siddhartha left Rajagrha to go to the foot of the mountain where many hermits and sages dwelt. On the way, he saw dust falling down from the mountain amidst the pounding sound of animal hoofs. Going closer, he found a large flock of sheep and goats moving along like a bank of clouds. They were being helplessly driven toward the city. At the rear of the flock, a little lamb was straggling, limping along painfully, its leg wounded and bleeding. Siddhartha noticed the little lamb and its mother walking in front of it constantly looking back in deep concern for her offspring. His heart was filled with pity.

៩៤-   ថ្ងៃមួយព្រះសិទ្ធត្ថទ្រង់យាងដោយព្រះបាទផ្ទាល់   ចាកចេញពីក្រុងរាជគ្រឹះទៅកាន់ជើងភ្នំមួយកន្លែងដែលមានតាបសឥសីគង់នៅជាច្រើន ។ នៅតាមផ្លូវព្រះអង្គទ្រង់ឃើញធូលីដីហុយឡើងទ្រលោម ធ្លាក់ចុះពីលើភ្នំព្រមទាំងស្នូរសទ្ទឹកសំលេងជើងសត្វរត់ផង ។ ដោយចេះតែនិមន្តកាន់តែជិតទៅៗ ព្រះអង្គទ្រង់ប្រទះឃើញចៀមនិងពពែមួយហ្វូងធំដែលកំពុងរត់តាមបណ្តោយផ្លូវ ប្រៀបដូចជាដុំពពក ។ សត្វទាំងឡាយនេះត្រូវគេកៀងដេញសំដៅទៅទីក្រុងយ៉ាងអនោចអធ័ម ។ នៅតាមក្រោយនៃហ្វូងចៀមនិងពពែនេះ. មានកូនចៀមតូចមួយដើររេរា១ខ្វកខ្វិច១ដោយមានការឈឺចាប់យ៉ាងខ្លាំង. ជើងរបស់វាត្រូវរបួសចេញឈាមហូរសស្រាក់ ។ ព្រះមហាករុណាសិទ្ធត្ថទ្រង់ទតឃើញកូនចៀមដ៏កំសត់នេះ ហើយមេរបស់វាកំពុងដើរពីខាងមុខចេះតែក្រឡេកមើលមកកូនវានៅខាងក្រោយជានិច្ចទាំងក្តីកើតទុក្ខក្រៀមក្រំបារម្ភព្រួយយ៉ាងជ្រាលជ្រៅចំពោះកូនតូចរបស់វា ។ ព្រះទ័យព្រះអង្គពោរពេញទៅដោយក្តីករុណាអាណិតអាសូរពន់ពេកណាស់ ។



95- So Siddhartha took the little lamb with the wounded leg up into his arms, gently fondling it while walking along behind the flock. When he saw the shepherds, he asked: "Where are you driving this herd to? They should normally be driven back in the evening! Why do you drive them back at noontime ?" The shepherds replied: "The King is holding a big sacrifice today, and we have been ordered to bring one hundred sheep and goats each to the city at noontime." Siddhartha said: "I'll go with you." He carried the little lamb in his arms all the way to the city.

៩៥- ឃើញយ៉ាងនេះហើយដូច្នេះ ព្រះសិទ្ធត្ថទ្រង់ចាប់បីកូនចៀមកំសត់ដែលជើងត្រូវរបួសនេះក្នុងព្រះហស្ថព្រះអង្គផ្ទាល់. រួចព្រះអង្គទ្រង់បំបោសអង្អែលសើរៗថ្នមៗនៅពេលកំពុងនិមន្តតាមពីក្រោយហ្វូងសត្វនោះ ។ នៅពេលដែលព្រះអង្គទ្រង់ទតឃើញពួកអ្នកគង្វាលចៀម. ព្រះអង្គទ្រង់មានព្រះបន្ទូលសួរថា " ម្នាលអ្នកគង្វាលទាំងឡាយ តើអ្នកដេញសត្វទាំងនេះទៅទីណា? ព្រោះតាមធម្មតាគេតែងតែដេញវាត្រឡប់ទៅកាន់កន្លែងក្រោលវិញនៅរាល់ៗល្ងាច! ចុះហេតុដូចម្ដេចបានជាអ្នកទាំងឡាយនាំគ្នាដេញវាវិលវិញក្នុងវេលាទើបថ្ងៃរសៀលដូច្នេះទៅវិញ?" ពួកអ្នកគង្វាលទាំងនោះឆ្លើយថា "បពិត្រព្រះអង្គ ព្រះរាជាទ្រង់ប្រារព្ធពិធីបូជាយញ្ញយ៉ាងធំក្នុងថ្ងៃនេះ ហើយព្រះអង្គទ្រង់ត្រាស់បញ្ជាឱ្យពួកយើងខ្ញុំនាំយកសត្វចៀមនិងពពែចំនួនមួយរយៗក្បាលចូលទៅក្នុងរាជធានីនាវេលារសៀលនេះឯង" ព្រះសិទ្ធត្ថ ទ្រង់មានព្រះបន្ទូលថា " បើអីចឹង. អាត្មានឹងទៅជាមួយអ្នកដែរ" ។ ព្រះអង្គទ្រង់បីអោបកូនចៀមតូចនេះ ទៅរហូតដល់រាជធានី ។



96- Walking behind the flock of sheep, Siddhartha reached the city; then he went toward the palace, where the sacrifice was being held. The King and a group of priests of the fire-worshipping cult were chanting hymns, while a big fire was burning on the altar. They were about to kill the flock of sheep as a sacrifice, but when the leader of the fire-worshippers raised his sword to sever the head of the first sheep, Siddhartha quickly moved up and stopped him.

៩៦-ទ្រង់និមន្តយាងតាមពីក្រោយហ្វូងចៀម ពពែទាំងនេះ ព្រះសិទ្ធត្ថក៏ទ្រង់យាងមកដល់រាជធានីរួចព្រះអង្គទ្រង់យាងសំដៅទៅកាន់ព្រះបរមរាជវាំងជាកន្លែងដែលគេកំពុងតែប្រារព្ធធ្វើពិធីបូជាយញ្ញ ។ ព្រះរាជា ព្រមទាំងបណ្ឌិតមួយក្រុមដែលជាអ្នកកាន់ជំនឿគោរពបូជាព្រះអគ្គីកំពុងនាំគ្នាសូត្រធមិថ្វាយ ព្រះអាទិទេពនៅខណៈដែលគេដុតភ្លើងឱ្យឆេះឡើងសន្ធោសន្ធៅនៅកន្លែងយញ្ញពិធី ។ ពួកអ្នកទាំងនោះហៀបនឹងសំលាប់សត្វចៀមបូជាទៅហើយ. ប៉ុន្តែនៅពេលដែលគណៈអធិបតីនៃក្រុមជាអ្នកបូជាព្រះអគ្គី លើកដាវយ៉ាងមុតដើម្បីកាត់ផ្ដាច់ក្បាលចៀមមួយជាដំបូងគេ ស្រាប់តែព្រះសិទ្ធត្ថមហាករុណាធិគុណទ្រង់ក្រោកឡើងយ៉ាងរហ័សរួចទ្រង់ឃាត់អ្នកសំលាប់ ។



97– In a grave and solemn manner, Siddhartha stopped the action of the leader of the fire-worshippers and persuaded the participants to discontinue the ceremony. He said to King Bimbisara: "Your Majesty! Don't let these worshippers destroy the lives of these poor animals." Then he pointed out to the worshippers themselves: "Life is inconceivably precious. Those who want to destroy it should realize that once it is destroyed it can never be recovered" Sid- dhartha alos spoke to people who were standing as winesses to this event; "All living creatures cling to life just like human beings. Why should people exert brutal force upon these friendly animals? The suffering of birth, old age, sickness and death will naturally take away their beloved lives."

៩៧- ក្នុងព្រះអាការៈក៏អង់អាចក្លាហាននិងហ្មឺងម៉ាត់ ព្រះសិទ្ធត្ថទ្រង់ក៏បញ្ឈប់នូវអំពើរបស់ប្រធាននៃពួកអ្នកបូជាព្រះភ្លើង ហើយព្រះអង្គទ្រង់បានសុំឱ្យអ្នកដែលបានចូលមកក្នុងពិធីនោះទាំងប៉ុន្មានឈប់បន្តពិធីនេះតទៅទៀត ។ ព្រះអង្គទ្រង់មានព្រះបន្ទូលទៅកាន់ព្រះបាទពិម្ពិសារថា "បពិត្រមហារាជ! សូមទ្រង់កុំបណ្ដោយឱ្យពួកបរិស័ទទាំងនេះសម្លាប់បំផ្លាញនូវជីវិតសត្វទាំងឡាយឡើយ" ។ បន្ទាប់មកព្រះអង្គ ទ្រង់សំដែងធម៌ដល់ពួកជនធ្វើពិធីទាំងនោះថា "នែ៎អ្នកទាំងឡាយ ជីវិតមានតំលៃណាស់មិនអាចកាត់ថ្លៃបានទេ ។ ជនណាដែលចង់សំលាប់បំបាត់ជីវិតគេ ជននោះគួរយល់ឱ្យច្បាស់ថាជីវិតកាលណាត្រូវគេសំលាប់ហើយមិនអាចរកជីវិតថ្មីមកជំនួសបានឡើយ" ។ ព្រះសិទ្ធត្ថទ្រង់បានសំដែងធម៌ដល់ប្រជាជនទាំងឡាយដែលកំពុងឈរត្រៀបត្រាជាសាក្សីនៃពិធីនេះផងដែរថា: "សព្វសត្វទាំងឡាយទាំងពួងដែលមានអាយុជីវិតសុទ្ធសឹងស្រលាញ់អាយុជីវិតដូចមនុស្សយើងដែរ ។ ចុះហេតុអ្វីក៏មនុស្សទាំងឡាយនោះប្រើអំពើសាហាវព្រៃផ្សៃទៅលើពពួកសត្វដែលជាមិត្តទាំងនេះទៅវិញ ? សេចក្ដីទុក្ខនៃការកើត ចាស់ ឈឺ ស្លាប់ រមែងតែងតែឆក់យកនូវអាយុសង្ខារជាទីស្រលាញ់របស់ខ្លួនទៅជាធម្មតាទេ" ·



98– Siddhartha continued: If human beings expect mercy, they ought to show mercy, for, according to the law of cause and effect, those who kill will, in turn, be killed. In short, if we expect happiness in the future, we must do no harm to any kind of creature whatsoever. For whoever sows the seeds of sorrow and agony will undoubtedly reap the same fruits."

៩៨- ព្រះសិទ្ធត្ថជាអម្ចាស់ទ្រង់បន្តថា "បើជនណាចង់បានមេត្តា. សន្ដោសប្រោសប្រណីពីអ្នកណាម្នាក់. ជននោះគួរតែចែករំលែកផ្សព្វផ្សាយមេត្តាប្រោសប្រណីរបស់ខ្លួនដល់អ្នកដទៃ. ព្រោះតាមច្បាប់ហេតុនិងផល បើអ្នកសំលាប់គេនឹងត្រូវគេសំលាប់វិញ ។ ដោយបំព្រួញមកថា ប្រសិនបើយើងចង់បានសេចក្ដីសុខទៅអនាគត យើងមិនត្រូវធ្វើអំពើដែលនាំឱ្យមានទុក្ខទោសដោយប្រការណាមួយដល់មនុស្សសត្វទាំងពួងទេ ។ បុគ្គលណាដែលសាបព្រោះពូជគឺសេចក្ដីទុក្ខ និងការឈឺចាប់ បុគ្គលនោះនឹងបានទទួលផលនៃពូជនោះវិញយ៉ាងពិតប្រាកដឥតសង្ស័យ" ។



99– The manner in which Siddhartha spoke to the King, the fire-worshippers and the people of Rajagrha was peaceful and elegant and full of compassion yet, at the same, forceful and determined. He completely changed the intention and belief of the King and the fire-worshippers. So King Bimbisara again asked Siddhartha to stay in his country to teach the people to be merciful and to protect animals. Siddhartha was deeply grateful to the King for his offer, but since he had not yet attained his goal of complete enlighten- ment, he once again gracefully declined the invitation and departed.

៩៩- ព្រះបន្ទូលដែលព្រះសិទ្ធត្ថទ្រង់ចំពោះព្រះរាជា. ក្រុមអ្នកគោរពបូជាព្រះអគ្គីព្រមទាំងប្រជាជនក្រុងរាជគ្រឹះ ធ្វើឱ្យអ្នកទាំងនោះពោរពេញដោយសុខសន្តិភាព និងជាវាចាដ៏សប្បុរសឧត្តមថ្លៃថ្នូរថែមទាំងពោរពេញទៅដោយមេត្តាករុណាទៀតផង. ដូចគ្នាដែរព្រះវាចាជាព្រះវាចាមានប្រសិទ្ធិភាព និងប្រាកដប្រជា ។ ព្រះអង្គបានសំដែងធម៌ធ្វើឱ្យព្រះមហាក្សត្រនិងពួកព្រាហ្មណ៍ទាំងឡាយដែលនិយមគោរពពិធីបូជាយញ្ញនេះផ្លាស់ចំណង់និងជំនឿរបស់ខ្លួន ។ ដោយទ្រង់បានព្រះសណ្ដាប់មានព្រះទ័យជឿជាក់ដូច្នោះហើយព្រះបាទពិម្ពិសារទ្រង់ក្រាបថ្វាយបង្គំអារាធនានិមន្តព្រះសិទ្ធត្ថឱ្យគង់នៅក្នុងប្រទេសរបស់ព្រះអង្គដើម្បីបានបង្រៀនដល់ប្រជារាស្ត្ររបស់ព្រះអង្គឱ្យមានមេត្តាករុណា និងចេះស្រលាញ់ការពារអាយុជីវិតចំពោះពួកសត្វទាំងឡាយ ។ ព្រះសិទ្ធត្ថទ្រង់សំដែងនូវកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅដល់ព្រះរាជាចំពោះព្រះអំណោយរបស់ព្រះអង្គ. ប៉ុន្តែដោយហេតុថាព្រះសិទ្ធត្ថមិនទាន់បានសំរេចនូវសម្មាសម្ពោធិញ្ញាណពេញបរិបូរណ៍. ព្រះអង្គទ្រង់បដិសេធមិនទទួលនូវការនិមន្តរបស់ព្រះរាជា ហើយទ្រង់ក៏និមន្តយាងចេញទៅ ។



100- Leaving Rajagrha, Siddhartha journeyed on toward the place where Arada-kalama the sage, lived. Arada-kalama was one of the best known scholars of that time, who had founded many institutes for learning of all kinds. Siddhartha stayed with Arada-kalama and studied very diligently under him. Soon his knowledge and capability could be favorably compared to his teacher's, and he became recognized as a prominent and virtuous disciple of the old sage, a situation which made Arada-kalama very happy.

១០០- កាលបើយាងចេញពីក្រុងរាជគហៈហើយព្រះសិទ្ធត្ថទ្រង់បន្តព្រះដំណើរឆ្ពោះទៅកាន់កន្លែងដែល **អាឡារកាលាមៈ** តាបសគង់នៅ ។ តាបសអាឡារកាលាមៈ គឺជាគ្រូម្នាក់ដ៏ល្បីល្បាញក្នុងចំណោមគ្រូល្បីៗជាច្រើនទៀតនាសម័យនោះ ដែលជាអ្នកបានបង្កើតឱ្យមានគ្រឹះស្ថានសិក្សាជាច្រើនសំរាប់ការសិក្សារៀនសូត្ររាល់មុខវិជ្ជាទាំងឡាយ ។ ព្រះសិទ្ធត្ថទ្រង់បានគង់នៅទីនោះជាមួយអាឡារកាលាមៈតាបស ហើយសិក្សាចំណេះវិជ្ជាក្នុងសំណាក់តាបសរូបនោះដោយយកព្រះទ័យទុកដាក់បំផុត ។ មិនយូរប៉ុន្មានចំណេះវិជ្ជានិងសមត្ថភាពរបស់ព្រះអង្គក៏បានចេះចាំស្មើនឹងគ្រូរបស់ព្រះអង្គ. ហើយព្រះអង្គត្រូវបានគេទទួលស្គាល់ថា ជាសិស្សដ៏ឆ្នើមនិងមានគុណសម្បត្តិល្អម្នាក់របស់តាបសនោះ ហើយក៏ជាព្រឹត្តិការណ៍មួយធ្វើឱ្យអាឡារកាលាមៈតាបសសប្បាយរីករាយយ៉ាងខ្លាំង ។



101– One day Arada-kalama said to Siddhartha: "Now you know everything that I know and you are able to teach as well as I can. What I know you know equally well. There is little difference between us. Stay here and help me teach the students" Siddhartha asked: "Don't you have anything else to teach me, Master? Can't you tell me how to escape from old age, sickness and death?" Arada-kalama made no reply, for he had taught Siddhartha all that he knew.

១០១- ថ្ងៃមួយ តាបសអារទកាលាមៈនិយាយទៅកាន់ព្រះសិទ្ធត្ថថា: "ឥឡូវនេះ ព្រះអង្គទ្រង់បានចេះដឹងនូវអ្វីៗសព្វយ៉ាងទាំងអស់ដែលទូលព្រះបង្គំចេះហើយ ព្រះអង្គអាចបង្រៀនបានដូចខ្ញុំដែរ ។ អ្វីដែលខ្ញុំចេះ ព្រះអង្គទ្រង់បានចេះយ៉ាងច្បាស់លាស់ស្មើនឹងខ្ញុំព្រះអង្គ ។ មានភាពខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះរវាងព្រះអង្គនិងទូលបង្គំ ។ សូមព្រះអង្គគង់នៅទីនេះហើយ ដើម្បីជួយខ្ញុំក្នុងការបង្រៀនសិស្សផង!" ចំណែកព្រះសិទ្ធត្ថវិញទ្រង់មានព្រះបន្ទូលសួរថា : "តើនៅមានវិជ្ជាអ្វីដើម្បីបង្រៀនអាត្មាទៀតទេ លោកគ្រូ ? តើលោកគ្រូមិនអាចប្រាប់អាត្មាអំពីរបៀបគេចចេញឱ្យផុតពីការ ចាស់, ឈឺ, ស្លាប់ បានឬទេ?" ។ អារទកាលាមៈតាបសនៅស្ងៀម ដោយមិនអាចឆ្លើយបាន ព្រោះគាត់បានបង្រៀនព្រះសិទ្ធត្ថនូវចំណេះវិជ្ជាដែលគាត់មានទាំង ប៉ុន្មានអស់ពីក្នុងខ្លួនហើយ ។



102- What the sage Arada-kalama had taught Siddhartha consisted mainly of the knowledge of meditation, the way to make the mind very tranquil in order to eliminate all consciousness about existence in any realm (Akimcanyayatana), and then how to remain in the joy of samadhi. But this kind of knowledge was neither thorough nor ultimate. It failed to satisfy Siddhartha, for it did not provide an answer to the problems of life and death, old age and sickness that had constantly occupied his mind. For this reason Siddhartha finally departed again to seek someone who might have higher knowledge than Arada-kalama and who would be able to teach him more.

១០២- វិជ្ជាដែលគ្រូអារទកាលាមៈបានបង្រៀនដល់ព្រះសិទ្ធត្ថ មានវិជ្ជាដ៏សំខាន់ៗស្តីអំពីសមាធិកម្មដ្ឋានដែលជាមាគ៌ាធ្វើចិត្តឱ្យស្ងប់ដើម្បីកំចាត់បង់ចោលនូវការគិតអំពីការកើតក្នុងភពណាមួយ (អាកិញ្ចញ្ញាយតន) ព្រមទាំងរបៀបតាំងនៅសប្បាយក្នុងសមាធិ ។ ក៏ប៉ុន្តែចំណេះវិជ្ជាបែបនេះ នៅតែមិនទាន់ប្រាកដប្រជា ថែមទាំងមិនទាន់ដល់ទីបំផុត (នៃសេចក្តីទុក្ខបានទេ) ។ ព្រះសិទ្ធត្ថទ្រង់នៅតែមិនទាន់ពេញព្រះទ័យនៅឡើយ ព្រោះវិជ្ជាបែបនេះនៅមិនទាន់ឆ្លើយតបចំពោះបញ្ហានៃការកើតនិងស្លាប់, ចាស់ជរា និងព្យាធិដែលចេះតែធ្វើឱ្យព្រះទ័យព្រះអង្គទ្រង់ខ្វាយខ្វល់ជានិច្ច ។ ដោយហេតុយ៉ាងនេះហើយ, ទីបំផុតព្រះសិទ្ធត្ថទ្រង់ក៏លាលោកគ្រូអាចារ្យ ហើយយាងចេញពីទីនោះបន្តព្រះដំណើរទៅទៀត ដើម្បីស្វែងរកគ្រូដែលមានចំណេះវិជ្ជាខ្ពង់ខ្ពស់ប្រសើរជាងគ្រូអារទកាលាមៈតាបស និងដែលអាចបង្រៀនព្រះអង្គបានតទៅទៀត ។



103-- Later, Siddhartha learned that an old sage named Udraka-ramaputra had profound learning and a highly virtuous character. So he approached Udrakarama-putra. He became his pupil, and studied and practiced devotedly until his knowledge and capability were equal to his master's. Udraka-ramaputra also became very fond of Siddhartha, admiring his intelligence and talent, and urged him to stay and help him teach his disciples.

១០៣- ក្រោយមកព្រះសិទ្ធត្ថទ្រង់បានដឹងថាមានតាបសម្នាក់ឈ្មោះ **ឧទ្ទកភរាមបុត្រ** មានចំណេះវិជ្ជាខ្ពង់ខ្ពស់ឧត្តុងឧត្តមព្រមទាំងចរិតលក្ខណៈប្រកបដោយគុណសម្បត្តិល្អក្រៃលែង ។ ដូច្នេះព្រះអង្គទ្រង់យាងទៅកន្លែងឧទកភរាមបុត្រតាបសនោះ. ទ្រង់បានសុំធ្វើជាសិស្សរបស់គាត់ បានសិក្សារៀនសូត្រនិងប្រតិបត្តិដោយគោរពរហូតដល់មានការចេះដឹង និងសមត្ថភាពស្មើនឹងគ្រូរបស់ព្រះអង្គ ។ ឧទកភរាមបុត្រតាបសស្រលាញ់ពេញចិត្តព្រះសិទ្ធត្ថណាស់ដោយបានសរសើរអំពីបញ្ញានិងទេពកោសល្យដ៏វាងវៃរបស់ព្រះអង្គ. ។ ហើយតាបសបានសុំឱ្យព្រះអង្គគង់នៅទីនោះជាមួយខ្លួនដើម្បីជួយបង្រៀនដល់សិស្សរបស់គាត់ ។



104 But Siddhartha was not completely satisfied with Udraka-ramarptra's teaching. What he taught was, indeed, higher than Arada-kalama's teaching had been. Practising with Udraka-ramaputra enabled one to silence ones mind so that he could be completely detached from all things, ideas and feeling. In such a mental state one could hardly say that one existed nor could one say that one did not exist (Naiva-samjna-nasamjnayatana). Even so, one still could not clearly understand the ever-present problem of life and death. Therefore, Siddhartha left Udraka-ramaputra's place also, and now be decided to stop visiting and learning here and there, around and about, but to search for the ultimate truth by means of his own wisdom and effort instead.

១០៤-ប៉ុន្តែទ្រង់នៅមិនទាន់សព្វព្រះទ័យទាំងស្រុងចំពោះការបង្រៀនរបស់ឧទកភរាមបុត្រតាបសនៅឡើយទេ ។ អ្វីដែលគាត់បានបង្រៀន ពិតជាល្អប្រសើរជាងការបង្រៀនរបស់អារទកាលាមៈតាបសមែន ។ ការហាត់រៀនជាមួយឧទកភរាមបុត្រអាចធ្វើឱ្យចិត្តបានស្ងប់ចេញចាកពីវត្ថុនិងអារម្មណ៍ទាំងឡាយបាន ។ តាមសភាវៈចិត្តបែបនេះ គេពិបាកនិយាយថា មានឬមិនមានសញ្ញាបានឡើយ (មានសញ្ញាមិនមាន)(**នេវសញ្ញានាសញ្ញាយតនៈ**)។ ទោះជាយ៉ាងនេះក្តី ក៏គេនៅតែយល់មិនបានច្បាស់លាស់អំពីបញ្ហាដែលចេះតែនាំឱ្យកើតមានការកើតនិងស្លាប់ដដែល ។ ព្រោះហេតុដូច្នោះ ព្រះសិទ្ធត្ថទ្រង់ក៏យាងចេញពីសំណាក់របស់ឧទកភរាមបុត្រទៀត ។ ហើយពេលនោះ ព្រះអង្គទ្រង់សំរេចព្រះទ័យថា ទ្រង់ឈប់សិក្សានៅទីណាៗទាំងអស់. ក្រៅតែពីស្វែងរកសច្ចធម៌ឱ្យដល់ទីបំផុតតាមមធ្យោបាយនៃព្រះបញ្ញា និងការខំព្យាយាមរបស់ព្រះអង្គផ្ទាល់តែប៉ុណ្ណោះ ។



105-In that era, just as in modern times, there were many Sramanas of various cults in India who renounced their families to practice asceticism. They believed that by starving themselves or tormenting their physical bodies, they would be reborn in the heavenly states amid eternal pleasure, and that the more they suffered during the present life, the more pleasure they would be rewarded with in the future. So they practiced hardship by indul- ging in all kinds of tough an strenuous acts.

១០៥-នៅក្នុងសម័យនោះ មានសមណជាច្រើនមកពីក្រុមវណ្ណៈផ្សេងៗក្នុងប្រទេសឥណ្ឌាដែលបានលះបង់ទ្រព្យសម្បត្តិគ្រួសារមកប្រព្រឹត្តិទុក្ករកិរិយា ។ ពួកអ្នកទាំងនោះមានជំនឿថា តាមរយៈការអត់អាហារ ឬក៏ធ្វើទារុណកម្មដល់រាងកាយ គេនឹងបានទៅចាប់កំណើតថ្មីនៅឋានសួគ៌ជាកន្លែងប្រកបដោយសេចក្ដីសប្បាយរីករាយសុខក្សេមក្សាន្តគ្មានទីបំផុត . ហើយការធ្វើដូច្នេះ . ពួកគេត្រូវរងទុក្ខវេទនាយ៉ាងខ្លាំងក្នុងពេលបច្ចុប្បន្ន តែគេក៏នឹងត្រូវបានទទួលសេចក្ដីសុខនាពេលអនាគត ។ ដូច្នេះហើយ . ជនទាំងឡាយនោះខំប្រតិបត្តិយ៉ាងតឹងរ៉ឹងតាមការប្រព្រឹត្តធ្វើខ្លួនឱ្យលំបាកវេទនាដោយប្រការផ្សេងៗ ។



106-Some of them reduced their daily food intake till they were eating almost nothing at all and became only skin and bones. Some stood silently on one foot. Some raised one of their hand, pointing to the sky until poor blood circulation finally dried and crippled their arm. Some clasped both hands tightly together and never loosened them, so that the fingernails completely penetrated the palms and grew through to the back of the hands. Some of them slept on boards pierced and fully covered with sharp nails.

១០៦- ជនខ្លះកាត់បន្ថយការបរិភោគអាហារប្រចាំថ្ងៃរបស់គេបន្តិចម្ដងៗរហូតដល់ឈប់បរិភោគអ្វីទាំងអស់ ហើយរូបរាងកាយនៅសល់តែស្បែកនិងឆ្អឹងតែប៉ុណ្ណោះ ។ អ្នកខ្លះធ្វើទណ្ឌកម្មខ្លួនដោយឈរតែជើងម្ខាងយ៉ាងស្ងប់ស្ងាត់ ។ អ្នកខ្លះទៀតលើកដៃម្ខាងចង្អុលទៅលើមេឃរហូតដល់ចរន្តឈាមក្នុងដៃស្ងួតតាំងលែងរត់ ។ ខ្លះទៀត ក្ដាប់ដៃទាំងពីរចូលគ្នាយ៉ាងណែនក្ដន់ ដោយមិនលាឬបន្ធូរដៃទាល់តែសោះ. ធ្វើដូច្នេះ យូរៗទៅក្រចកដៃដុះវែងឡើងៗចាក់ទម្លុះបាតដៃធ្លាយចេញទៅខ្នងដៃទាំងសងខាង ។ ទុក្ករៈជនខ្លះទៀត . ដេកសន្ធឹងលើបន្ទះក្ដាដែលបោះដែកគោលមុតស្រួចច្រូងច្រាង ។



107-Siddhartha did try, in various ways, to become an ascetic. He thought that if he increased his hardship to a certain degree, he would most certainly become enlightend. So when he came to Uruvilva on his way to Magadha and found there a nice quiet place with level ground and lush trees, cool water flowing in a nearby stream, and a Senani Village not far away where he could go for alms, he decided to remain at that place to practice austere asceticism, using many special techniques.

១០៧-ព្រះសិទ្ធត្ថទ្រង់ខំព្យាយាមយ៉ាងខ្លាំងតាមវិធីផ្សេងៗជាច្រើន ដើម្បីធ្វើជាទុក្ករបុគ្គលម្នាក់ដែរ ។ ព្រះអង្គទ្រង់ព្រះតិរិះថា បើព្រះអង្គទ្រង់ខំបង្កើនសេចក្ដីទុក្ខលំបាកឱ្យកើនច្រើនដល់កំរិតណាមួយ ព្រះអង្គប្រាកដជានឹងបានត្រាស់ដឹងជាក់ជាមិនខាន ។ ដូច្នេះ នៅពេលព្រះអង្គយាងមក **ឧរុវេលប្រទេស** តាមផ្លូវទៅកាន់ដែនមគធៈ, ព្រះអង្គទ្រង់បានទតឃើញព្រៃមួយកន្លែងស្ងប់ស្ងាត់ល្អណាស់ មានផ្ទៃដីរាបស្មើល្អ ព្រមទាំងដើមឈើទាំងឡាយមានមែកត្រសុំសាខា មានផ្កាស្លឹកល្អស្រស់បំព្រង. នៅក្បែរនោះមានស្ទឹងមួយ. មានទឹកថ្លាយង់សែនត្រជាក់ហូរមិនដាច់ ។ ចំណែកភូមិ **សេនានិគម** ក៏តាំងនៅមិនឆ្ងាយពីនោះដែរ ដែលអាចឱ្យព្រះអង្គទ្រង់និមន្តទៅបិណ្ឌបាត្របានយ៉ាងស្រួល . ព្រះអង្គទ្រង់សំរេចព្រះទ័យគង់នៅទីនោះដើម្បីបំពេញទុក្ករកិរិយាយ៉ាងលំបាក . ដោយប្រើនូវបច្ចេកទេសពិសេសៗអស្ចារ្យជាច្រើន ដើម្បីឱ្យបានសំរេចនូវការត្រាស់ដឹង ។



108– At the time there were also five other persons-Kaundinya, Bhadrika, Baspa, Mahanama and Asvajit–who had become Sramanas and followed Siddhartha to Uruvilva. They believed that Siddhartha would finally attain enlightenment by practising asceticism with such complete devotion, and that when he became enlightened he would naturally teach them, as his disciples, what he had attained.

១០៨-នៅពេលជាមួយគ្នានោះ មានជនទាំងឡាយប្រាំនាក់ផ្សេងទៀតគឺ **កោណ្ឌញ្ញៈ** **ភទ្ទិយៈ**, **វប្បៈ** **មហានាម** និង **អស្សជិ** ដែលបានបួសជាសមណៈ រួចនិមន្តតាមព្រះសិទ្ធត្ថទៅឧរុវេលប្រទេស ។ សមណៈទាំងប្រាំអង្គជឿថា ព្រះសិទ្ធត្ថប្រាកដជានឹងបានត្រាស់ដឹងមិនខានតាមការប្រព្រឹត្តិទុក្ករកិរិយា ដោយការប្ដេជ្ញាយ៉ាងប្ដូរផ្ដាច់បែបនេះ ហើយពួកគេជឿថា នៅពេលណាព្រះអង្គទ្រង់បានសំរេចការត្រាស់ដឹងហើយ ព្រះអង្គនឹងបង្រៀនដល់ពួកគេក្នុងនាមជាសាវ័ករបស់ព្រះអង្គ នូវអ្វីដែលព្រះអង្គទ្រង់បានសំរេចហើយនោះ ។



109-Siddhartha practiced a wide variety of special forms of asceticism and then began to reduce his diet until finally he arrived at the point where he was eating nothing at all. He became so thin that his whole bony frame was clearly visible, yet this hard practice did not discourage him one bit. One day, while he was meditating alone, he fainted because of exhaustion. At that time a shepherd boy just happened to pass by. He immediately surmised that Siddhartha was about to die because he had fasted too much, for the people of that place all knew that this holy man had eaten nothing for many days.

១០៩-ព្រះសិទ្ធត្ថទ្រង់ធ្វើទុក្ករកិរិយាតាមរបៀបចូរៗពិសេសៗជាច្រើនបែប. បន្ទាប់មកទ្រង់ក៏ចាប់ផ្ដើមបន្ថយនូវអាហារបន្តិចម្ដងៗ រហូតទីបំផុតព្រះអង្គទ្រង់លែងសោយអ្វីទាំងអស់ ។ ព្រះអង្គប្រែទៅជាស្គមស្គាំងយ៉ាងខ្លាំង ដែលមើលទៅឃើញសុទ្ធតែឆ្អឹងទាំងអស់. ការប្រព្រឹត្តិដ៏លំបាកតឹងរ៉ឹងប៉ុណ្ណឹងហើយ ព្រះអង្គនៅតែមិនរួញរា មិនធ្លាក់ទឹកចិត្តសូម្បីដល់បន្តិចឡើយ ។ មានថ្ងៃមួយនោះ នៅពេលដែលព្រះអង្គកំពុងចំរើនភាវនាធម៌តែមួយអង្គឯង. ព្រះអង្គទ្រង់ខ្សោយខ្សោះអស់ព្រះកាយពលរហូតដល់សន្លប់ដួលដេកស្ដូកស្ដឹងលែងដឹងខ្លួន។ ពេលនោះមានក្មេងគង្វាលចៀមម្នាក់បានដើរកាត់តាមនោះប្រទះឃើញព្រះអង្គ ។ វាសន្និដ្ឋានថា ព្រះសិទ្ធត្ថមុខជានឹងដល់នូវទីវង្គតជីឆាប់ៗនេះពុំខាន ព្រោះព្រះអង្គទ្រង់ខ្សោយខ្លាំងណាស់ មនុស្សទាំងឡាយនៅទីនោះបានដឹងថាអរិយបុគ្គលអង្គនេះទ្រង់មិនឆាន់អ្វីទាល់តែសោះអស់ពេលជាច្រើនថ្ងៃមកហើយ ។



110– So he ran back to his flock, pulled out a mother goat and returned to the place where Siddhartha had fainted, and he helped Siddhartha recover consciousness by feeding him goat's milk. Now Siddhartha felt better and began to think and reason: "How did he faint and revive, why was he better now?" Finally he concluded that without the goat's milk from the shepherd boy he would have died before ever attaining enlightenment.

១១០- ឃើញហេតុដូច្នេះ ក្មេងគង្វាលចៀមនោះ រត់សំដៅទៅហ្វូងចៀមរបស់ខ្លួនចាប់ដឹកមេចៀមមួយក្បាលត្រឡប់មកកាន់កន្លែងដែលព្រះសិទ្ធត្ថទ្រង់កំពុងដួលដេកសន្លប់ រួចវាបានជួយធ្វើឱ្យព្រះសិទ្ធត្ថទ្រង់មានព្រះកំលាំងដឹងខ្លួនឡើងវិញ ដោយបានប្រគេនថ្វាយទឹកដោះចៀមដល់ព្រះអង្គឆាន់ ។ ឥឡូវនេះព្រះសិទ្ធត្ថទ្រង់មានព្រះសុខភាពល្អឡើងវិញហើយ ព្រះអង្គទ្រង់មានព្រះរាជតរិះពិចារណារកហេតុផលថា : "តើហេតុអ្វីបានព្រះអង្គទ្រង់ដល់នូវភាពសន្លប់ហត់ហេវ ហើយដូចម្ដេចបានជាព្រះអង្គទ្រង់ដឹងខ្លួនរស់ឡើងវិញ. ពេលឥឡូវនេះហេតុអ្វីក៏ព្រះអង្គទ្រង់មានព្រះសុខភាពល្អប្រសើរឡើងវិញ" ។ ជាចុងបញ្ចប់ព្រះអង្គទ្រង់កំណត់បាន ថា បើកុំតែបានទឹកដោះពីក្មេងគង្វាលចៀមម្នាក់នោះមកឆាន់ កុំអីព្រះអង្គដល់នូវសេចក្ដីស្លាប់មុននឹងបានសំរេចការត្រាស់ដឹងទៅហើយ ។



111– The shepherd boy received Siddhartha's blessing and returned to his flock with great joy for having had the opportunity to help revive the holy man he so revered. Siddhartha continued to sit and meditate under the tree, and at dusk he heard a group of girls singing on their way to the city: "With the strings too loose, the lute does not sound. Tighten the strings too much, they will break apart. Not too loose, not too tight, the lute sounds so nice!"

១១១- ក្មេងឃ្វាលចៀមបានទទួលនូវពរសព្ទសាធុការពីព្រះសិទ្ធត្ថរួចហើយក៏ត្រឡប់ទៅកាន់ហ្វូងចៀមរបស់ខ្លួនវិញទាំងសេចក្ដីសប្បាយរីករាយឥតឧបមា ព្រោះតែបានឱកាសដ៏ល្អជួយសង្គ្រោះជីវិតអរិយបុគ្គលគួរឱ្យគោរពពន់ពេកនេះឱ្យរស់ឡើងវិញ ។ ព្រះសិទ្ធត្ថទ្រង់ចាប់បន្តអង្គុយចំរើនកម្មដ្ឋាននៅក្រោមដើមឈើតទៅទៀត ។ ហើយនៅពេលព្រលប់នោះ ព្រះអង្គទ្រង់បានឮសំឡេងពួកកុមារីមួយក្រុមស្រែកច្រៀងបណ្ដើរដើរបណ្ដើរនៅតាមផ្លូវចូលទៅកាន់រាជធានីមានទំនុកថា : "បើខ្សែធូរពេក ពិណនឹងមិនឮសំឡេងពិរោះ, បើរឹតឱ្យតឹងពេកនឹងត្រូវដាច់ខ្សែអស់ ។ មិនត្រូវឱ្យធូរពេក មិនត្រូវឱ្យតឹងពេក ពិណនឹងឮសំឡេងពិរោះអស្ចារ្យក្រៃលែង" ។



112- Siddhartha was deeply moved by the girls's song. He had tightened his string of life too much! Should he die before attaining enlightenment, all the hardships he had gone through would be meaningless. Tormenting one's physical body was certaintly not the right way to seek the unltimate truth! Thus he decided to stop practicing asceticism and only to continue his mental diligence in his search for ultimate enlightenment. From that time on, Siddhartha regularly went for alms and ate every morning.

១១២- ព្រះសិទ្ធត្ថទ្រង់ភ្ញាក់ព្រះទ័យយ៉ាងខ្លាំង ដោយទ្រង់បានឮចំរៀងពួកស្រីក្រមុំទាំងឡាយ ។ ព្រះអង្គទ្រង់បានរឹតបន្តឹងខ្សែជីវិតរបស់ព្រះអង្គឱ្យតឹងហួសពេក ! . ប្រសិនបើព្រះអង្គទ្រង់សោយទិវង្គតមុនពេលបានសំរេចការត្រាស់ដឹងនោះ. ការខំព្យាយាមក៏សែនលំបាកទាំងប៉ុន្មានដែលទ្រង់បានធ្វើកន្លងមក នឹងទៅជាគ្មានន័យអ្វីទាំងអស់ ។ ការធ្វើទារុណកម្មដល់រាងកាយប្រាកដមិនមែនជាផ្លូវត្រូវដើម្បីស្វែងរកបរមត្ថសច្ចៈទេ ។ ដោយហេតុនោះហើយ ទើបព្រះអង្គទ្រង់សំរេចព្រះទ័យឈប់ធ្វើទុក្ករកិរិយាតទៅទៀត . ហើយទ្រង់ខំបន្តប្រតិបត្តិតាមតែព្រះបញ្ញាព្រះអង្គ ដើម្បីស្វែងរកការត្រាស់ដឹងឱ្យដល់ទីបំផុតតែប៉ុណ្ណោះ ។ ចាប់តាំងពីពេលនោះមក ព្រះសិទ្ធត្ថទ្រង់ក៏និមន្តទៅបិណ្ឌបាតជាប្រក្រតីនិងទ្រង់ឆាន់ចង្ហាន់ជារៀងរាល់ព្រឹកតាមធម្មតាវិញ ។



113-Now Siddhartha's health was completely restored, and his complexion became as glowing as gold, the same complexion he had when he lived in the royal palace before. Although was quite clear now that attempting enlightenment by practising strict asceticism was just as impossible as twining sand to make a rope, the five Sramanas who had followed him felt quite otherwise. They still firmly believed that practising strict asceticism was the only way to enlightenment. When Siddhartha gave up asceticism and returned to normal eating habits, they thought he had become a glutton, so they left him alone and went to Mrgadava (now Sarnath) near Varanasi (now Benares).

១១៣-ឥឡូវនេះព្រះសុខភាពព្រះសិទ្ធត្ថទ្រង់បានស្រួលល្អដូចដើមទាំងស្រុងវិញហើយ ចំណែកព្រះឆវីវណ្ណវិញក៏មានពន្លឺភ្លឺដូចមាស ដូចកាលដែលព្រះអង្គទ្រង់គង់នៅក្នុងព្រះរាជវាំងពីពេលមុនដែរ ។ ពេលនេះ ទោះបីព្រះសិទ្ធត្ថទ្រង់យល់យ៉ាងច្បាស់ក្នុងព្រះទ័យថា ការប៉ងប្រាថ្នាឱ្យបានត្រាស់ដឹងតាមការធ្វើទុក្ករកិរិយាដ៏តឹងហួសហេតុនេះ មិនអាចបានសំរេច ប្រៀបដូចជាពុំខ្ទកខ្សាច់ដែលមិនអាចវិញបញ្ចូលធ្វើជាខ្សែបានយ៉ាងណាក៏ដោយ ក៏សមណៈទាំង៥អង្គដែលតាមបំរើព្រះអង្គ យល់ឃើញផ្ទុយស្រឡះខុសពីព្រះអង្គទៅវិញ ។ សមណៈទាំងនោះនៅតែមានជំនឿយ៉ាងច្បាស់ថា ការប្រព្រឹត្តិទុក្ករកិរិយាដ៏តឹងរឹងគឺជាផ្លូវតែមួយគត់ដើម្បីឱ្យបានត្រាស់ដឹង ។ ពេលដែលព្រះសិទ្ធត្ថបានលះបង់ទុក្ករកម្មនោះចោល ហើយត្រឡប់មកប្រព្រឹត្តការឆាន់ចង្ហាន់ជាធម្មតាតាមទម្លាប់វិញដូច្នេះ ក៏ស្រាប់តែពួកសមណៈទាំងឡាយនោះគិតថា ព្រះអង្គបែរមកជាអ្នកប្រាថ្នាច្រើនវិញហើយ. ដោយបានឃើញនិងយល់ដូច្នោះ. ពួកភិក្ខុទាំងនោះនាំគ្នារត់ចោលព្រះអង្គឆ្ពោះទៅកាន់ព្រៃមិគ្គទាយវ័ន (បច្ចុប្បន្នហៅថា **សារនាថ**) ក្បែរក្រុងពារាណសី (បច្ចុប្បន្នហៅថា **បេនរេស**) ដោយទុក ឱ្យព្រះអង្គគង់នៅតែមួយព្រះអង្គឯង ។



114– One morning a girl named **Sujata**, who lived in the village, cooked a pot of delicious rice milk porridge and brought it over as an offering to **Siddhartha**. After presenting the offering, the noble girl said: "I wish you success in your aspiration as I have succeeded in my aspiration!" **Siddhartha** ate the porridge she offered him and felt it was very beneficial in improving both his physical and mental stamina.

**Sujata** had made a wish that a child be born to her and then she offered food to **Siddhartha** to show her gratitude.

១១៤- នៅវេលាព្រឹកមួយ មានស្ត្រីម្នាក់ឈ្មោះ **សុជាតា** ដែលជាអ្នករស់នៅក្នុងភូមិនោះ បានចំអិនមធុ-បាយាស (បាយលាយដោយទឹកដោះគោ ជាដើម )ដ៏មានឱជារសឈ្ងុយឆ្ងប់ឆ្ងាញ់ពិសា យកទៅថ្វាយប្រគេនដល់ព្រះសិទ្ធត្ថ ។ បន្ទាប់ពីប្រគេន ចង្ហាន់ដល់ព្រះអង្គរួចហើយ. ស្ត្រីដ៏ឧត្តមប្រសើរនេះពោលថា " ខ្ញុំម្ចាស់សូមឱ្យព្រះអង្គបានសំរេចជោគជ័យតាមសេចក្តីប្រាថ្នារបស់ព្រះអង្គដូចដែលខ្ញុំម្ចាស់បានសំរេចបំណងនៃខ្ញុំម្ចាស់រួចមកហើយដែរ ! " ។ ព្រះសិទ្ធត្ថទ្រង់ឆាន់មធុបាយាសដែលនាងបានប្រគេនទាំងអស់ ហើយទ្រង់ដឹងថាចង្ហាន់មធុបាយាសនេះ មានសារប្រយោជន៍ច្រើនណាស់ ធ្វើឱ្យមានភាពអំណត់ធន់ទាំងផ្នែកកាយចិត្តកើនឡើងយ៉ាងល្អប្រសើរ ។

នាងសុជាតាធ្លាប់បានសច្ចាប្រណិធានថា សូមឱ្យនាងបានបុត្រ (ប្រុស )មួយ កាលបើសេចក្តីប្រាថ្នានោះបានសំរេចហើយ នាងក៏បានថ្វាយចង្ហាន់ដល់ព្រះសិទ្ធត្ថដើម្បីជាការសងគុណ ។



115- That same day, **Siddhartha** went for a bath in the Nairanjana River; then he sat down under a **Sala** tree by the riverbank and concentrated himself in meditation, hoping to attain enlightenment in the silence of the night when no one might be passing by. At dusk **Siddhartha** left the Sala tree and walked to a large Bodhi tree, which he had chosen previously as the place for his meditation. On the way he met a straw-peddler named **Sotthiya** and accepted from him an offering of a bunch of straw. So he made a seat with the straw and sat down under the large Bodhi tree, facing east.

១១៥-នៅថ្ងៃដដែលនោះ ព្រះសិទ្ធត្ថទ្រង់យាងទៅស្រង់ព្រះវារីក្នុងស្ទឹង **នេរញ្ជរា** . បន្ទាប់មកព្រះអង្គទ្រង់គង់នៅក្រោមដើមសាលព្រឹក្ស (ដើមរាំងភ្នំ) ក្បែរមាត់ស្ទឹងប្រឹងប្រមូលអារម្មណ៍ចុះក្នុងកម្មដ្ឋាន. ដោយសង្ឃឹមថា នឹងបានសំរេចនូវសម្មាសម្ពោធិញ្ញាណក្នុងវេលារាត្រីស្ងាត់នោះមិនខានឡើយ ។ នៅពេលព្រលប់នៃយប់នោះ. ព្រះសិទ្ធត្ថព្រះអង្គទ្រង់ចាកចេញពីដើមសាលព្រឹក្ស យាងទៅកាន់ដើមពោធិព្រឹក្សដ៏ធំត្រសុំសាខាមួយដើមដែលព្រះអង្គទ្រង់បានជ្រើសរើសទុកតាំងពីពេលមុនមកថា ជាកន្លែងសំរាប់ព្រះអង្គចំរើនកម្មដ្ឋាន ។ នៅតាមផ្លូវដែលព្រះអង្គយាងទៅ ព្រះអង្គបានជួបនឹងអ្នកច្រូតស្មៅស្ពារម្នាក់ឈ្មោះ **សោត្ថិយះ** ហើយព្រះអង្គបានទទួលនូវផង្វាយស្មៅស្ពារមួយបាច់ពីគាត់ ។ ព្រះអង្គទ្រង់ក្រាលស្មៅស្ពារធ្វើជាបល្ល័ង្កនៅក្រោមដើមពោធិព្រឹក្ស រួចហើយទ្រង់ក៏គង់លើបល្ល័ង្កនោះ ដោយទ្រង់បែរព្រះភ័ក្ត្រទៅទិសខាងកើត ។



116– Having sat down under the Bodhi tree, Siddhartha made a vow to himself: " Even if my blood dries up and my muscles shrink leaving skin and bones only, I will not leave this seat until I finally and absolutely achieve the goal of finding, for myself and all mankind, a way of deliverance from the suffering of the turning round of life and death." In short, Siddhartha sat under the Bodhi tree and vowed that he would not leave that spot until he had attained enlightenment.

១១៦-ដោយទ្រង់គង់ក្រោមដើមពោធិព្រឹក្សស្រួលបួលហើយ . ព្រះសិទ្ធត្ថទ្រង់តាំងសច្ចាធិដ្ឋានថា : " ទោះបីជាឈាម សាច់របស់អាត្មាអញរីងស្ងួតហួតហែងអស់ទៅ នៅសល់តែស្បែកនិងឆ្អឹងក៏ដោយ ក៏អាត្មាអញនឹងមិនក្រោកចាកពីបល្ល័ង្កនេះជាដាច់ខាត. លុះត្រាតែអាត្មាអញបានសំរេចយ៉ាងពិតប្រាកដដល់គោលដៅមាគ៌ារំដោះឱ្យរួចផុតពីសេចក្ដីទុក្ខក្នុងវាលវដ្ដសង្សារនៃការកើត ស្លាប់ សំរាប់ខ្លួនឯងផងនិងសំរាប់មនុស្សសត្វទាំងឡាយផង " ។

ដោយសង្ខេប. ព្រះសិទ្ធត្ថគង់ក្រោមដើមពោធិព្រឹក្ស ហើយទ្រង់អធិដ្ឋានយ៉ាងមាំថា "ព្រះអង្គនឹងមិនក្រោកចាកពីគល់ពោធិព្រឹក្សនេះឡើយ ដរាបណាព្រះអង្គទ្រង់មិនបានសំរេចការត្រាស់ដឹងជាព្រះពុទ្ធទេ" ។



117– From that time on, Siddhartha concentrated his will and aroused his mind to ward off the disturbances coming from nature and to cast away the memory of the illusory joys of the past. He completely detached himself from all worldly thoughts and devoted his whole mind to the search for the ultimate truth. In his searching and reflection he asked: "How does all suffering arise? How can one detach himself from suffering?" Since Siddhartha was still a young man, only thirty-five-years old, images of the pleasures provided for him by his father when he lived in the palace still appeared, at times, in his mind.

១១៧-ចាប់ពីពេលនោះមក. ព្រះសិទ្ធត្ថទ្រង់តាំងប្រមូលអារម្មណ៍ឱ្យមូលល្អ រួចញុំាងព្រះទ័យឱ្យកើតឡើង ទប់ស្កាត់រារាំងមិនឱ្យមានអារម្មណ៍ដែលកើតពីសភាវមិនល្អណាមួយមករំខានបាន និងដើម្បីកំចាត់បង់នូវស្នាមគំនូសសង្ខារចាស់នៃការសប្បាយងប់ងល់វង្វេងវង្វាន់ច្រឡំចោលឱ្យអស់ ។ ព្រះអង្គទ្រង់បានកាត់ផ្តាច់ចេញផុតពីគំនិតស្រមើលស្រមៃបែបលោកីយ៍បានពេញបរិបូណ៌ ហើយទ្រង់តាំងប្តេជ្ញាព្រះទ័យប្តូរផ្តាច់ថា នឹងខំស្វែងរកឱ្យឃើញនូវបរមត្ថសច្ចៈឱ្យដល់ទីបំផុត ។ ក្នុងការស្វែងរកនិងព្រះតំរិះពិចារណានោះ ព្រះអង្គទ្រង់សួរព្រះអង្គឯងថា " តើសេចក្តីទុក្ខទាំងឡាយកើតឡើងដូចម្តេច ? តើគេអាចដកខ្លួនចេញឱ្យផុតពីសេចក្តីទុក្ខបានយ៉ាងណា ? " ។ ដោយហេតុតែព្រះសិទ្ធត្ថជាអម្ចាស់មានព្រះជន្មនៅក្មេងនៅឡើយ ទើបតែបាន៣៥ព្រះវស្សាប៉ុណ្ណោះ . ម្ល៉ោះហើយ អារម្មណ៍សប្បាយត្រេកត្រអាលភ្លើតភ្លើនទាំងឡាយដែលព្រះរាជបិតាចេះតែបង្កើតឱ្យមានសំរាប់ព្រះអង្គកាលពីទ្រង់គង់នៅក្នុងព្រះបរមរាជវាំង នៅតែលេចឡើងក្នុងព្រះទ័យព្រះអង្គក្នុងពេលនេះដដែល ។



118– These phantoms distracted Siddhartha's mind, enticing him to linger on the pleasures of the past and even arousing his desire to return to the royal palace and to enjoy the sensual life of former days. But because of his resolute vow, Siddhartha resisted these temptations with forceful mental effort. Finally, he succeeded in completely dispersing all the illusory thoughts that were disturbing him. His mind became calm and tranquil like pond water on a breezeless day. He was in deep Samadhi.

១១៨-មារទាំងឡាយបានធ្វើឱ្យព្រះទ័យព្រះអង្គរាយមាយ ធ្វើឱ្យព្រះអង្គស្រលាញ់ពេញចិត្តជាប់ជំពាក់ទៅរកអារម្មណ៍សប្បាយរីករាយផ្សេងៗក្នុងអតីតៈ និងមកដាស់ពញ្ញាក់ព្រះអង្គឱ្យមានតម្រេកនឹកចង់ត្រឡប់ទៅព្រះបរមរាជវាំង ទៅសប្បាយភ្លើតភ្លើនជាមួយនឹងជីវិតដែលពោរពេញទៅដោយកាមរាគៈ ដូចកាលពីគ្រាដើមវិញ ។ តែដោយសារការតាំងសច្ចាធិដ្ឋានយ៉ាងប្តូរផ្តាច់ ព្រះសិទ្ធត្ថទ្រង់ខំតស៊ូទប់ទល់នឹងតណ្ហាទាំងនេះបានដោយព្រះទ័យព្យាយាមដ៏ខ្លាំងក្លា "**វីរិយបារមី**" ។ ទីបញ្ចប់ទ្រង់បានសំរេចជោគជ័យពេញបរិបូណ៌ក្នុងការកំចាត់បង់នូវសេចក្តីយល់ខុសទាំងឡាយដែលតែងមករំខានព្រះអង្គ ។ ព្រះទ័យរបស់ព្រះអង្គមានសន្តិភាពស្ងប់ស្ងាត់ល្អណាស់ប្រៀបបីដូចជាទឹកក្នុងបឹងនៅពេលដែលគ្មានខ្យល់បោកបក់ត្រូវដូច្នោះដែរ ។ ព្រះអង្គទ្រង់គង់សិប់ក្នុងសមាធិយ៉ាងជ្រៅ ។



119-In the tranquility of Samadhi, Siddhartha searched and observed mentally, trying to find the source of his own life. Thus he acquired the power of being aware of all his previous lives ( Purvenivasanusmrti ). Through further insight, he also acquired the divine vision ( Divyacaksus), the power to see all things and to know the future rebirths of all beings. He thus came to realize that the unceasing ciycle of death and rebirth of all beings is solely a manifestation of one's Karma; that is, one's thoughts and deeds. People could be born to a better life than they presently enjoyed, encountering all sorts of happiness, because they had done good deeds. Some, on the other hand, could be born to a condition worse than their present one and suffer very much because they had done bad deeds.

១១៩- ក្នុងភាពស្ងប់ស៊ប់ចុះក្នុងសមាធិកម្មដ្ឋាន ព្រះសិទ្ធត្ថទ្រង់បានរំពឹងគិតនិងពិនិត្យមើលតាមព្រះបញ្ញាញាណ ទ្រង់ខំព្យាយាមរកប្រភពឫសគល់នៃខ្សែជីវិតរបស់ព្រះអង្គផ្ទាល់ ។ ព្រោះហេតុដូច្នោះ ព្រះអង្គទ្រង់បានសំរេចនូវការរលឹកឃើញនូវអតីតជីវិតជាអនេកជាតិរបស់ព្រះអង្គ ( **បុព្វេនិវាសានុស្សតិ** ) ។ តាមរយៈការចំរើនវិបស្សនាកម្មដ្ឋានកាន់តែជ្រៅទៅៗ ព្រះអង្គទ្រង់បានសំរេចនូវព្រះចក្ខុវិញ្ញាណដ៏អស្ចារ្យ ( **ទិព្វចក្ខុ** ) បារមីញាណដែលអាចមើលឃើញនូវអ្វីៗទាំងពួងនិងដឹងនូវគ្រប់ជាតិកំណើតក្នុងជាតិខាងមុខរបស់មនុស្សសត្វទាំងអស់ ។ ព្រះអង្គទ្រង់រលឹកឃើញថា កង់ចក្រនៃការវិលកើតវិលស្លាប់, ស្លាប់ កើតមិនមានទីបញ្ចប់របស់មនុស្សសត្វទាំងឡាយគឺជាការកើតឡើងដោយសារតែកម្មតែម្យ៉ាងប៉ុណ្ណោះ គឺអំពើដែលខ្លួនបានធ្វើដោយកាយ វាចា ចិត្ត ។ អ្នកខ្លះគេកើតមកមានជីវិតរស់នៅល្អប្រសើរឧត្តុងឧត្តម គេបានសុខកាយសប្បាយចិត្តក្នុងបច្ចុប្បន្នជាតិនេះ បានជួបប្រទះនូវសុភមង្គលវិបុលសុខគ្រប់បែបយ៉ាង ព្រោះជនទាំងឡាយនោះ គេបានធ្វើកម្មជាកុសលកាលពីជាតិមុនៗមក ។ ចំណែកអ្នកដែលកើតមកមានលក្ខណៈទីទ័លក្រីក្រតោកយ៉ាក រូបអាក្រក់ខ្មោះខ្មួរនិងរងទុក្ខលំបាកវេទនាជាអតិបរិមា ព្រោះគេបានធ្វើអំពើអាក្រក់កាលពីជាតិមុនៗមក ។



120-Finally he observed that the ultimate cause of the turning round of birth and death in the vast sea of worldly suffering, that mankind and all other sentient beings are involved in, is ignorance (Moha) and the attachment to transient and illusory pleasures. And for those who are unwilling to remain in the cycle of death and rebirth, there is only one way to escape; that is, by the complete destruction or elimination of all lustful desires. Siddhartha thus acquired Asravaksaya, the extinction of outflows. He knew that he had delivered himself from all passions and delusions, that he had discovered the cause of and the method of elimination of all suffering, and that he had attained enlightenment. This was a great event that occurred before dawn on the full moon day of the Visakha month. Siddhartha Gautama of the Sakya Clan, at the age of thirty-five, attained supreme enlightenment and became the Buddha under the Bodhi tree by the bank of the Nairanjana River. Since then the world has possessed a shining lamp.

១២០-ព្រះអង្គទ្រង់ប្រមើលមើលឃើញថា ហេតុទីបំផុតនៃការអន្ទោលវិលកើតស្លាប់ៗក្នុងសមុទ្រសង្សារនៃទុក្ខគ្មានទីបញ្ចប់ដែលមនុស្សសត្វទាំងឡាយតែងតែធ្លាក់លិចលង់គឺសេចក្ដីល្ងីតល្ងង់វង្វេងភាន់ច្រឡំ ( **មោហៈ** ) និងការជាប់ជំពាក់ទៅនឹងកាមរាគៈសប្បាយភ្លើតភ្លើន ។ ចំពោះមនុស្សសត្វទាំងឡាយណាដែលមានការនឿយណាយក្នុងសង្សារ-ចក្រនៃការកើតស្លាប់ៗនេះ មានមាគ៌ាតែមួយគត់ដើម្បីគេចវេសជៀសវាងឱ្យផុតពីការកំចាត់បង់ឬគាស់រំលើងចោលឱ្យអស់នូវកាមតណ្ហាទាំងឡាយ ។ ព្រោះហេតុដូច្នោះ ព្រះសិទ្ធត្ថបរមពោធិញាណទ្រង់ក៏បានសំរេចនូវ **អាសវក្ខ-យញ្ញាណ** ជាទីអស់ទៅនៃគងកិលេសទាំងពួងដែលជាគ្រឿងត្រាំនៅក្នុងខន្ធសន្ដាន ។ ព្រះអង្គទ្រង់ជ្រាបច្បាស់ថាព្រះអង្គបានរួចផុតពីកិលេសតណ្ហានិងគងអវិជ្ជាល្ងីតល្ងង់វង្វេងភាន់ច្រឡំទាំងឡាយហើយ. ព្រះអង្គទ្រង់បានរកឃើញហេតុដែលនាំឱ្យកើតទុក្ខ និងវិធីសាស្ត្រនៃការគាស់រំលើងសេចក្ដីទុក្ខ និងទ្រង់បានជ្រាបដោយព្រះអង្គឯងយ៉ាង ច្បាស់ថា ព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញាណពេញបរិបូណ៌ហើយ ។ នេះជាព្រឹត្តិការណ៍១ដ៏អស្ចារ្យដែលកើតមានឡើង **មុនពេលថ្ងៃរះនៃថ្ងៃ១៥កើតពេញបូណ៌មី ខែពិសាខ** ។ ព្រះសិទ្ធត្ថគោតមនៃសក្យត្រកូលទ្រង់បានសំរេចការត្រាស់ដឹងដ៏ប្រពៃ បានត្រាស់ជា **ព្រះពុទ្ធ** ក្រោមដើមពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងព្រះជន្មា៣៥ព្រះវស្សា ។ ព្រោះហេតុដូច្នោះហើយ ពិភពលោកក៏បានទទួលនូវពន្លឺប្រទីបដ៏ភ្លឺចិញ្ចែងចិញ្ចាចតាំងពីពេលនោះមក ។



121-Having attained supreme enlightenment and freed himself from all worldly suffering, the Buddha remained contentedly in the happiness of Nirvana; that is, the happiness arising from both subduing all passions and liberation from all suffering. Later a **Brahmana** approached him under the banyan tree, saluted him courteously and asked: "**Gautama**! To be a true Brahmana and a noble person, what kind of moral character must one have?"

១២១- ដោយទ្រង់បានសំរេចការត្រាស់ដឹងដ៏ប្រសើរនិងបានរំដោះផុតពីសេចក្តីទុក្ខក្នុងលោកនេះទាំងអស់ហើយ. ព្រះពុទ្ធបរមគ្រូជាម្ចាស់គង់នៅយ៉ាងក្សេមក្សាន្តក្នុងសេចក្តីសុខនៃព្រះនិព្វានគឺសេចក្តីសុខដែលកើតឡើងពីការសំលាប់ញ៉ាំញីនូវកិលេសតណ្ហាទាំងឡាយនិងការបានរំដោះរួចផុតពីកងទុក្ខទាំងពួង ។ បន្ទិចក្រោយមក មាន**ព្រាហ្មណ៍**ម្នាក់បានចូលមកជួបនឹងព្រះអង្គនៅក្រោមដើមពោធិព្រឹក្ស បានសម្តែងការគោរព ចំពោះព្រះអង្គដ៏សមគួរ .រួចហើយទូលសួរព្រះអង្គថា: ˝បពិត្រ **ព្រះគោតម** ដ៏ចំរើន! ដើម្បីឱ្យបានជាព្រាហ្មណ៍ពិតប្រាកដ និងជាអរិយបុគ្គលពិតនោះ តើគេត្រូវមានធម៌ដូចម្តេច ?˝



122-The Buddha paid no heed to the rudeness of being called by name instead of by his title 'Buddha'or 'Bhagavant' but answered him directly: "A true Brahmana must abandon all evil, give up haughtiness, be prudent and clean, pursue extensive learning and practice pure living. He must differ from ordinary people in his conduct to deserve to be called a Brahmana." The Brahmana murmurred to himself as he left: "This Sramana Gautama really sees through my mind! This Sramana Gautama really sees through my mind.

១២២-ព្រះពុទ្ធជាម្ចាស់ទ្រង់មិនយកព្រះទ័យទុកដាក់អាក់អន់នឹងពាក្យសំដីអសុរោះ ដែលហៅចំឈ្មោះព្រះអង្គ ដោយមិនហៅថា ˝**ព្រះពុទ្ធ**˝ ឬ ˝**ព្រះភគវន្ត**˝ នោះឡើយ ផ្ទុយទៅវិញព្រះអង្គទ្រង់បានឆ្លើយដោយត្រង់ៗថា ˝ម្នាលព្រាហ្មណ៍. ព្រាហ្មណ៍ពិតប្រាកដនុះ ត្រូវលះបង់អំពើបាបអាក្រក់ទាំងអស់ បោះបង់ចោលនូវអំនួតក្រអឺតក្រទមទាំងអស់ ដោយមានចិត្តប្រុងប្រយ័ត្ននិងស្អាតស្អំជានិច្ច ខិតខំស្វែងរកការរៀនសូត្រ ការយល់ដឹងឱ្យបានវែងឆ្ងាយទូលំទូលាយ និងរៀនរស់នៅក្នុងជីវិតបរិសុទ្ធ ។ អ្នកនោះឯងត្រូវតែមានលក្ខណៈផ្សេងពីសាមញ្ញជនក្នុងការប្រព្រឹត្តិប្រតិបត្តិដើម្បីឱ្យសមនឹងពាក្យគេហៅថា ជាព្រាហ្មណ៍ពិត ។ ព្រាហ្មណ៍កាលបើស្តាប់ឮដូច្នេះ ហើយខ្មាស់ទញ់ទាល់គំនិតក៏ចាកចេញទៅដោយនិយាយក្នុងចិត្តថា ˝ព្រះសមណគោត្តនេះច្បាស់ជាទ្រង់ជ្រាបចិត្តអាត្មាអញដោយពិត! ព្រះសមណគោត្តនេះ ច្បាស់ជាទ្រង់ជ្រាបចិត្តអាត្មាអញដោយពិត!˝ ។



123-Many days later, while the Buddha was resting under a pipala tree, two merchants passed by. They found the Buddha sitting extraordinarily calmly and joyously like somebody who had won the biggest battle, pleased with his victory. So they reverently offered the Buddha the exquisite food they had brought with them and being deeply impressed by the Buddha's appearance and speech, they requested that the Buddha accept them as disciples. The names of the two merchants were Tapussa and Bhallika. Because both of them took refuge in the Buddha, they became the Buddha's first two disciples.

១២៣-ជាច្រើនថ្ងៃក្រោយមក នៅពេលដែលព្រះពុទ្ធបរមគ្រូជាម្ចាស់កំពុងគង់សំរាកនៅក្រោមដើម **រំភស** (ដើម Pipala) មាននាយពាណិជ្ជពីរនាក់បានធ្វើដំណើរកាត់តាមនោះ ។ ពួកគេបានជួបនឹងព្រះពុទ្ធកំពុងគង់យ៉ាងធម្មតា ដោយស្ងៀមស្ងាត់និងយ៉ាងសប្បាយរីករាយបីដូចជាមនុស្សដែលបានទទួលជោគជ័យក្នុងសង្គ្រាមក្តៅដ៏ធំបំផុត ហើយបានសប្បាយរីករាយក្នុងជ័យជំនះរបស់ខ្លួន ។ ឃើញដូច្នេះ នាយពាណិជ្ជទាំងពីរក៏បន្ទន់កាយថ្វាយភោជនាហារដ៏មានរស់ឆ្ងាញ់ពិសាដែលបានដាក់តាមខ្លួនប្រគេនដល់ព្រះពុទ្ធជាម្ចាស់ដោយសេចក្តីគោរព និងចាប់អារម្មណ៍យ៉ាងខ្លាំងដោយបានឃើញព្រះអាការៈ និងបានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គ ពួកជនទាំងពីរនាក់ក៏បានក្រាបថ្វាយបង្គំទូលសុំឱ្យព្រះពុទ្ធជាម្ចាស់ទ្រង់មេត្តាទទួលយកខ្លួនធ្វើជាសាវ័ក ។ នាយទាំងពីរនេះ គឺឈ្មោះ **តបុស្សៈ** និង **ភល្លិកៈ** ។ ដោយហេតុជនទាំងពីរនាក់បានចូលជ្រកកោនជាទីពឹងក្នុង ព្រះពុទ្ធ គេក៏បានជាសាវ័កមុនគេបង្អស់របស់ព្រះពុទ្ធបរមគ្រូជាម្ចាស់ ។



124-After a long rest, the Buddha began to plan what he should do for the futere. At first he thought: "The Dharma I have comprehended is difficult and profound, and it can hardly be accepted by most people, whose desire-nature is very strong." But with great compassion and unsurpassed wisdom, the Buddha then concluded: "Some people have light passion and few vexations, some people have fairly little desire. Such people may be able to accept this Dharma much as the lotus extends its stalk from the bottom of the pond up into the air to receive sunshine. I, therefore, should not hold secret the radiant truth, but shall make it known everywhere so that all people can benefit from it equally." Thus he decided to propagate the dharma.

១២៤-ក្រោយពីគង់សំរាកអស់ពេលយូរបន្តិចមក ព្រះពុទ្ធអង្គទ្រង់រំពឹងពិចារណាទូវអ្វីដែលព្រះអង្គគួរនឹងធ្វើសំរាប់ពេលខាងមុខ ។ ជាដំបូងព្រះអង្គទ្រង់ព្រះតំរិះថាៈ “ធម៌ដែលតថាគតបានសំរេចចេះដឹងទាំងប៉ុន្មានមានគម្ពីរជ្រាលជ្រៅណាស់ ជាធម៌ដែលមនុស្សភាគច្រើនជាអ្នកមានកិលេសតណ្ហាក្រាស់ជោគជាំពិបាកនឹងទទួលយកបាន ”។ តែដោយសារព្រះមហាករុណាដ៏ធំនិងបញ្ញាដ៏លើសលប់ ពេលនេះព្រះអង្គទ្រង់រំពឹងពិចារណាថាៈ “មនុស្សសត្វពួកខ្លះមានរាគៈតណ្ហាស្តើងនិងមានទោសៈតិច មនុស្សសត្វពួកខ្លះទៀតមានកិលេសតណ្ហាតិចតួចស្តួចស្តើងបំផុត ។ មនុស្សទាំងឡាយនោះអាចនឹងទទួលយកព្រះធម៌នេះបានច្រើន ប្រៀបដូចផ្កាឈូកដែលដុះលូតលាស់ចេញផុតពីទឹកស្រះរងចាំទទួលពន្លឺរស្មីនៃព្រះអាទិត្យដើម្បីនឹងរីកដូច្នេះដែរ ។ ព្រោះហេតុដូច្នេះ តថាគតមិនគួរលាក់បាំងទុកនូវសច្ចធម៌ដ៏អស្ចារ្យនេះទេ តថាគតត្រូវតែចែករំលែកផ្សព្វផ្សាយព្រះធម៌អស្ចារ្យនេះឱ្យមនុស្សសត្វទាំងឡាយបានដឹងគ្រប់ទីទាំងអស់ដើម្បីឱ្យជនទាំងឡាយនោះបានទទួលផលប្រយោជន៍ពីព្រះធម៌នេះស្មើ១គ្នា ”។ ដូច្នេះហើយព្រះអង្គក៏ទ្រង់សំរេចព្រះទ័យផ្សព្វផ្សាយព្រះធម៌ប្រោសដល់សត្វលោក ។



125– After making up his mind thus, the Buddha began to ponder: "Whom shall I convert first? This person must be inclined to the teaching of Dharma and must be quick in understanding it". First, he thought of his own master Arada-kalama, who was a wise man of reason and had very light passion. He was definitely the person to accept the dharma. But he soon learned that Arada-kalama had passed away. He then thought of his other master, Udraka-ramaputra, but soon found out that he had also died. Finally, the five Sramanas who had followed him before in the practice of asceticism at Uruvilva came round to the Buddha's consciousness. When he learned that they were now at Mrgadava, near Varanasi (Benares), he left Unuvilva at once in order to look for them .

១២៥- ក្រោយពីបានសំរេចព្រះទ័យដូច្នេះហើយ ព្រះសម្មាសម្ពុទ្ធទ្រង់រំពឹងគិតថា: " តើនរណាដែលតថាគតត្រូវប្រោសមុនគេ? ជននោះដែលពិតជាអ្នកមានចិត្តទោរទន់ទៅរកការប្រៀនប្រដៅធម៌ ហើយពិតជានឹងបានយល់ជ្រួតជ្រាបព្រះធម៌ដោយរហ័ស "។ ព្រះបរមសាស្តាចារ្យជាម្ចាស់ មុនដំបូងទ្រង់រំពឹងគិតដល់គ្រូអាឡារកាលាមៈ ដែលជាអ្នកមានប្រាជ្ញាយល់ដឹងនូវហេតុផល និងមានរាគតណ្ហាស្តើងបំផុត ។ គាត់ជាមនុស្សដែលទទួលយកបាននូវព្រះធម៌ដោយពិតប្រាកដ ។ ប៉ុន្តែភ្លាមនោះព្រះអង្គទ្រង់ប្រមើលមើលទៅឃើញថា អារទកាលាមៈតាបសបានសុគតបាត់ទៅហើយ ។ បន្ទាប់មកព្រះអង្គទ្រង់បានពិចារណាគិតដល់គ្រូផ្សេងទៀតគឺ ឧទកៈតាបស ប៉ុន្តែរំពេចនោះទ្រង់បានជ្រាបច្បាស់ថា តាបសនោះក៏សុគតបាត់ទៅហើយដែរ ។ ជាចុងក្រោយទ្រង់គិតដល់ពួកសមណៈទាំង៥អង្គដែលបានតាមបំរើព្រះអង្គតាំងតែពីមុនព្រះអង្គធ្វើទុក្ករកិរិយានៅឧរុវេលាប្រទេសរហូតដល់ព្រះពុទ្ធជាម្ចាស់លះបង់ទុក្ករកិរិយានោះវិញ ។ នៅពេលដែលព្រះអង្គទ្រង់ជ្រាបច្បាស់ថាពួកភិក្ខុទាំងនោះគង់នៅក្នុងព្រៃមិគទាយវ័ន ក្បែរក្រុងពារាណសី (បេណារេស) ព្រះសាស្តាចារ្យជាម្ចាស់ទ្រង់ក៏យាងចេញពីឧរុវេលាប្រទេស នៅពេលនោះតែម្តង ដើម្បីស្វែងរកពួកភិក្ខុទាំងឡាយនោះ ។



126– At Mrgadava, when the five Sramamas saw the Buddha approaching in the distance, they spoke among themselves; "Look there! Sramana Gautama is coming straight over. He has abandoned asceticism and has become a voracious person. When he arrives, let's not talk to him nor even greet him nor take his robe and bowl. Let's only prepare a cushion here. Let him sit down if he likes; otherwise let him stand. Who would bother to greet a man of shaky will like him!"

១២៦-នៅឯព្រៃមិគទាយវ័ន, ពេលដែលសមណៈទាំង៥អង្គបានឃើញព្រះពុទ្ធជាអម្ចាស់ពីចម្ងាយដែលកំពុងតែស្តេចយាងមក, ពួកភិក្ខុទាំងអស់និយាយគ្នាថា " ចូរមើលហ្ន៎! សមណៈគោតមកំពុងនិមន្តត្រង់មករកយើងហើយ ។ ព្រះអង្គទ្រង់បានបោះបង់ទុក្ករកម្មចោល ហើយត្រឡប់មកជាអ្នកប្រាថ្នាច្រើនទៅវិញ ។ នៅពេលព្រះអង្គនិមន្តមកដល់, ចូរយើងកុំនិយាយអ្វីជាមួយនឹងព្រះអង្គឡើយ, ចូរកុំធ្វើបដិសណ្ឋារកិច្ចគោរពព្រះអង្គ ទាំងកុំទទួលចីវរនិងបាត្រពីព្រះអង្គឱ្យសោះ ។ យើងគ្រាន់តែក្រាលអាសនៈទុកចោលនៅទីនេះបានហើយ ។ ទុកឱ្យព្រះអង្គគង់ដោយព្រះអង្គឯងទៅចុះ, បើមិនអ៊ីចឹងទេ ទុកឱ្យព្រះអង្គទ្រង់ឈរក៏បានដែរ ។ តើមាននរណា គេទៅរវល់ខ្វល់ខ្វាយរាក់ទាក់ជាមួយនឹងមនុស្សក្រឡិចក្រឡុចដូចព្រះអង្គនុ៎ះ ! " ។



127-But when the five Sramanas looked at the Buddha as he approached nearer to them, they found that he was not the sort of person they had thought him to be. They began to be aware that the Buddha was incomparably noble and serious and brilliant in the light of his halo; they had never seen such person before. They were so astonished, indeed, that they unconsciously forgot what they had just been saying. Some of them quickly ran over and bowed, respectfully taking his robe and bowl from the Buddha's hands, while others prepared the cushion on the seat and rushed to get water to serve him.

១២៧-ប៉ុន្តែខណៈដែលសមណៈទាំង៥អង្គក្រឡេកភ្នែកទៅឃើញព្រះពុទ្ធជាម្ចាស់ នៅពេលដែលព្រះអង្គនិមន្តមកកាន់តែជិតដល់ពួកខ្លួន. សមណៈទាំងអស់បានឃើញថា ព្រះអង្គមិនមែនជាមនុស្សដូចដែលគេបានគិតទុកនោះទេ ។ គេបានដឹងយ៉ាងច្បាស់ថា ព្រះពុទ្ធជាបុគ្គលដ៏ប្រសើរអស្ចារ្យ មានព្រះបញ្ញាវាងវៃក្រៃលែងឥតប្រៀបផ្ទឹមបាន មានពន្លឺរស្មីចិញ្ចែងចិញ្ចាចផ្សាយចេញពីរង្វង់ព្រះសីសៈព្រះអង្គ. ពួកសមណៈទាំងអស់មិនធ្លាប់ឃើញបុគ្គលបែបនេះទាល់តែសោះតាំងតែពីមុនមក ។ មែនហើយ. ពួកគេភ្ញាក់ផ្អើលចិត្តឥតឧបមា ដែលធ្វើឱ្យគេភ្លេចអស់នូវអ្វីៗដែលគេទើបបាននិយាយគ្នា ។ អង្គខ្លះរត់ទៅគោរពថ្វាយបង្គំព្រះអង្គ . ខ្លះទទួលយកត្រៃចីវរនិងបាត្រពីព្រះពុទ្ធបរមគ្រូដោយគារវភក្តីបំផុត . អង្គខ្លះទៀតរៀបចំក្រាលអាសនៈនិមន្តព្រះអង្គគង់និងស្ទុះស្ទារម្នីម្នាទៅដងទឹកបំរើព្រះអង្គដោយសព្វគ្រប់ ។



128- After sitting down on the cushion they had prepared, the Buddha began to speak: "Sramanas! I have attained the truth of Nirvana of the unborn and undying, and I want to expound and introduce it to you. If you learn it and practice it according to my direction, you will soon be enlightened, not in the future, but in the present life or even in the present moment. I tell you nothing but the truth that you must transcend birth and death by yourselves!"

១២៨-ក្រោយពីទ្រង់គង់លើកំរាលដែលពួកសមណៈបានក្រាលទទួលស្រេចហើយ. ព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះពុទ្ធដីកាថា : " ម្នាលសមណៈទាំងឡាយ ! តថាគត បានសំរេចសេចក្តីពិតនៃព្រះនិព្វាន ( និព្វានសច្ចៈ ) ដែលជាធម៌លែងកើត និងលែងស្លាប់ទៀតហើយ . តថាគតមានបំណងនឹងសំដែងធម៌នេះប្រាប់ដល់អ្នកទាំងឡាយ ។ បើអ្នកទាំងឡាយបានសិក្សាយល់ជ្រួតជ្រាបនិងប្រតិបត្តិធម៌នេះតាមការចង្អុលបង្ហាញរបស់តថាគត. អ្នកនឹងបានសំរេចធម៌ត្រាស់ដឹងក្នុងពេលឆាប់ៗនេះ ដោយមិនចាំដល់ពេលអនាគតឡើយ គឺក្នុងជីវិតបច្ចុប្បន្នជាតិនេះតែម្តង ។ តថាគតមិនសំដែងប្រាប់នូវអ្វីក្រៅពីសេចក្តីពិតដែលអ្នកត្រូវតែខិតខំពុះពារហែលឆ្លងឱ្យផុតពីការកើតនិងការស្លាប់ដោយខ្លួនអ្នកទេ ! " ។



129– On hearing the Buddha's words, the five Sramanas could not help doubting him; for they had seen him devotedly practicing before in pursuit of the ultimate truth, but then he had stopped . Now he came and said he had already attained the unborn and undying nirvana! So the five sramanas were reluctant to believe what the Buddha was saying, and they raised many questions with the Buddha. At last the Buddha said: "Sramanas! Please think. Did I ever tell you all these things before when we stayed together? Did I ever try to convince you that I had found the supreme truth?" The five Sramanas admitted that, indeed, the Buddha had never said such things before, so they no longer refused to accept the Buddha's teachings.

១២៩-ដោយបានស្តាប់ព្រះពុទ្ធដីកាជាហូរហែមក. សមណៈទាំង៥អង្គនៅតែមិនអស់មន្ទិលសង្ស័យចំពោះព្រះអង្គនៅឡើយ ដោយលោកបានឃើញព្រះអង្គប្រព្រឹត្តប្រតិបត្តិយ៉ាងប្តូរផ្តាច់តាំងពីពេលមុនមកក្នុងការស្វែងរកបរមត្ថសច្ចៈ ប៉ុន្តែក្រោយមកព្រះអង្គបែរជាទ្រង់បោះបង់ចោលវិញ ។ ឥឡូវនេះ ព្រះអង្គត្រឡប់ជាមកមានព្រះតម្រាស់ថា ព្រះអង្គបានសំរេចដល់ព្រះនិព្វានដែលលែងកើត លែងស្លាប់ទៀត ! ដូច្នេះ ហើយ បានជាសមណៈទាំង៥អង្គស្ទើរស្ទាក់ពិបាកជឿបាននូវអ្វីដែលព្រះអង្គបានសំដែង. រួចពួកសមណៈថែមទាំងលើកយកសំណួរជាច្រើនសួរចំពោះព្រះពុទ្ធជាម្ចាស់ ។ នៅទីបំផុត ព្រះដ៏ទ្រង់យសជាម្ចាស់នៃយើងទ្រង់ត្រាស់ថា " នែ៎ សមណៈទាំងឡាយ ! ចូរអ្នកទាំងឡាយគិតទៅមើល ។ តាំងពីមុនមក ពេលដែលយើងនៅជាមួយគ្នា តើតថាគតធ្លាប់សំដែងប្រាប់នូវធម៌ទាំងឡាយនេះដល់អ្នកទាំងឡាយដែរឬទេ ? តើតថាគតធ្លាប់ព្យាយាមធ្វើឱ្យអ្នកជឿថា តថាគតបានរកឃើញនូវអរិយសច្ចធម៌ដូច្នេះដែរឬទេ ? សមណៈទាំង៥អង្គអស់មន្ទិលសង្ស័យ ហើយក៏ទទួលយល់ព្រមថា ពិតមែនហើយ. ព្រះពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ពុំដែលត្រាស់សំដែងធម៌យ៉ាងដូច្នេះឡើយ . ហើយលោកក៏យល់ព្រមទទួលយកការបង្រៀនធម៌របស់ព្រះអង្គដោយសុទ្ធចិត្ត ។



120-Finally he observed that the ultimate cause of the turning round of birth and death in the vast sea of worldly suffering, that mankind and all other sentient beings are involved in, is ignorance (Moha) and the attachment to transient and illusory pleasures. And for those who are unwilling to remain in the cycle of death and rebirth, there is only one way to escape; that is, by the complete destruction or elimination of all lustful desires. Siddhartha thus acquired Asravaksaya, the extinction of outflows. He knew that he had delivered himself from all passions and delusions, that he had discovered the cause of and the method of elimination of all suffering, and that he had attained enlightenment. This was a great event that occurred before dawn on the full moon day of the Visakha month. Siddhartha Gautama of the Sakya Clan, at the age of thirty-five, attained supreme enlightenment and became the Buddha under the Bodhi tree by the bank of the Nairanjana River. Since then the world has possessed a shining lamp.

១២០-ព្រះអង្គទ្រង់ប្រមើលមើលឃើញថា ហេតុទីបំផុតនៃការអន្ទោលវិលកើតស្លាប់ៗក្នុងសមុទ្រសង្សារនៃទុក្ខគ្មានទីបញ្ចប់ដែលមនុស្សសត្វទាំងឡាយតែងតែធ្លាក់លិចលង់គឺសេចក្តីល្ងិតល្ងង់វង្វេងភាន់ច្រឡំ ( **មោហៈ** ) និងការជាប់ជំពាក់ទៅនឹងកាមរាគៈសប្បាយភ្លើតភ្លើន ។ ចំពោះមនុស្សសត្វទាំងឡាយណាដែលមានការនឿយណាយក្នុងសង្សារ-ចក្រនៃការកើតស្លាប់ៗនេះ មានមាគ៌ាតែមួយគត់ដើម្បីគេចវេសជៀសវាងឱ្យផុតពីការកំចាត់បង់ឬគាស់រំលើងចោលឱ្យអស់នូវកាមតណ្ហាទាំងឡាយ ។ ព្រោះហេតុដូច្នោះ ព្រះសិទ្ធត្ថបរមពោធិញាណទ្រង់ក៏បានសំរេចនូវ **អាសវក្ខ-យញ្ញាណ** ជាទីអស់ទៅនៃកងកិលេសទាំងពួងដែលជាគ្រឿងត្រាំនៅក្នុងខន្ធសន្តាន ។ ព្រះអង្គទ្រង់ជ្រាបច្បាស់ថា ព្រះអង្គបានរួចផុតពីកិលេសតណ្ហានិងកងអវិជ្ជាល្ងិតល្ងង់វង្វេងភាន់ច្រឡំទាំងឡាយហើយ. ព្រះអង្គទ្រង់បានរកឃើញហេតុដែលនាំឱ្យកើតទុក្ខ និងវិធីសាស្ត្រនៃការគាស់រំលើងសេចក្តីទុក្ខ និងទ្រង់បានជ្រាបដោយព្រះអង្គឯងយ៉ាង ច្បាស់ថា ព្រះអង្គបានត្រាស់ដឹងនូវសម្មាសម្ពោធិញាណពេញបរិបូណ៌ហើយ ។ នេះជាព្រឹត្តិការណ៍១ដ៏អស្ចារ្យដែលកើតមានឡើង **មុនពេលភ្លឺនៃថ្ងៃ១៥កើតពេញបុណ៌មី ខែពិសាខ** ។ ព្រះសិទ្ធត្ថគោតមនៃសក្យត្រកូលទ្រង់បានសំរេចការត្រាស់ដឹងដ៏ប្រពៃ បានត្រាស់ជា **ព្រះពុទ្ធ** ក្រោមដើមពោធិព្រឹក្ស ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងព្រះជន្ម៣៥ព្រះវស្សា ។ ព្រោះហេតុដូច្នោះហើយ ពិភពលោកក៏បានទទួលនូវពន្លឺប្រទីបដ៏ភ្លឺចិញ្ចែងចិញ្ចាចតាំងពីពេលនោះមក ។



131-While the Buddha was in Mrgadava, a young man named Yasas, who was the son of a millionaire of Varanasi, suddenly one day grew tired of his family and of his lustful life with many women. He ran away from home secretly and happened to meet the Buddha on his way. Upon hearing the Buddha preach and on learning the benefits of Dharma practice, he became exultant and requested permission to leave home and practice with the Buddha. On the same day, Yasas's father, in search of his son, met the Buddha and asked him about his son. The Buddha instructed him on appropriate points of the dharma causing him to understand and joy arose in him and allowed his son to leave home and become a monk.

១៣១-ពេលដែលព្រះពុទ្ធជាម្ចាស់គង់នៅក្នុងមិគទាយវ័ន, មានបុរសម្នាក់ឈ្មោះ **យស** ជាកូនរបស់មហាសេដ្ឋីម្នាក់នៃក្រុងពារាណសី, ថ្ងៃមួយ មានការធឿយណាយធុញទ្រាន់ចំពោះគ្រួសារនិងជីវិតរស់នៅដែលពោរពេញទៅដោយតម្រេកតណ្ហាជាមួយពួកស្រីជាច្រើន កើនឡើងកាន់តែខ្លាំងឡើង១ ។ គាត់ក៏បានលួចរត់ចេញពីផ្ទះ ដោយស្ងប់ស្ងាត់មិនឱ្យអ្នកណាម្នាក់ដឹង ហើយក៏បានជួបនឹងព្រះពុទ្ធជាម្ចាស់នៅតាមផ្លូវ ។ ដោយបានស្តាប់ធម៌ដែលព្រះពុទ្ធបរមគ្រូទ្រង់សំដែងនិងដោយបានយល់ជាក់ច្បាស់អំពីផលប្រយោជន៍នៃការប្រតិបត្តិ ធម៌ គាត់ប្រែជាមានចិត្តសប្បាយរីករាយ រួចបានថ្វាយបង្គំទូលសុំសេចក្តីអនុញ្ញាតលះបង់ផ្ទះសំបែងដើម្បីបានប្រតិបត្តិធម៌ជាមួយព្រះពុទ្ធជាអម្ចាស់ ។ នៅថ្ងៃជាមួយគ្នានោះ, បិតាយសដែលបានតាមរកកូនក៏បានជួបនឹងព្រះពុទ្ធ ហើយបានទូលសួរព្រះអង្គអំពីកូនរបស់គាត់ ។ ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់បានទេសនាទូន្មានគាត់នូវបញ្ហាធម៌ដ៏សមរម្យ ញ៉ាំងគាត់ឱ្យបានយល់ធម៌, ពេលនោះ គាត់កើតមានបីតិសប្បាយរីករាយក្នុងធម៌ រួចហើយក៏យល់ព្រមអនុញ្ញាតឱ្យកូនមកបួស ។



132-After hearing the Buddha preach, the rich man was very happy and he also took refuge in the Buddha-dharma, and he expressed his wish to be a Buddhist lay follower and follow life after life the Buddha-dharma. He then invited the Buddha and Yasas to his home on the next morning for an offering. Later, four Yasas' best friends also left home and became Buddhist bhikkhus and they, in turn, led fifty young men of noble families to become Buddhist bhikkhus. Without the need of the Buddha's supervision, they all learned diligently and practiced strictly and before long, they all attained the stage of arhant.

១៣២-ក្រោយពីបានស្តាប់ព្រះធម៌ព្រះអង្គ, សេដ្ឋីមានបីតិបាមោជ្ជៈសប្បាយក្រៃលែង, រួចគាត់ក៏បានយកព្រះពុទ្ធ ព្រះធម៌ជាទីពឹងទីរលឹក, បានតាំងសេចក្តីប្រាថ្នាសុំឱ្យបានជាឧបាសកម្នាក់ក្នុងព្រះពុទ្ធសាសនានិងបានគោរពប្រតិបត្តិតាមព្រះពុទ្ធគ្រប់១ជាតិ ។ បន្ទាប់មក គាត់បាននិមន្តព្រះសម្ពុទ្ធនិងព្រះយសភិក្ខុទៅផ្ទះរបស់គាត់ដើម្បីទទួលភត្តនៅវេលាព្រឹកស្អែក ។ ក្រោយមកទៀត . កល្យាណមិត្ត៤នាក់របស់ព្រះយសក៏បានមកបួសជាភិក្ខុតាមព្រះយស ហើយភិក្ខុទាំង៤អង្គបាននាំសំលាញ់៥០នាក់មកពីត្រកូលអភិជនមកបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនាផងដែរ ។ ដោយពុំចាំបាច់មានការត្រួតត្រាមើលពីព្រះពុទ្ធជាម្ចាស់ទាល់តែសោះ, ភិក្ខុទាំងឡាយខិតខំព្យាយាមសិក្សារៀនសូត្រដោយព្រះទ័យទុកដាក់និងប្រតិបត្តិដ៏ហ្មត់ចត់បំផុត, មិនយូរប៉ុន្មានពួកភិក្ខុទាំងអស់ក៏បានសំរេចជាព្រះអរហន្តគ្រប់១អង្គ ។



133- When the Buddha had sixty bhiksus among his disciples, he held a meeting directing the bhiksus to propagate the dharma. The Buddha said: "Bhikkhus! I have been released from all the bondages of mankind and devas, and you have been released also. Now you are going to propagate the Dharma to other places to give more people the chance of having the same benefit and happiness. No two of you should go the same way. Be sure to spread the dharma to all places far and near so that human life may be purified and brightened. There are people in the world who have light passion and little desire. To such people ,missing the apportunity to hear dharma means great lost of benefit. there are people ready for dharma, and they will be able to understand it clearly. I myself will go out to preach at Uruvilva."

១៣៣-នៅពេលដែលព្រះពុទ្ធទ្រង់បានភិក្ខុសាវ័ក៦០អង្គ. ព្រះអង្គទ្រង់ប្រារព្ធកិច្ចប្រជុំមួយដើម្បីឱ្យភិក្ខុទាំងអស់និមន្តទៅផ្សព្វផ្សាយព្រះធម៌ ។ ព្រះអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ! តថាគតបានរួចរំដោះផុតពីចំណងទាំងឡាយនៃមនុស្សនិងទេវតាហើយ. អ្នកទាំងឡាយក៏ដូច្នោះដែរ ។ ឥឡូវនេះ ចូរអ្នកទាំងឡាយទៅផ្សព្វផ្សាយព្រះធម៌នៅតាមតំបន់ផ្សេងៗ ដើម្បីឱ្យប្រជាជនកាន់តែច្រើនឡើងៗទៀតមានឱកាសទទួលយកនូវប្រយោជន៍និងសេចក្តីសុខដូចគ្នា ។ អ្នកមិនត្រូវត្រាច់ទៅមានគ្នាពីរនាក់ក្នុងផ្លូវតែមួយទេ ។ ចូរខំផ្សាយព្រះធម៌ទៅគ្រប់ទិសទីទាំងអស់ ដើម្បីឱ្យមនុស្សទាំងឡាយអាចបានដុះខាត់សំអាតចិត្តនិងទទួលនូវពន្លឺព្រះធម៌ ។ មានមនុស្សខ្លះក្នុងលោកសន្និវាសនេះ ជាអ្នកមានកាមកិលេសស្រាលស្តើងនិងតណ្ហាតិច ។ មនុស្សបែបនោះ កាលបើមិនបានស្តាប់ព្រះធម៌ទេ មានន័យថា គេនឹងត្រូវខាតបង់ប្រយោជន៍ដ៏ធំធេង ។ គេជាមនុស្សរង់ចាំតែព្រះធម៌ប៉ុណ្ណោះ ហើយគេនឹងបានយល់ព្រះធម៌យ៉ាងច្បាស់ ។ ចុះឱ្យតថាគតទៅសំដែងនៅឧរុវេលប្រទេស " ។



134- After the Buddha had sent out, for the first time, sixty of his arhant disciples to preach at various places, he left Mrgadava and journeyed toward Magadha in the south-east and finally arrived at Uruvilva village. He took up residence at the place of the knot-hair cult, a group of a thousand people, the leaders of whom were the three Kasyapa brothers. In order to break through their wrong views completely, the Buddha expounded to their leaders, basic Buddha-dharma which he had recently realized. After hearing the Buddha's sermon, they all were full of joy and made a request to leave home to become Buddhist monks. The three Kasyapa brothers and the thousand followers all became arhants later.

១៣៤-បន្ទាប់ពីព្រះបរមគ្រូទ្រង់បានបញ្ជូនព្រះអរហន្តសាវ័កទាំង៦០អង្គទៅសំដែងធម៌នៅតាមស្រុកតូចធំនិតមរាជធានីផ្សេងៗរួចហើយ. ព្រះអង្គទ្រង់ក៏យាងចេញពីព្រៃមិគទាយវន និមន្តឆ្ពោះទៅនគរមគធៈប៉ែកខាងទិសនិរតី បានទៅដល់ភូមិមួយឈ្មោះឧរុវេលា ។ ព្រះអង្គទ្រង់បានគង់នៅត្រង់កន្លែងរបស់ពួកអ្នកកាន់ប្រពៃណីបួងសក់ ‹ ព្រាហ្មណ៍ › ជាក្រុមមួយដែលមានមនុស្ស១ពាន់នាក់ .គ្រូនៃព្រាហ្មណ៍ទាំងនោះគឺ **កស្សបៈ** ទាំង៣ដែលជាបងប្អូននឹងគ្នា ។ ដើម្បីបំបាក់នូវទិដ្ឋិយល់ខុសរបស់ព្រាហ្មណ៍ទាំងឡាយឱ្យបាក់ខ្ទេចខ្ទី. ព្រះវិជិតមារជាម្ចាស់ទ្រង់សំដែងធម៌ ពន្យល់ដល់ជនជាគ្រូរបស់ព្រាហ្មណ៍ទាំងនោះនូវគោលធម៌ដែលព្រះអង្គទើបនឹងបានត្រាស់ដឹងថ្មីៗ ។ ក្រោយពីបានស្តាប់ព្រះធម៌ទេសនារបស់ព្រះអង្គចប់ ជនទាំងឡាយមានចិត្តពេញទៅដោយបីតិសប្បាយរីករាយ ហើយបានក្រាបថ្វាយបង្គំទូលសុំបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា ។ មិនយូរប៉ុន្មាន. កស្សបទាំង៣ និងសិស្សទាំង១ពាន់នាក់ក៏បានសំរេចធម៌ជាព្រះអរហន្តទាំងអស់អង្គ ។



135-Then the Buddha took his arhant disciples and went to Rajagrha to fulfill his promise to King Bimbisara to teach and enlighten the people of Magadha. Upon arriving at Rajagrha, Buddha and his disciples resided at Palm Garden; and with a fully compassionate heart, he preached in various ways to cause King Bimpisara and his people to comprehend and they expressed their own wish to be the Buddha's disciples.

១៣៥-បន្ទាប់មក ព្រះបរមសាស្តាទ្រង់នាំព្រះអរហន្តទាំងអស់និមន្តទៅកាន់នគររាជគ្រឹះ ដើម្បីបំពេញតាមការសន្យារបស់ព្រះអង្គថ្វាយព្រះបាទពិម្ពិសារ ដើម្បីបង្រៀនដល់ជនទាំងឡាយក្នុងដែនមគធៈឱ្យបានយល់ដឹងព្រះធម៌ ។ កាលបើបានដល់នគររាជគ្រឹះហើយ . ព្រះពុទ្ធព្រមទាំងសាវ័កទាំងអស់ទ្រង់គង់នៅក្នុងសួនតាលវ័ន (ព្រៃត្នោត) ដោយព្រះទ័យពោរពេញទៅដោយព្រះមហាករុណា. ព្រះអង្គទ្រង់សំដែងព្រះធម៌តាមរបៀបផ្សេងៗជាច្រើន ធ្វើឱ្យព្រះបាទពិម្ពិសារនិងប្រជារាស្ត្រព្រះអង្គបានយល់ដឹងនូវធម៌និងចូលចិត្តគ្រប់ៗគ្នា ហើយជនទាំងឡាយបានប្រគល់កាយថ្វាយខ្លួនសុំធ្វើជាបរិស័ទរបស់ព្រះអង្គ ។



**136-King Bimpisara** told the Buddha that when he was a crown prince, he had the wish that besides being a king he would also someday, be the first among all kings to hear teaching of the Buddha, who had attained the supreme enlightenment. Now all his wishes had been realized, and so he decided to take refuge in the **Buddha**, the **Dharma** and the **Sangha** and formally become a grhapati (i.e, a Buddhist follower at home). Later he offered to donate **Venuvana**, a park in a bamboo grove, to the Buddha as a residence for the bhiksus. Hence **Venuvana** became the earliest monastery in Buddhist history.

១៣៦-ព្រះបាទពិម្ពិសាររាជទ្រង់ធ្លាប់បានទូលព្រះពុទ្ធជាម្ចាស់ថា កាលពីព្រះអង្គនៅជារជ្ជទាយាទ ទ្រង់បានធ្វើសេចក្តីប្រាថ្នាថា ក្រៅពីឋានៈជាព្រះមហាក្សត្រ នៅថ្ងៃណាមួយខាងមុខ សូមឱ្យព្រះអង្គបានជាអ្នកទីមួយក្នុងចំណោមមហាក្សត្រទាំងឡាយដែលនឹងបានស្តាប់ធម៌របស់ព្រះពុទ្ធ ជាបុគ្គលបានត្រាស់ដឹងនូវធម៌ដ៏ប្រសើរបំផុតនេះ ។ ពេលនេះ រាល់សេចក្តីបំណងរបស់ព្រះអង្គបានសំរេចដូចប្រាថ្នា. ដូច្នេះព្រះអង្គទ្រង់ក៏សំរេចព្រះទ័យយកព្រះពុទ្ធ ព្រះធម៌និងព្រះសង្ឃជាទីពឹងទីរលឹក ហើយក៏ដល់នូវភាពជាគហបតីមួយរូប (គឺជាពុទ្ធសាសនិកមួយរូបដែលមានការគ្រប់គ្រងផ្ទះ) ។ ក្រោយមកទៀត ព្រះមហារាជបានថ្វាយដីឧទ្យានមួយកន្លែងឈ្មោះ **វេឡុវ័ន**. ជាឧទ្យានព្រៃឫស្សី .ដល់ព្រះពុទ្ធជាម្ចាស់ដើម្បីធ្វើជាវត្តសំរាប់ភិក្ខុសង្ឃគង់នៅ ។ ព្រោះហេតុដូច្នោះ . ឧទ្យានវេឡុវ័ន ក៏បានក្លាយជាវត្តមួយមុនគេបង្អស់ក្នុងព្រះពុទ្ធសាសនា ។



137-One morning, on his way from Venuvana to Rajagrha to accept his daily ration of food, the Buddha encountered a youth who was wet through and through, looking as if he had just emerged from the water. The young man stood in the middle of the road and bowed one after the other to the east, south, west and north; then he raised his head and saluted heaven, and at the last, knelt down and saluted the earth. Then he cast grain in all the directions he had saluted.

១៣៧-មានព្រឹកមួយនោះ. ពេលព្រះអង្គកំពុងព្រះដំណើរពីវត្តវេឡុវ៉នទៅក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត្រ. ព្រះបរមគ្រូទ្រង់បានជួបមាណពម្នាក់ដែលខ្លួនគេទាំងមូលទទឹកជោគគ្មានសល់ មើលទៅហាក់ដូចជាគាត់ទើបឡើងមកពីក្នុងទឹក ។ មាណពនោះឈរចំកណ្ដាលផ្លូវ រួចឱនថ្វាយបង្គំគោរពទិសទាំង៤. ខាងកើត. ខាងត្បូង . ខាងលិច និង ខាងជើង. បន្ទាប់មក គាត់ងើបងើយក្បាលឡើងលើគោរពសំពះដល់ស្ថានលើ ហើយចុងក្រោយលុតជង្គង់ចុះថ្វាយបង្គំគោរពស្ថានក្រោម ។ បន្ទាន់មកទៀតគាត់ក៏បានរោយគ្រាប់ធញ្ញជាតិទៅគ្រប់ទិសទាំងអស់ដែលគាត់បានថ្វាយបង្គំ ។



138-The Buddha watched the youth finishing his strange ritual in the thoroughfare and asked him why he did all these things. The youth replied that he observed according to the directions that his father had given him when he died and that the purpose of performing this ritual every morning was to prevent an evil thing from befalling him from any direction. After hearing his answer, the Buddha said to the youth: "It is very good that you can honestly follow your father's last instructions! But the real meaning of your father's instructions and the ritual he wished you to observe is quite differant from what you think."

១៣៨-ព្រះបរមសាស្ដាចារ្យទ្រង់ឈរសំលឹងមើលមាណពនោះរហូតដល់ចប់ប្រពៃណីដ៏ចម្លែករបស់គាត់នៅតាមផងផ្លូវថ្នា រួចព្រះអង្គទ្រង់សួរមាណពថា ហេតុអ្វីបានជាគាត់ធ្វើដូច្នេះ ។ មាណពឆ្លើយថា បានជាគាត់ថ្វាយបង្គំ គឺធ្វើទៅតាមបណ្ដាំរបស់ឪពុកគាត់ដែលបានផ្ដាំកាលពីគាត់ហៀបនឹងស្លាប់ទៅ ហើយគោលបំណងនៃការប្រតិបត្តិទំនៀមទម្លាប់នេះជារៀងរាល់ព្រឹក គឺដើម្បីការពាររាល់គ្រោះកាចចង្រៃទាំងឡាយពីទិសណាទីមួយកុំឱ្យកើតមានដល់គាត់ ។ ក្រោយពីទ្រង់បានស្ដាប់ឮដូច្នេះមក. ព្រះអង្គទ្រង់ត្រាស់ថា "ជាការល្អប្រពៃពេកណាស់ ដែលអ្នកចេះគោរពតាមដ៏ស្មោះអស់ពីចិត្តនូវបណ្ដាំចុងក្រោយរបស់ឪពុកអ្នក! ក៏ប៉ុន្តែន័យពិតនៃបណ្ដាំរបស់ឪពុកអ្នកនិងពិធីទំនៀមទម្លាប់ដែលគាត់ចង់ឱ្យអ្នកគោរពប្រតិបត្តិតាមនោះ គឺប្រាកដជាមានន័យល្អជាងអ្វីដែលអ្នកយល់ឃើញ" ។



139- "Your father told you to salute the east and spread grain. What he really meant was that you should respect and support those who have shown kindness or any kind of favor to you– that is, your parents. By saluting the south, you should understand that your father wanted you to be aware that you should respect and treat your teachers well. Saluting the west means loving and protecting your wife and children. Saluting the north means honoring your friends and relatives. By your saluting the heavens above, your father meant that you should pay reverence to Sramanas, Bramanas and saints."

១៣៩- " ឪពុករបស់អ្នក ប្រាប់អ្នកឱ្យថ្វាយបង្គំទិសខាងកើតហើយបាចគ្រាប់ធញ្ញជាតិ ។ អ្វីដែលគាត់ចង់និយាយនោះគឺថា អ្នកគួរថ្វាយបង្គំគោរពប្រតិបត្តិនិងចិញ្ចឹមរក្សាជនណាដែលមានមេត្តាករុណាឬការស្រលាញ់ចំពោះអ្នកគឺឪពុកម្តាយរបស់អ្នក ។ ការដែលគាត់ឱ្យថ្វាយបង្គំទិសខាងត្បូង. ចូរយល់ថា ឪពុកអ្នកចង់ឱ្យអ្នកដឹងថា អ្នកត្រូវគោរពយកចិត្តទុកដាក់និងប្រតិបត្តិបំរើគ្រូរបស់អ្នកឱ្យបានល្អ ។ ការឱ្យថ្វាយបង្គំទិសខាងលិច មានន័យថា ឱ្យចេះស្រលាញ់ថ្នាក់ថ្នមនិងរក្សាការពារបុត្រភរិយារបស់ខ្លួនឱ្យបានល្អ ។ ការឱ្យថ្វាយបង្គំទិសខាងជើងមានន័យថា ឱ្យចេះស្រលាញ់សន្ដោសប្រណីដល់មិត្តសំលាញ់និងញាតិសាលោហិតទាំងឡាយរបស់អ្នក ។ ការឱ្យថ្វាយបង្គំទិសខាងលើនោះ. ឪពុករបស់អ្នកចង់និយាយថា ឱ្យអ្នកគោរពប្រណិបត្តិដល់ពួកសមណៈ ពួកព្រាហ្មណ៍និងព្រះអរហន្តទាំងឡាយ " ។



140- "To salute the earth below means treating others kindly, not only people, but also animals and the lowest creatures alike, without discrimination. Your father had all this in mind, so he told you to salute in this manner in order to prevent evil from falling upon you from any direction whatsoever." The Buddha then expounded to the youth, whose name was **Sujata**, what one should do for himself and others in order to bring happiness and a better life to everybody now and in the future. The Buddha also instructed **Sujata** not to kill, not to steal, not to commit adultery, not to utter false speech, and not to partake of any intoxicant– that is, he gave him the well-known five precepts.

១៤០- "ការថ្វាយបង្គំទិសខាងក្រោម មានន័យថា ធ្វើអ្វីមួយទៅលើអ្នកដទៃត្រូវប្រកបដោយចិត្តមេត្តា. មិនមែនតែចំពោះមនុស្សទេ ថែមទាំងពពួកសត្វធំតូចទាំងឡាយ ដោយមិនមានការប្រកាន់រើសអើងអ្វីឡើយ ។ ឪពុកអ្នកមានធម៌នេះនៅក្នុងចិត្ត. ដូច្នេះហើយបានជាគាត់ប្រាប់អ្នកឱ្យគោរពប្រតិបត្តិតាមអាការៈយ៉ាងនេះដើម្បីការពាររាំងអំពើបាបអកុសលអំពីទិសផ្សេងៗកុំឱ្យកើតមានដល់អ្នកបាន" ។ បន្ទាប់មក ព្រះពុទ្ធអង្គទ្រង់សំដែងធម៌ប្រោសមាណព. ដែលមានឈ្មោះថា **សុជាត** នូវអ្វីដែលបុគ្គលគួរធ្វើសំរាប់ខ្លួនឯងផង និងសំរាប់អ្នកដទៃផង ដើម្បីនាំមកនូវសេចក្តីសុខចំរើននិងការរស់នៅដ៏ប្រសើរដល់ជនទាំងឡាយ ទាំងក្នុងពេលបច្ចុប្បន្ននិងបរលោកខាងមុខ ។ ព្រះដ៏មានជោគទ្រង់បានបង្រៀនសុជាតនូវសិក្ខាបទដ៏អស្ចារ្យទាំង៥គឺ មិនត្រូវសំលាប់បំបាត់ជីវិត មិនត្រូវលួច មិនត្រូវប្រព្រឹត្តិខុសក្នុងកាម មិនត្រូវពោលពាក្យកុហក់ និងមិនត្រូវសេពគ្រឿងញៀន គ្រឿងស្រវឹងទាំងឡាយ ។



141-Afterwards the Buddha advised him to work and earn his living diligently, to take good care of the wealth he would amass, and at the same time, to avoid being avaricious and to use his wealth properly, not only for his own benefit. The Buddha instruc- ted him to divide his money into four portions: one part should be used for the support of his family; one part for the expansion of his business; one part to help the poor and needy people of society; and the remaining part should be saved for any emergency. Sujata listened reverently to the Buddha's instruction and later requested the Buddha to accept him as a disciple. For the rest of his life he saluted the six directions in the manner and with the understanding that the Buddha had taught him.

១៤១-ជាចុងក្រោយបន្ទាប់តមកទៀត . ព្រះបរមគ្រូទ្រង់ប្រទានដំបូន្មានដល់គាត់ឱ្យខិតខំប្រកបរបរចិញ្ចឹមជីវិតដោយយកចិត្តទុកដាក់ . ថែរក្សាឱ្យបានល្អនូវទ្រព្យសម្បត្តិដែលរកបានមក. មិនត្រូវមានមច្ឆរិយៈ. ត្រូវចេះចាត់ចែងប្រើប្រាស់ទ្រព្យរបស់ខ្លួនដោយប្រពៃ. មិនមែនសំរាប់តែប្រយោជន៍ខ្លួនប៉ុណ្ណោះទេ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងប្រាប់ឱ្យគាត់ចេះបែងចែកប្រាក់ដែលរកបានមកជាបួនចំណែកគឺ: មួយផ្នែកប្រើសំរាប់ចិញ្ចឹមគ្រួសារ. មួយផ្នែកសំរាប់ជាទុនរកស៊ី . មួយផ្នែកទៀត សំរាប់ជួយសង្គ្រោះជនក្រីក្រលំបាកទុគ៌តក្នុងសង្គម. ហើយចំណែកដែលនៅសល់ចុងក្រោយ ត្រូវសន្សំទុកសំរាប់ពេលមានគ្រោះអាសន្នយប់ថ្ងៃណាមួយ ។ សុជាត ស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ដោយគោរព ហើយក៏ក្រាបបង្គំទូលសុំឱ្យព្រះអង្គទទួលយកគាត់ធ្វើជាសាវ័កមួយរូប ។ ពេញមួយជីវិតរបស់គាត់ គាត់គោរពប្រតិបត្តិទិសទាំង៦តាមដែលព្រះអង្គបានបង្រៀន ។



142- During the Buddha's sojourn in the vicinity of Rajagrha, there was a well-known master of one of the heretical schools, whose name was Samjayan Vairatiputra, living in the area. He had about two hundred pupils, and among them Upatisya and Kolita were the most learned. These two pupils, however, were not satisfied with what their master had taught them, and they hoped to learn that higher and more profound knowledge that lead to no birth and no death. They were the best of friends, and their education and knowledge were on the same level. So they made an agreement that each would try his best with his intelligence and training to search for the highest knowledge, and that as soon as one had found it, he would immediately inform the other.

១៤២-ក្នុងកំឡុងពេលគង់នៅជាបណ្តោះអាសន្នរបស់ព្រះពុទ្ធនៅជាយក្រុងរាជគ្រឹះនោះ. មានគ្រូម្នាក់ឈ្មោះ **សញ្ជ័យ** ជាគ្រូប្រចាំសាលាមួយក្នុងចំណោមសាលាលទ្ធិដទៃទៀត មានកេរ្តិ៍ឈ្មោះល្បីល្បាញណាស់ រស់នៅក្នុងនិគមនោះ ។ គាត់មានសិស្សគណប្រហែលជាពីររយនាក់ ហើយក្នុងចំណោមសិស្សទាំងអស់មាន **ឧប-តិស្ស:** និង **កោលិត:** ជាសិស្សមានប្រាជ្ញាវាងវៃបំផុត។ ទោះជាយ៉ាងនេះក្តី .សិស្សទាំងពីរនាក់នៅតែមិនទាន់អស់ចិត្តនឹងអ្វីដែលគ្រូរបស់ខ្លួនបានបង្រៀន គេមានបំណងចង់រៀនសូត្រយកចំណេះវិជ្ជាមានគំរិតជ្រាលជ្រៅនិងខ្ពង់ខ្ពស់ជាងនេះថែមទៀត ដែលនឹងនាំទៅរកការឈប់កើតនិងឈប់ស្លាប់ទៀត ។ ពួកគេជាកល្យាណមិត្តនឹងគ្នា ហើយការសិក្សានិងការចេះដឹងរបស់គេមានគំរិតស្មើគ្នា ។ ដូច្នេះ អ្នកទាំងពីរបានសន្យានឹងគ្នាថា ម្នាក់ៗត្រូវខិតខំព្យាយាមអស់ពីសមត្ថភាពតាមបញ្ញាផងខ្លួននិងត្រូវខំហ្វឹកហ្វឺនស្រាវជ្រាវរកនូវមោក្ខធម៌ ហើយថាបើនរណាបានជួបមុន អ្នកនោះត្រូវប្រាប់ដល់អ្នកម្នាក់ទៀតភ្លាម ។



143-One morning, as Upatisya was walking along the road toward Rajagrha, he saw a Sramana holding out his food bowl. The manner of this Sramana was so elegent, neat, pe- aceful and serious, even when he was begging for food, that Upatisya was very much astonished. The nearer he approached to the Sramana, the stronger became his wonder and, at the same time, his admiration, because he saw flowing from his countenance unlimited peace and happiness. Apparently this Sramana had cut himself away from all fear. Upatisya thought: " This Sramana must have found the ultimate truth that we are pursuing, or he must be, at least, a disciple of one who has found the ultimate truth. I am anxious to know who his master is and what his master teaches. I must follow him. I must find the truth.

១៤៣- នៅវេលាព្រឹកមួយ ពេលដែលឧបតិស្សៈកំពុងដើរតាមដងផ្លូវឆ្ពោះទៅក្រុងរាជគ្រឹះ គាត់បានឃើញព្រះសមណៈមួយអង្គកំពុងនិមន្តបិណ្ឌបាត ។ សមណៈអង្គនេះមានឥន្ទ្រិយ៍ប្លែក ស្រគតស្រគំថ្លៃថ្នូនិងពោរពេញទៅដោយសុខសន្តិភាពពន់ពេកណាស់ . សូម្បីពេលលោកកំពុងនិមន្តបិណ្ឌបាត ក៏អាការៈលក្ខណៈនោះធ្វើឱ្យឧបតិស្សៈចាប់អារម្មណ៍យ៉ាងខ្លាំង ។ គាត់ដើរកាន់តែជិតដល់ភិក្ខុអង្គនោះ គាត់ចាប់អារម្មណ៍និងនឹកស្ងើចសសើរក្នុងចិត្តកាន់តែខ្លាំងឡើងៗ ព្រោះគាត់បានឃើញទឹកមុខរបស់លោកហូរស្រោចស្រប់ពេញទៅដោយសេចក្តីសុខ និងសន្តិភាពមិនអាចនឹងពណ៌នាបាន ។ តាមមើលទៅសមណៈអង្គនេះពិតជាបានកាត់ផ្តាច់ខ្លួនលោកចេញផុតពីសេចក្តីភ័យខ្លាចទាំងអស់ហើយ( មោក្ខធម៌ ) ។ ឧបតិស្សៈគិតថាៈ "សមណៈអង្គនេះលោកច្បាស់ជាបានរកឃើញនូវបរមត្ថសច្ចធម៌ដែលយើងកំពុងតែតាមរកហ្នឹងហើយមើលទៅ ឬយ៉ាងហោចណាស់ក៏លោកជាសាវ័កនៃសាស្តាចារ្យណាម្នាក់ដែលរកបានឃើញនូវបរមត្ថសច្ចៈមិនខាន ។ ខ្ញុំចង់ដឹងណាស់ថាតើអ្នកណាជាគ្រូរបស់លោក ហើយគ្រូរបស់លោកបង្រៀនធម៌អ្វី ។ អាត្មាអញត្រូវតែដើរតាមលោកសិនអាត្មាអញ ត្រូវស្វែងរកសច្ចធម៌ឱ្យត្រាតែបាន !" ។



144- But Upatisya felt that it was improper to question him while he was accepting alms, so he followed him at a distance until he had finished his daily accepting alms and had left the city of Rajagrha. Then he came forward, reverently gave his regards as if he were talking to an old acquaintance, and then asked him: "Venerable Master! Your manner is so peaceful and your look so serene that I should really like to know who your teacher is. Under whose direction did you leave home and take up the pure life? What is the name of your teacher and what did he teach you ?"

១៤៤- តែឧបតិស្សៈគិតថា មិនគួរសួរលោកពេលកំពុងនិមន្តបិណ្ឌបាតទេ ដូច្នេះគាត់ចេះតែដើរតាមក្រោយលោករហូតទាល់តែដល់ពេលលោកឈប់បិណ្ឌបាត ហើយនិមន្តចេញពីក្រុងរាជគ្រឹះវិញ ។ ពេលនោះគាត់ដើរសំដៅទៅរកព្រះភិក្ខុ. ធ្វើការសំណេះសំណាលសាកសួរដោយសេចក្តីគោរពហាក់បីដូចជាគាត់កំពុងនិយាយទៅកាន់មនុស្សដែលធ្លាប់ស្គាល់គ្នាពីមុនមក. រួចហើយគាត់សួរថា "បពិត្រ លោកម្ចាស់ដ៏ចំរើន! ឥន្ទ្រិយ៍របស់ព្រះអង្គពោរពេញទៅដោយសន្តិភាពណាស់ មើលទៅលោកម្ចាស់ស្ងប់ស្ងាត់ល្អណាស់ដែលធ្វើឱ្យខ្ញុំចង់ដឹងចង់ស្គាល់ថា តើគ្រូរបស់លោកម្ចាស់ជាអ្នកណា ។ បានស្តាប់ធម៌របស់បុគ្គលណា បានជាលោកម្ចាស់ចាកចេញពីផ្ទះមករស់នៅក្នុងជីវិតដ៏បរិសុទ្ធបែបនេះ ? តើលោកគ្រូរបស់លោកម្ចាស់ឈ្មោះអ្វី ហើយគាត់បង្រៀនអ្វីដល់លោកម្ចាស់ ?" ។



145- The Sramana answered smilingly: "Venerable Master! Let me tell you that there is a great Sramana of the Sakya clan, who gave up his throne and left home to practice pure living. I left my home also to practice with this great Sramana. The Buddha is my teacher, and I practice in accordance with his *teaching.*" Upatisya thought to himself that perhaps he could learn the dharma of no-birth and no-death, which he and his friend Kolita had been pursuing for a long time, from this great Sramana. So he inquired anxiously: "Venerable Master what is this teaching of the Buddha? What has your master taught you? I should like very much to know its meaning."

១៤៥-ព្រះភិក្ខុអង្គនោះមានថេរដីការតបដោយញញឹមថា " ម្ចាលឧបាសកដ៏ចំរើន ! ចាំអាត្មាជំរាបឱ្យបានដឹងគឺមានមហាសមណៈដ៏អស្ចារ្យមួយព្រះអង្គមកពីសក្យត្រកូលដែលលះបង់រាជបល្ល័ង្ក ហើយចាកចេញពីរាជវាំងមកប្រព្រឹត្តប្រតិបត្តិធម៌ក្នុងជីវិតរស់នៅដ៏បរិសុទ្ធ ។ ចំណែកអាត្មានេះ ក៏បានចាកចេញពីផ្ទះមកប្រតិបត្តិធម៌ជាមួយនឹងមហាសមណៈនោះដែរ។ **ព្រះពុទ្ធ** ជាគ្រូរបស់អាត្មា. អាត្មាប្រតិបត្តិតាមការបង្រៀនរបស់ព្រះអង្គ"។ ឧបតិស្សៈនឹកគិតក្នុងចិត្តថា មើលទៅប្រហែលជាលោកអង្គនេះបានរៀននូវអមតធម៌ (ធម៌ដែលនាំឱ្យលែងមានការកើតនិងការស្លាប់)ពីមហាសមណៈអង្គនោះហើយ ជាធម៌ដែលអាត្មាអញនិងសំលាញ់កោលិតៈកំពុងតែតាមស្វែងរកអស់ពេលជាយូរអង្វែងមក ។ ដូច្នេះ មិនបង្អង់យូរគាត់ក៏សួរទៀតថា "លោកម្ចាស់ដ៏ចំរើន! តើព្រះពុទ្ធបង្រៀនធម៌អ្វី? តើគ្រូលោកម្ចាស់បង្រៀនធម៌អ្វីដល់លោកម្ចាស់? ខ្ញុំព្រះករុណាចង់ដឹងអត្ថន័យ របស់ធម៌នេះខ្លាំងណាស់ " ។



146- The Sramana answered him in a mild tone: "It has not been very long time since I left home to learn and practice with the Buddha. Therefore , I have not learned very much about the Buddha's teaching, and thus I am not able to explain it to you fully in detail. But if you would like to know only the general content of his teaching, I could tell you about it in a few sentences. Upatisya replied hastily: "I should very much like to know; please tell me just the general contents!" The Sramana said: "Fine! Now listen! The Buddha said 'All things arise from causes and conditions; all things also vanish because of causes and conditions.'. Our great Buddha often said so."

១៤៦-ព្រះសមណៈមានថេរដីការតិចៗតបថា "មិនជាយូរពេកទេតាំងពីអាត្មាបានចេញពីផ្ទះមកសិក្សាប្រតិបត្តិជាមួយព្រះពុទ្ធជាម្ចាស់មក ។ ហេតុដូច្នេះ, អាត្មាភាពក៏មិនទាន់បានចេះដឹងជ្រៅជ្រះច្រើនអំពីការបង្រៀនរបស់ព្រះអង្គដែរ .ដូចនេះ អាត្មាមិនអាចនឹងសំដែងពន្យល់ធម៌នេះដល់លោកម្ចាស់ឱ្យពិស្តារបានទេ ។ តែល្ហើយ បើអ្នកចង់ដឹងអំពីគោលនៃធម៌ក្នុងការបង្រៀនរបស់ព្រះអង្គ. អាត្មាអាចសំដែងប្រាប់លោកម្ចាស់នូវធម៌នោះបានពីរ-បីឃ្លា ។ ឮដូច្នោះមិនបង្អង់យូរ. ឧបតិស្សៈឆ្លើយតបវិញយ៉ាងរហ័សថា " លោកម្ចាស់ . ខ្ញុំព្រះករុណាចង់ដឹងខ្លាំងណាស់ . សូមលោកម្ចាស់ព្រះមេត្តាប្រាប់ខ្ញុំករុណាតែខ្លឹមសារនៃគោលធម៌ប៉ុណ្ណោះទៅបានហើយ!" ។ លោកមានថេរដីការថា " បើអ៊ីចឹងល្អណាស់! ឥឡូវនេះ ចូរអ្នកស្តាប់! ព្រះពុទ្ធជាម្ចាស់សំដែងថា: 'ធម៌ទាំងឡាយសុទ្ធតែកើតឡើងអំពីហេតុនិងបច្ច័យ ហើយធម៌ទាំងឡាយរលត់ទៅវិញក៏ដោយសារហេតុនិងបច្ច័យផងដែរ' ព្រះពុទ្ធបរមគ្រូជាម្ចាស់ទ្រង់តែងសំដែងយ៉ាងនេះជារឿយៗ " ។



147– As Upatisya heard these words in the shadow of the gate to the city, the radiance of Buddha-Dharma was already lightening up his mind: "All things which had come to pass or were coming to pass would, without any possible exception, go to destruction and extinction; only those things which did not arise or come to pass, thus avoiding death or destruction, were free." Upatisya said to the Sramana, "If you have learned this kind of knowledge from your master, you have certainly already gotten rid of the fear of death, and this goal has not yet been achieved by anyone else. "After having said this, he thanked the Sramana profoundly. He then asked him where he might find the Buddha. Then he departed, intending to pass the good news on to Kolita, that he himself had already obtained the dharma of non-arising and non-extinction.

១៤៧-ក្នុងខណៈដែលឧបតិស្សៈបានស្តាប់ថេរដីការលោកនៅត្រង់មួប់ទ្វាររបងចូលទៅកាន់រាជធានីដូច្នោះហើយ. ធម្មបីតិធ្វើឱ្យគាត់ភ្លឺស្វាងឡើងប្រាកដក្នុងចិត្តគឺ: " ធមិទាំងឡាយដែលបានកើតឡើងរួចហើយ ឬកំពុងកើតមាន នឹងត្រូវព្រាត់ប្រាសវិនាសសាបសូន្យទៅវិញជាធម្មតា ដោយពុំមានការលើកលែងឡើយ . មានតែធមិទាំងឡាយណាដែលមិនទាន់កើតឡើង ឬមិនទាន់មានមកដល់តែប៉ុណ្ណោះទេ ទើបបានគេចផុតពីការស្លាប់ ឬផុតពីការវិនាសព្រាត់ប្រាស់. បានរួចរំដោះ" ។ ឧបតិស្សៈពោលទៅកាន់លោកថាៈ "បើលោកម្ចាស់បានសិក្សាវិជ្ជាបែបនេះពីគ្រូរបស់លោកម្ចាស់ហើយ . លោកម្ចាស់ប្រាកដជាបានទូវអមតធមិរួចជាស្រេចហើយ. ហើយគោលដៅនេះក៏មិនមានបុគ្គលណាមួយបានសំរេចទៀតនៅឡើយ " ។ ក្រោយពីបានពោលយ៉ាងនោះ. គាត់ក៏បានសំដែងការអរព្រះគុណយ៉ាងជ្រាលជ្រៅក្រៃលែងដល់ព្រះសមណៈអង្គនោះ ។ គាត់បានទូលសួររកកន្លែងដែលព្រះបរមសាស្តាគង់នៅ ។ បន្ទាប់មកគាត់ក៏ថ្វាយបង្គំលាចេញទៅ ក្នុងបំណងទៅប្រាប់ដំណឹងល្អនេះដល់សំលាញ់កោលិតៈ ព្រោះខ្លួនគាត់បានទទួលនូវធមិដែលនាំឱ្យលែងមានការកើតនិងការស្លាប់វិនាសសាបសូន្យនោះរួចហើយ ( មោក្ខធមិ ) ។



148- Now Upatisya's face was flowing with the brilliant radiance of joy too just like the face of the sramana who had told him the truth of neither arising nor passing away. When Kolita saw him approaching, he immediately knew that his friend had acquired the utmost joy, so he asked: "My friend! Just look at this bright splendor on your face! You must have found the truth of neither birth nor death, for which we have been searching for a long time. Have you? Upatisya answered jubilantly: "Yes! My friend! I already attained to the dharma of no-birth no-death." Kolita asked eagerly: "How did you do it, my friend? How did you do it?" Upatisya told his friend Kolita about the remarkable sramana he had met and repeated to him the words he had heard.

១៤៨- ពេលនេះ ផ្ទៃមុខរបស់ឧបតិស្សៈ ពោរពេញទៅដោយធម្មបីតិភ្លឺត្រចះត្រចង់ មានបីតិសប្បាយរីករាយដូចព្រះភ័ក្ត្រព្រះសមណៈដែលបានសំដែងប្រាប់នូវអមតធមិដល់គាត់ផងដែរ ។ នៅពេលដែលកោលិតៈបានឃើញគាត់មកដល់. ភ្លាមនោះ គាត់ដឹងថា សំលាញ់របស់គាត់ពិតជាបានសំរេចនូវធមិដែលនាំមកនូវសេចក្តីសុខក្សេមក្សាន្តគ្មានទីបំផុតហើយ. ដោយហេតុនេះ គាត់ក៏សួរថា " នែ៎ សំលាញ់! ចូរមើលទៅមុខរបស់អ្នកមានភាពអស្ចារ្យអ្វីម្ល៉េះ! សំលាញ់ឯងប្រាកដជាបានជួបប្រទះនូវអមតធមិ ដែលយើងទាំងពីរខំស្វះស្វែងរកអស់ពេលដ៏យូរលង់ណាស់មកហើយ ។ អីមែនទេសំលាញ់? " ឧបតិស្សៈឆ្លើយប្រាប់ដោយសោមនស្ស ថាៈ " មែនហើយ! ប្រាកដមែនហើយ! សំលាញ់! ខ្ញុំបានទទួលនូវអមតធមិនោះរួចហើយ" ។ កោលិតៈ ទទូចសួរដោយចង់ដឹងចង់ឮយ៉ាងខ្លាំងថា : " តើឯងធ្វើដូចម្តេច. សំលាញ់ ? តើអ្នកប្រតិបត្តិយ៉ាងណា ? " ។ ឧបតិស្សៈក៏បានប្រាប់ដល់កោលិតៈជាសំលាញ់របស់ខ្លួនអំពីរឿងសមណៈដែលគួរឱ្យកត់សំគាល់មួយអង្គ ដែលគាត់បានជួប ហើយគាត់ក៏បានសំដែងប្រាប់ដល់សំលាញ់របស់គាត់អំពីធមិទាំងឡាយដែលគាត់បានចេះ ។



149-Instantly, **Kolita** also awoke and saw the way. He now realized that what is neither created nor annihilated does not exist among the nature of worldly things produced by sight, sound, smell, taste, touch and ideas; for that which is neither created nor annihilated cannot be either produced or destroyed. Finally, the two of them went to see Buddha and asked him to accept them as bhiksus. Later on they attained to the **Arahant** Fruit and became the Buddha's chief disciples. They were known everywhere for their high wisdom and great supernatural powe under the more familiar names of **Sariputa** and **Maudgalyayana**. The Sramana who had told them the dharma of neither creation nor annihilation was Bhiksu **Asvajit**, and the verse that was handed down became known as the " Verse of Bhikkhu Asvajit."

១៤៩- រំពេចភ្លាមនោះ. កោលិតៈ ក៏បានរលឹកឃើញមាគ៌ានោះផងដែរ( សំរេចសោតាបត្តិផល ) ។ ឥឡូវនេះ គាត់បានដឹងច្បាស់ថា អ្វីៗដែលគេមិនបានបង្កើតឡើង ទាំងមិនបានធ្វើឱ្យសូន្យទៅ មិនមាននៅក្នុងអារម្មណ៍ទាំងឡាយក្នុងលោក ដែលកើតឡើងតាមការឃើញរូប . ឮសំលេង. ធំក្លិន. ដឹងរស. ការពាល់ត្រូវ និងការគិតទេ . ហេតុដូច្នោះ អ្វីមួយដែលគេមិនបានបង្កើតឡើង ទាំងមិនបានធ្វើឱ្យសូន្យទៅនោះ វាមិនអាចកើតមានឡើង ឬរលត់សូន្យទៅវិញបានឡើយ ។ ទីបំផុត ជនទាំងពីរក៏ធ្វើដំណើរទៅជួបនឹងព្រះពុទ្ធជាម្ចាស់ ហើយទូលសុំឱ្យព្រះអង្គទ្រង់បំបួសខ្លួនជាភិក្ខុ ។ មិនយូរប៉ុន្មាន ភិក្ខុទាំងពីរអង្គក៏បានសំរេចផលជាព្រះអរហន្ត ព្រមទាំងមានងារជាព្រះអគ្គសាវ័កដ៏ឆ្នើមរបស់ព្រះពុទ្ធ ។ ភិក្ខុទាំងពីរអង្គមានឈ្មោះបោះសំលេងល្បីល្បាញទៅគ្រប់ទិសទីទាំងអស់ដោយសារព្រះបញ្ញាវាងវៃនិងឫទ្ធានុភាពអស្ចារ្យហួសវិស័យធម្មជាតិ និងថែមទាំងបានទទួលព្រះនាមថ្មីថា **ព្រះសារីបុត្រ** និង **ព្រះមោគ្គល្លាន** ។ ចំណែកព្រះសមណៈដែលបានសំដែងនូវអមតធម៌ដល់ភិក្ខុទាំងពីរអង្គនោះគឺភិក្ខុ **អស្សជិ**. ហើយគាថា ដែលលោកសំដែងនោះ គេដឹងឮមកថា " គាថារបស់ភិក្ខុ **អស្សជិ** " ។



150- When the Buddha was residing at Rajagraha, a conference was held at Venuvana for all the disciples on the full moon day of the third month (Khmer era) of the year. The meeting was initiated by the simultaneous return of the one-thousand two-hundred and fifty arhant disciples from their respective dharma-propagating missions. Since they had not contacted each other and yet had arrived on the same day to report their accomplishments to the Buddha. It was indeed a most unusual occasion and pleased the Buddha as well as his disciples very much.

១៥០-ក្នុងពេលដែលព្រះពុទ្ធបរមគ្រូជាម្ចាស់កំពុងគង់នៅនគររាជគ្រឹះ នៅក្នុងវត្តវេឡុវ័នមានប្រារព្ធធ្វើសង្ឃសន្និបាតមួយដល់ភិក្ខុសង្ឃសាវ័កទាំងឡាយនៅថ្ងៃពេញបូណ៌មីក្នុងឆ្នាំនោះ ។ មហាសន្និបាតប្រារព្ធធ្វើឡើងដោយព្រះអរហន្តសាវ័ក១២៥០អង្គដែលបាននិមន្តត្រឡប់មកពីផ្សព្វផ្សាយព្រះធម៌ក្នុងពេលដំណាលគ្នា ។ ដោយហេតុថា ពួកភិក្ខុទាំងអស់ឥតបានទាក់ទងគ្នាឱ្យដឹងជាមុនឡើយ ហើយក៏បាននិមន្តមកដល់ក្នុងថ្ងៃតែមួយជាមួយគ្នា មកថ្វាយបង្គំទូលអំពីជោគជ័យរបស់ខ្លួនដល់ព្រះពុទ្ធអង្គ. មហាសន្និបាតនោះជាឱកាសមួយដ៏អស្ចារ្យបំផុត ធ្វើឱ្យព្រះបរមសាស្តាព្រមទាំងសាវ័កទាំងអស់សប្បាយរីករាយឥតឧបមា ។



151– The Buddha felt that this occasion was a proper time for instruction, so he gathered all his disciples together at Venuvana and instructed them to practice and preach following the same basic principles. The essence of this instruction was: 1) Do not do any evil 2) Do practice all the wholesome acts 3) Purify your mind from defilements. There are four important things to remember about the occasion of this gathering. These are:

១៥១- ព្រះពុទ្ធបរមគ្រូជាម្ចាស់ទ្រង់រំពឹងឃើញថា ឱកាសនេះជាឱកាសមួយដ៏សមគួរល្មមនឹងសំដែងធម៌. ដូច្នេះ ព្រះអង្គទ្រង់ប្រមូលភិក្ខុសាវ័កទាំងអស់ឱ្យមកប្រជុំគ្នានៅក្នុងវត្តវេឡុវ័ន ហើយទ្រង់បានសំដែងឱវាទបាតិមោក្ខទូន្មានប្រៀនប្រដៅភិក្ខុទាំងនោះឱ្យប្រតិបត្តិ និងប្រកាន់ខ្ជាប់នូវគោលការណ៍ចំបង១ដូច១គ្នា ។ ខ្លឹមសារនៃព្រះឱវាទនោះគឺ ១-កុំធ្វើបាប ២-ចូរធ្វើអំពើកុសល ៣-ចូរសំអាតចិត្តឱ្យបរិសុទ្ធប្រាសចាកកិលេសទាំងឡាយ ។ មានរឿងសំខាន់១ទាំងឡាយ៤យ៉ាងទៀតដែលត្រូវចងចាំអំពីសម័យប្រជុំនោះគឺ :



152– 1) All the attending disciples were arhants 2) All these arhant disciples were bhikkhus ordained by the Buddha personally 3) The one-thousand two-hundred and fifty arhant disciples did not make previous appointments to arrive on the same day and 4) The Buddha's instruction given on that day became known as the Pratimoksa Instructions. To celebrate these four memorable facts or events, Theravada Buddhists have celebrated the "Dharma Respecting Festival" every year on the full moon day of the third month ever since that first conference was held.

១៥២- ១-ភិក្ខុទាំងអស់ដែលបាននិមន្តមកសុទ្ធតែជាព្រះអរហន្ត ២-ព្រះអរហន្តសាវ័កទាំងអស់ត្រូវបានបំបួសជាភិក្ខុដោយព្រះពុទ្ធជាម្ចាស់ផ្ទាល់ ( ឯហិភិក្ខុ ) ៣-ព្រះអរហន្តទាំង១២៥០អង្គនិមន្តមកដល់ក្នុងថ្ងៃតែមួយដោយឥតមានការកំណត់គ្នាជាមុនទេ ៤-ឱវាទរបស់ព្រះអង្គដែលទ្រង់សំដែងនៅថ្ងៃនោះគឺជា**ឱវាទបាតិមោក្ខ** ។ ដើម្បីប្រារព្ធពិធីរំលឹកនឹកដល់ព្រឹត្តិការណ៍ដែលត្រូវចងចាំទាំង៤យ៉ាងនេះ. ពុទ្ធសាសនិកថេរវាទយើងតែងតែប្រារព្ធធ្វើពិធី "**បុណ្យគោរពនឹកគុណព្រះធម៌**" ( **មាឃបូជា** ) នៅថ្ងៃពេញបូណ៌មី ខែមាឃជាប់ជារៀងរាល់ឆ្នាំ ចាប់តាំងពីមានធ្វើសង្ឃសន្និបាតលើកទី១រហូតមក ។



153– When King Suddhodana learned that his crown-prince had attained enlightenment and become the Buddha and that he was staying at Rajagrha, he sent a young official named Kalodayin, one of the playmates of Siddhartha's youth, to invite him to Kapilavastu. He wished he could see the Buddha once more while he was living. To honor his father's wish the Buddha promised to visit him, and so, at the proper time, he and his disciples went to Kapilavastu.

១៥៣- នៅពេលដែលព្រះបាទសុទ្ធោទនៈទ្រង់បានជ្រាបថា ព្រះរាជបុត្ររបស់ព្រះអង្គទ្រង់បានត្រាស់ជាព្រះពុទ្ធហើយ១ទ្រង់កំពុងនៅឯនគររាជគ្រឹះដូច្នេះ ព្រះរាជាទ្រង់បញ្ជូនមន្ត្រីវ័យក្មេងម្នាក់‹ អាមាត្យ › ឈ្មោះ **កាឡុទាយី** ជាមនុស្សម្នាក់ធ្លាប់លេងជាមួយព្រះសិទ្ធត្ថកាលនៅក្មេង១. ឱ្យទៅនិមន្តព្រះអង្គមកនគរកបិលវត្ថុ ។ ព្រះរាជាមានព្រះទ័យចង់ឃើញព្រះពុទ្ធបានម្តងនៅពេលដែលព្រះអង្គទ្រង់កំពុងគង់ព្រះជន្មនៅ ។ ដើម្បីផ្តល់កិត្តិយសបំពេញព្រះបំណងព្រះបិតា ព្រះពុទ្ធបរមគ្រូទ្រង់បានសន្យាថា នឹងយាងទៅជួបព្រះអង្គ រួចហើយពេលនេះជាពេលដ៏សមគួរព្រះបរមសាស្តាចារ្យព្រមទាំងសាវ័កទាំងឡាយក៏ទ្រង់និមន្តទៅកាន់នគរកបិលវត្ថុ ។



154– One evening the Buddha took his disciples to Kapilavastu. When they arrived there they stayed at Nyagrodha Garden, outside the city, where King Suddhodana had provided residences for them. The next morning, as he did every day, the Buddha led his disciples through the streets of the city to accept food. People watched them marching along; and someone went to report to the King. King Suddhodana was both surprised and angered to hear that the prince was asking for alms from his own people.

១៥៤-នៅសាយណ្ហសម័យថ្ងៃមួយ ព្រះពុទ្ធទ្រង់នាំសាវ័កទាំងឡាយនិមន្តទៅកាន់ក្រុងកបិលវត្ថុ ។ ពេលដែលព្រះអង្គនិងសាវ័កទាំងឡាយនិមន្តដល់ទីនេះ ទ្រង់គង់ក្នុងសួននិគ្រោធក្រៅរាជធានី ជាទីដែលព្រះបាទសុទ្ធោទនៈជ្រះថ្លាថ្វាយប្រគេនកន្លែងស្នាក់នៅដល់ព្រះពុទ្ធនិងសាវ័ករបស់ព្រះអង្គ ។ ព្រឹកស្អែកឡើង ដូចដែលព្រះអង្គតែងប្រព្រឹត្តកិច្ចវត្តរាល់ថ្ងៃដែរ ព្រះអង្គទ្រង់នាំសាវ័កនិមន្តកាត់តាមវិថីនានាក្នុងរាជធានីដើម្បីបិណ្ឌបាត ។ មនុស្សម្នាទាំងពួងនាំគ្នាស់លឹងមើលព្រះពុទ្ធនិងព្រះអរហន្តទាំងឡាយដែលកំពុងនិមន្តតាមផ្លូវ ហើយអ្នកខ្លះទៀត ក៏រត់ទៅថ្វាយដំណឹងនេះដល់ព្រះមហារាជ ។ ព្រះបាទសុទ្ធោទនៈទ្រង់ភ្ញាក់ផ្អើលនិងទ្រង់ព្រះពិរោធដោយគ្រាន់តែបានជ្រាបថា ព្រះរាជបុត្រដើរសុំអាហារពីប្រជារាស្ត្ររបស់ព្រះអង្គ ។



155- King Suddhodana ordered his driver to rush him to the street where the Buddha was asking for food. On arriving, he saw the Buddha and his disciples marching along with their bowls already full of food. They were making their way through a crowd who were paying them reverence, and they were just about to turn toward the palace. But King Suddhadana was angry and disappointed. The prince begging for food in his own country! In his own country the crown-prince was entitled to take anything he wanted without asking for permission at all! So the king, looking at the situation in this way, naturally felt quite vexed.

១៥៥-ព្រះបាទសុទ្ធោទនៈទ្រង់ត្រាស់បញ្ជាឱ្យនាយសារថីបររាជរថនាំព្រះអង្គទៅកាន់វីថិ ដែលព្រះពុទ្ធអង្គកំពុងនិមន្តបិណ្ឌបាត ។ ពេលយាងដល់ ព្រះរាជាទ្រង់បានទតឃើញព្រះពុទ្ធជាម្ចាស់ព្រមទាំងសាវ័កទាំងឡាយកំពុងនិមន្តជាជួរដោយមានបាត្រពេញទៅដោយអាហាររួចជាស្រេច ។ ព្រះពុទ្ធនិងសាវ័កនិមន្តកាត់តាមហ្វូងប្រជាជនទាំងឡាយដែលគេកំពុងនាំគ្នាធ្វើសក្ការៈគោរពព្រះអង្គនិងភិក្ខុសង្ឃ ហើយព្រះអង្គនិងភិក្ខុសង្ឃទាំងអស់ប្រុងនឹងត្រឡប់ចូលទៅព្រះរាជវាំង ។ ប៉ុន្តែ ព្រះមហារាជសុទ្ធោទនៈទ្រង់ព្រះពិរោធនិងមិនសប្បាយព្រះទ័យសោះឡើយ ។ ព្រះអង្គទ្រង់ត្រាស់ថា: ព្រះរាជបុត្រសុំម្ហូបអាហារក្នុងព្រះនគរ! ក្នុងនគរនេះ ព្រះរាជបុត្រមានអំណាចយកអ្វីៗទាំងអស់ដែលព្រះអង្គត្រូវការ ដោយពុំចាំបាច់សុំការអនុញ្ញាតអ្វីទាំងអស់! ដូច្នេះ បានជាមហាក្សត្រកាលដែលទតឃើញស្ថានភាពបែបនេះ ទ្រង់ក៏មានអារម្មណ៍ខ្មាស់មួរម៉ៅតែម្តង ។



156-King Suddhodana went before the Buddha and reproached him in a tone of disappointment and indignation: "My son! Is this the good news that I, your father, am to receive? You have abandoned your father and left the country. You are the son of the King, but has the heir to the throne yet been decided? Oh! My son! Today you have done a most disgraceful thing to your father and the royal family. On what occasion have your ancestors ever done such a thing. On what occasion have we ever accepted food like beggars?"

១៥៦-ព្រះបាទសុទ្ធោទនៈយាងទៅចំពីមុខព្រះពុទ្ធ ហើយទ្រង់ស្តីបន្ទោសព្រះអង្គដោយអាការៈអាក់អន់តូចព្រះទ័យយ៉ាងខ្លាំងថា: "នែ៎ បុត្រសំលាញ់! ហ្នឹងហើយឬជាដំណឹងល្អដែលយើងជាបិតាត្រូវបានទទួល ? បុត្របានបោះបង់បិតាចោល ហើយរត់ចេញពីនគរទៀត ។ កូនជាបុត្រព្រះមហាក្សត្រ តែនៅតែមិនទាន់សំរេចព្រះទ័យទទួលស្នងមរតកត្រងរាជ្យទេឬ? អ្ហា៎! ម្ចាស់ថ្លៃអើយ! ថ្ងៃនេះបុត្រឯងបានធ្វើអំពើដ៏គួរឱ្យអាមាស់អាប់ឱនកិត្តិយសបំផុតដល់ព្រះបិតានិងព្រះរាជវង្សានុវង្ស ។ តាំងពីកាលណាមកក៏ដោយ រាជវង្សដូនតាកូនឯង មិនដែលធ្វើយ៉ាងហ្នឹងទេ ។ តាំងពីសម័យណាក៏ដោយ តើយើងធ្លាប់សោយអាហារដូចអ្នកសុំទានអ៊ីចឹងដែរឬទេ ?



157–The Buddha spoke calmly to his angry, non-comprehending father: "Fathe! This is done, in reality, in accordance with the customs of my ancestors." King Suddhodana answered: "Everybody knows that your ancestors were kings and that none of them ever did such shameful things." The Buddha continued calmly: "Father! It is true, but I am not talking about worldly ancestors."

១៥៧-ព្រះពុទ្ធទ្រង់មានពុទ្ធដីកាប្រកបដោយសន្តិភាពតបទៅព្រះវររាជបិតាដែលកំពុងតែយល់ខុសនិងមានកំហឹងថា: ˝បពិត្រព្រះមហារាជ ! តាមភាពពិត ការធ្វើនេះស្របទៅតាមទម្លាប់ប្រពៃណីនៃបុព្វបុរសទាំងឡាយពីបុរាណរបស់តថាគត ˝ ។ ព្រះបាទសុទ្ធោទនៈមានព្រះរាជឱង្ការតបថា : ˝ ជនទាំងឡាយតែងដឹងថាបុព្វបុរសពីបុរាណរបស់បុត្រគឺព្រះមហាក្សត្រ ហើយគ្មានមហាក្សត្រអង្គណាមួយទៅប្រព្រឹត្តអំពើសុំទានដ៏គួរឱ្យអាមាស់នេះឡើយ ˝ ។ ព្រះបរមគ្រូត្រាស់បន្តដោយព្រះទ័យស្ងប់ស្ងាត់ថា ˝ បពិត្រមហារាជ ! ពិតណាស់. ប៉ុន្តែតថាគតមិននិយាយអំពីបុព្វបុរសសម័យដើមក្នុងលោកសន្និវាសនេះឡើយ ˝ ។



158- "Now I am perpetuating the tradition of all the Buddhas of the past. I mean that I am now the Buddha, and in accepting food offered I do what all of my ancestors have done. All past Buddhas did so, and you must understand that asking for food is done for the purpose of converting people. What all the Buddhas practice, I also do." After ending his speech, the Buddha explained some fundamentals of the Buddha– dharma to King Suddhodana to wipe out his father's anger. Then the King took the food bowl from the Buddha's hand and asked him and his disciples to accept food in the palace.

១៥៨-ឥឡូវនេះ តថាគតកំពុងប្រព្រឹត្តធ្វើតាមប្រពៃណីព្រះពុទ្ធទាំងឡាយគ្រប់ៗព្រះអង្គពីបុរាណ ។ តថាគតចង់និយាយថា ឥឡូវនេះ តថាគត ជាព្រះពុទ្ធមួយព្រះអង្គ ហើយការសុំអាហារពីអ្នកស្រុកដែលតថាគតធ្វើជាប្រក្រតីនេះ គឺជាបែបផែនរបស់ព្រះពុទ្ធគ្រប់អង្គពីបុរាណដែលព្រះអង្គបានធ្វើ ។ ព្រះពុទ្ធពីបុរាណគ្រប់ព្រះអង្គទ្រង់បានធ្វើដូច្នេះ. សូមមហារាជយល់ថា ការនិមន្តបិណ្ឌបាត្រ ធ្វើឡើងក្នុងបំណងប្រោសមនុស្សទាំងឡាយដែលមានសទ្ធា ។ អ្វីដែលព្រះពុទ្ធគ្រប់ៗព្រះអង្គតែងតែប្រតិបត្តិ តថាគតក៏ប្រតិបត្តិដូចគ្នាដែរ˝ ។ បន្ទាប់ពីមានព្រះពុទ្ធដីកាដូចនេះចប់ហើយ ព្រះអង្គទ្រង់សំដែងពន្យល់បន្តនូវគោលធម៌សំខាន់ៗខ្លះទៀតថ្វាយព្រះបរមរាជាសុទ្ធោទនៈដើម្បីធ្វើឱ្យរំសាយនូវកំហឹងព្រះបិតាព្រះអង្គចោលឱ្យអស់ ។ ពេលនោះ ស្រាប់តែព្រះរាជាទ្រង់ទទួលបាត្រពីព្រះហស្តព្រះពុទ្ធជាម្ចាស់ រួចហើយទ្រង់និមន្តព្រះអង្គ ព្រមទាំងភិក្ខុសង្ឃទាំងអស់ទៅទទួលភត្តក្នុងព្រះរាជវាំង ។



159– In the royal palace, after finishing the very exquisite meal which the King had offered him, the Buddha began to preach to him, his relatives, the officials and all the other people there. He explained in detail the supreme truth he had attained and the method for eliminating all suffering. Everyone in the audience was able to understand, and they received the teaching with confidence and reverently put it into practice and became followers of the Buddha forever.

១៥៩-នៅក្នុងព្រះបរមរាជវាំងនោះ ក្រោយពីសំរេចភត្តកិច្ចដ៏ប្រណីតក្រៃលែងដែលព្រះរាជាទ្រង់បានថ្វាយរួចហើយ . ព្រះបរមសាស្ដាចារ្យទ្រង់សំដែងធម្មទេសនាដល់ព្រះមហារាជ, ព្រះញាតិវង្ស, អាមាត្យ មន្ត្រី ព្រមទាំងជនទាំងឡាយក្នុងទីនោះ ។ ព្រះអង្គទ្រង់សំដែងពន្យល់យ៉ាងពិស្ដារអំពីអរិយសច្ចៈដែលព្រះអង្គបានត្រាស់ដឹងនិងអំពីរបៀបកំចាត់បង់នូវសេចក្ដីទុក្ខសោកទាំងពួងចោលឱ្យអស់ ។ អ្នកដែលបានចូលរួម ស្ដាប់ទាំងអស់បានយល់ដឹងព្រះធម៌ ហើយគេព្រមទទួលយកព្រះធម៌ដោយការជឿជាក់ក្រៃលែង និងយកទៅប្រតិបត្តិដោយគោរព ហើយថែមទាំងបានសុំថ្វាយខ្លួនជាឧបាសក ឧបាសិការបស់ព្រះអង្គជារៀងរហូត ។



160– Later, at the request of King Suddhodana, the Buddha, took two senior disciples and went to Lady Yasodhara's living quarters to see her individually, for she was quite sad at not having been able to hear the Buddha's sermon. The Buddha very compassionately enumerated the virtuous deeds of her past and then explained the dharma to her. At that time, Prince Rahula was seven years old. He was later ordained by the Buddha and became the first Sramanera in the Buddhist teaching.

១៦០-ក្រោយមកទៀត . ដោយទ្រង់យល់ព្រមតាមសំណូមពររបស់ព្រះពុទ្ធបិតា. ព្រះពុទ្ធជាម្ចាស់ទ្រង់នាំអគ្គសាវ័កពីរព្រះអង្គនិមន្តទៅជួបព្រះនាងយសោធរានៅឯព្រះដំណាក់របស់ព្រះនាងផ្ទាល់ ព្រោះព្រះនាងមានទុក្ខក្រៀមក្រំជាទម្ងន់ដោយសារតែមិនបានស្ដាប់ព្រះធម៌ទេសនារបស់ព្រះអង្គ ។ ព្រះពុទ្ធទ្រង់រៀបរាប់សសើរព្រះនាងប្រកបដោយករុណាក្រៃលែង អំពីគុណបុណ្យរបស់ព្រះនាងក្នុងអតីតជាតិ និងទ្រង់សំដែងធម៌ពន្យល់ដល់ព្រះនាង ។ កាលណោះ ព្រះអង្គម្ចាស់រាហុលកុមារព្រះជន្មទើបបាន៧ព្រះវស្សា ។ ក្រោយមកព្រះអង្គទ្រង់ឱ្យបំបួសរាហុល ហើយលោកក៏បានឡើងជាសាមណេរភាពមុនគេបង្អស់ក្នុងព្រះពុទ្ធសាសនា ។



161-Besides **Rahula**, the Buddha also converted his step-brother **Nanda** and several princes of the **Sakya Clan**. They and many other young men of Kapilavastu all left home and followed the Buddha as bhiksus. After the Buddha had left Kapilavastu, six more princes rushed to Anupiya Village to request that the Buddha accept them as bhiksus. Their names were Bhadrika, Anirudha, Bhagu, Kimpila, Ananda, and Devadatta.

១៦១-បន្ទាប់ពីបំបួសរាហុលកុមាររួចមក ព្រះអង្គក៏បានប្រោស នន្ទ ដែលជាប្អូន (ឪពុកជាមួយគ្នានឹងព្រះអង្គ តែម្តាយទីទៃ) ផងដែរ ព្រមទាំងព្រះអង្គម្ចាស់កុមារជាច្រើនទៀតនៃសក្យត្រកូល ។ ជនទាំងឡាយព្រមទាំងយុវជនក្មេងៗជាច្រើនទៀតក្នុងនគរកបិលវត្ថុនាំគ្នាចាកចេញពីផ្ទះទៅបួសជាភិក្ខុតាមព្រះពុទ្ធអង្គ ។ ក្រោយពេលដែលព្រះអង្គទ្រង់យាងចេញពីនគរកបិលវត្ថុទៅ មានសក្យបុត្រ៦អង្គទៀតបានទៅកាន់ អនុបិយនិគម ទូលសុំព្រះពុទ្ធឱ្យព្រះអង្គទ្រង់ទទួលបំបួសពួកគេទាំងអស់ជាភិក្ខុគឺ **ភទ្ទិយ អនុរុទ្ធ ភគុ កិម្ពិល អានន្ទ** និង **ទេវទត្ត** ។



162-Many years after he left Kapilavastu, the Buddha went back again with his step brother Nanda, his cousin Ananda, and Sariputra and Maudgalyana. This time he went to visit his father King Suddhodana, who was seriously ill. Overjoyed at seeing the Buddha again, he showed some improvement, and every body thought that the King might recover; but the improvement in his health did not last for long. Since King Suddhodana was very old, he could no longer resist any onslaught of illness, and two or three days later his condition became serious once again and finally he passed away. His death caused everybody to grieve very deeply.

១៦២-អស់កាលជាច្រើនឆ្នាំក្រោយពីព្រះអង្គបានយាងចេញពីនគរកបិលវត្ថុ ព្រះពុទ្ធទ្រង់យាងត្រឡប់មកវិញម្តងទៀតជាមួយ **នន្ទ** ដែលជាប្អូន. **រាហុល** ជាព្រះរាជបុត្រ. **អានន្ទ** ជាប្អូនជីដូនមួយរបស់ព្រះអង្គ ព្រមទាំង**ព្រះសារីបុត្រ** និង **មោគ្គល្លាន** ។ ម្តងនេះព្រះអង្គស្តេចយាងទៅសួរសុខទុក្ខព្រះបាទសុទ្ធោទនៈ ជាព្រះពុទ្ធបិតាដែលព្រះអង្គទ្រង់ប្រឈួនយ៉ាងខ្លាំង ។ ព្រះរាជាទ្រង់សប្បាយព្រះទ័យឥតឧបមាពេលដែលទ្រង់ទត ឃើញព្រះពុទ្ធអង្គជាថ្មីម្តងទៀត ព្រះរាជាទ្រង់បញ្ចេញអាការៈហាក់ប្រសើរឡើងវិញ ហើយជនទាំងឡាយគិតថា ព្រះមហារាជទ្រង់ប្រហែលជា ជាសះស្បើយឡើងវិញហើយ ប៉ុន្តែមិនយូរប៉ុន្មានព្រះសុខភាពមិនបានស្ថិតនៅអស់ពេលយូរឡើយ ។ ដោយហេតុថាព្រះបាទសុទ្ធោទនៈទ្រង់មានព្រះជន្មចាស់ខ្លាំងផង ព្រះអង្គទ្រង់មិនអាចតស៊ូទប់ទល់ជួយសង្គ្រោះឱ្យរួចផុតពីព្រះរោគាពាធនោះបានយូរអង្វែងទេ ពីរបីថ្ងៃក្រោយមកទ្រង់ក៏ដល់នូវសភាពធ្ងន់ធ្ងរខ្លាំងឡើងម្តងទៀត. ហើយទីបំផុតព្រះរាជាព្រះអង្គទ្រង់សោយទីវង្គតទៅ ។ មរណភាពរបស់ព្រះអង្គធ្វើឱ្យមហាជនទាំងឡាយដល់នូវទុក្ខខ្សឹកខ្សួលសោយសោកយ៉ាងក្រៃលែង ។



163- The Buddha's aunt, Maha-Prajapati, had nursed and brought up the Buddha as if he were her own son. When her husband, King Suddhodana, passed away, she became very sad and began to feel tired of the worldly life. She came to prefer a pure kind of life, she liked to follow the Buddha, listen to the Buddha-dharma and wished she could leave home and join his group of monks in the practice of dharma. So she led a group of women who were unwilling to become court ladies, and they followed the Buddha everywhere.

១៦៣-ចំណែកព្រះមាតុច្ឆារបស់ព្រះពុទ្ធគឺព្រះនាងមហាបជាបតិ ដែលព្រះនាងបានចិញ្ចឹមបីបមថ្នមថែរក្សាព្រះពុទ្ធជាម្ចាស់ កាលនៅជាកុមារប្រៀបបីដូចជាបុត្រព្រះនាងបង្កើត ។ នៅពេលដែលព្រះរាជាស្វាមីព្រះនាងគឺព្រះបាទសុទ្ធោទនៈទ្រង់សោយព្រះទីវង្គតហើយ ព្រះនាងទ្រង់ដល់នូវសេចក្តីទុក្ខព្រួយក្រៀមក្រំព្រះម័យជាពន្លឹក ហើយទ្រង់មានការនឿយណាយធុញថប់ក្នុងជីវិតនាលោកិយនេះ ។ ព្រះនាងសព្វព្រះម័យក្នុងជីវិតបរិសុទ្ធ ចង់ដើរតាមព្រះពុទ្ធ ទ្រង់ចង់ស្តាប់ធម៌ព្រះពុទ្ធ ហើយព្រះនាងទ្រង់មានបំណងប្រាថ្នាចង់ចាកចេញពីព្រះរាជវាំងទៅចូលរួមក្នុងសង្គមសង្ឃដើម្បីបានប្រតិបត្តិព្រះធម៌ ។ ដូច្នេះព្រះនាងទ្រង់បាននាំស្ត្រីមួយក្រុមដែលសុទ្ធតែជាអ្នកមិនចង់ធ្វើជាមេផ្ទះ ហើយពួកគេក៏បានដើរតាមព្រះពុទ្ធគ្រប់ទីកន្លែងទាំងអស់ ។



164-Lady Maha-Prajapati requested the Buddha's kind-permission to let her leave home and become a nun so that she could follow him closely and learn and practice according to his teaching as other bhiksus did. Although she implored him again and again that she and the other women be accepted as bhiksunis, she was three times refused by Buddha. At this she became so disappointed and felt so deeply hurt that she and other women all began to weep.

១៦៤-ព្រះនាងមហាបជាបតិទ្រង់បង្គំទូលសុំព្រះពុទ្ធានុញ្ញាតចេញពីផ្ទះទៅបួសជាភិក្ខុនី ដើម្បីព្រះនាងបានទៅជិតព្រះអង្គ និងបានរៀន បានប្រតិបត្តិធម៌ដូចដែលព្រះអង្គទ្រង់បានបង្រៀនភិក្ខុឯទៀតដែរ ។ ទោះបីព្រះនាងខំទទូចអង្វរម្តងជាពីរដង សុំឱ្យព្រះអង្គទ្រង់ទទួលបំបួសព្រះនាងព្រមទាំងស្ត្រីឯទៀតជាភិក្ខុនីក៏ដោយ . ក៏ព្រះពុទ្ធជាម្ចាស់ទ្រង់បដិសេធគ្រប់ពេលទាំងអស់ ។ ដោយហេតុយ៉ាងនេះ ព្រះនាងកើតទុក្ខទោមនស្សក្នុងព្រះម័យយ៉ាងខ្លាំង ព្រះនាងនិងស្ត្រីទាំងឡាយទៀត ទ្រង់ព្រះកន្សែងយំសោកខ្សឹកខ្សួលគ្រប់ៗគ្នា ។



165-When King Suddhodana's cremation was ended, the Buddha left Kapilavastu and began travelling and preaching from place to place. At one point he came to the country of Vaisali and resided at the Mahavana Monastery. Lady Maha-Prajapati and her group of women all shaved their heads, put on Kasayas (robes for monks or nuns), and journeyed on foot toward Vaisali. They could only walk a short distance each day, so it took them a long time to arrive finally at Mahavana Monastery, where the Buddha was staying.

១៦៥-នៅពេលដែលព្រះរាជពិធីបុណ្យបូជាព្រះសពនៃព្រះបាទសុទ្ធោទនៈចប់សព្វគ្រប់ហើយ ព្រះបរមគ្រូទ្រង់យាងចេញពីក្រុងកបិលវត្ថុ ទ្រង់ព្រះពុទ្ធដំណើរសំដែងធម៌ប្រោសសត្វពីកន្លែងមួយទៅកន្លែងមួយជាប់រហូត ។ ព្រះអង្គទ្រង់យាងចូលនគរវេសាលី ហើយទ្រង់គង់នៅក្នុងវត្តមហាវ៉ន ។ ព្រះមហាបជាបតិ ព្រម ទាំងស្ត្រីទាំងអស់នាំគ្នាកោរសក់. ស្លៀកដណ្តប់សំពត់កាសាយព័ស្ត្រ (គ្រឿងស្លៀកដណ្តប់សំរាប់អ្នកបួស) ធ្វើដំណើរដោយផ្ទាល់ជើងឆ្ពោះទៅកាន់នគរវេសាលី ។ មួយថ្ងៃៗព្រះនាងនិងស្ត្រីឯទៀតធ្វើដំណើរបានចំងាយផ្លូវជិតៗប៉ុណ្ណោះ ដូច្នេះការធ្វើដំណើរត្រូវចំណាយពេលយ៉ាងយូរ ដើម្បីឱ្យបានទៅដល់វត្តមហាវ៉នដែលព្រះពុទ្ធកំពុងគង់នៅ ។



166- When they arrived, after walking a long time, their feet were all swollen, and their bodies had become thin and weakened by fatigue. Maha-Prajapati stood at the entrance to the monastery and could not hold back her tears. Ananda had just come out of the monastery gate and found the lady weeping sorrowfully. He asked her why she was crying. The lady said: " Venerable Ananda! The Buddha did not allow me and my women to leave home. I want nothing else. I wish only to leave home and become a nun, and so I am crying!"

១៦៦- ពេលដែលស្ត្រីទាំងឡាយនោះបានទៅដល់. ក្រោយពីធ្វើដំណើរវែងឆ្ងាយមក ជើងរបស់គេឡើងហើមរូបរាងកាយមានសភាពស្គមស្គាំងថមថយខ្សោយកំលាំងដោយសារតែការនឿយហត់ ។ ព្រះនាងបជាបតិទ្រង់ឈរត្រង់ទ្វារចូលវត្ត ហើយទ្រង់មិនអាចទប់ទល់តំកល់ទឹកនេត្រាមិនឱ្យហូរបានឡើយ ។ ពេលនោះ ចំពេលព្រះអានន្ទនិមន្តចេញមកក្រៅទ្វាររបងវត្ត ក៏ស្រាប់តែឃើញព្រះនាងទ្រង់កំពុងព្រះកន្សែងពោរពេញទៅដោយសេចក្តីទុក្ខលំបាក ។ លោកក៏សួរព្រះនាងថា ហេតុអ្វីបានជាព្រះនាងទ្រង់ព្រះកន្សែងយ៉ាងនេះ ។ ព្រះនាងមានព្រះសុវណ្ណីថា "បពិត្រព្រះអានន្ទដ៏ចំរើន! ព្រះពុទ្ធទ្រង់មិនអនុញ្ញាតឱ្យខ្ញុំម្ចាស់និងស្ត្រីភេទទាំងឡាយចេញចាកផ្ទះទៅបួសឡើយ ។ ខ្ញុំព្រះករុណាម្ចាស់មិនត្រូវការចង់បានអ្វីទៀតទេ ។ ខ្ញុំម្ចាស់មានបំណងប្រាថ្នាតែម្យ៉ាង សុំឱ្យតែបានបួសជាភិក្ខុនីតែប៉ុណ្ណោះ , ដូច្នេះហើយ បានជាខ្ញុំព្រះករុណាយំ !" ។



167– Ananda consoled her: "My noble lady! Please wait here for a little while. If this is so, I shall entreat the Buddha to have compassion and to allow women to practice Dharma as well as the bhiksus." Promising the lady that he would do all he could to help her, Ananda then went back into the monastery to see the Buddha. With deep reverence, he requested that the Buddha show his mercy and let women leave home as men were allowed to do. But the Buddha replied: "Ananda! No, no! Do not ask me to do this!"

១៦៧-ព្រះអានន្ទអង្វរលួងលោមព្រះនាងថា " បពិត្រ ព្រះនាងដ៏ចំរើន ! សូមទ្រង់រង់ចាំនៅទីនេះសិនហើយ ។ បើការនេះដូច្នេះមែន ចាំអាត្មានឹងអង្វរសុំឱ្យព្រះអង្គទ្រង់មេត្តាប្រោសអនុញ្ញាតដល់ស្ត្រីទាំងឡាយបានបួសប្រតិបត្តិធម៌ដូចភិក្ខុដែរ "។ ដោយបានសន្យាថា លោកនឹងខំប្រឹងជួយព្រះនាងអស់ពីសមត្ថភាព. បន្ទាប់មកព្រះអានន្ទនិមន្តត្រឡប់ចូលទៅក្នុងវត្តវិញ ដើម្បីចូលគាល់ព្រះអង្គ ។ ដោយការគោរពដ៏ខ្ពង់ខ្ពស់បំផុត ព្រះអានន្ទ ក៏បានទូលសុំព្រះពុទ្ធជាម្ចាស់ឱ្យទ្រង់ព្រះមេត្តានុញ្ញាតដល់ពួកស្ត្រីទាំងឡាយបានបួសដូចពួកប្រុសៗផងដែរ ។ ប៉ុន្តែព្រះបរមគ្រូទ្រង់ត្រាស់ថា " នែ៎ អានន្ទ! ទេ មិនបានទេ ! ចូរកុំឱ្យតថាគតធ្វើដូច្នេះឱ្យសោះ !" ។



168- Ananda did not back down but, with courage, persisted in his entreaty for a second and even a third time; but even so the Buddha refused his request each time. Ananda thought to himself: "The Buddha does not consent upon my direct request. Maybe he will consent if I plead in a different way." So he asked: "Buddha! If women quit worldly affairs and become nuns and strictly practice pure living according to dharma, will they be able to follow the order of the Holly path to attain the four fruits? Will they be able to attain nirvana?" The Buddha replied: "Ananda! If women quit worldly affairs, become nuns and practice according to dharma, they too can during this present lifetime, attain the stages of arhant and nirvana.

១៦៨- ព្រះអានន្ទមិនសុខចិត្តសោះឡើយ . ដោយសេចក្តីអង់អាចក្លាហាន. លោកខំទទូចអង្វរសុំការសន្ដោសប្រណីដល់ទៅពីរ-បីលើក តែព្រះពុទ្ធជាម្ចាស់ទ្រង់មិនអនុញ្ញាតរាល់លើក ។ អានន្ទគិតថា: "ព្រះពុទ្ធទ្រង់មិនយល់ព្រមតាមការទូលសុំត្រង់ៗសោះ ។ ប្រហែលជាព្រះអង្គទ្រង់យល់ព្រមជាក់ជាមិនខាន ប្រសិនបើអាត្មាអញអង្វរសុំតាមមធ្យោបាយផ្សេងៗវិញ " ។ ដូច្នេះហើយ លោកក៏ទូលសួរព្រះអង្គថា :" បពិត្រ ព្រះអង្គដ៏ចំរើន! ស្ត្រីទាំងឡាយ បើគេលះបង់កិច្ចការទាំងពួងក្នុងលោក ហើយមកបួស ខំប្រឹងព្យាយាមប្រតិបត្តិដ៏ហ្មត់ចត់ ក្នុងការរស់នៅដ៏បរិសុទ្ធតាមធម៌វិន័យ តើគេអាចប្រតិបត្តិតាមអរិយមគ្គដើម្បីឱ្យបានសំរេចនូវផលទាំង ៤ បានដែរឬទេ ? តើគេអាចសំរេចបានព្រះនិព្វានដែរឬទេ ? " ព្រះបរមសាស្ដាចារ្យទ្រង់ត្រាស់ថា :" ម្នាលអានន្ទ ! បើពួកស្ត្រីទាំងឡាយលះបង់កិច្ចការសព្វយ៉ាងក្នុងលោក ហើយបានមកបួសជាភិក្ខុនីនិងបានប្រតិបត្តិតាមធម៌វិន័យនោះ គេនឹងបានសំរេចជាព្រះអរហន្ត ចូលកាន់ព្រះនិព្វានក្នុងជាតិជាបច្ចុប្បន្ននេះដោយពិត "។



169– Ananda then said: "In that case, I beg the Buddha to consider that, lady Maha Prajapati has, in former times, done you the greatest favor; for she is your aunt, as well as your foster-mother, and she breast-fed you from the time your mother passed away, taught you and brought you up in place of your mother. Buddha, I beg you, for the sake of this lady, kindly allow women to leave home like men so that they can also practice the Buddha– dharma in pursuit of the highest holy fruit that you have expounded to the people of the world."

១៦៩-ពេលនោះ ព្រះអានន្ទក្រាបបង្គំទូលបន្តថា: "ក្នុងករណីនេះឯង ខ្ញុំព្រះករុណាសុំឱ្យព្រះអង្គទ្រង់ព្រះតិរះពិចារណាថា: ព្រះនាងមហាបជាបតិ កាលពីមុនទ្រង់បានធ្វើការចិញ្ចឹមស្រលាញ់ថ្នាក់ថ្នមបំផុតចំពោះព្រះអង្គ ដោយព្រះនាងទ្រង់ជាព្រះមាតុច្ឆាផង ទ្រង់ជាព្រះមាតាចិញ្ចឹមផង. ព្រះនាងទ្រង់បានបំបៅដោះព្រះអង្គតាំងពីពេលដែលព្រះមាតារបស់ព្រះអង្គសោយព្រះទីវង្គតទៅ ព្រមទាំងបង្ហាត់បង្រៀនប្រៀនប្រដៅព្រះអង្គ និងចិញ្ចឹមបីបាច់ថែរក្សាព្រះអង្គជំនួសព្រះមាតាបង្កើត ។ បពិត្រព្រះករុណាដ៏ចំរើន ដើម្បីជាប្រយោជន៍ដល់ស្ត្រីម្នាក់នេះ ខ្ញុំម្ចាស់សូមឱ្យព្រះអង្គព្រះមេត្តាប្រោសប្រណីអនុញ្ញាតដល់ស្ត្រីទាំងឡាយ បានចាកចេញពីផ្ទះទៅបួសដូចពួកប្រុសៗដែរ ដើម្បីឱ្យគេបានប្រតិបត្តិធម៌ បានសំរេចនូវអរិយផលដ៏ឧត្តមបំផុតដូចដែលព្រះអង្គបានសំដែងដល់មនុស្សទាំងឡាយក្នុងលោកនេះ " ។



170– The Buddha said: "All right, Ananda! If lady Maha–Prajapati is willing to observe the 'eight ways of showing respect' strictly , I shall allow her to leave home!" Then he explained the eight forms of showing respect to Ananda, and finally he stood up and said: "Ananda! If lady Maha–Prajapati willingly observes these eight forms of showing respect all her life, she will be a bhikhuni, pure in conduct and complete in virtue!"

១៧០-ព្រះអង្គទ្រង់ត្រាស់ថា " ត្រូវហើយអានន្ទ ! ដូច្នេះ បើព្រះនាងមហាបជាបតិព្រមគោរពប្រតិបត្តិរក្សាខ្ជាប់បាននូវគរុធម៌៨ ប្រការ. តថាគតនឹងអនុញ្ញាតឱ្យបាន ! " ពេលនោះ ព្រះអង្គទ្រង់សំដែងពន្យល់អំពីគរុធម៌ទាំង៨ប្រការដល់ព្រះអានន្ទ ជាចុងក្រោយព្រះអង្គទ្រង់ក្រោកឈរឡើង ហើយត្រាស់បន្តថា: "ម្នាលអានន្ទ ! បើព្រះនាងមហាបជាបតិព្រមរក្សាឱ្យបានខ្ជាប់ប្រាកដនូវគរុធម៌ទាំង ៨ ប្រការនេះ អស់មួយជីវិត. ព្រះនាងនឹងបានបួសជាភិក្ខុនី . បានប្រព្រឹត្តនូវព្រហ្មចរិយធម៌នឹងបានសំរេចនូវគុណធម៌ពេញបរិបូរណ៍ !" ។



171- Having the Buddha's permission, Ananda went out to tell Lady Maha-Prajapati what the Buddha had said. The Lady was very happy, and she said to Ananda: "Venerable Ananda! Young girls love to dress up, they shampoo and bathe themselves and then, with both hands raise beautiful fragrant flower garlands to place on their heads carefully and adjusting and fixing this decoration. Likewise, I shall observe the eight commandments as if they were a garland of flowers on a young girl's head and make sure that this garland does not fall from my head throughout my life".

១៧១- ដោយបានទទួលពុទ្ធានុញ្ញាតហើយ ព្រះអានន្ទក៏ម្មីម្នាងនិមន្តទៅប្រាប់ព្រះនាងមហាបជាបតិនូវអ្វី ដែលព្រះពុទ្ធទ្រង់បានសំដែង ។ ព្រះនាងទ្រង់សប្បាយព្រះទ័យឥតឧបមា ហើយក៏មានបន្ទូលទៅកាន់ព្រះអានន្ទថា: "បពិត្រព្រះអានន្ទម្ចាស់! កុមារីស្រីក្រមុំចូលចិត្តតាក់តែងកាយ. ពួកនាងងូតទឹកកក់សក់.បន្ទាប់មកដៃទាំងទ្វេលើកកំរងផ្កាដ៏ល្អស្រស់ស្អាត មានក្លិនក្រអូបឈ្ងុយឈ្ងប់ បំពាក់លើក្បាលរបស់គេ. គេតុបតែងស្អិតស្អាងលំអខ្លួនដោយយកចិត្តទុកដាក់បំផុត ។ យ៉ាងណាមិញ. ខ្ញុំម្ចាស់នឹងគោរពប្រតិបត្តិតាមគរុធម៌ទាំង៨ប្រការនេះ ឱ្យដូចជាកំរងផ្កាដែលស្ថិតនៅលើក្បាលស្ត្រីក្រមុំទាំងឡាយដូច្នោះដែរ . ហើយខ្ញុំម្ចាស់ធានាថាមិនធ្វើកំរងផ្កាគឺ គរុធម៌៨ នេះ ឱ្យរបូតធ្លាក់ចុះពីក្បាលខ្ញុំម្ចាស់រហូតអស់មួយជីវិត "។



172- Ananda return to see the Buddha once again, bowed and then said: "Buddha! Lady Maha-Prajapati is willing to observe strictly the eight ways of showing respect that you mentioned, for she has now realized her desire of being able to become a bhikkhuni!" The Buddha said: "Ananda, with women in the order the correct doctrine of dharma will prevail for a shorter period than with men, for if a tribe has more women than men, how can they ward off ferocious bandits and resist outside oppression? With women as nuns, the Buddha Dharma cannot prevail for very long." (According to the Buddha's prediction, if women joined the sangha, starting with Maha-Prajapati as the first bhiksuni the time of prevalence of the dharma would be shortened by five- hundred years.)

១៧២- អានន្ទត្រឡប់ទៅជួបព្រះពុទ្ធជាម្ចាស់ម្តងទៀត ថ្វាយបង្គំដោយគោរព រួចទូលថា "បពិត្រព្រះអង្គដ៏ចំរើន! ព្រះនាងមហាបជាបតិ ទ្រង់យល់ព្រមគោរពប្រតិបត្តិតាមដ៏តឹងរឹងបំផុតនូវគរុធម៌ទាំង៨ប្រការដែលព្រះអង្គបានសំដែងហើយ ព្រោះឥឡូវនេះ ព្រះនាងយល់ដឹងយ៉ាងច្បាស់អំពីចេតនានៃការបួសជាភិក្ខុនីហើយ !" ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា " ម្នាលអានន្ទ! បើស្ត្រីទាំងឡាយបួស មានជំនឿយល់ឃើញត្រូវចំពោះធម៌ នឹងបានសំរេចធម៌ក្នុងរយៈពេលខ្លីជាងបុរស. ព្រោះថាប្រសិនបើក្នុងក្រុមមួយ មានសុទ្ធតែស្ត្រីច្រើនជាងបុរស តើគេអាចការពាររារាំងពួកចោរឆក់ប្លន់ដ៏កាចសាហាវនិងតស៊ូរំដោះឱ្យរួចផុតពីការសង្កត់សង្កិនដូចម្តេចបាន ? ដូច្នេះ បើស្ត្រីទាំងឡាយបួសជាភិក្ខុនី .ព្រះធម៌នឹងឱ្យសំរេចផលក្នុងពេលឆាប់ៗ " ។

(តាមព្រះពុទ្ធព្យាករណ៍ថា បើស្ត្រីចូលបួសជាសង្ឃ. ដូចដែលមានមហាបជាបតិ ជាបឋមភិក្ខុនីនោះ ពេលវេលានៃការរីកសាយនៃព្រះធម៌នឹងត្រូវរោយរៀវថយចុះនៅត្រឹម៥០០ឆ្នាំ) ។



173– Of all the disciples of the Buddha, Ananda, his cousin, revered the Buddha most. He was, therefore selected to be the Buddha's close attendant. Another of Buddha's cousins had also left home and similarly become a monk when the Buddha was fifty-five years old. But this cousin's actions were all contrary to Ananda's. Instead of obeying and serving the Buddha, he competed with him on every occation, was very envious of him, and tried every trick, with the help of evil people among his relatives and friends, to disrupt the Sangha. This cousin's name was Devadatta.

១៧៣- ក្នុងចំណោមសាវ័កទាំងអស់របស់ព្រះអង្គ មានព្រះអានន្ទជាប្អូនជីដូនមួយ មានការគោរពស្រលាញ់ព្រះពុទ្ធជាទីបំផុត ។ ព្រោះហេតុដូច្នោះ ព្រះអានន្ទ ត្រូវបានជ្រើសរើសឱ្យធ្វើជាពុទ្ធុបដ្ឋាក ។ បងប្អូនជីដូន-មួយម្នាក់ទៀត ក្នុងចំណោមជីដូនមួយជាច្រើនរបស់ព្រះអង្គក៏បានមកបួសផងដែរ ក្នុងពេលព្រះអង្គទ្រង់មានព្រះជន្ម៥៥ព្រះវស្សា ។ ប៉ុន្តែ រាល់ទង្វើរបស់សង្ឃអង្គនេះខុសគ្នាស្រឡះពីទង្វើរបស់ព្រះអានន្ទ ។ មិនត្រឹមតែមិនគោរពបំរើព្រះពុទ្ធអង្គប៉ុណ្ណោះទេ តែគេប្រកួតប្រជែងប្រឆាំងនឹងព្រះអង្គគ្រប់ពេល មានការច្រណែនឈ្នានីសនឹងព្រះអង្គយ៉ាងខ្លាំង ព្យាយាមព្យាបាទគ្រប់ល្បិចកល់ ដោយមានការជួយជ្រោមជ្រែងពីពួកមនុស្សអាក្រក់ដែលជាសាច់ញាតិនិងមិត្រភ័ក្រ្តរបស់ខ្លួនដើម្បីធ្វើសង្ឃភេទ (បំបែកបំបាក់សង្ឃ)។ ជីដូនមួយរបស់ព្រះអង្គម្នាក់នេះឈ្មោះថា **ទេវទត្ត** ។



174– Devadatta was a haughty man. He was especially dissatisfied because Sariputra and Maudgalyana, both not of the Sakya clan, had been chosen to be the Buddha's chief disciples and were very much honored by all. So he left the sangha and went alone to Rajagrha in order to contact Ajatasatru, the crown prince of King Bimbisara. At Rajagrha he spoke in a manner that Prince Ajatasatru admired and gained his respect. So the Prince built a splendid monastery near Rajagrha, which was to be used solely as Devadatta's residence, and promised to support him forever.

១៧៤-ទេវទត្តគឺមនុស្សក្រអឺតក្រទមក្អេងក្អាងច្រឡោងខាមម្នាក់ ។ លោកមានការតូចចិត្តយ៉ាងខ្លាំង ព្រោះតែព្រះសារីបុត្រនិងព្រះមោគ្គល្លាន ដោយអ្នកទាំងពីរនេះមិនមែនជាសក្យត្រកូល តែត្រូវបានជ្រើសតាំងឱ្យធ្វើជាអគ្គសាវ័ករបស់ព្រះពុទ្ធ ហើយបានទទួលការគោរពស្រលាញ់ ផ្តល់កិត្តិយសយ៉ាងក្រៃលែងពីមហាជនទាំងឡាយ ។ ដូច្នេះ លោកក៏សំរេចចិត្តចេញពីសង្ឃគណៈទៅកាន់ក្រុងរាជគ្រឹះតែមួយអង្គឯង ដើម្បីទំនាក់ទំនងចងសម្ព័ន្ធភាពជាមួយនឹងព្រះរាជកុមារ **អជាតសត្តុ** ដែលជារជ្ជទាយាទរបស់ព្រះបាទពិម្ពិសារ ។ នៅក្នុងក្រុងរាជគ្រឹះនោះ លោកសំដែងអាការដែលធ្វើឱ្យអជាតសត្តុរាជកុមារកោតសរសើរស្ញប់ស្ញែង រហូតទទួលបានការគោរពស្រលាញ់ពីរាជកុមារ ។ ហេតុនោះ. រាជកុមារក៏បានសាងវត្តមួយដ៏ល្អអស្ចារ្យនៅក្បែរក្រុងរាជគ្រឹះ សំរាប់តែភិក្ខុទេវទត្តគង់នៅតែម្នាក់ឯងប៉ុណ្ណោះ ហើយថែមទាំងសន្យាថា នឹងជួយឧបត្ថម្ភជ្រោមជ្រែងជារៀងរហូត ។



175– Many years later, the Buddha went to Rajagrha again. Devadatta visited him and requested his permission to establish a new sangha with himself as leader. The Buddha turned down his request, explaining that anything that divides a sangha would not result in good consequences. But Devadatta persisted in carrying out his own plan regardless of the Buddha's warning, and his plan had the complete support of Prince Ajatasatru. However, the King Bimbisara, the prince's father, remained a firm supporter of the Buddha and flatly refused to co-operate in establishing the new Sangha.

១៧៥-អស់ពេលជាច្រើនឆ្នាំមក ព្រះពុទ្ធបរមគ្រូទ្រង់យាងទៅកាន់នគររាជគ្រឹះម្តងទៀត ។ ចំណែកភិក្ខុទេវទត្តក៏បានចូលជួបនឹងព្រះអង្គ ហើយបានទូលសុំការអនុញ្ញាតបង្កើតឱ្យមានសង្ឃគណៈថ្មីមួយទៀត ដោយលើកខ្លួនលោកជាប្រធាន ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ច្រានចោលសំណើសុំនោះ ដោយទ្រង់ពន្យល់ហេតុផលឱ្យឃើញថា ការបំបែកសង្ឃជាច្រើនបក្សពួក នឹងមិនបានផ្តល់ផលល្អឡើយ ។ ប៉ុន្តែ ភិក្ខុទេវទត្តនៅតែចចេសរឹងរូសអនុវត្តតាមផែនការរបស់ខ្លួន ដោយមិនអើពើយកចិត្តទុកដាក់នឹងការទូន្មានហាមប្រាមរបស់ព្រះបរមគ្រូជាម្ចាស់ទាល់តែសោះ ។ ហើយកិច្ចការនេះទទួលបានការគាំទ្រដ៏ពេញទំហឹងពីព្រះរាជកុមារអជាតសត្តុ ។ ទោះជាយ៉ាងនេះក្តី ចំពោះព្រះបាទពិម្ពិសារជាព្រះរាជបិតាវិញ នៅតែជាអ្នកឧបត្ថម្ភយ៉ាងឆ្នើមបំផុតរបស់ព្រះពុទ្ធដដែល ហើយទ្រង់បដិសេធដាច់ខាតមិនចូលរួមក្នុងការបង្កើតសង្ឃគណៈថ្មីនោះឡើយ ។



176– Using devious means, Devadatta enticed Prince Ajatasatru so that the latter trusted him completely and did everything according to his intention. When Devadatta was satisfied that he had firm control over the prince's will, he suggested to Prince Ajatasatru that he should banish his father and become King of Magadha himself, for then he could do whatever he liked, such as helping Devadatta establish the new Sangha, without any hindrance. Prince Ajatasatru followed his suggestion. He put his father in prison, gave him no food and finally starved him to death. This incident occurred in the thirty-seventh year after the Buddha attained the state of perfect enlightenment.

១៧៦-ដោយបានប្រើគ្រប់មធ្យោបាយអាក្រក់, ភិក្ខុទេវទត្តញុះញង់បញ្ចុះបញ្ចូលអជាតសត្តុរាជកុមារ ដើម្បីធ្វើឱ្យរាជកុមារមានជំនឿទុកចិត្តលើខ្លួនទាំងស្រុង ហើយធ្វើអ្វីៗគ្រប់យ៉ាងតាមតែបំណងរបស់ខ្លួន ។ នៅពេលដែលទេវទត្តសប្បាយចិត្តដឹងថា ខ្លួនគាត់បានត្រួតត្រាលើចិត្តគំនិតនៃរាជកុមារទាំងស្រុងហើយ, គាត់ក៏ស្នើសុំរាជកុមារអជាតសត្តុថា រាជកុមារគួរតែបំបរបង់រាជបិតា ហើយទ្រង់ឡើងសោយរាជសម្បត្តិជាស្តេចគ្រប់គ្រងដែនមគធៈដោយព្រះអង្គឯងតែម្តង, ពេលនោះ រាជកុមារអាចធ្វើអ្វីៗបានតាមសព្វព្រះទ័យ ដូចជាជួយឱ្យទេវទត្តបង្កើតគណសង្ឃថ្មីជាដើម ដោយឥតមានឧបសគ្គអ្វីរាំងស្ទះឡើយ ។ អជាសត្តុកុមារទ្រង់ធ្វើតាមការញុះញង់ទាំងអស់ ។ ទ្រង់ក៏ចាប់ព្រះរាជបិតារបស់ខ្លួនដាក់គុក មិនឱ្យអាហារសោយ . ទីបំផុតធ្វើបាបបង្អត់អាហារព្រះបិតាខ្លួនគ្រាតែព្រះអង្គចូលទីវង្គត ។ ឧបត្តិហេតុនេះ កើតមានឡើងក្រោយពេលព្រះពុទ្ធត្រាស់ដឹងបាន៣៧វស្សា ។



177- Now Devadatta had enough power to make his move, for the new King was his friend and supporter, willing to do, with all his effort, whatever Devadatta proposed to him. So that Devadatta asked the prince to recruit a group of skillful archers and hire them at high pay to kill the Buddha, but when they came upon the Buddha's residence and noticed the peace, kindness, solemnity and reverence in the Buddha's manner, they were very much impressed and immediately realized that they should not harm the Buddha. So they went all together to the Buddha and confessed to him that they felt guilty at being hired to perform such an evil aet. The Buddha pardoned them and consoled them gently and they, in return, all vowed to follow the Buddha as his disciples.

១៧៧- ពេលនេះ ទេវទត្តប្រមូលកំលាំងបានគ្រប់គ្រាន់ដើម្បីធ្វើចលនារបស់ខ្លួន ព្រោះដោយបានមហាក្សត្រថ្មីដែលជាសំលាញ់និងជាអ្នកគាំទ្រវាល់សកម្មភាព ។ ដូច្នេះ ទេវទត្តក៏បានទូលសុំព្រះរាជកុមារឱ្យប្រមូលក្រុមអ្នកបាញ់ធ្នូដ៏ស្ទាត់ជំនាញបានមួយក្រុម ដោយជូលពួកគេក្នុងតំលៃខ្ពស់បំផុត ដើម្បីឱ្យទៅធ្វើគត់ព្រះពុទ្ធជាម្ចាស់. ប៉ុន្តែពេលដែលជនទាំងនោះទៅដល់កន្លែងដែលព្រះអង្គគង់នៅ បានសំគាល់ឃើញថា ព្រះពុទ្ធចរិយាទ្រង់ប្រកបដោយភាពស្ងប់ស្ងាត់ ពោរពេញទៅដោយមេត្តាករុណា មានភាពស្រគត់ស្រគំនិងគួរជាទីគោរពបូជាក្រៃលែង . ពួកជនទាំងនោះ ចាប់អារម្មណ៍ពេញចិត្តយ៉ាងខ្លាំង ហើយភ្លាមនោះ ពួកគេដឹងខ្លួនថា គេមិនគួរណាធ្វើកម្មអាក្រក់ចំពោះព្រះពុទ្ធឡើយ ។ ដោយយល់ឃើញត្រូវយ៉ាងនេះ ពួកគេវាល់គ្នាចេញទៅបង្ហាញខ្លួនចំពោះព្រះអង្គ ហើយសារភាពចំពោះព្រះភ័ក្ត្រព្រះអង្គនូវទោសកំហុសដែលខ្លួនបានស៊ីឈ្នួលគេមកធ្វើបាបកម្មដ៏សាហាវព្រៃផ្សៃបែបនេះ ។ ព្រះមហាករុណាជាម្ចាស់នៃយើងទ្រង់ប្រោសប្រទានទោសនិងទ្រង់សំដែងធម៌ដល់ជនទាំងឡាយប្រកបដោយមេត្តាករុណា ហើយជនទាំងអស់ក៏ប្តេជ្ញាចិត្តដើរតាមព្រះពុទ្ធជាម្ចាស់ ក្នុងនាមជាសាវ័ករបស់ព្រះអង្គរហូតមក ។



178- When all plots to kill the Buddha by using other people failed, Devadatta decided to take matters into his own hands and do it himself. He waited on the side of Grdhrakuta Mountain above a road near the Buddha's residence, which the Buddha often used to go on. One evening, just as the Buddha was walking b, Devadatta, hiding above, pushed a huge stone down the hillside, intending to kill the Buddha. But the stone, which was aimed at the Buddha's head, suddenly broke into many small pieces; only one sharp fragment hit the Buddha's foot, causing some bleeding but no serious damage. The Buddha returned to the monastery and received treatment from the famous physician Jivaka.

១៧៨- គ្រប់ដែលគំរោងការធ្វើឃាតព្រះអង្គមិនបានសំរេច. ទេវទត្តសំរេចចិត្តចាត់វិធានការហើនេះដោយខ្លួនឯងផ្ទាល់ ។ ទេវទត្តពួនសម្ងំចាំទៅម្ខាងភ្នំគិជ្ឈកូដ ខាងលើផ្លូវដែលព្រះពុទ្ធតែងនិមន្តជាប្រក្រតី ជិតកន្លែងដែលព្រះអង្គគង់នៅ ។ ល្ងាចថ្ងៃមួយ . ចំពេលដែលព្រះអង្គកំពុងតែនិមន្តតាមផ្លូវនោះ. ទេវទត្តដែលបានលាក់ខ្លួនពួនអាត្មាចាំរួចជាស្រេចនៅខាងលើភ្នំ ក៏បានរុញប្រមៀលដុំថ្មមួយដុំយ៉ាងធំទំលាក់ចុះមកក្រោមក្នុងបំណងធ្វើគតព្រះពុទ្ធអង្គ ។ ប៉ុន្តែ ដុំថ្មដែលប៉ងឱ្យធ្លាក់ចំព្រះសិរៈព្រះអង្គ ភ្លាមនោះ ក៏បានបែកខ្ចាយទៅជាដុំតូចៗអស់. មានតែបំណែកថ្មស្រួចតូចមួយដុំប៉ុណ្ណោះដែលធ្លាក់ប៉ះចំព្រះបាទព្រះអង្គបណ្តាលឱ្យចេញលោហិតបន្តិចបន្តួច ប៉ុន្តែគ្មានគ្រោះថ្នាក់អ្វីធ្ងន់ធ្ងរឡើយ ។ ព្រះពុទ្ធទ្រង់ក៏យាងត្រឡប់ទៅកាន់វត្តវិញ ហើយទ្រង់បានទទួលការព្យាបាលពីគ្រូពេទ្យដ៏ល្បីល្បាញម្នាក់ឈ្មោះ **អាជីវក** ។



179– Again his deadly plot had failed, but Devadatta still continued eagerly to do harm to the Buddha. This time his plan was to set loose the wild elephant Nalagiri, in order to kill the Buddha on the road, which the Buddha took when he went out for alms at Rajagrha. However, when the wild elephant approached the Buddha, it failed to act as Devadatta had expected, but on the contrary, became calm, for it was tamed by the Buddha's enormous compassion. Thereafter, Devadatta could do nothing but stopped planning to murder the Buddha, yet he still intended to disrupt the Sangha.

១៧៩- ផែនការធ្វើពុទ្ធឃាតមិនបានសំរេចម្តងហើយម្តងទៀត ប៉ុន្តែទេវទត្តនៅតែព្យាយាមបន្តបង្កគ្រោះថ្នាក់ដល់ព្រះពុទ្ធអង្គយ៉ាងអន្ទះសារ ។ ម្តងនេះទៀត ផែនការរបស់គាត់គឺព្រលែងដំរីមួយដ៏កាចសាហាវក្រៃពេក ឈ្មោះនាឡាគិរី ក្នុងបំណងឱ្យព្រេចព្រះពុទ្ធជាម្ចាស់ឱ្យអស់ព្រះជន្មនៅតាមផ្លូវនៅពេលព្រះអង្គកំពុងនិមន្តបិណ្ឌបាត្រក្នុងក្រុងរាជគ្រឹះ ។ ទោះជាយ៉ាងនេះក្តី. ពេលដែលដំរីដ៏កំណាចនេះចូលទៅដល់ចំពោះព្រះភ័ក្រ្តព្រះអង្គ វាបែរជាមិនហ៊ានព្រេចព្រះអង្គដូចដែលទេវទត្តសង្ឃឹមទុកឡើយ មិនតែប៉ុណ្ណោះ វាត្រឡប់ជាស្លូតបាក់បបខ្ចបខ្ចាចលែងកាចទៅវិញ ដោយសារតែព្រះវិជិតមារជាម្ចាស់ទ្រង់ផ្សាំងវាដោយមេត្តាបារមីរបស់ព្រះអង្គ ។ ក្រោយ១មកទៀត ទេវទត្តក៏មិនអាចធ្វើអ្វីបានទាល់តែសោះ ក្រៅតែពីឈប់តាមសំលាប់ព្រះអង្គ ប៉ុន្តែគាត់នៅតែមានបំណងបំបែកសង្ឃឱ្យបែកធ្លាដដែល ។



180- In order to give the bhiksus the impression that what he practiced was even stricter than what the Buddha taught, Devadatta once again went to see the Buddha, acting as if he had never even tried to disrupt the Sangha. He requested the Buddha to enforce a more stringent code of behavior, as other monastic sects did, such as not allowing bhiksus to live in covered houses, but only in the open, under trees in the forest. He also asked the Buddha to prevent bhiksus from eating any kind of meat, and he suggested to the Buddha that anyone who failed to observe this rule should be ousted from the Sangha.

១៨០- ដើម្បីដាក់ការគាបសង្កត់ដល់ភិក្ខុសង្ឃទាំងឡាយនូវអ្វីដែលខ្លួនបានប្រព្រឹត្តកន្លងមក គឺមានការតឹងរឹងជាងអ្វីដែល (វិន័យ) ព្រះពុទ្ធអង្គទ្រង់បានបង្រៀនកន្លងមក . ទេវទត្តក៏ទៅជួបព្រះសាស្តាម្តងទៀត សំដែងអាកប្បកិរិយាបីដូចជាលោកមិនធ្លាប់ធ្វើសង្ឃភេទម្តងណាឡើយ ។ ភិក្ខុទេវទត្តបានស្នើសុំឱ្យព្រះបរមគ្រូរឹតបន្តឹងវិន័យឱ្យកាន់តែតឹងថែមទៀត ឱ្យដូចពួកបព្វជិតនិកាយផ្សេង១ឯទៀត. ដូចជាមិនអនុញ្ញាតឱ្យភិក្ខុគង់នៅក្នុងកុដិប្រក់បិទបាំងដោយដំបូល. តែត្រូវនៅក្នុងទីវាល ក្រោមដើមឈើក្នុងព្រៃតែប៉ុណ្ណោះ ។ លោកក៏បានសុំទៀតថា ឱ្យព្រះអង្គដាក់បំរាមកុំឱ្យភិក្ខុសង្ឃទាំងឡាយឆាន់សាច់គ្រប់ប្រភេទ. លោកសុំព្រះអង្គថា បើភិក្ខុអង្គណាមួយល្មើសនឹងវិន័យនេះត្រូវតែបណ្តេញចេញពីសង្ឃ ។



181- The Buddha openly refused Devadatta's request, saying: "If some bhiksus prefer to live in the open or under trees, they are free to do so; but if anyone does not like to do so, he may choose to live in whatever kind of accommodation his patron provides." Regarding Devadatta's other suggestions for tightening up of the rules, the Buddha ruled in a similar manner: "If anyone wishes to eat only the food he has been offered, or to wear clothes made only of cloth strips picked up in the woods or from garbage piles, or to eat only vegetable and no meat, he is free to do so; but if someone does not wish to do so, he does not have to." Finally, Buddha warned Devadatta: "Do not attempt to disrupt the Sangha, for you will reap the evil fruits of such an attempt."

១៨១- ព្រះសម្មាសម្ពុទ្ធទ្រង់មិនយល់ព្រមដាច់ខាតចំពោះការស្នើសុំរបស់ទេវទត្ត. តែទ្រង់គ្រាន់តែត្រាស់តបថា: "ប្រសិនបើភិក្ខុអង្គណា ពេញចិត្តគង់នៅទីវាល ឬក្រោមដើមឈើ ភិក្ខុនុំះចូរនៅបានតាមសប្បាយ តែបើភិក្ខុអង្គណាមិនចង់នៅទីដូច្នេះទេ ភិក្ខុនុំះអាចជ្រើសរើសនៅទីណាមួយក៏បានតាមដែលទាយកប្រគេន "។ ដើម្បីឱ្យមាតលក្ខណៈស្របតាមអធ្យាយស្រ័យសុំខ្វះៗរបស់ទេវទត្ត ព្រះមហាករុណាក៏ទ្រង់បញ្ញត្តិវិន័យដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាដែរ ថា : " បើភិក្ខុអង្គណា ប្រាថ្នាចង់ឆាន់អាហារភោជនដែលបានមកពីដើរបិណ្ឌបាត្រ. ឬស្លៀកដណ្តប់ស្បង់ចីវរធ្វើពីបន្ទះសំពត់ដែលរើសបានមកពីក្នុងព្រៃឬគំនរសំរាម ( សំពត់បង្សុកូល) ឬឆាន់តែបន្លែ មិនឆាន់សាច់. ភិក្ខុអង្គនោះធ្វើដូច្នោះបាន ដោយឥតមានទាស់ខុសអ្វីឡើយ" ។ ចុងបញ្ចប់ ព្រះបរមគ្រូទ្រង់ទូន្មានទេវទត្តថា " ចូរអ្នកកុំមានបំណងអ្វីមួយធ្វើឱ្យសង្ឃបែកបាក់គ្នាឱ្យសោះ ព្រោះថា ធ្វើដូច្នោះ អ្នកនឹងត្រូវទទួលផលអកុសលនេះវិញមិនខានឡើយ" ។



182- Devadatta, however, paid no attention to the Buddha's warning and left feeling very spiteful. Soon he led away a group of bhikkhus who trusted him and formed a new Sangha with himself as their leader, and strictly observed his new code of living. Being aware of all this, the Buddha sent Sariputra to advise this group of bhiksus to get themselves out of this unfortunate situation. Sariputra arrived just as Devadatta was taking his nap. He then related honestly what the Buddha's opinion was regarding the formation of the new Sangha and also pointed out to them may facts about Devadatta's character and actions. This new information and insight changed the minds of all the bhikkhus, and they all returned with Sariputra to the Buddha.

១៨២- ទោះជាយ៉ាងណាក៏ដោយ. ទេវទត្តមិនយកចិត្តទុកដាក់គោរពតាមទូន្មានរបស់ព្រះអង្គឡើយ រួចហើយក៏ក្រោកចេញទៅទាំងចិត្តមួម៉ៅពុះកញ្ជ្រោលបំផុត ។ មិនយូរប៉ុន្មាន ទេវទត្តក៏ដឹកនាំបានភិក្ខុមួយចំនួនដែលស្រលាញ់ជឿជាក់លើខ្លួន ហើយបង្កើតបានជាគណសង្ឃថ្មីមួយនៅក្នុងប្រទេសនេះ ដែលមានខ្លួនលោកជាប្រធាន ហើយគោរពតាមច្បាប់វិន័យថ្មីរបស់ខ្លួនយ៉ាងតឹងរឹង ។ ដោយទ្រង់បានជ្រាបរឿងនេះសព្វគ្រប់. ព្រះដ៏មានជោគ ទ្រង់ត្រាស់ប្រើព្រះសារីបុត្រទៅសំដែងធម៌ពន្យល់ភិក្ខុទាំងនោះ ឱ្យដកខ្លួនចេញពីស្ថានការណ៍អកុសលនេះ ។ ព្រះសារីបុត្រនិមន្តទៅដល់ ចំពេលដែលទេវទត្តកំពុងសឹងសំរាកពេលថ្ងៃ ។ ពេលនោះ ព្រះសារីបុត្រមានថេរដីកា ប្រាប់ចំៗអំពីព្រះពុទ្ធតំរិះគិតឃើញពីការបង្កើតឱ្យមានគណសង្ឃថ្មីនោះយ៉ាងណា. ហើយថែមទាំងបានបង្ហាញភិក្ខុទាំងអស់ឱ្យឃើញពីអំពើនិងអាកប្បកិរិយាជាច្រើនទៀតរបស់ទេវទត្ត ។ ដំណឹងថ្មី ព្រមទាំងការយល់ដឹងឃើញច្បាស់នេះ បានធ្វើឱ្យភិក្ខុទាំងអស់ផ្លាស់ប្តូរចិត្តគំនិត ហើយព្រមវិលត្រឡប់មកជាមួយព្រះសារីបុត្រមកនៅជាមួយព្រះពុទ្ធបរមគ្រូវិញ ។



183- When Devadatta woke up from his afternoon nap, he became aware that it was still unusually everywhere. He came out to investigate and found that there was not a single bhikkhu remaining. After a while others told him that Sariputra had come and talked to the bhikkhus and took them back to Buddha. Devadatta was extremely furious, but since he could not walk for a long way because of his body was weak, he ordered his servants to prepare a sedan-chair and to carry him to see the Buddha so that he could find out what the Buddha's purpose was in drawing back to himself all the bhikkhus.

១៨៣- នៅពេលទេវទត្តភ្ញាក់ឡើង លោកដឹងថា គ្រប់ទីកន្លែងនៅតែមានភាពមិនធម្មតាដដែល ។ លោកចេញមកមើលខាងក្រៅ ក៏ស្រាប់តែមិនឃើញមានភិក្ខុនៅសល់សូម្បីមួយអង្គឡើយ ។ បន្តិចក្រោយមក មានជនមួយចំនួនប្រាប់ថា ព្រះសារីបុត្រនិមន្តមកនិយាយបញ្ចុះបញ្ចូលភិក្ខុទាំងឡាយ ហើយក៏នាំភិក្ខុទាំងអស់ត្រឡប់ទៅរកព្រះពុទ្ធវិញអស់ ។ ទេវទត្តញ័រញ័រឆ្មោះ និងច្រឡោតយ៉ាងខ្លាំង តែដោយកំលាំងចុះខ្សោយ លោកមិនអាចធ្វើដំណើរបានឆ្ងាយ ក៏បញ្ជាឱ្យអ្នកបំរើរៀបចំគ្រែស្នែងសែងលោកទៅជួបនឹងព្រះពុទ្ធដើម្បីដោះស្រាយនាំយកភិក្ខុទាំងឡាយមកនៅជាមួយខ្លួនវិញ ។



**184-When the bhiksus learned that Devadatta was approaching in a rage, they offered their opinion, requesting that the Buddha he should hide himself, for they feared that an irritated Devadattta might become dangerous when he saw the Buddha. But the Buddha was not in the least afraid. He said to Sariputra: "Deva- datta cannot do any harm to the Buddha." Later on; people found that what the Buddha had said was extremely true, for the bhiksus were soon informed that Devadatta had died unexpectedly when the chair-bearers paused on the road for a short rest. From that time until the Buddha's nirvana, the Sangha was never disrupted again.**

១៨៤-កាលដែលភិក្ខុទាំងឡាយដឹងថា ទេវទត្តនិមន្តមកទាំងប្រកបដោយកំហឹងពុះពោរផង. ភិក្ខុទាំងឡាយ បានពិគ្រោះយោបល់គ្នា សុំឱ្យព្រះពុទ្ធជាម្ចាស់ទ្រង់លាក់ព្រះអង្គសិន ព្រោះគេមានការភ័យខ្លាចទេវទត្តកំណាចអាចធ្វើឱ្យព្រះអង្គគ្រោះថ្នាក់ ។ តែព្រះដ៏មានជោគខ្មែយើងទ្រង់មិនមានការភ័យខ្លាចដល់តិចឡើយ ។ ព្រះអង្គទ្រង់ត្រាស់ទៅកាន់ព្រះសារីបុត្រថា: "ភិក្ខុទេវទត្តមិនអាចធ្វើឱ្យតថាគតដល់នូវសេចក្ដីអន្តរាយបានទេ" ។ មហាជនទាំងឡាយដឹងថា អ្វីដែលព្រះអង្គមានដីកាហើយ គឺសុទ្ធតែជាការពិតទាំងអស់ ។ បន្តិចក្រោយមក ភិក្ខុទាំងឡាយមានគេប្រាប់ថា ទេវទត្តដល់នូវមរណៈភាពដែលមិនគួរឱ្យជឿ នៅខណៈដែលនាយស្នែងឈប់សំរាកតាមផ្លូវ ។ ចាប់តាំងពីពេលនោះមករហូតដល់ព្រះពុទ្ធបរិនិព្វានទៅ គណសង្ឃទាំងមូលគង់នៅជាសុខសប្បាយ ឥតមានអ្នកបំបែកបំបាក់ទៀតឡើយ ។



185- The Buddha taught and converted beings for forty-five years algether. He traveled to and from the neighboring kingdoms in India, both large and small, always on foot, never using any vehicle. During the rainy seasons, he stayed at monasteries offered to him by various patrons. The places the Buddha stayed at most often were Venuvana, near Rajagrha, offered to him by King Bimbisara, and Jetavana, near Sravasti, donated by Anathapindika. During these years, the Buddha worked diligently every day to teach and to propagate the dhamma.

១៨៥- ព្រះបរមគ្រូជាម្ចាស់នៃយើង ទ្រង់បានប្រោសសត្វលោកអស់៤៥ព្រះវស្សា ។ ព្រះអង្គទ្រង់យាងទៅមកគ្រប់ព្រះរាជាណាចក្រតូចធំជិតខាងទាំងអស់ក្នុងប្រទេសឥណ្ឌា. ទ្រង់និមន្តដោយព្រះបាទផ្ទាល់ មិនដែលមានយានជំនិះអ្វីឡើយ ។ រៀងរាល់រដូវវស្សា ព្រះអង្គទ្រង់គង់ចាំវស្សាក្នុងអារាមនានា ដែលទាយកទាយិកាទាំងឡាយថ្វាយប្រគេនព្រះអង្គ ។ កន្លែងដែលព្រះពុទ្ធអង្គគង់នៅញឹកញាប់ជាងគេបំផុតគឺ វត្តវេឡុវ័នក្បែរក្រុងរាជគ្រឹះដែលព្រះបាទពិម្ពិសារសាងថ្វាយ និងវត្តជេតពន ក្បែរក្រុងសាវត្ថីជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីសាងថ្វាយព្រះអង្គ ។ ក្នុងកំឡុងពេលទាំង៤៥ព្រះវស្សា ព្រះពុទ្ធជាម្ចាស់នៃយើងទ្រង់តែងបំពេញពុទ្ធកិច្ចដ៏ខ្ជាប់ខ្ជួនជារៀងរាល់ថ្ងៃ ក្នុងការបង្រៀនធម៌និងផ្សព្វផ្សាយព្រះធម៌ ។



186- The Buddha usually got up before dawn, took a bath, and then went into Samadhi to examine people's natures and characters. When he found that someone was suitable and ready to accept his teaching, he would go to that person's place and convert him that very day. After daybreak, the Buddha put on his robe, took his bowl, and went for alms from people in the neighborhood. He sometimes went alone and sometimes with bhikkhus in neat files, everyone with bowl in hand; and in a peaceful and gracious manner they passed by one house after another, accepting food from all patrons.

១៨៦- ជាធម្មតា ព្រះពុទ្ធជាម្ចាស់ទ្រង់តើនឡើងពីសឹងមុនពេលអរុណរះ. ទ្រង់ស្រង់ទឹក រួចហើយទ្រង់គង់ធ្វើសមាធិប្រមើលមើលឧបនិស្ស័យសត្វលោកទាំងពួង ។ កាលដែលព្រះអង្គទ្រង់ជ្រាបថា អ្នកណាមួយមានឧបនិស្ស័យគួរនឹងទទួលយកព្រះធម៌បាន ព្រះអង្គក៏ស្ដេចយាងទៅកាន់លំនៅដ្ឋានរបស់អ្នកនោះ ហើយសំដែងធម៌ប្រោសក្នុងថ្ងៃនោះតែម្ដង ។ ក្រោយពេលអរុណរះភ្លឺស្រឡះហើយ ព្រះអង្គទ្រង់ឃ្លុំចីវរ ទ្រង់កាន់បាត្រ រួចក៏យាងទៅបិណ្ឌបាត ។ មានពេលខ្លះព្រះអង្គទ្រង់យាងតែមួយព្រះអង្គឯង ជួនពេលខ្លះយាងទៅជាមួយនឹងភិក្ខុទាំងឡាយ ដោយនិមន្តជាជួរយ៉ាងសមរម្យបំផុត ។ ភិក្ខុទាំងអស់សុទ្ធតែប្រដាប់ដោយបាត្រក្នុងដៃគ្រប់១អង្គ ហើយទ្រង់និមន្តបិណ្ឌបាតតាមផ្ទះទាយកទាយិកាពីផ្ទះមួយទៅផ្ទះមួយប្រកបដោយ តុល្យ-ភាព និងមានអាការៈគួរជាទីជ្រះថ្លានិងគួរជាទីពិតពិលរមិលមើលក្រៃពេក ។



187- Sometimes there were people who respectfully invited the Buddha to their homes to accept offerings. The Buddha usually accepted the invitation only if there was a proper reason. At the patron's home, the Buddha would sit on a prepared mat, and the patron would take the Buddha's bowl and fill it with the best food and offer it to him. After eating food and washing his hands, the Buddha expounded dharma to the people who were there, causing them to understand that after doing good or bad things, they would correspondingly gain either happiness or misery, in either this or in a future life. He also advised and instructed them to practice diligently the Buddhadharma. There after the Buddha returned to the monastery.

១៨៧- ជូនកាលមានទាយក ទាយិកា មកក្រាបថ្វាយបង្គំនិមន្តព្រះអង្គទៅទទួលភត្តនៅឯផ្ទះរបស់ខ្លួន ។ ប្រសិនជាការសមរម្យ ព្រះអង្គទ្រង់តែងទទួលការនិមន្តរបស់ទាយកទាយិកានោះៗ ។ នៅឯផ្ទះទាយកទាយិកា ព្រះអង្គទ្រង់គង់លើអាសនៈដែលគេរៀបចំបំរុងទុករួចជាស្រេច ហើយជនជាម្ចាស់ផ្ទះក៏ទទួលយកបាត្ររបស់ ព្រះអង្គទៅដាក់បំពេញដោយភោជនដ៏ប្រណីត ហើយក៏ថ្វាយព្រះអង្គឆាន់ ។ ក្រោយពីទ្រង់បានសំរេចភត្តកិច្ចបរិបូណ៌ហើយ ព្រះបរមសាស្តាចារ្យទ្រង់សំដែងធម៌ដល់ជនទាំងឡាយដែលមកជុំគ្នានៅទីនោះ. ញ៉ាំងជននោះៗឱ្យបានយល់ច្បាស់ថា អំពើល្អឬអាក្រក់ដែលខ្លួនបានធ្វើហើយ ខ្លួនឯងនឹងជាអ្នកទទួលផលជាសុខឬទុក្ខយ៉ាងពិតប្រាកដ ក្នុងពេលបច្ចុប្បន្នឬអនាគតមិនខានឡើយ ។ ព្រះមហាករុណាជាម្ចាស់ទ្រង់ប្រទានព្រះឱវាទដល់ជនទាំងឡាយឱ្យខំប្រព្រឹត្តប្រតិបត្តិធម៌ដោយយកចិត្តទុកដាក់ ។ កាលបើសំដែងធម៌ចប់ហើយព្រះអង្គទ្រង់យាងត្រឡប់ទៅវត្តវិញ ។



188- In the monastery, the Buddha used to sit quietly in the rest hall or under a tree in the surroundings waiting until all the bhiksus had returned from their alms round and had finished eating and then went for a while into his room to rest. When all the bhikkhus had assembled in the discussion hall, the Buddha would give a sermon that befitted the particular occasion. Or he would encourage the bhiksus during their discussion to learn and practice diligently the Buddha-dharma so that they might achieve the final goal of attaining nirvana in this present life.

១៨៨- នៅឯក្នុងវត្តនោះវិញ . ព្រះពុទ្ធជាម្ចាស់ទ្រង់តែងគង់ដោយស្ងៀមស្ងាត់នៅក្នុងសាលាសំរាក ឬនៅក្រោមម្លប់ឈើ មួយអន្លើដោយបរិស័ទនៅអមជុំវិញ ទ្រង់រង់ចាំលុះត្រាតែភិក្ខុទាំងឡាយនិមន្តត្រឡប់មកពីបិណ្ឌបាត កាលបើទ្រង់ឆាន់រួចរាល់ហើយ ព្រះអង្គទ្រង់យាងទៅសំរាកបន្តិច ។ លុះដល់ភិក្ខុទាំងឡាយមកជុំគ្នាក្នុងសាលាធម្មសភាអស់ហើយ ព្រះអង្គទ្រង់ប្រោសប្រទានធម្មវិសេសទេសនាសមគួរទៅដល់កាលវេលា ។ ម្យ៉ាងទៀត ព្រះអង្គទ្រង់តែងសរសើរដល់ភិក្ខុទាំងឡាយនៅពេលកំពុងធ្វើធម្មសាកច្ឆាធម៌ ឱ្យខំប្រឹងយកចិត្តទុកដាក់រៀននិងប្រតិបត្តិធម៌វិន័យឱ្យបានត្រឹមត្រូវ ដើម្បីឱ្យភិក្ខុទាំងអស់បានសំរេចដល់គោលដៅនៃព្រះនិព្វានក្នុងបច្ចុប្បន្នជាតិនេះ ។



189– When the Buddha had finished expounding the dharma, some bhikkhus often requested that the Buddha outline the main objectives of dharma so that they could understand and recite it in a way that befitted their particular natures and capacities. The Buddha would then consider the nature and the degree of advancement of the individual and give an easy intelligible or a very deep verse that was most suitable for that particular person. There after the bhiksus dispersed, each bhiksu would find a quiet place in the forest or under a tree or in a deserted dwelling, where he would sit down to meditate and recite the verse that the Buddha had given to him. The Buddha would also return to his own living quarters.

១៨៩- ពេលដែលព្រះបរមគ្រូទ្រង់សំដែងធម៌ចប់ហើយ . ជាធម្មតា មានភិក្ខុអង្គខ្លះលោកតែងទូលសូរឱ្យទ្រង់បញ្ជាក់បន្ថែមនូវគោលធម៌សំខាន់ៗ ដើម្បីឱ្យខ្លួនបានយល់ច្បាស់និងទន្ទេញឱ្យចាំតាមរបៀបណាមួយ ដែលសមតាមឧបនិស្ស័យរបស់ខ្លួន ។ ពេលនោះ ព្រះមហាករុណាទ្រង់ពិចារណាមើលនូវចរិតលក្ខណៈនិងគតិនៃការចំរើនជឿនលឿនរបស់ភិក្ខុ រួចហើយទ្រង់ក៏ត្រាស់សំដែងជាឃ្លាខ្លីៗ ន័យរាក់ៗ ដែលងាយនឹងយល់បានបំផុតសំរាប់ភិក្ខុដែលមានប្រាជ្ញាតិច ឬឃ្លាដែលមានន័យជ្រាលជ្រៅសំរាប់ភិក្ខុដែលមានប្រាជ្ញាយល់ដឹងខ្ពង់ខ្ពស់ ។ ក្រោយពីបានស្តាប់ព្រះអង្គរួចហើយ ភិក្ខុទាំងឡាយក៏និមន្តទៅកាន់ទីផ្សេងៗគ្នា. អង្គខ្លះស្វែងរកកន្លែងស្ងប់ស្ងាត់នៅក្នុងព្រៃឬនៅក្រោមដើមឈើឬនៅក្នុងផ្ទះស្ងាត់ដែលគេបោះបង់ចោល ដែលជាកន្លែងលោកអាចគង់ចំរើនវិបស្សនាកម្មដ្ឋាននិងសាធ្យាយធម៌ដែលព្រះពុទ្ធអង្គទ្រង់បានបង្រៀនរួចហើយ ។ បន្ទាប់ពីនោះមក ព្រះពុទ្ធបរមគ្រូទ្រង់យាងត្រឡប់ទៅកាន់ព្រះគន្ធកុដិរបស់ព្រះអង្គវិញ ។



190– In summertime, if the Buddha stayed at certain places, the people in the neighborhood would come to visit him in the evening. Some came with offerings; some came to listen to his preaching. By various means and using skillful and marvelous language, the Buddha always made everyone understand what he said. Everybody–whether rich, poor, learned or ignorant– felt that the Buddha had expounded the dharma for him. Thus, after the sermon, everybody was happy and satisfied and showed before the Buddha that he had confidence in the Buddha-dharma and would put it strictly and reverently into practice throughout his lifetime.

១៩០- នៅក្នុងតិម្ហន្តរដូវ បើព្រះបរមគ្រូទ្រង់គង់នៅកន្លែងណាមួយ ប្រជាជនទាំងឡាយដែលនៅស្រុកភូមិក្បែរនោះ តែងតែនាំគ្នាទៅថ្វាយបង្គំគាល់ព្រះអង្គក្នុងពេលល្ងាច ។ អ្នកខ្លះមានទេយ្យវត្ថុសំរាប់ថ្វាយប្រគេនព្រះអង្គ . ខ្លះទៀតមកដើម្បីស្តាប់ធម្មទេសនា ។ ដោយមានមធ្យោបាយផ្សេងៗជាច្រើន និងការចេះប្រើសំនីភាសាដ៏ប៉ិនប្រសប់អស្ចារ្យគួរឱ្យស្ងប់ស្ងែង ព្រះដ៏ទ្រង់ញាណតែងតែធ្វើឱ្យមហាជនទាំងឡាយបានយល់នូវធម៌ដែលព្រះអង្គបានសំដែងហើយ ។ ជនទាំងឡាយ មោះជាអ្នកមាន អ្នកក្រ អ្នកមានប្រាជ្ញា ឬឥតប្រាជ្ញាក្តីក៏ដឹងបានថា ព្រះអង្គសំដែងធម៌ដល់ខ្លួនគេដែរ ។ ហេតុដូច្នោះ ក្រោយពីបានស្តាប់ធម្មទេសនាចប់ ជនទាំងឡាយនោះ មានចិត្តសប្បាយរីករាយនិងពេញចិត្ត បានបង្ហាញឱ្យឃើញនៅចំពោះព្រះភ័ក្ត្រព្រះអង្គថាពួកគេមានជំនឿទុកចិត្តលើព្រះពុទ្ធ ព្រះធម៌ហើយៗ គេនឹងគោរពប្រតិបត្តិតាមដ៏ហ្មត់ចត់អស់មួយជីវិត ។



191- After the people had left, the Buddha returned to the monastery to bathe, but if there was a suitable river or pond in the vicinity, he might take a bath there in the evening. After his bath, the Buddha would enter into Samadhi to rest for some time and then continue to receive bhikkhus coming from other places. The Buddha would inquire about how they were tought and instruct them and explain to them the Buddha-dharma, which was difficult to understand, bringing them to understand it and leave afterwards full of joy.

១៩១-កាលបើបរិស័ទទាំងឡាយចាកចេញទៅផ្ទះអស់ហើយ ព្រះពុទ្ធជាម្ចាស់ទ្រង់ក៏យាងត្រឡប់ទៅវត្តវិញដើម្បីស្រង់ទឹក តែប្រសិនបើមានស្រះទឹកឬស្ទឹងដ៏សមគួរនៅក្បែរ ព្រះអង្គទ្រង់ស្រង់ទឹកនៅទីនោះនាវេលា ល្ងាចតែម្តង ។ បន្ទាប់មក ព្រះអង្គទ្រង់ធ្វើសមាធិមួយរយៈពេលខ្លី រួចហើយគង់ចាំទទួលភិក្ខុទាំងឡាយដែលនិមន្តមកពីតំបន់ផ្សេងៗបន្តទៀត ។ ព្រះពុទ្ធទ្រង់សួរភិក្ខុទាំងឡាយថា បានរៀនអ្វីខ្លះហើយ រួចទ្រង់ក៏បង្រៀនភិក្ខុទាំងឡាយនោះ ព្រមទាំងពន្យល់ទូវធម៌ដែលលំបាកនឹងយល់ ឱ្យយល់បានដោយងាយ បន្ទាប់មក ភិក្ខុទាំងអស់និមន្តចេញទៅពោរពេញដោយសេចក្តីសប្បាយរីករាយ ។



192- Being tired after sitting all day, the Buddha took his "promenade" at the dusk time. He walked back and forth in one place within the monastery to get rid of his fatigue and to regain his freshness. Every evening, after his promenade, the Buddha would talk again with the bhiksus. Late at night important persons, such as knigs might come to visit the Buddha and inquire about certain problems; and the Buddha used to answer their questions and they took leave afterwards full of joy.

១៩២- ដោយមានការនឿយហត់ក្រោយពីការគង់ពេញមួយថ្ងៃមក. ក្នុងវេលាព្រលប់ព្រះពុទ្ធជាម្ចាស់ទ្រង់និមន្តចង្ក្រមដើម្បីសំរាកព្រះកាយ ។ ព្រះអង្គទ្រង់យាងចង្ក្រមទៅមកៗក្នុងវត្ត ដើម្បីបន្ធូបន្ថយការនឿយហត់អស់កំលាំងនិងទទួលយកនូវភាពស្រស់ស្រាយនៃខ្យល់បរិសុទ្ធឡើងវិញ ។ រៀងរាល់ល្ងាច បន្ទាប់ពីទ្រង់យាងចង្ក្រមរួចហើយ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងធម៌ដល់ភិក្ខុទាំងឡាយជាបន្ត ។ វេលាយប់បន្តិចទៅ មានមនុស្សសំខាន់ៗដូចជាព្រះមហាក្សត្រជាដើម ទ្រង់យាងចូលជួបនឹងព្រះពុទ្ធជាម្ចាស់និងទ្រង់ទូលសួរអំពីបញ្ហាផ្សេងៗ ហើយព្រះអង្គទ្រង់តែងឆ្លើយបំភ្លឺនូវបញ្ហាទាំងឡាយនោះៗ បន្ទាប់មក ព្រះរាជាទ្រង់យាងត្រឡប់ទៅបរមរាជវាំងវិញដោយព្រះទ័យសោមនស្សរីករាយបំផុត ។



193– After that it was time to go to sleep. The Buddha slept on his right side down, his two legs slightly bent, the left one on the right one; his left hand was placed on his left thigh, and his right hand was bent back placed under his right cheek. The Buddha went quietly to sleep at the proper time and awoke before dawn. Then he entered into Samadhi to explore the natures of his prospective audiences for the day and continued after daybreak to expound the dharma.

១៩៣- បន្ទាប់មកទៀត ក៏ដល់ពេលដែលព្រះអង្គទ្រង់ចូលផ្ទុំ ។ ព្រះពុទ្ធបរមគ្រូទ្រង់ផ្ទុំផ្ទៀងបែរមកខាងស្ដាំ ព្រះបាទាទាំងគូរទ្រង់អង្គុញបន្តិច. ព្រះបាទឆ្វេងទ្រង់ផ្គងដាក់លើព្រះបាទស្ដាំ. ព្រះហស្ដឆ្វេងទ្រង់ដាក់លើភ្លៅឆ្វេង និងព្រះហស្ដស្ដាំទ្រង់ដាក់ទ្រថ្ពាល់ស្ដាំ ។ ព្រះពុទ្ធអង្គទ្រង់ផ្ទុំក្នុងវេលាដ៏សមគួរមួយនិងទ្រង់តើនឡើង វិញមុនវេលាអរុណរះ ។ ពេលនោះ. ព្រះអង្គទ្រង់គង់ចំរើនសមាធិ ដើម្បីប្រមើលមើលឧបនិស្ស័យនៃមនុស្សសត្វទាំងឡាយសំរាប់ប្រោសនៅពេលថ្ងៃស្អែក ហើយក្រោយវេលាអរុណរះព្រះអង្គទ្រង់ផ្សព្វផ្សាយព្រះធម៌បន្តទៀត ។



194- The Buddha had been teaching and converting people for forty-five years, yet he always worked very hard, never slackening, in his dharma-propagating work. When he was not journeying on the road, he spent his time not only expounding the dharma but also, because of his vast knowledge and lofty deep wisdom, solving problems for those people whom he encountered and directing them to their realization of the true meaning of life. He always showed his willingness to help when someone approached him with a problem or question, whether he was a farmer, a gardener, a blacksmith or a cartmaker.

១៩៤- ព្រះបរមសាស្ដាចារ្យទ្រង់បានបង្រៀនប្រៀនប្រដៅនិងប្រោសមនុស្សសត្វអស់៤៥ព្រះវស្សា. ព្រះអង្គទ្រង់តែងតែបំពេញពុទ្ធកិច្ចយ៉ាងលំបាក. មិនដែលខ្ជិលច្រអូសក្នុងកិច្ចការផ្សព្វផ្សាយព្រះធម៌របស់ព្រះអង្គឡើយ ។ ដោយសារតែចំណេះវិជ្ជាយល់ដឹងដ៏មហាធំធេងនិងព្រះបញ្ញាដ៏ខ្ពង់ខ្ពស់និងជ្រាលជ្រៅបំផុត ព្រះអង្គទ្រង់មិនត្រឹមតែសំដែងធម៌ប៉ុណ្ណោះទេ ថែមទាំងដោះស្រាយបញ្ហាផ្សេងៗរបស់ប្រជាជនទាំងឡាយដែលព្រះអង្គទ្រង់បានជួប ហើយណែនាំទូន្មានឱ្យគេបានភ្ញាក់រឭកយល់ដឹងអំពីបញ្ហាពិតៗនៃជីវិត ។ ព្រះមហាករុណាទ្រង់តែងបង្ហាញឱ្យឃើញពីទឹកព្រះទ័យរបស់ព្រះអង្គ ដើម្បីជួយដល់សព្វមនុស្សសត្វនៅពេលដែលគេមករកព្រះអង្គដោយមានបញ្ហាឬចម្ងល់អ្វីមួយកើតឡើង ទោះបីជននោះ ជាកសិករ ,ជាអ្នកថែសួន. ជាជាងដែក ឬជាជាងរទេះក៏ដោយ ។



195– The Buddha was never reluctant to answer difficult questions or explain complicated problem nor had he ever been irked by any inquirer or unable to answer a question. The Buddha always expounded the dharma in a way most suitable to the nature of the people, whether they came to learn out of sincerity or whether they were there only to heckle. Those who came to inquire about the more profound aspects of dharma were cordially welcomed and offered perfect and complete explanations. And those who came to challenge or test the Buddha were always defeated by his wisdom, and would finally express their desire to be the Buddha's loyal disciples for the rest of their lives.

១៩៥- ព្រះសាស្តាទ្រង់ពុំដែលមានព្រះទ័យស្ទាក់ស្ទើរក្នុងការឆ្លើយបំភ្លឺនូវរាល់សំណួរលំបាកៗឬក៏ពន្យល់អំពីបញ្ហាដែលមានភាពស្មុគស្មាញទេ ទាំងមិនដែលធុញទ្រាន់ជាមួយជនដែលទៅរកព្រះអង្គ ឬមិនដែលទាល់ឆ្លើយនឹងសំណួរដល់ម្តងណាឡើយ ។ ព្រះអង្គទ្រង់តែងសំដែងធម៌តាមវិធីដ៏សមរម្យបំផុត ដល់និស្ស័យមនុស្សសត្វទាំងពួង ទោះបីជននោះ មករៀនធម៌ដោយគោរពស្មោះស្ម័គ្រ ឬទោះបីមកគ្រាន់តែផ្ចាញ់ផ្ចាលរំខានព្រះអង្គក៏ដោយ ។ ជនទាំងឡាយណាដែលមកសួរចង់យល់ដឹងអំពីបញ្ហាធម៌ដែលមានសេចក្តីជ្រាលជ្រៅ ក៏ត្រូវបានទទួលដោយរាក់ទាក់ និងធ្វើអធិប្បាយពន្យល់ដ៏ល្អឥតខ្ចោះ ។ ចំណែកពួកជនទាំងឡាយដែលមកដើម្បីប្រកួតប្រជែង ឬគ្រាន់តែដើម្បីសាកល្បងនឹងព្រះអង្គ ក៏ត្រូវទទួលបរាជ័យដោយសារតែព្រះបញ្ញារបស់ព្រះអង្គ ហើយដល់ទីបំផុត គេក៏បង្ហាញឱ្យឃើញពីឆន្ទៈរបស់គេ សុំធ្វើជាសាវ័កដ៏ស្មោះរបស់ព្រះអង្គអស់មួយជីវិត ។



196– In the forty-five years of his travelling and preaching career, the Buddha had reached his eightieth year. He realized that his travelling around was about to end, for he felt his physical strength was declining even though his mind was as strong as ever. Knowing that he could not remain in the world much longer, the Buddha decided to journey north to the foothill of Himalayas, the region most familiar to him in his younger days. His intention was to enter Nirvana in that place, so he left the Rajagrha with Ananda and a group of bhikkhus.

១៩៦- ក្នុងវស្សាទី៤៥នៃព្រះពុទ្ធដំណើរប្រោសសត្វ ព្រះអង្គទ្រង់មានព្រះជន្មយាងចូល៨០ព្រះវស្សា ។ ព្រះដ៏ទ្រង់ញាណទ្រង់ជ្រាបថា ការធ្វើដំណើរប្រោសសត្វរបស់ព្រះអង្គដល់ទីបញ្ចប់ហើយ ដោយព្រះអង្គទ្រង់ដឹងច្បាស់ថា កំលាំងកាយរបស់ព្រះអង្គមានការខ្សោយចុះ ទោះបីជាកំលាំងចិត្តព្រះទ័យរបស់ព្រះអង្គនៅខ្លាំងក្លាដូចមុនក៏ដោយ ។ ដោយទ្រង់ជ្រាបថា ព្រះអង្គមិនអាចមានព្រះជន្មគង់នៅក្នុងលោកនេះបានយូរអង្វែងទៀត ព្រះអង្គទ្រង់សំរេចព្រះទ័យយាងទៅទិសខាងជើងសំដៅទៅជើងភ្នំហិមពាន្ត ជាទីកន្លែងដែលមានមនុស្សជាទីស្និតស្នាលបំផុតចំពោះព្រះអង្គកាលពីទ្រង់ព្រះជន្មវ័យក្មេង ។ ព្រះពុទ្ធជាម្ចាស់ទ្រង់មានព្រះបំណងយាងចូលកាន់ព្រះបរមនិព្វានក្នុងកន្លែងនោះ. ដូច្នេះ ក៏ព្រះអង្គទ្រង់និមន្តចេញពីក្រុងរាជគ្រឹះជាមួយព្រះអានន្ទនិងព្រះភិក្ខុសង្ឃទាំងពួង ។



197– On the way north, the Buddha went through the kingdom of Patali and then turned northward passing Vaisali. The Buddha had stayed in Vaisali before, where he received the offering of Amravana Garden from the dissolute girl Amrapali, who had competed with the princess of the country in making offerings to the Buddha. When the Buddha arrived at the Bamboo Grove Village, he ordered his bhikkhus to take up residence for the rainy season anywhere they liked, but the Buddha and Ananda decided to remain for the rainy season there in the village.

១៩៧- តាមផ្លូវទៅទិសខាងជើងនោះ . ព្រះពុទ្ធអង្គទ្រង់យាងកាត់ព្រះរាជាណាចក្រ **បាតលី** បន្ទាប់មក សំដៅត្រង់ទៅទិសខាងជើងកាត់តាមក្រុង **វេសាលី** ។ កាលពីមុន ព្រះបរមគ្រូទ្រង់ធ្លាប់បានគង់នៅក្នុងក្រុងវេសាលីនេះ ជាកន្លែងដែលព្រះអង្គទ្រង់បានទទួលដីសួន **អម្ពវ័ន** ពីនាង **អម្ពបាលី** ដែលបានដណ្ដើមប្រជែងគ្នាជាមួយនឹងអ្នកអង្គម្ចាស់ក្នុងនគរនេះ ក្នុងការថ្វាយទានដល់ព្រះពុទ្ធ ។ នៅពេលដែលព្រះសាស្ដាយាងចូលដល់ព្រៃវេឡុវ័នហើយ ព្រះអង្គទ្រង់ត្រាស់ឱ្យភិក្ខុទាំងឡាយធ្វើកន្លែងស្នាក់នៅចាំវស្សាត្រង់ទីណាមួយដែលភិក្ខុពេញចិត្ត . ក៏ប៉ុន្តែព្រះពុទ្ធជាម្ចាស់និងព្រះអានន្ទសំរេចព្រះទ័យគង់ចាំវស្សាក្នុងភូមិ នោះ ។



198- During his stay for the rainy season at Bamboo Grove Village, the Buddha became seriously ill, but later on he gradually recovered and his pain completely disappeared. One day at noon, Ananda made up the cushion for the Buddha so that he could sit in the shade of the monastery. Ananda said: "Buddha! I am so happy to see that you have recovered your normal health. I was very sad before to see you so seriously ill. But I always thought that you would not go into Nirvana at that time but would continue to instruct us bhiksus further and long enough so that the bhiksus could become the foundation in putting into practice what was thaught by the Buddha after your Nirvana.

១៩៨- អំឡុងពេលដែលគង់ចាំព្រះវស្សាក្នុងព្រៃវេឡុវ័ន. ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រឈួនជាទម្ងន់តែបន្តិចក្រោយមកទ្រង់ក៏ជាសះស្បើយបន្តិចម្ដងៗរហូតដល់ព្រះរោគាពាធនោះជាស្រឡះ ។ ថ្ងៃមួយ វេលារសៀល ព្រះអានន្ទបានរៀបចំក្រាលកំរាលប្រគេនព្រះអង្គគង់ក្រោមម្លប់សំយាបកុដិ ។ ព្រះអានន្ទមានថេរដីកាថា " បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គសប្បាយចិត្តណាស់ ដោយបានឃើញព្រះអង្គទ្រង់បានជាសះស្បើយ មានព្រះសុខភាពធម្មតាវិញដូច្នេះ ។ ពីមុនខ្ញុំព្រះអង្គមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយឃើញព្រះអង្គទ្រង់ប្រឈួន ជាទម្ងន់ ។ ខ្ញុំព្រះអង្គតែងតែគិតថា ព្រះអង្គទ្រង់នឹងមិនទាន់ចូលនិព្វាននាពេលនោះទេ គឺថា ព្រះអង្គនឹងបន្តបង្រៀនភិក្ខុទាំងឡាយបានយូរល្មមតទៅទៀត ដើម្បីឱ្យភិក្ខុទាំងអស់មានលំនឹងមាំក្នុងការប្រតិបត្តិធម៌ដែលព្រះអង្គបានបង្រៀនរួចហើយ ក្រោយពីព្រះអង្គនិព្វានទៅ ។



199-The Buddha said: "Ananda! What can the bhikkhus still expect from me?" I have told everything there is to know about dharma; there is nothing else left. By this time, the bhikkhus should know the way to practice, to verify their practice and to attain nirvana; I do not keep any secret. With all my heart I wish the very best for all the bhikkhus and have high expectation and hope for them. I have told them everything they should know up to the time of their final deliverance from suffering. Ananda! I am an old man now; my strength is ebbing; my time is closed to its end; I am eighty already! Therefore, you should depend on yourselves, for oneself is the place to abide in. Do not depend on others. Dharma is what you should depend on, for dharma is the root of mind, and nothing else is." Finally the Buddha repeated: "Ananda! Any bhikkhus who is determined to practice is to be considered the most progressive one in the Sanhga!"

១៩៩- ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា: "ម្នាលអានន្ទ! តើភិក្ខុទាំងឡាយនៅចង់បានអ្វីពីតថាគតទៀត? " តថាគត បានប្រាប់អស់ហើយអំពីធម៌ដែលត្រូវយល់ដឹង. គ្មានអ្វីទៀតដែលមិនទាន់បានបង្រៀនទេ ។ ឥឡូវនេះ ភិក្ខុទាំងឡាយគួរតែយល់ពីផ្លូវដែលត្រូវប្រតិបត្តិ ផ្លូវដែលត្រូវធ្វើឱ្យប្រាកដប្រជាក្នុងការប្រតិបត្តិរបស់ខ្លួន និងផ្លូវដែលនឹងបានសំរេចព្រះនិព្វាន. តថាគតឥតមានលាក់បាំងអ្វីទុកឡើយ ។ ដោយសេចក្តីស្មោះអស់ពីចិត្ត របស់តថាគត។សូមឱ្យទទ្វើដ៏ល្អបំផុតនេះ មានដល់ភិក្ខុគ្រប់អង្គ ហើយតថាគតមានជំនឿនិងសង្ឃឹមយ៉ាងមុតមាំចំពោះភិក្ខុទាំងអស់ ។ តថាគតបានបង្រៀននូវធម៌ទាំងឡាយដល់ភិក្ខុ ហើយភិក្ខុទាំងអស់គួរយល់ដឹងចងចាំរហូតដល់ពេលបានរំដោះរួចផុតពីសេចក្តីទុក្ខជាចុងក្រោយ ។ ម្នាលអានន្ទ! ឥឡូវនេះ តថាគតចាស់ហើយ កំលាំងពលំរបស់តថាគតចុះខ្សោយខ្លាំងណាស់ ហើយពេលវេលាក៏ខិតជិតដល់ទីបញ្ចប់ដែរ តថាគតមានវស្សា ៨០ហើយ ! ។ ព្រោះហេតុដូច្នោះ អ្នកទាំងឡាយចូរទីពឹងលើខ្លួនឯងចុះ, ព្រោះថាខ្លួនគឺជាទីពឹងរបស់ខ្លួន ។ ចូរកុំទីពឹងលើអ្នកដទៃឡើយ ។ អ្នកត្រូវយកព្រះធម៌ជាទីពឹង ព្រោះថា ព្រះធម៌ជាដើមចមនៃចិត្ត. គ្មានទីពឹងអ្វីក្រៅពីធម៌ទៀតទេ" ។ ទីបញ្ចប់ព្រះអង្គមានបន្ទូលទៀតថា "ម្នាលអានន្ទ ! ភិក្ខុណាមួយដែលបានប្តេជ្ញាចិត្តចូលមកប្រតិបត្តិធម៌ហើយ ត្រូវឱ្យភិក្ខុនុះពិចារណានូវធម៌ដែលនាំឱ្យមានសេចក្តីចំរើនដល់សង្ឃ ! "។



200– At daybreak, the Buddha felt more comfortable and was able to go for alms in the city of Vaisali. After eating, the Buddha left for Pava Stupa and told Ananda to bring the cushion so that he could take a happy rest at midday. While the Buddha was sitting alone under the shade of a tree, he investigated with his mind the cause and the condition of his passing away and concluded that he would enter Nirvana after three months. When Ananda came over to him, the Buddha said: "Ananda! On the fifteenth day of the Visakha month the Buddha will enter Nirvana; it is only three months away."

២០០-លុះព្រឹកឡើង ព្រះសាស្តាទ្រង់សោយនូវអារម្មណ៍ជាសុខស្រួលច្រើនក្នុងព្រះកាយហើយ ទ្រង់និមន្តទៅបិណ្ឌបាតក្នុងក្រុងវេសាលី ។ ក្រោយពីទ្រង់សោយចង្ហាន់រួចហើយ ព្រះអង្គទ្រង់យាងទៅកាន់ចេតិយ៍បាវា ទ្រង់ត្រាស់ប្រាប់អានន្ទឱ្យយកកំរាលទៅរៀបចំក្រាលប្រគេនព្រះអង្គសំរាកវេលាថ្ងៃត្រង់ ។ ខណៈដែលព្រះអង្គទ្រង់កំពុងគង់តែមួយព្រះអង្គឯងក្រោមម្លប់ឈើនោះ ព្រះអង្គទ្រង់រំពឹងពិនិត្យមើលអំពីហេតុផលនៃការចូលបរិនិព្វានរបស់ព្រះអង្គ រួចហើយព្រះអង្គទ្រង់សំរេចព្រះទ័យថា ទ្រង់នឹងចូលកាន់ព្រះបរមនិព្វានក្នុងពេលបីខែទៀត ។ ពេលដែលព្រះអានន្ទនិមន្តមកជិត ព្រះដ៏ទ្រង់ញាណជាម្ចាស់នៃយើងទ្រង់ត្រាស់ថា " ម្នាលអានន្ទ ! នៅថ្ងៃ១៥កើត ពេញបូណ៌មីខែពិសាខ តថាគតនឹងរំលត់ខន្ធចូលកាន់ព្រះបរមនិព្វានហើយ.គឺនៅសល់តែបីខែទៀតប៉ុណ្ណោះ " ។



201– Ananda implored him: " Please do not enter Nirvana, Buddha. Please stay and continue to help people to stop suffering!" The Buddha said to Ananda: "Ananda! The Buddha has completely severed himself from the karmic effects of life and death, and will attain Nirvana three months from now. Further, death is unavoidable, and nothing can exist forever. Ananda! Do not think about this now. Come, let us go to Mahavana Monastery, and ask the bhikkhus of Vaisali to assemble there." At the Buddha's order, Ananda left. When the bhikkhus had gathered at Mahavana, Ananda went to inform the Buddha.

២០១- អានន្ទក្រាបថ្វាយបង្គំអង្វរព្រះអង្គថា " បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះអង្គទ្រង់កុំទាន់ចូលនិព្វានឡើយ ។ សូមព្រះអង្គព្រះមេត្តាគង់នៅតទៅទៀត ដើម្បីឱ្យជួយមនុស្សសត្វទាំងឡាយបានរួចផុតពីសេចក្តីទុក្ខ!" ។ ព្រះពុទ្ធជាម្ចាស់មានព្រះតម្រាស់ទៅកាន់អានន្ទថា " ម្នាលអានន្ទ ! ព្រះតថាគតបានកាត់ផ្តាច់ទាំងស្រុងផុតពីផលកម្មដែលនាំឱ្យកើតនិងស្លាប់ហើយ តថាគតនឹងសំរេចចូលនិព្វានក្នុងរយៈពេលបីខែទៀតដោយគិតចាប់ពីពេលនេះតទៅ ។ ជាងនេះទៀត សេចក្តីស្លាប់មិនអាចចៀសវាងឱ្យផុតបានឡើយ ហើយក៏គ្មានអ្វី ដែលអាចស្ថិតស្ថេរនៅជាប់ជារៀងរហូតបានដែរ ។ ចូរអ្នកចូលមក យើងនឹងទៅកាន់វត្តមហាវ៉នហើយ ចូរអ្នកហៅភិក្ខុទាំងឡាយក្នុងក្រុងពារាណសីឱ្យមកប្រជុំគ្នាក្នុងទីនេះ"។ ដោយបានទទួលតាមព្រះពុទ្ធដីកា ហើយព្រះមហាអានន្ទក៏និមន្តចេញទៅ ។ ពេលដែលភិក្ខុទាំងឡាយមកជុំគ្នាក្នុងវត្តមហាវ៉នអស់ហើយ .អានន្ទក៏ក្រាបបង្គំទូលដំណឹងនេះដល់ព្រះពុទ្ធអង្គវិញ ។



202– The Buddha went to the place of the assembly and there gave his most important instruction. He also expressed the final expectations he had of the bhiksus, encouraging them to observe strictly all the Buddha's teaching, for the best benefit of people in the world. Helping beings to practice and to learn the Buddhadharma and serving as models for the people in the world. Finally he repeated: "All worldly things are transient and illusory. You must practice and learn diligently and think about the future improvement of yourselves. Guard your own mind, do not be heedless, so that you can then expect liberation from all the suffering of the turning round of birth and death.

២០២- ព្រះពុទ្ធទ្រង់យាងទៅកាន់ទីជុំនុំសង្ឃ .ហើយទ្រង់ប្រទានព្រះឱវាទដ៏សំខាន់បំផុតដល់ពួកភិក្ខុ ។ ព្រះអង្គទ្រង់សំដែងឱ្យឃើញអំពីសេចក្តីសង្ឃឹមជាចុងក្រោយដែលព្រះអង្គមានចំពោះភិក្ខុ. ទ្រង់សរសើរលើកទឹកចិត្តដល់ភិក្ខុទាំងឡាយឱ្យមានការគោរពប្រតិបត្តិហ្មត់ចត់នូវធម៌វិន័យដែលព្រះអង្គទ្រង់បានបង្រៀនរួចហើយ ដើម្បីជាប្រយោជន៍ដល់មនុស្សទាំងឡាយក្នុងលោក. ជួយឱ្យមនុស្សសត្វទាំងឡាយបានប្រតិបត្តិនិងសិក្សាព្រះធម៌និងថែរក្សាទុកជាខ្នាតប្រតិបត្តិ សំរាប់មនុស្សសត្វទាំងឡាយក្នុងលោកនេះ ។ ជាចុងក្រោយព្រះអង្គត្រាស់ទៀតថា : " អ្វីៗទាំងពួងក្នុងលោកសន្និវាសនេះ សុទ្ធតែមិនទៀងទាត់ស្ថិតស្ថេរឡើយ ។ ភិក្ខុទាំងឡាយ ត្រូវតែប្រតិបត្តិនិងសិក្សារៀនសូត្រធម៌វិន័យដោយយកចិត្តទុកដាក់ និងចូរគិតអំពីប្រយោជន៍របស់ខ្លួននាពេលអនាគត ។ ចូរគ្រប់គ្រងការពារចិត្តរបស់ខ្លួន . ចូរកុំប្រមាទ. ដូច្នេះ អ្នកអាចនឹងបានរំដោះរួចផុតពីសេចក្តីទុក្ខពីការវិលវល់កើត ស្លាប់. ស្លាប់ កើត ទៀតហើយ " ។



203- One morning, in order to take a final look at the city of Vaisali, the Buddha and Ananda went for alms there. The Buddha said to Ananda: "Ananda! This is the last time that I shall see the city of Vaisali. Ananda! Let's go to Bhanda Village." At Bhanda, he took a rest, then preached to the people there together with his disciples. after visiting the village of Hatthi, Amba and Jambu, finally arrived at the city of Bhoga where he stopped at the Ananda Stupa. There Buddha pointed out to the bhikkhus the four ways teaching in order to check the principles of the Buddha-dharma. Then he continued his journey with disciples to the city of Pava and rested at the Mango Garen which belonged to Cunda, the son of a goldsmith.

២០៣- នៅវេលាព្រឹកមួយ ដោយទ្រង់ចង់ទតរាជធានីវេសាលីជាចុងក្រោយ .ព្រះពុទ្ធជាម្ចាស់និងព្រះអានន្ទក៏បានយាងទៅបិណ្ឌបាតនៅទីនោះ ។ ព្រះបរមគ្រូមានព្រះពុទ្ធដីកាទៅកាន់អានន្ទថា: "ម្នាលអានន្ទ! នេះជាលើកចុងក្រោយហើយដែលតថាគតបានឃើញក្រុងវេសាលី ។ អានន្ទ ! យើងទៅកាន់ភូមិ **ភណ្ឌ**"។ នៅឯភូមិភណ្ឌ ព្រះអង្គទ្រង់គង់សំរាកនៅទីនោះនិងទ្រង់បានសំដែងធម៌ដល់ប្រជាជនទាំងឡាយ. ក្រោយមក រួមជាមួយភិក្ខុសាវ័កទាំងពួងទ្រង់យាងទតតាមភូមិនានាដូចជា **ហត្ថី** . **អម្ពះ** និង **ជម្ពូ** ហើយទីបំផុត ក៏ទៅដល់ក្រុង **ភោគះ**. ព្រះអង្គទ្រង់ឈប់ត្រង់កន្លែង **អានន្ទចេតីយ៍** ។ នៅទីនោះ ព្រះអង្គទ្រង់សំដែងប្រាប់ដល់ភិក្ខុទាំងឡាយឱ្យឃើញច្បាស់ថា មាតិកធម៌ទាំងឡាយមាន៤យ៉ាង ដើម្បីពិនិត្យមើលគោលសំខាន់ៗនៃធម៌ ។ បន្ទាប់មក ទ្រង់បន្តព្រះពុទ្ធដំណើរជាមួយនឹងសាវ័កទាំងឡាយទៅកាន់ក្រុង **បាវា** ហើយទ្រង់ឈប់សំរាកនៅក្នុងឧទ្យានអម្ពវ័ន (ឧទ្យានព្រៃស្វាយ) ដែលជាសួនរបស់ **ចុន្ទ** ជាកូនប្រុសរបស់ជាងមាសម្នាក់ ។



204- The Buddha preached to Cunda and his family causing them to have confidence in and take refuge in Buddha-dharma. He then accepted Cunda's invitation to receive offerings at his home the next morning. In the food that Cunda offered the Buddha there was mixed in it a kind of fungus grown on sandalwood, which, when the Buddha ate it, caused his former illness to flare up even more seriously than before. However, the Buddha bore the pain with all his strength and continued to journey onward, hoping to reach Kusinagara.

២០៤- ព្រះភគវន្តមុនីទ្រង់សំដែងធម៌ដល់នាយចុន្ទនិងក្រុមគ្រួសាររបស់គាត់ ញ៉ាំងពួកគាត់ឱ្យមានជំនឿទុកចិត្តក្នុងព្រះធម៌និងយកព្រះធម៌ជាទីពឹងទីរលឹក ។ បន្ទាប់មក ព្រះអង្គទ្រង់ទទួលការអារាធនានិមន្តរបស់នាយចុន្ទ ដើម្បីទទួលភត្តនៅឯផ្ទះរបស់គាត់ក្នុងវេលាព្រឹកស្អែក ។ នៅក្នុងចង្ហាន់ដែលនាយចុន្ទថ្វាយដល់ព្រះសាស្តានោះ មានស្ងួលាយប្រភេទផ្សិតម្យ៉ាងដែលដុះនៅនឹងដើមច័ន្ទន៍ក្រស្នា . ពេលដែលព្រះអង្គឆាន់រួចហើយធ្វើឱ្យព្រះរោគាពាធចាស់របស់ព្រះអង្គលាប់ឡើងវិញកាន់តែធ្ងន់ធ្ងរខ្លាំងជាងមុន ។ ទោះជាយ៉ាងនេះក្តី ព្រះពុទ្ធជាអម្ចាស់ទ្រង់ខំអត់ទ្រាំទប់ទល់នឹងការឈឺចាប់អស់ពីកំលាំងកាយ ហើយទ្រង់បន្តដំណើរតទៅទៀតដោយទ្រង់មានព្រះទ័យសង្ឃឹមថា នឹងយាងឱ្យបានដល់នគរកុសិនារា ។



205– Taking a short rest every once in a while along the way, the Buddha gradually approached Kusinagara. While he paused under a tree, he met Pukusa, a prince of the Malla Clan and one of the old sages Arada-kalama's disciples, who was on his way from Kusinagara to Pava and had asked for the opportunity to see the Buddha. The Buddha preached the dharma of being peace-abiding to him then there arose confidence in him, and he vowed to take, for all his life, refuge in the Buddha, Dharma and Sangha and he respectfully presented the Buddha with two rolls of fine gold-colored cloth. The Buddha accepted only one roll, and had Pukusa offered the other roll to Ananda. The Buddha then crossed the Kakuttha River, took a rest for a while, and arrived at Hiranyavati River, which was within the boundaries of Kusinagara.

២០៥-ដោយទ្រង់បានឈប់សំរាកជាញឹកញាប់ខណៈពេលកំពុងពុទ្ធដំណើរ. ព្រះអង្គទ្រង់ចេះតែយាងបន្តបន្តិចម្តងៗរហូតបានដល់នគរកុសិនារា ។ ពេលដែលព្រះអង្គឈប់សំរាកក្រោមដើមឈើ. ព្រះអង្គទ្រង់បានជួបនឹង **បុក្កុស** ជារជ្ជទាយាទ នៃសក្យត្រកូលដែន **មល្លះ** និងជាសិស្សម្នាក់ក្នុងចំណោមសិស្សទាំងឡាយរបស់អារទកាលាមៈតាបស . ដែលកំពុងរាជដំណើរពីនគរកុសិនារាទៅបាវា ហើយក៏បានសុំឱកាសជួបនឹងព្រះពុទ្ធជាម្ចាស់ ។ ព្រះអង្គទ្រង់បានសំដែងធម៌អំពីការរស់នៅប្រកបដោយសន្តិភាពដល់ព្រះអង្គម្ចាស់អង្គនោះៗ ក៏មានជំនឿជ្រះថ្លាចំពោះព្រះពុទ្ធអង្គ ហើយតាំងប្តេជ្ញាព្រះទ័យយកព្រះពុទ្ធ ព្រះធម៌និងព្រះសង្ឃជាទីពឹងទីរលឹកអស់មួយជីវិត . ហើយទ្រង់ក៏បានថ្វាយសំពត់ពណ៌មាសដ៏ល្អចំនួនពីរដុំដល់ព្រះពុទ្ធជាម្ចាស់ដោយគោរព ។ ព្រះអង្គទ្រង់ទទួលយកតែមួយដុំប៉ុណ្ណោះ ហើយទ្រង់ត្រាស់ឱ្យបុក្កុសៈ ប្រគេនសំពត់មួយដុំទៀតដល់ព្រះអានន្ទ ។ បន្ទាប់មកទៀត ព្រះពុទ្ធអង្គទ្រង់និមន្តឆ្លងស្ទឹង **កកុដ្ឋា** រួចហើយក៏បានទៅដល់ស្ទឹង **ហិរញ្ញវតី** ជាស្ទឹងមួយស្ថិតនៅត្រង់ព្រំប្រទល់នៃនគរកុសិនារា ។



206– After crossing the Hiranyavati River, they arrived at Salavana, a holiday resort of the royal clan of Malla, which was outside the city of Kusinagara. The Buddha felt he could go no further, and said to Ananda: "Ananda! Prepare a place for me to lie down between those two Sala trees. I feel very tired." Ananda took the Buddha's big robe, folded it four ways, and placed it on the bed between the two big Sala trees. The Buddha then lay down on his side, with head towards the north. The Buddha did not fall asleep, but only rested to relieve his pain and fatigue. His mind remained as tranquil as it had ever been.

២០៦- ក្រោយពីទ្រង់បានឆ្លងស្ទឹងហិរញ្ញវតីរួចហើយ. ព្រះអង្គនិងព្រះអានន្ទក៏បាននិមន្តដល់ព្រៃសាលវ័ន . ជារមណីយដ្ឋានកំសាន្តនៃពួកក្សត្រដែនមល្លៈ. ដែលជាឧទ្យានមួយស្ថិតនៅខាងក្រៅរាជធានីនៃនគរកុសិនារា ។ ព្រះដ៏ទ្រង់ញាណជាម្ចាស់ទ្រង់ជ្រាបថា ព្រះអង្គទ្រង់មិនអាចបន្តដំណើរទៅមុខទៀតបានឡើយ ក៏ទ្រង់ត្រាស់ទៅព្រះអានន្ទថាៈ "ម្នាលអានន្ទ! ចូរអ្នករៀបចំកន្លែងឱ្យតថាគតសំរាកនៅចន្លោះក្រោមដើមសាលព្រឹក្សទាំងពីរនេះចុះ ។ តថាគតអស់កំលាំងខ្លាំងណាស់" ។ អានន្ទយកសំពត់សង្ឃាដីរបស់ព្រះអង្គមកបត់ជាបួន ហើយក៏ក្រាលសំពត់នោះលើគ្រែ ត្រង់ចន្លោះដើមសាលព្រឹក្សដ៏ធំទាំងគូរ ។ ព្រះបរមគ្រូទ្រង់ផ្ទុំផ្សៀងព្រះកេសបែរទៅទិសខាងជើង ។ ព្រះអង្គទ្រង់ផ្ទុំពុំលក់ទាល់តែសោះ តែគ្រាន់បានសំរាក ឱ្យបានធូរស្បើយពីការឈឺចាប់ និងអស់កំលាំងប៉ុណ្ណោះ ។ ឯព្រះទ័យព្រះអង្គទ្រង់នៅតែមានភាពស្ងប់ស្ងាត់ប្រាសចាកភាពរវើរវាយ ដូចពីមុនដដែល ។



207– Ananda felt that the Buddha was really about to leave him this time, and he could not bear the grief in his heart. So he left the Buddha and wept in an isolated place among the trees, muttering to himself: "Unlike other bhiksus, I have not yet attained the stage of arhant. I have to continue to learn and practice, but now my teacher will pass away and leave me behind. I shall lose my compassionate master forever and be left all alone!" His face flooded with tears.

២០៧- ព្រះអានន្ទដឹងថា ព្រះពុទ្ធអង្គប្រាកដជានឹងឃ្លាតចាកពីរូបលោកក្នុងពេលនេះ. លោកមិនអាចទប់ទល់សេចក្ដីទុក្ខសោកទង្គិះខ្សឹកខ្សួលនេះបានឡើយ ។ ដូច្នេះ លោកក៏និមន្តចេញពីព្រះពុទ្ធអង្គទៅយំក្នុងទីឆ្ងាយកណ្ដាលព្រៃ. និយាយទាំងអាក់អួលថា " មិនដូចភិក្ខុដទៃទៀតសោះ. អាត្មាអញមិនទាន់បានសំរេចញជាព្រះអរហន្តនៅឡើយ ។ អាត្មាអញត្រូវខំរៀននិងប្រតិបត្តិតទៅទៀត តែឥឡូវនេះ គ្រូរបស់អាត្មាអញនឹងរំលត់ខន្ធចូលកាន់ព្រះនិព្វានចោលអាត្មាអញហើយ ។ អាត្មានឹងត្រូវបាត់បង់គ្រូដ៏ប្រកបដោយករុណាធម៌នេះជារៀងរហូត ហើយនឹងត្រូវនៅឯកោតែឯង ! " ។ ព្រះភ័ក្ត្រលោកជោគជោរជន់ទៅដោយទឹកភ្នែក ។



208- When the Buddha opend his eyes and failed to find Ananda, he asked the bhikkhus who were at his side: "Where did Ananda go?" The bhikkhus replied: "Ananda is weeping in a hidden place. He says that he has not attained the stage of arhant and has to keep on learning and practicing, but that his ever-compassionate teacher is going to leave him!" The Buddha said: "Bhiksu! go to tell Ananda that the Buddha is looking for him." The bhikkhu did as he was ordered. When Ananda came back, the Buddha comforted him very kindly and compassionately.

២០៨- ខណៈដែលព្រះពុទ្ធជាម្ចាស់ទ្រង់បើកព្រះនេត្រឡើង ទតមិនឃើញព្រះអានន្ទ. ព្រះអង្គទ្រង់ត្រាស់សួរភិក្ខុទាំងឡាយដែលនៅក្បែរព្រះអង្គថា: "ម្នាលភិក្ខុទាំងឡាយ , ចុះអានន្ទទៅណាហើយ ? " ភិក្ខុទាំងនោះក្រាបបង្គំទូលថា "ម្ចាស់អានន្ទកំពុងយំក្នុងទីស្ងាត់ក្នុងព្រៃឯណោះព្រះអង្គ ។ លោកមានដីកាថា លោក-នៅមិនទាន់បានសំរេចជាព្រះអរហន្តនៅឡើយ ហើយត្រូវបន្តរៀនសូត្រនិងប្រតិបត្តិតទៅទៀត . តែថាព្រះបរមគ្រូដ៏ពេញដោយករុណារបស់លោកនឹងនិព្វានចោលលោក!" ។ ព្រះមហាករុណាទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ! ចូរអ្នកទាំងឡាយទៅប្រាប់អានន្ទថា តថាគតកំពុងរកគេ" ។ ភិក្ខុទាំងនោះក៏ទទួលតាមព្រះពុទ្ធដីកា ។ ពេលដែលព្រះអានន្ទត្រឡប់មកវិញ ព្រះមហាករុណាទ្រង់ត្រាស់លួងលោមព្រះអានន្ទដោយមេត្តាករុណាអាណិតអាសូរក្រៃលែង ។



209– The Buddha praised Ananda in front of the other bhikkhus, saying: "All the Buddhas in the past had excellent attendants, but they could not excel Ananda, my attendant. All the Buddhas in the future will have excellent attendants, but they will not excel what Ananda has done for me. Ananda is the best and most clever attendant I have ever had. Ananda knows how to arrange just the right time for me to meet with visitors. Ananda has always treated them pleasantly and spoken well with them. Every visitor has found only the very highest satisfaction in the way Ananda has received and treated him. When Ananda tells a person something, he always listens so attentively, as to surpass all the expectations of Ananda. Ananda has, at all times, been my most excellent attendant!"

២០៩-ព្រះអង្គទ្រង់សរសើរព្រះអានន្ទនៅចំពោះមុខភិក្ខុទាំងឡាយដោយព្រះពុទ្ធដីកាថា: "ព្រះពុទ្ធទាំងឡាយពីបុរាណមកទ្រង់មានឧបដ្ឋាកដ៏ល្អប្រសើរ ប៉ុន្តែពុទ្ធុបដ្ឋាកទាំងឡាយនោះ មិនល្អស្មើនឹងអានន្ទដែលជាឧបដ្ឋាករបស់តថាគតឡើយ ។ ព្រះពុទ្ធទាំងឡាយក្នុងពេលអនាគតក៏នឹងមានឧបដ្ឋាកដ៏ល្អប្រសើរដូចគ្នា ប៉ុន្តែអ្នកទាំងនោះនៅតែមិនស្មើនឹងអានន្ទដែលបំរើតថាគតដែរ ។ អានន្ទគឺជាអ្នកបំរើដ៏ល្អនិងឆ្លាតវាងវៃបំផុត ដែលតថាគតពុំធ្លាប់ជួប ។ អានន្ទស្គាល់របៀបរៀបចំត្រូវតាមពេលវេលាឱ្យតថាគត ដើម្បីជួបនឹងអ្នកដែលប្រាថ្នាមកជួបតថាគត ។ ជានិច្ចកាល, អានន្ទចេះធ្វើបដិសណ្ឋារកិច្ច និយាយរាក់ទាក់ធ្វើឱ្យជនទាំងឡាយបានសប្បាយរីករាយ ។ ជនគ្រប់គ្នាដែលមកដល់ហើយ មានការសប្បាយចិត្តយ៉ាងក្រៃលែង ដោយអានន្ទបានទទួល បដិសណ្ឋារកិច្ចពួកគេ ។ ពេលដែលអានន្ទប្រាប់អ្វីមួយដល់ជនណាម្នាក់ គេរមែងស្តាប់ដោយយកចិត្តទុកដាក់បំផុតលើសពីអ្វីដែលអានន្ទសង្ឃឹមទុកមុនទៅទៀត ។ គ្រប់ពេលវេលាទាំងអស់ អានន្ទជាឧបដ្ឋាកដ៏ល្អអស្ចារ្យបំផុតរបស់តថាគត !" ។



210– Later, Ananda said to the Buddha: "Buddha! Please do not enter Nirvana in such improper, out-of-the-way, small place. Please select one of the large cities such as Rajagrha, Sravasti, Vaisali, or some other city and enter Nirvana there. In those places there are many rich and powerful persons who are your disciples; they will bear the responsibility for arrangement of your holy remains."

២១០- បន្តិចក្រោយមក, អានន្ទក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា: "បពិត្រព្រះអង្គដ៏ចំរើន ! សូមទ្រង់កុំទាន់ចូលនិព្វានក្នុងកន្លែងដ៏តូចមិនសមរម្យឆ្ងាយពីផ្លូវដូច្នេះអី ។ សូមព្រះអង្គទ្រង់ជ្រើសរើសយកទីក្រុងធំណាមួយក្នុងចំណោមទីក្រុងទាំងឡាយដូចជា ក្រុងរាជគ្រឹះ, សាវត្ថី, វេសាលី ឬក៏ទីក្រុងណាមួយផ្សេងៗទៀត ហើយសឹមទ្រង់យាងចូលនិព្វានក្នុងទីនោះ ។ នៅក្នុងទីកន្លែងទាំងឡាយនោះសម្បូរដោយអ្នកមានអំណាចបុណ្យស័ក្តិនិងទ្រព្យសម្បត្តិដែលសុទ្ធតែជាសាវ័ករបស់ព្រះអង្គ, ពួកគេនឹងទទួលខុសត្រូវលើការចាត់ចែងព្រះសពរបស់ព្រះអង្គ" ។



211-The Buddha said to Ananda: "No! Ananda, Dont's say that! You should not think of this place as a small and insignificant and unimportant place. Long ago this was a prosperous metropolis, a capital city, the residence of a Cakravarti King. Ananda! Go to Kusinagara and tell the king and the people that tonight, during the last watch of the night, the Buddha will enter Nirvana in this forest, and if they wish to, they should come to see me before that time." Ananda went to Kusinagara with several bhiksus and told King Malla and his people what the Buddha had said.

២១១-ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទៅកាន់អានន្ទថា " ទេ ! មិនបានទេអានន្ទ, ចូរអ្នកកុំនិយាយបែបនេះ! ។ អ្នកមិនគួរយល់ថា ទីនេះជាកន្លែងតូច មិនសំខាន់ មិនល្អដូច្នេះឡើយ ។ កាលពីយូរលង់កន្លងទៅហើយ ទីនេះជាទីក្រុងដ៏រុងរឿងមួយ, ជារាជធានីមួយនៃស្ដេចចក្រព័ត្រាធិរាជ ។ ម្នាលអានន្ទ! ចូរអ្នកទៅកាន់នគរកុសិនារា ថ្វាយដំណឹងនេះដល់ព្រះរាជានិងប្រាប់ដល់ប្រជាជនទាំងឡាយក្នុងយប់នេះតែម្ដងថា នៅវេលាជិតភ្លឺនៃយប់នេះ តថាគតនឹងចូលនិព្វាននៅក្នុងព្រៃនេះ ហើយប្រសិនបើជនទាំងឡាយនោះចង់ឃើញតថាគត សូមឱ្យគេមកមើលតថាគតមុនពេលនោះចុះ"។ អានន្ទក៏និមន្តទៅកាន់នគរកុសិនារាជាមួយនឹងភិក្ខុទាំងឡាយ ហើយក៏បានថ្វាយដំណឹងនេះដល់ព្រះបាទមល្លៈ និងប្រាប់ដល់ប្រជារាស្ត្ររបស់ព្រះរាជាតាមព្រះបន្ទូលនៃព្រះពុទ្ធបរមគ្រូ ។



212- When the King and people of Kusinagara learned from Ananda that the Buddha was about to enter Nirvana, they all wept sadly and said: " It is too early for the Buddha to enter Nirvana. Too soon is extinguished the light of the world!" Lamenting men, women, and children flocked to Salavana, where the Buddha was staying, hoping that they might see the Buddha once more and express their concern for him. People visited the Buddha in groups in an orderly manner. Everybody was unwilling to leave him, however.

២១២- កាលដែលព្រះបរមរាជាព្រមទាំងប្រជារាស្ត្រក្នុងនគរកុសិនារាបានជ្រាបដំណឹងនេះពីអានន្ទថា ព្រះបរមសាស្ដាទ្រង់ហៀបនឹងចូលបរមនិព្វានដូច្នោះហើយ ជនទាំងឡាយមួញយំសោយសោកខ្សឹកខ្សួលស្ដាយស្រណោះអាឡោះអាល័យព្រះអង្គគ្រប់ៗគ្នា និយាយថាៈ " មិនគួរណាព្រះពុទ្ធបរមគ្រូនៃយើងឆាប់ចូលនិព្វានដូច្នេះសោះ ។ លោកនេះនឹងត្រូវអស់ពន្លឺរស្មី ប្រែទៅជាងងឹតសូន្យសុងហើយ! " ។ ទាំងបុរសស្ត្រីនិងកុមារតូចធំយំសោកសង្រេងសំលេងខ្លាំងៗ នាំគ្នាពពាក់ពពូនចូលទៅកាន់ព្រៃសាលវ័នជាកន្លែងដែលព្រះអង្គកំពុងគង់នៅ ដោយសង្ឃឹមថា ឱ្យបានឃើញព្រះពុទ្ធអង្គជាចុងក្រោយម្ដងទៀត និងថ្វាយបង្គំសំដែងការសោកស្ដាយចំពោះព្រះអង្គ ។ មនុស្សម្នាទាំងឡាយនាំគ្នាទៅមើលព្រះអង្គជាពួកជាក្រុមតាមលំដាប់លំដោយហូរហែរតៗគ្នាមិនដាច់ ។ យ៉ាងណាក៏ដោយ, គ្មានជនណាម្នាក់ចង់ឃ្លាតចាកចេញពីព្រះអង្គឡើយ ។



213– An itinerant young man of a heretical cult, whose name was Subhadra, happened to be in Kusinagara on that time. When he learned the Buddha was about to enter Nirvana, he decided to visit him in order to ask him some questions that had been bothering him and he believed that only the Buddha would be able to give him a thorough explanation. Subhadra went to Salavana and asked Ananda for permission to see the Buddha in order to have his questions answered before the Buddha entered Nirvana.

២១៣- មានបុរសវ័យក្មេងដែលធ្វើដំណើរផ្លូវឆ្ងាយម្នាក់នៃពួកអ្នកកាន់ជំនឿដទៃ. ឈ្មោះ **សុភទ្ទ** បានទៅដល់នគរកុសិនារា ។ កាលបើគាត់បានឮថា ព្រះពុទ្ធជិតនឹងចូលនិព្វានដូច្នោះ គាត់ក៏សំរេចចិត្តទៅជួបព្រះអង្គ ដើម្បីទូលសួរព្រះអង្គនូវបញ្ហាមួយចំនួនដែលចេះតែធ្វើឱ្យគាត់តប់ប្រមល់ខ្វល់ខ្វាយយូរមកហើយៗគាត់ជឿថា មានតែព្រះពុទ្ធប៉ុណ្ណោះ ដែលអាចពន្យល់ឱ្យគាត់យល់ច្បាស់លាស់បាន ។ សុភទ្ទក៏ធ្វើដំណើរទៅកាន់ឧទ្យានសាលវ័ន ហើយក៏សុំសេចក្តីអនុញ្ញាតពីព្រះអានន្ទ ដើម្បីបានជួបនឹងព្រះពុទ្ធ ទូលសុំឱ្យព្រះអង្គទ្រង់ឆ្លើយបំភ្លឺបញ្ហាទាំងឡាយរបស់គាត់ មុននឹងព្រះអង្គចូលកាន់ព្រះបរមនិព្វាន ។



214- Ananda said to him: "No, No! Subhadra! The Buddha is very tired, you must not bother him with any questions now." But Subhadra was very anxious to see the Buddha. He pleaded again and again, and Ananda rejected him again and again, holding to the fact that the Buddha was very ill and should not be bothered by anyone. But when the Buddha heard them both talking, he knew Subhadra's intention and ordered Ananda to let him come in.

២១៤- អានន្ទនិយាយឃាត់គាត់ថា ទេ. ទេ៎ មិនបានទេ សុភទ្ទ! ព្រះពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់កំពង់អស់កំលាំងខ្លាំងណាស់. ពេលនេះ អ្នកមិនត្រូវទៅរំខានព្រះអង្គដោយប្រការណាមួយឡើយ ៉ ។ ប៉ុន្តែសុភទ្ទ មានចិត្តអន្ទះសារចង់ជួបព្រះពុទ្ធជាពន់ពេក ។ គាត់ខំទទូចអង្វរម្តងហើយម្តងទៀត ចំណែកព្រះអានន្ទបដិសេធរាល់លើក ដោយសំអាងលើសភាពការណ៍ពិតដែលថា ព្រះពុទ្ធអង្គទ្រង់កំពុងប្រឈួនយ៉ាងខ្លាំង មិនគួរឱ្យមានអ្នកណាម្នាក់មករំខានព្រះអង្គឡើយ ។ ប៉ុន្តែពេលដែលព្រះបរមគ្រូជាម្ចាស់ ទ្រង់ឮអ្នកទាំងពីរនិយាយ ក្នាព្រះអង្គទ្រង់ដឹងពីបំណងរបស់សុភទ្ទ ហើយក៏ទ្រង់ត្រាស់ឱ្យអានន្ទអនុញ្ញាតឱ្យគាត់បានចូលមកជួប ។



215– The Buddha told Ananda: "Ananda! Do not stop Subhadra, let him come in as he wishes. What he wants is to ask me about some problems he has in practicing the Buddha-dharma; he does not mean to disturb me with meaningless trifles. My explanations will make him understand immediately." So Ananda permitted Subhadra to go in to see the Buddha and ask his questions.

២១៥- ព្រះពុទ្ធត្រាស់ប្រាប់អានន្ទថា: "ម្នាលអានន្ទ! ចូរអ្នកកុំឃាត់សុភទ្រឡើយ . គាត់ចង់ចូលមកហើយ ឱ្យចូលមកចុះ ។ អ្វីដែលគាត់ចង់នោះគឺសួរតថាគត អំពីបញ្ហាខ្លះៗក្នុងការប្រតិបត្តិធម៌. គាត់ពុំមានបំណងរំខានតថាគតដល់តិចតួចឡើយ ។ ឱវាទពន្យល់របស់តថាគតនឹងធ្វើឱ្យគេយល់បានភ្លាមៗមួយរំពេច " ។ ឮដូច្នេះ អានន្ទក៏អនុញ្ញាតឱ្យសុភទ្ទចូលជួបព្រះអង្គ ដើម្បីទូលសួរបញ្ហាទាំងពួង ។



216– Having listen to Subhadra's question, the Buddha began preaching to him till all the puzzles in his mind were solved and any problems cleared up. In Subhadra there arose confidence and he requested the Buddha to accept him as a bhikkhu. The Buddha gave him the opportunity and ordered Ananda to shave his head. Thus Subhadra became the last bhikkhu converted by the Buddha. Like Kaundinya, the first bhikhkhu converted by the Buddha at Mrgadava, Subhadra learned and practiced the Buddha-dharma very diligently, and before long he attained the stage of arhant.

២១៦- ដោយទ្រង់បានស្តាប់នូវសំណួររបស់សុភទ្រ ព្រះមហាករុណាទ្រង់ក៏សំដែងបកស្រាយពន្យល់គាត់រហូតទាល់តែបញ្ហាចម្ងល់ក្នុងចិត្តគាត់បានស្រាយបំភ្លឺធ្វើឱ្យគាត់យល់ច្បាស់លាស់បាន ។ សុភទ្ទមានជំនឿជឿជាក់ជ្រះថ្លាក្នុងព្រះពុទ្ធ ហើយក៏ក្រាបទូលសុំព្រះពុទ្ធអង្គ ឱ្យទ្រង់បំបួសគាត់ជាភិក្ខុមួយអង្គ ។ ព្រះពុទ្ធបរមគ្រូជាម្ចាស់ទ្រង់បានទទួល ហើយក៏ត្រាស់ឱ្យអានន្ទកោរសក់ឱ្យគាត់ ។ ព្រោះហេតុដូច្នោះ សុភទ្ទ ក៏បានជាបច្ឆិមភិក្ខុក្រោយគេបង្អស់(ក្នុងពុទ្ធសាសនា)ដែលព្រះអង្គទ្រង់ប្រោសបំបួស ។ ដូចយ៉ាង កោណ្ឌញ្ញ ជាបឋមភិក្ខុដែលព្រះអង្គទ្រង់បានប្រោសបំបួសនៅក្នុងព្រៃមិគទាយវ័ន. ចំណែកឯសុភទ្ទភិក្ខុបានខិតខំសិក្សាស្វាធ្យាយនិងប្រតិបត្តិធម៌ដោយយកចិត្តទុកដាក់ខ្លាំងក្លាបំផុត មិនយូរប៉ុន្មានលោកក៏បានសំរេចជាព្រះអរហន្ត ។



217- Later, the Buddha gave the bhikkhus at his side a chance to raise any last questions by asking if any of them still had doubts about the Buddha-dharma. But none of the bhikkhus had any doubt whatsoever about the Triratana of Buddha, Dharma and Sangha. The Buddha then said to the bhikkhus for the last time: "Bhikkhus! This is the last occasion for me to talk to you. All actions and deeds are transient and you must detach yourselves from them completely, do not be heedless!"

២១៧- បន្តិចក្រោយមក ព្រះមហាករុណាទ្រង់បើកឱកាសឱ្យភិក្ខុទាំងឡាយសួរសំណួរជាចុងក្រោយ ក្រែងបើមានភិក្ខុអង្គណាមួយនៅមានសន្ទិះសង្ស័យអំពីព្រះធម៌ ។ ប៉ុន្តែឥតមានភិក្ខុអង្គណា នៅមានចម្ងល់សង្ស័យអំពីព្រះរតនត្រ័យទាំងបីគឺពុទ្ធរតនៈ, ធម្មរតនៈ និងសង្ឃរតនៈទៀតឡើយ ។ ពេលនោះ ព្រះបរមគ្រូទ្រង់ត្រាស់ទៅកាន់ភិក្ខុទាំងឡាយជាលើចុងក្រោយថា: "ម្នាលភិក្ខុទាំងឡាយ! ពេលនេះ ជាឱកាសចុងក្រោយដែលតថាគតផ្តាំអ្នកទាំងឡាយ ។ សង្ខារធម៌ទាំងឡាយមិនទៀងទេ អ្នកទាំងឡាយត្រូវផ្តាច់ខ្លួនចេញឱ្យផុតស្រឡះពីសង្ខារធម៌ទាំងនោះ ចូរអ្នកទាំងឡាយកុំប្រមាទ !" ។



218- The Buddha then entered Samadhi, reaching the ninth realm of Dhyana; from the deep ninth dhyana he receded to the realm of the fourth dhyana. When he had emerged from the fourth dhyana, he completely exterminated the five skandhas (accumulations that bind people to the cycle of birth and death) so that he would never again have rebirth or death in either this or in other realm or in other worlds. At that time, Buddha, the perfectly enlightened one, at the age of eighty, entered the Mahaparinirvana in the last watch of the night of the full moon day of the Visakha month in the Sala grove outside the city of Kusinagara, where King Malla ruled. The brilliant lamp was extinguished! But the lamp of Dharma, that is, the Buddha's teaching, exists forever and will carry thousands and thousands of people in our world across the stream of life and death to Nirvana.

២១៨- បន្ទាប់មក ព្រះភគវន្តអនន្តគុណ ទ្រង់តាំងព្រះទ័យចូលក្នុងសមាធិ ឡើងទៅដល់ឈានទី៩ ពីឈានទី៩ ចុះមកកាន់ឈានទី៤វិញ ។ នៅពេលដែលព្រះអង្គទ្រង់ចេញផុតពីឈានទី៤វិញហើយ, ព្រះអង្គទ្រង់បានរំដោះចេញផុតទាំងស្រុងពីខន្ធទាំង៥ (ចំណងដែលចងមនុស្សសត្វឱ្យនៅក្នុងវដ្តសង្សារនៃការវិលកើត វិល-ស្លាប់គ្មានទីបញ្ចប់) ដូច្នេះ ព្រះត្រ័យលោកនាថ ព្រះអង្គទ្រង់លែងវិលត្រឡប់មករកការកើតនិង ស្លាប់ទៀតហើយ ទាំងក្នុងលោកនេះ និងលោកផ្សេងៗទៀត ។

ក្នុងពេលនោះ ព្រះពុទ្ធដែលជាអ្នកបានត្រាស់ដឹងយ៉ាងល្អឯក ទ្រង់មានព្រះជន្ម៨០ព្រះវស្សា ទ្រង់រំលត់ខន្ធចូលកាន់ព្រះមហាបរិនិព្វាន ក្នុងវេលាទៀបភ្លឺនៃរាត្រី**ថ្ងៃពេញបូណ៌មីខែពិសាខ** នៅក្រោមដើមសាលព្រឹក្ស ខាងក្រៅរាជធានីនៃនគរកុសិនារាដែលគ្រប់គ្រងដោយស្តេចមល្លរាជ ។ ចង្កៀងដ៏ភ្លឺចិញ្ចាចត្រូវរលត់បាត់ទៅហើយ! ប៉ុន្តែពន្លឺចង្កៀងនៃព្រះធម៌គឺពុទ្ធោវាទគង់នៅជាចរមានជារៀងរហូត ហើយព្រះធម៌នឹងដឹកនាំចម្លងមនុស្សសត្វដ៏ច្រើនអនេកក្នុងលោកយើងនេះឱ្យឆ្លងផុតពីខ្សែជីវិតគឺការអន្ទោលកើត ស្លាប់ឱ្យដល់ស្ថានអមតមហានិព្វានគ្រប់ៗគ្នា ។.......